ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កម្មវិធីសិក្សាស្តីពី

# កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

## សៀវភៅសំរាប់សិក្ខាកាម

## សប្តាហ៍ទី ១

## ខែ មីនា ២០០៧

**សហការឧបត្ថម្ភដោយៈ**

CDC
CENTERS FOR DISEASE CONTROL AND PREVENTION

unicef

បកប្រែក្រៅផ្លូវការជាភាសាខ្មែរពីភាសាអង់គ្លេស
សូមមេត្តាអធ្យាស្រ័យចំពោះកំហុសឆ្គងនៃអក្ខរាវិរុទ្ធទាំងឡាយ

## មាតិកា


**អារម្ភកថា**........................................................................................................................................................................៣

**សេចក្តីថ្លែងអំណរគុណ**.........................................................................................................................................................៤

**សេចក្តីផ្តើមនៃកម្មវិធីសិក្សា**....................................................................................................................................................៥

**បញ្ជីរាយនាមអក្សរកាត់**.........................................................................................................................................................៦

**ម៉ូឌុលទី១:** ព័ត៌មានជាមូលដ្ឋានស្តីអំពីមេរោគអេដស៍-ជំងឺអេដស៍..................................................................................................៩

**ម៉ូឌុលទី២:** ការមាក់ងាយនិងរើសអើងពាក់ព័ន្ធនឹងមេរោគអេដស៍-ជំងឺអេដស៍...............................................................................២៥

**ម៉ូឌុលទី៣:** ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (MTCT)................................................................................................៣៧

**ម៉ូឌុលទី៤:** ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ( PMTCT)...................................................................................៤៣

**៤.១:** ការបង្ការបឋមនៃការចម្លងមេរោគអេដស៍...........................................................................................................៤៥

**៤.២:** ការបង្ការការមានកូនមិនតាមបំណងនៅលើស្ត្រីផ្ទុកមេរោគអេដស៍.......................................................................................៥៩

**៤.៣:** ការបង្ការការចម្លងមេរោគអេដស៍ពីស្ត្រីផ្ទុកមេរោគអេដស៍ទៅកូនរបស់គាត់ ( PMTCT ).........................................................៦៣

**៤.៣.១:** សេវា PMTCT ការព្យាបាលនិងការបង្ការដោយឱសថប្រឆាំងមេរោគអេដស៍....................................................................៦៥

**៤.៣.២:** ការថែទាំនៅពេលមានផ្ទៃពោះ ពេលឈឺពោះសម្រាលនិងសម្រាល ការថែទាំក្រោយសម្រាលនិងការតាមដានថែទាំបន្ត........................៨៣

**៤.៣.៣:** ការចិញ្ចឹមកូនក្នុងបរិបទនៃមេរោគអេដស៍-ជំងឺអេដស៍..........................................................................................១០៣

**៤.៣.៤:** សុវត្ថិភាពនៅកន្លែងធ្វើការ...........................................................................................................................១២១

**៤.៤:** ការថែទាំនិងគាំទ្របន្ត......................................................................................................................................១៣៥

**ម៉ូឌុលទី៥:** ការថែទាំដល់អ្នកផ្តល់ប្រឹក្សា.......................................................................................................................................១៤៧

**ម៉ូឌុលទី៦:** ការតាមដាននិងវាយតម្លៃ..........................................................................................................................................១៥៥

**ចម្លើយ:**.........................................................................................................................................................................១៧១

**បញ្ជីរាយឯកសារយោង**..........................................................................................................................................................១៨១

# អារម្ភកថា

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាគឺជាប្រទេសដែលកំពុងតែប្រឈមនឹងការរីករាលដាលនៃមេរោគអេដស៍-ជំងឺអេដស៍ដ៏ខ្លាំងជាងគេនៅក្នុងតំបន់អាស៊ី ។ ខណៈដែលប្រេវ៉ាឡង់នៃអ្នកឆ្លងមេរោគអេដស៍នៅកម្ពុជាបានធ្លាក់ចុះក្នុងចំណោមក្រុមប្រឈមខ្ពស់ គេបានសង្កេតឃើញថាប្រេវ៉ាឡង់នៃស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលបានមកទទួលសេវាថែទាំផ្ទៃពោះហាក់ដូចជាមិនមានការប្រែប្រួលឡើយ (២.២% នៅឆ្នាំ ២០០៣) ។ កំណើនអត្រានៃអ្នកឆ្លងមេរោគអេដស៍ថ្មី បានកើតឡើងតាមរយៈការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ។

ការចម្លងមេរោគអេដស៍ពីម្តាយទៅកូនគឺជាបញ្ហាចំពោះមុខមួយដែលរាជរដ្ឋាភិបាល ជាពិសេសក្រសួងសុខាភិបាលត្រូវដោះស្រាយជាបន្ទាន់ ដើម្បីជួយទប់ស្កាត់ការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដែលចេះតែមានកំណើនកើនឡើងជាលំដាប់ ។ ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយពីចំណេះដឹងស្តីអំពីមេរោគអេដស៍-ជំងឺអេដស៍ ជាពិសេសការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដល់មន្ត្រីព្រមទាំងបុគ្គលិកសុខាភិបាលនានា ក្រសួងសុខាភិបាលបានសម្រេចអនុញ្ញាតឱ្យមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក រៀបរៀងជាសៀវភៅសម្រាប់បណ្តុះបណ្តាលនេះឡើង ។

សៀវភៅបណ្តុះបណ្តាលស្តីអំពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននេះ គឺជាមគ្គុទេសក៏មួយដ៏សំខាន់និងជាជំនួយដល់មន្ត្រី-បុគ្គលិកទាំងឡាយក្នុងការអនុវត្តន៏ផ្តល់សេវាថែទាំ ព្យាបាលនិងគាំទ្រដ៏មានប្រសិទ្ធិភាពខ្ពស់ដល់ស្ត្រីមានផ្ទៃពោះទាំងឡាយ ជាពិសេសស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ព្រមទាំងកូននិងគ្រួសាររបស់គាត់ ។

ភ្នំពេញ,ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៧



ឯ.ឧ. សាស្ត្រាចារ្យ **អេង ហួត**

រដ្ឋលេខាធិការក្រសួងសុខាភិបាល

# សេចក្តីថ្លែងអំណរគុណ

សៀវភៅសម្រាប់បណ្តុះបណ្តាលស្តីអំពីកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដែលបានរៀបរៀងកែសម្រួលជាថ្មី ត្រូវបានបញ្ចប់ជាស្ថាពរដោយមានការចូលរួមពីគ្រប់ដៃគូរួមការងារជាច្រើនដែលបានផ្តល់ជាមតិយោបល់ដ៏មានសារៈសំខាន់ ។

ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជូនដល់សមាជិក សមាជិកានៃក្រុមការងារបច្ចេកទេសនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមផ្តល់ជាជំនួយបច្ចេកទេសក្នុងការរៀបចំសៀវភៅបណ្តុះបណ្តាលនេះឡើង ។

ខ្ញុំសូមថ្លែងអំណរគុណជាពន្លឺកដល់អង្គការសុខភាពពិភពលោក មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ និង មូលនិធិសកលប្រយុទ្ធនឹងជំងឺអេដស៍ របេងនិង គ្រុនចាញ់ ដែលបានឧបត្ថម្ភគាំទ្រជាថវិកាសម្រាប់រៀបចំសៀវភៅបណ្តុះបណ្តាលស្តីអំពីកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលជាមគ្គុទេសក៏សម្រាប់មន្ត្រី- បុគ្គលិកនៅតាមមន្ទីរពេទ្យនិងមណ្ឌលសុខភាពនានា ក្នុងការអនុវត្តន៏ផ្តល់សេវាថែទាំបន្តមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ
ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រនៃការទទួលបានជាសកលនៃអ្នកផ្ទុកមេរោគអេដស៍-ជំងឺអេដស៍ក្នុងការបង្ការថែទាំ ព្យាបាល និងការគាំទ្រ ។

ខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់មន្ត្រី-បុគ្គលិកនៃការិយាល័យកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលបានចំណាយអស់កម្លាំងកាយចិត្តនិងពេលវេលាក្នុងការពិនិត្យកែតម្រូវអត្ថន័យ និងបកប្រែឯកសារសម្រាប់ការបណ្តុះបណ្តាលនេះ ។

សមិទ្ធិផលដ៏ធំធេងនេះគឺផ្តើមចេញពីការគាំទ្រយ៉ាងពេញទំហឹងរបស់ក្រសួងសុខាភិបាល ។ ជាចុងបញ្ចាប់ ខ្ញុំសូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងសុខាភិបាលដែលជានិច្ចកាលតែងតែគាំទ្រដល់កិច្ចគាំពារសុខភាពមាតានិងទារក ជាពិសេសកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យមានដំណើរការរលូនទៅមុខជានិរន្តរ៍ ។

ភ្នំពេញ,ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៧



សាស្ត្រាចារ្យ **គុំ កាណាល់**

ប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក

# សេចក្ដីផ្ដើមនៃកម្មវិធីសិក្សា

## របៀបប្រើប្រាស់សៀវភៅ

សៀវភៅសម្រាប់សិក្ខាកាមនេះ គឺជាមគ្គុទេសក៏ដ៏សំខាន់របស់អ្នកនៅក្នុងការសិក្សានេះ។ អ្នកត្រូវរក្សាវាជាប់នឹងខ្លួនអ្នកគ្រប់ពេលវេលា។ នៅក្នុងទំព័របន្ទាប់ទៅនេះ អ្នកនឹងឃើញមានវត្ថុបំណងនៃការបណ្ដុះបណ្ដាល សកម្មភាពនៃការបណ្ដុះបណ្ដាល ស្លាយសម្រាប់បញ្ចាំង និងចំណុចសំខាន់ៗនៃម៉ូឌុលនីមួយៗ។ អ្នកមិនចាំបាច់ធ្វើការកត់សម្គាល់ជាលំអិតនៅក្នុងពេលសិក្សាទេ។ តែទោះបីជាយ៉ាងណាក្ដី អ្នកអាចឃើញមានចំណុចគួរឱ្យចាប់អារម្មណ៍ខ្លះដែលអ្នកត្រូវការកត់ត្រាទុក ដូចជាឧទាហរណ៍ដែលបានមកពីការពិភាក្សា។ អ្នកនឹងឃើញមានសេចក្ដីអធិប្បាយខ្លីៗនៃសកម្មភាពសិក្សា។ គ្រូសម្របសម្រួលនឹងពន្យល់អ្នកឱ្យកាន់តែលំអិតពីសកម្មភាពនីមួយៗ។

សៀវភៅនេះក៏មានផ្ទុកនូវទម្រង់បែបបទករណីសិក្សានិងបញ្ជីផ្ទៀងផ្ទាត់សម្រាប់ធ្វើលំហាត់ ព្រមទាំងព័ត៌មានជាមូលដ្ឋានសម្រាប់ម៉ូឌុលខ្លះ។ ចម្លើយនៃសំណួរនីមួយៗមានភ្ជាប់នៅផ្នែកខាងក្រោយនៃសៀវភៅនីមួយៗ។

សូមរក្សាសៀវភៅនេះទុកនៅក្រោយពេលបញ្ចប់វគ្គសិក្សា និងសូមប្រើប្រាស់វាជាឯកសារយោងសម្រាប់ការអនុវត្តន៍របស់អ្នក។

# បញ្ជីរាយពាក្យសរសេរជាអក្សរកាត់

| | |
|---|---|
| 3TC | ឡាមីវុយឌីន (Lamivudine) |
| AIDS | ចង្កោមរោគសញ្ញាដែលធ្វើឱ្យប្រព័ន្ធសរីរាង្គកាយចុះខ្សោយ (Acquired Immune Deficiency Syndrome) |
| ANC | ការថែទាំផ្ទៃពោះមុនពេលសម្រាល (Antenatal Care) |
| ART | ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (Antiretroviral Therapy) |
| ARV | ឱសថប្រឆាំងមេរោគអេដស៍ (Antiretroviral “drug”) |
| AZT | ហ្ស៊ីដូវុយឌីន (Zidovudine) |
| BCC | ការប្រាស្រ័យទាក់ទងដែលនាំឱ្យមានការផ្លាស់ប្តូរឥរិយាបថ (Behaviour Change Communication) |
| CBO | អង្គការដែលធ្វើការនៅតាមសហគមន៍ (Community-based Organization) |
| CoC | ការថែទាំព្យាបាលបន្ត (Continuum of Care) |
| CoCCC | គណៈកម្មការសម្របសម្រួលការថែទាំព្យាបាលបន្ត (Continuum of Care Coordination Committee) |
| CPA | កញ្ចប់សកម្មភាពបង្គ្រប់ (Complementary Package of Activities) |
| CPN+ | បណ្តាញអ្នកផ្ទុកមេរោគអេដស៍នៅប្រទេសកម្ពុជា (Cambodian Network of PLHA) |
| CSW | ស្ត្រីរកស៊ីផ្លូវភេទ (Commercial Sex Worker) |
| FBO | អង្គការសាសនា (Faith-based Organization) |
| Hb | អេម៉ូក្លូប៊ីន (Haemoglobin) |
| HBC | ការថែទាំនៅតាមផ្ទះ (Home-based Care) |
| HC | មណ្ឌលសុខភាព (Health Center) |
| HCBC | ការថែទាំនៅតាមសហគមន៍និងនៅតាមផ្ទះ (Home-and Community-based Care) |
| HCW(s) | បុគ្គលិកសុខាភិបាល (Health Care Worker”s”) |
| HFBC | ការថែទាំនៅតាមគ្រឹះស្ថានសុខាភិបាល (Health Facility-based Care) |
| HIV | មេរោគអេដស៍ (Human Immunodeficiency Virus) |
| HIV+ | មានផ្ទុកមេរោគអេដស៍ (HIV infected or HIV positive) |
| HIV- | គ្មានផ្ទុកមេរោគអេដស៍ (HIV negative) |
| HSS | ការធ្វើអង្កេតស្រាវជ្រាវប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍ (HIV Sentinel Survey “Cambodia”) |
| NMCHC | មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក (National Maternal and Child Health Center) |
| NVP | ណេវីរ៉ាពីន (Nevirapine) |
| IDU | អ្នកចាក់គ្រឿងញៀន (Injecting Drug User) |

| | |
|---|---|
| IEC | ព័ត៌មាន អប់រំ និង ទំនាក់ទំនង (Information Education Communication) |
| IPD | អគារសម្រាប់អ្នកជំងឺសម្រាកព្យាបាល (Inpatient Department) |
| M&E | ការតាមដាននិងវាយតម្លៃ (Monitoring and Evaluation) |
| MMM | មណ្ឌលមិត្តជួយមិត្ត (Mondul Mith Chuoy Mith “Friends Help Friends Centre”) |
| mmm | មណ្ឌលមិត្តជួយមិត្តសម្រាប់កុមារ (Little Mondul Mith Chouy Mith “for children”) |
| MoH | ក្រសួងសុខាភិបាល (Ministry of Health) |
| MPA | កញ្ចប់សកម្មភាពអប្បបរិមា (Minimum Package of Activities) |
| MSM | បុរសដែលរួមភេទជាមួយបុរស (Men who have sex with men) |
| MTCT | ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (Mother-to-Child transmission of HIV infection) |
| NCHADS | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ (National Center for HIV/AIDS, Dermatology, and STD) |
| OD | ស្រុកប្រតិបត្តិ (សម្រាប់ការគ្រប់គ្រងសុខាភិបាលដែលអាចមាន២ ឬ ច្រើនស្រុករដ្ឋបាល) (Operational District) |
| OI | ជំងឺឱកាសនិយម (Opportunistic Infection) |
| OPD | អគារពិនិត្យជំងឺក្រៅ (Outpatient Department) |
| PCP | ជំងឺហើមសួតដែលបង្កដោយមេរោគ (*Pneumocystis carinii* Pneumonia) (renamed Pneumocystic jirovecii) |
| PHD | មន្ទីរសុខាភិបាលខេត្ត (Provincial Health Departement) |
| PLHA | អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ (Person or people Living with HIV/AIDS) |
| PLHA-SG | ក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ (People Living wth HIV/AIDS Support Group) |
| PMTCT | ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (Prevention of Mother-to-Child Transmission of HIV infection) |
| RH | មន្ទីរពេទ្យបង្អែក (Referral Hospital) |
| RTI | ការបង្ករោគឆ្លងនៅផ្លូវបន្តពូជ (Reproductive Tract Infection) |
| STD | ជំងឺកាមរោគ (Sexually Transmitted Disease) |
| STI | ជំងឺកាមរោគ (Sexually Transmitted Infection) |
| TB | ជំងឺរបេង (Tuberculosis) |
| TB/HIV | ជំងឺរបេង/អេដស៍ (Dual or co-infection with both TB and HIV) |
| TWG | ក្រុមការងារបច្ចេកទេស (Technical Working Group) |
| UNICEF | មូលនិធិរបស់អង្គការសហប្រជាជាតិដើម្បីកុមារ (United Nations Children’s Fund) |
| USAID | ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក (United States Agency for International Development) |
| VCCT | ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់ (Voluntary Confidential Counselling and Testing) |
| WHO | អង្គការសុខភាពពិភពលោក (World Health Organization) |

# ម៉ូឌុលទី១

# ព័ត៌មានជាមូលដ្ឋានស្តីពីមេរោគអេដស៍-ជំងឺអេដស៍

## វត្ថុបំណង

នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមទាំងអស់អាចនឹង:

១.អធិប្បាយអំពីអេពីដេមីសាស្ត្រនៃមេរោគអេដស៍នៅកម្ពុជា

២.កំណត់និយមន័យនៃពាក្យ HIV និង AIDS

៣.ពិភាក្សាអំពីការវិវត្តន៍នៃមេរោគអេដស៍នៅក្នុងខ្លួនមនុស្ស

៤.កំណត់បានអំពីកត្តាប្រឈមនឹងការចម្លងមេរោគអេដស៍

៥.រាយបញ្ជីស្តីអំពីឥរិយាបថដែលនាំឱ្យមានការចម្លងនិងមិននាំឱ្យមានការចម្លង



*រយៈពេល: ២ម៉ោង១០នាទី*

## សកម្មភាពទី១: មេរៀន: ការរីករាលដាលនៃមេរោគអេដស៍-ជំងឺអេដស៍នៅលើពិភពលោកនិងនៅកម្ពុជា

» **ស្លាយទី៥:** ចំណាំថា ក្នុងចំណោមអ្នកឆ្លងថ្មីទាំងអស់នៅទូទាំងពិភពលោកមាន ១៣ភាគរយ គឺជាកុមារដែលមានអាយុក្រោម១៥ឆ្នាំ

» **ស្លាយទី៦:** ចំណាំថា ទោះបីជាចំនួនអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជាបានធ្លាក់ចុះហើយក៏ដោយ ក៏ចំនួននេះធ្លាក់ចុះតែលើអ្នកផ្ទុកមេរោគអេដស៍ជាបុរសតែប៉ុណ្ណោះ ។ រីឯចំនួនស្ត្រីផ្ទុកមេរោគអេដស៍មិនធ្លាក់ចុះទេ ។

» **លើស្លាយទី៧:** ចំណាំលើចំណុចក្រហម ។ វាតំណាងពីការចម្លងរោគអេដស៍ពីម្តាយទៅកូនដែលកំពុងតែកើនឡើង ។

» **លើស្លាយទី៨:** ចំណាំថា ទោះបីជាការឆ្លងក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទបានធ្លាក់ចុះខ្លាំងក៏ដោយ  ក៏ចំនួនស្ត្រីផ្ទុកមេរោគអេដស៍ដែលមកសេវាថែទាំផ្ទៃពោះមិនមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ទេ

### សង្ខេបការរីករាលដាលជាសកលនៃមេរោគអេដស៍_ជម្ងឺអេដស៍នៅឆ្នាំ២០០៥:
### តាមការប៉ាន់ប្រមាណរបស់ UNAIDS/WHO  ឆ្នាំ២០០៥

| | |
|---|---|
| ចំនួនប្រជាជនដែលរស់នៅជាមួយមេរោគអេដស៍ ឆ្នាំ២០០៥ | មាន៣៨.៦លាននាក់ ដែលនៅក្នុងនោះមានកុមារអាយុក្រោម១៥ឆ្នាំចំនួន២.៣លាននាក់ |
| ចំនួនប្រជាជនដែលទើបនឹងឆ្លងមេរោគអេដស៍ថ្មី ឆ្នាំ២០០៥ | មាន៤.១លាននាក់ ដែលនៅក្នុងនោះ មានកុមារអាយុក្រោម១៥ឆ្នាំ ចំនួន៥៤០,០០០នាក់ * |
| ចំនួនប្រជាជនដែលស្លាប់ដោយសារជម្ងឺអេដស៍ ឆ្នាំ២០០៥ | មាន២.៨លាននាក់ ដែលនៅក្នុងនោះមានកុមារអាយុក្រោម១៥ឆ្នាំចំនួន៣៨០,០០០នាក់ |

* ភាគច្រើននៃកុមារដែលទើបនឹងឆ្លងថ្មីនេះ គឺឆ្លងតាមរយៈពីម្តាយទៅកូន

5

### ចំនួនប្រជាជនកម្ពុជាអាយុពី  ១៥_៤៩ឆ្នាំ
### ដែលបានប៉ាន់ស្មានថាមានផ្ទុកមេរោគអេដស៍_ជម្ងឺអេដស៍  ១៩៩០_២០០៣




6

*HIV Sentinel Surveillance, NCHADS, MOH 2003

### សមាមាត្រនៃការឆ្លងមេរោគអេដស៍បែងចែកទៅតាមរបៀបនៃការចម្លង
### ១៩៩២_២០០២




HIV Sentinel Surveillance, NCHADS, MOH 2003

## ប្រេវ៉ាឡង់នៃមេរោគអេដស៍នៅកម្ពុជា ក្នុងចំណោមក្រុមដែលបានធ្វើអង្កេតពីឆ្នាំ ១៩៩៦_២០០៣




8

*HIV Sentinel Surveillance, NCHADS, MOH 2003, adjusted weighted data, smoothed with EPP

## ការឆ្លងមេរោគអេដស៍នៅលើស្ត្រី និងកុមារនៅកម្ពុជា

- នៅប្រទេសកម្ពុជាបច្ចុប្បន្ន ក្នុងចំណោមប្រជាជនដែលឆ្លងមេរោគអេដស៍ មានស្ត្រីប្រហែល ៥០ ភាគរយ*
- ក្នុងចំណោមអ្នកឆ្លងមេរោគអេដស៍ថ្មី ដែលមានអាយុពី ១៥-៤៩ឆ្នាំ * ឆ្នាំ២០០៣ មានស្ត្រីប្រហែល ៦,៣៥០ នាក់និងបុរស ១,៧០០នាក់
- មានទារកដែលទើបនឹងកើតចំនួនពី ៧,០០០ ទៅ ១០,០០០ នាក់ប្រឈមនឹងការឆ្លង មេរោគអេដស៍ពីម្តាយជារៀងរាល់ឆ្នាំ **
- មានករណីឆ្លងថ្មីរហូតដល់ ៤០ភាគរយ អាចបណ្តាលមកពីការចម្លងពីម្តាយទៅកូន ***

*HIV Sentinel Surveillance, NCHADS, MOH 2003
**Calculated from estimated births (WHO World Health Report 2005, Cambodia) x HIV prevalence
***Projections for HIV.AIDS in Cambodia: 2000-2010. The Cambodia Working Group on HIV/AIDS Projection, November 2002.

9

## សកម្មភាពទី២: បំផុសគំនិត: ផលប៉ះពាល់នៃមេរោគអេដស៍នៅកម្ពុជា

» គ្រូនឹងស្នើឱ្យអ្នកគិតដល់សំណួរ:
តើផលប៉ះពាល់នៃមេរោគអេដស៍នៅកម្ពុជាមានអ្វីខ្លះ?

## ផលប៉ះពាល់នៃមេរោគអេដស៍_ជម្ងឺអេដស៍នៅកម្ពុជា

នៅឆ្នាំ ២០០៣ គេបានប៉ាន់ស្មានថា មានប្រជាជនពេញវ័យប្រមាណ ១២៣.១០០នាក់* មានផ្ទុកមេរោគអេដស៍នៅកម្ពុជា

បើគ្មានការព្យាបាលទេ ប្រជាជនទាំងនេះ នឹង:
- ធ្លាក់ខ្លួនឈឺ មិនអាចធ្វើការបាន និងមិនអាចថែរក្សាគ្រួសាររបស់គេបាន
- ជាយថាហេតុវានឹងវិវត្តទៅរកជម្ងឺអេដស៍ និង ទីបញ្ចប់ឈានទៅរកការស្លាប់

អ្នកផ្ទុកមេរោគអេដស៍ទាំងនោះអាច:
- ចម្លងមេរោគអេដស៍ទៅដៃគូរួមភេទរបស់គាត់
- ចម្លងមេរោគអេដស៍ទៅកូនរបស់គាត់
- បន្សល់ទុកនូវកុមារកំព្រា

*HIV Sentinel Surveillance, NCHADS, MOH 2003 (adult aged 15-49)

11

## សកម្មភាពទី៣: ពាក្យគន្លឹះ និយមន័យនៃពាក្យ មេរោគអេដស៍-ជំងឺអេដស៍

» គ្រូនឹងសួរថា:

១.. តើមេរោគអេដស៍មានន័យថាយ៉ាងដូចម្ដេច?

២. តើជំងឺអេដស៍មានន័យថាយ៉ាងដូចម្ដេច?

» បន្ទាប់មកគ្រូនឹងសុំឱ្យអ្នកឆ្លើយ និងទុកឱកាសឱ្យអ្នកធ្វើការពិភាក្សាគ្នាអំពីបញ្ហានោះ

### តើមេរោគអេដស៍ (HIV) និងជម្ងឺអេដស៍ (AIDS) ជាអ្វី?

**មេរោគអេដស៍**
HIV

- Human មនុស្ស
- Immunodeficiency ភាពចុះខ្សោយនៃប្រព័ន្ធការពារ
- Virus វីរុស

មេរោគអេដស៍ គឺជាវីរុសមួយប្រភេទ ហៅថា Retrovirusដែលធ្វើឱ្យប្រព័ន្ធការពាររាងកាយរបស់មនុស្សចុះខ្សោយ

**ជម្ងឺអេដស៍**
AIDS

- Acquired មិនមែនពីកំណើត
- Immuno- ប្រព័ន្ធការពារ
- Deficiency ភាពចុះខ្សោយ
- Syndrome ចង្កោមរោគសញ្ញា

គឺជាចង្កោមរោគសញ្ញាដែលវិវត្តនៅលើអ្នកផ្ទុកមេរោគអេដស៍ នៅពេលដែលប្រព័ន្ធការពាររាងកាយធ្លាក់ចុះខ្សោយ ។

13

### HIV-1 និង HIV-2

នៅទូទាំងពិភពលោកមានមេរោគអេដស៍ ២ប្រភេទ:

- HIV-១ និង HIV-២
  - មេរោគអេដស៍នេះឆ្លងតាមវិធីដូចគ្នា
  - មានការបង្កដោយជម្ងឺឱកាសនិយមប្រហាក់ប្រហែលគ្នា
  - HIV-១ មានច្រើនជាទូទៅនៅលើពិភពលោក ។ គេឃើញវីរុសប្រភេទនេះមាននៅកម្ពុជា និងនៅប្រទេស ខ្លះនៃភូមិភាគអាស៊ីអាគ្នេយ៍

តើ HIV-២ ខុសពី HIV-១ យ៉ាងដូចម្ដេចខ្លះ?

- HIV-២ ត្រូវបានរកឃើញជាច្រើននៅអាហ្វ្រិកខាងលិច ប្រទេសអង់ហ្គោឡា និងប្រទេសម៉ូស្សមបិក
- HIV-២ មិនងាយឆ្លងដូច HIV-១ទេ
- HIV-២ វិវត្តយឺតជាង HIV-១
- ការចម្លងពីម្ដាយទៅកូន ចំពោះ HIV-២ កំរកើតមានណាស់ ។

14

### ពាក្យបច្ចេកទេស

- HIV+ ឬ HIV វិជ្ជមាន

មានន័យថា មនុស្សម្នាក់ឆ្លងមេរោគអេដស៍ នៅពេលធ្វើតេស្តឈាមលទ្ធផលបង្ហាញថា វិជ្ជមាន ។

- HIV- ឬ HIV អវិជ្ជមាន

មានន័យថា មនុស្សម្នាក់មិនបានឆ្លងមេរោគអេដស៍ទេ ឬលទ្ធផលតេស្តឈាមរបស់គេបង្ហាញថាអវិជ្ជមាន ។

15

## សកម្មភាពទី៤: បំផុសគំនិត: ផលប៉ះពាល់នៃមេរោគអេដស៍ក្រោយពីឆ្លង

» សម្រាប់សកម្មភាពនេះ អ្នកនឹងត្រូវធ្វើការជាគូៗ

» គ្រូនឹងសួរអ្នកថា:

១. តើមេរោគអេដស៍មានឥទ្ធិពលអ្វីទៅលើរាងកាយរបស់មនុស្ស?

២. តើមានអ្វីកើតឡើងនៅពេលដែលមនុស្សម្នាក់ឆ្លងមេរោគអេដស៍?

---

### ប្រព័ន្ធការពាររបស់មនុស្ស និង កោសិកា CD4

- មនុស្សដែលមានសុខភាពល្អ មានប្រព័ន្ធការពាររឹងមាំ។ ប្រព័ន្ធនេះអាចការពារសរីរាង្គប្រឆាំងនឹងជម្ងឺនានា
- កោសិកាឈាម "ស" ជាប្រព័ន្ធការពារមួយយ៉ាងសំខាន់
- កោសិកាឈាម "ស" មួយប្រភេទហៅថា CD4 មានសញ្ញាសំគាល់នៅផ្ទៃខាងលើនៃកោសិកា
- ចំនួនកោសិកា CD4 នេះអាចរាប់បានតាមការពិនិត្យឈាម
- ការធ្វើតេស្តនេះគឺជាវិធីដ៏ល្អសំរាប់ត្រួតពិនិត្យមើលប្រព័ន្ធការពារសរីរាង្គកាយ ថាតើវានៅមានដំណើរការល្អប្រសើរ ឬ ចុះខ្សោយ។

17

### ការរាប់ចំនួនកោសិកា CD4 និង ជម្ងឺ

- មនុស្សដែលមានប្រព័ន្ធភាពស៊ាំធម្មតា មានកោសិកា **CD4** ចន្លោះពី ៤៥០ ទៅ១៥០០ ក្នុងមួយមីលីម៉ែត្រគូបឈាម
- បើសិនជាចំនួនកោសិកា **CD4** ធ្លាក់ចុះទាបជាង ៤៥០ / មម៣ អ្នកផ្ទុកមេរោគអេដស៍ អាចផ្តើមមានការបង្ករោគផ្សេងៗទៀត(រួមមានជម្ងឺឱកាសនិយម)
- បើសិនជាចំនួនកោសិកា **CD4** ធ្លាក់ចុះទាបជាង ២០០ / មម៣ អ្នកផ្ទុកមេរោគអេដស៍អាចប្រឈមនឹងជម្ងឺឆ្លងធ្ងន់ធ្ងរ និង ជម្ងឺមហារីក។

18

## តើមេរោគអេដស៍មានសកម្មភាពអ្វីខ្លះ ?

មេរោគអេដស៍:

- ធ្វើឱ្យប៉ះពាល់ដល់កោសិកានៃប្រព័ន្ធការពារ-ជាពិសេសកោសិកា **CD4**
- មេរោគអេដស៍បានប្រើប្រាស់កោសិកា **CD4** ដែលរងនូវការប៉ះពាល់ដើម្បីធ្វើការពង្រីកចំនួនវីរុសថ្មី
- វាសំលាប់កោសិកា **CD4**

- មេរោគអេដស៍អាចបំបែកខ្លួនក្នុង១ថ្ងៃបានប្រហែល ១០ កោដិ
- កោសិកា **CD4** ប្រហែល ២០០លាន ត្រូវបានបំផ្លាញរៀងរាល់ថ្ងៃ

(ខ្លួនមនុស្សអាចផលិតកោសិកា **CD4** ប្រមាណ១០០លាន ជារៀងរាល់ថ្ងៃ)

បន្ទុកវីរុស គឺជាបរិមាណវីរុសនៅក្នុងឈាម ។ គេអាចវាស់បានដោយធ្វើតេស្ត HIV-RNA PCR

19

## តើមេរោគអេដស៍ប៉ះពាល់ដល់អ្វីខ្លះ?

- មេរោគអេដស៍វាយប្រហារទៅលើកោសិកា CD4 និងបំផ្លាញប្រព័ន្ធការពារសរីរាង្គបន្តិចម្តងៗ
- អ្នកផ្ទុកមេរោគអេដស៍ចាប់ផ្តើមចុះខ្សោយហើយងាយនឹងទទួលរងនូវការឆ្លងរោគផ្សេងៗ
  - ជម្ងឺដែលអាចកើតមានជាញឹកញាប់នៅលើមនុស្សធម្មតា
  - ជម្ងឺឱកាសនិយមពិសេសៗ ដែលកើតមានតែលើអ្នកផ្ទុកមេរោគអេដស៍
- អ្នកផ្ទុកមេរោគអេដស៍ធ្លាក់ខ្លួនឈឺកាន់តែខ្លាំងឡើង និងឈានទៅរកការស្លាប់

20

## សកម្មភាពទី៥: មេរៀន: ការវិវត្តន៍ពីអ្នកផ្ទុកមេរោគអេដស៍ទៅជាអ្នកជំងឺអេដស៍

» ការវិវត្តន៍ពីមេរោគអេដស៍ទៅជាជំងឺអេដស៍: ស្លាយទី២២

» សម្គាល់ថាតើ កោសិកាCD4ធ្លាក់ចុះនៅពេលដែលបន្ទុកមេរោគអេដស៍ឡើងយ៉ាងដូចម្តេចខ្លះ?

## ការវិវត្តន៍នៃមេរោគអេដស៍ (១)




22

## ការវិវត្តន៍នៃមេរោគអេដស៍ (២)

ការឆ្លងមេរោគអេដស៍នៅដំណាក់កាលដំបូង:

- កើតមានឡើងនៅក្នុងរយៈពេល២-៣សប្តាហ៍ដំបូងក្រោយពីឆ្លង
- អ្នកផ្ទុកមេរោគអេដស៍អាចមានសុខភាពល្អនៅរយៈពេលនេះ ឬ
- អាចមានគ្រុន កន្ទួលរមាស់ និង ឡើងកូនកណ្តុរ (រោគសញ្ញានៃជម្ងឺអេដស៍ស្រួចស្រាវ)

23

## ការវិវត្តន៍នៃមេរោគអេដស៍ (៣)

តើ Sero-conversion មានន័យថាដូចម្តេច?

- អ្នកផ្ទុកមេរោគអេដស៍បានបង្កើតនូវអង្គបដិបក្ខប្រាណប្រឆាំងមេរោគអេដស៍
- អង្គបដិបក្ខប្រាណនេះអាចមើលឃើញតាមរយៈការធ្វើតេស្តរកអង្គបដិបក្ខប្រាណមេរោគអេដស៍

តើជាធម្មតាមានអ្វីកើតឡើង?

- នៅពេលដែលទើបនឹងឆ្លងថ្មីៗ ចំនួនមេរោគអេដស៍នៅក្នុងខ្លួនបានកើនឡើងយ៉ាងឆាប់រហ័ស (បន្ទុកវីរុសកើនឡើង)
- ៤-៦ សប្តាហ៍ក្រោយ (ជួនកាលរហូតដល់៣ខែ) សរីរាង្គចាប់ផ្តើមផលិតអង្គបដិបក្ខប្រាណប្រឆាំងនឹងមេរោគអេដស៍ ។ នៅពេលនោះការធ្វើតេស្តឈាមចាប់ផ្តើមឃើញមានវិជ្ជមាន ។

**រយៈពេលចំហ :** មានន័យថាបុគ្គលមានផ្ទុកមេរោគអេដស៍ហើយ តែអង្គបដិបក្ខប្រាណមិនទាន់ផលិត ។ នៅពេលនោះលទ្ធផលតេស្តអាចអវិជ្ជមាន ។

24

## ការវិវត្តន៍នៃមេរោគអេដស៍ (៤)

- ដំណាក់កាលមិនទាន់មានរោគសញ្ញា

  នៅរយៈពេលប៉ុន្មានឆ្នាំដំបូងបន្ទាប់ពីឆ្លងមេរោគអេដស៍ បរិមាណមេរោគបានថយចុះបន្តិចម្តងៗ ប្រព័ន្ធការពារចុះខ្សោយបន្តិច ក៏ប៉ុន្តែអាចនៅដំណើរការល្អប្រសើរ ។

- ដំណាក់កាលមានរោគសញ្ញា

  ច្រើនឆ្នាំបន្ទាប់មកបរិមាណមេរោគអេដស៍បានចាប់ផ្តើមកើនឡើងជាថ្មីម្តងទៀត ។ ប្រព័ន្ធភាពស៊ាំបានចុះខ្សោយយ៉ាងខ្លាំង ។ អ្នកជម្ងឺងាយនឹងទទួលរងនូវជម្ងឺឆ្លងនានាដែលជាធម្មតាអាចព្យាបាលបាន ។

- ដំណាក់កាលជម្ងឺអេដស៍

  នៅក្នុងដំណាក់កាលនេះ ប្រព័ន្ធភាពស៊ាំបានរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរ ហើយអ្នកជម្ងឺប្រឈមនឹងជម្ងឺឆ្លងធ្ងន់ធ្ងរដែលគំរាមកំហែងដល់ជីវិត ។

25

## ដំណាក់កាលគ្លីនិកនៃជម្ងឺអេដស៍របស់អង្គការសុខភាពពិភពលោក

អង្គការសុខភាពពិភពលោកបានរៀបចំបង្កើតប្រព័ន្ធចំណាត់ថ្នាក់គ្លីនិកនៃជម្ងឺអេដស៍ ដែលអាចប្រើប្រាស់សំរាប់វាយតម្លៃសភាពនៃជម្ងឺអេដស៍ដោយសញ្ញាគ្លីនិក ដូចជា:

- បើសិនអតិថិជនថ្មីម្នាក់ត្រូវបានសង្ស័យថាមានផ្ទុកមេរោគអេដស៍ និង ត្រូវការបញ្ជូនឱ្យទៅ ធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត
- សភាពធ្ងន់ធ្ងររបស់បុគ្គលដែលរងគ្រោះដោយសារមេរោគអេដស៍-ជម្ងឺអេដស៍យ៉ាងដូចម្តេច?
- អ្នកជម្ងឺដល់ពេលដែលត្រូវព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ហើយឬនៅ (ART)

ប្រព័ន្ធដំណាក់កាលគ្លីនិកនៃជម្ងឺអេដស៍មានភាពខុសគ្នារវាងមនុស្សពេញវ័យ និងកុមារ ។

26

## ដំណាក់កាលទី១នៃជម្ងឺអេដស៍លើមនុស្សពេញវ័យៈ មិនទាន់មានរោគសញ្ញា

- មិនស្រកទំងន់
- មិនមានរោគសញ្ញា

ឬក៏

- គ្រាន់តែមានកូនកណ្តុរពាសពេញខ្លួន PGL (Persistent Generalized Lymphadenophathy)

និង ឬ លទ្ធភាពអនុវត្តកិរិតទី១: អ្នកជម្ងឺនៅមានសកម្មភាពធម្មតា

**PGL:** មានកូនកណ្តុរនៅសងខាងក មិនមានការឈឺចាប់ទេ

27

## ដំណាក់កាលទី២នៃជម្ងឺអេដស៍លើមនុស្សពេញវ័យៈ មានជម្ងឺមិនសូវធ្ងន់ធ្ងរ

- ស្រកទំងន់តិចជាង១០%
- មានដំបៅ ឬ ប្រេះចង្កែកបបូរមាត់ (ANGULAR CHEILITIS)
- រមាស់ពងបែក (seborrhoea or prurigo)
- មាន Herpes Zoster ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ
- មានជម្ងឺរលាកផ្លូវដង្ហើមផ្នែកខាងលើ កើតសាចុះសាឡើង (sinusitis or otitis)
- ដំបៅមាត់កើតសាចុះសាឡើង



Angular cheilitis



Herpes Zoster

និង ឬ លទ្ធភាពអនុវត្តកិរិតទី២: អ្នកជម្ងឺមានរោគសញ្ញា ប៉ុន្តែនៅមានសកម្មភាពធម្មតា

28

## ដំណាក់កាលទី៣នៃជម្ងឺអេដស៍លើមនុស្សពេញវ័យៈ មានជម្ងឺធ្ងន់ធ្ងរមធ្យម

- ស្រកទំងន់លើសពី ១០ភាគរយ
- ផ្សិតក្នុងមាត់ ឬ
- Oral hairy leukoplakia
- រាកលើសពី ១ខែ
- គ្រុនក្តៅគ្មានមូលហេតុ លើសពី១ខែ
- ផ្សិតនៅទ្វារមាសលើសពី១ខែ
- របេងសួតក្នុងកំឡុងពេល១ឆ្នាំកន្លងទៅ
- ជម្ងឺឆ្លងដោយមេរោគបាក់តេរីធ្ងន់ធ្ងរ (រលាកសួត, បង្ករោគនៅសាច់ដុំ ។ល ។)



ផ្សិតក្នុងមាត់

និង ឬ លទ្ធភាពអនុវត្តកិរិតទី៣: ដេកលើគ្រែតិចជាង៥០ភាគរយក្នុង១ថ្ងៃ ក្នុងខែកន្លងទៅនេះ ។

29

## ដំណាក់កាលទី៤នៃជម្ងឺអេដស៍លើមនុស្សពេញវ័យៈ មានជម្ងឺអេដស៍ធ្ងន់ធ្ងរ

លក្ខណៈដែលបញ្ជាក់ពីសភាពជម្ងឺអេដស៍មានៈ

- អ្នកជម្ងឺមានសភាពស្គមកំព្រឹង
- មានជម្ងឺរលាកស្រោមខួរក្បាល
- ផ្សិតនៅផ្លូវបំពង់អាហារ
- Herpes Simplex ulcerations រយៈពេលលើសពី១ខែនៅប្រដាប់បន្តពូជ និង នៅរន្ធគូថ
- រលាកស្រោមខួរក្បាលដោយពពួកមេរោគ Cryptococcal Meningitis
- របេងក្រៅសួត
  - -Pneumocystis Carinii (ហើមសួត)
- ជម្ងឺឱកាសនិយមផ្សេងទៀតៈ
  - -Toxoplasmosis of the brain
  - -Cryptosporidiosis មានជាមួយនឹងជម្ងឺរាកលើសពី១ខែ
  - -Cytomegalovirus (CMV) infection
- ជម្ងឺមហារីកទាក់ទងនឹងជម្ងឺអេដស៍
  - -Lymphoma
  - -មហារីកមាត់ស្បូនធ្ងន់ធ្ងរ
  - -Kaposi’s Sarcoma

លទ្ធភាពអនុវត្តកិរិតទី៤: ដេកលើគ្រែច្រើនជាង ៥០ភាគរយ ក្នុងខែកន្លងទៅនេះ ។

30

» ពិនិត្យមើលពីដំណាក់កាលគ្លីនិកនៃជំងឺអេដស៍នៅស្លាយទី៣១

» ចូរឆ្លើយនឹងសំណួរដោយមើលក្នុងសៀវភៅសម្រាប់សិក្ខាកាម (ក្នុងឧបសម្ព័ន្ធទី១)

| សំណួរ | ស្លាយទី៣១ | ដំណាក់កាល |
|---|---|---|
| ១ | បុរសផ្ទុកមេរោគអេដស៍អាយុ២៥ឆ្នាំម្នាក់ មានដំបៅផ្សិតនៅមាត់និងមានរាកម្តងម្កាល រយៈពេលជាង១ខែ | |
| ២ | ស្ត្រីផ្ទុកមេរោគអេដស៍អាយុ៤០ឆ្នាំម្នាក់ មានហើមកូនកណ្តុរតូចៗនៅកនិងក្រោមក្លៀករបស់គាត់។ គាត់មានសុខភាពល្អនិងនៅធ្វើសកម្មភាពបានធម្មតា | |
| ៣ | បុរសផ្ទុកមេរោគអេដស៍អាយុ៣៦ឆ្នាំម្នាក់ មានរូបរាងស្គមយ៉ាងខ្លាំង តួញត្អែរថាមានគ្រុនរយៈពេល៣ខែមកហើយនិងមិនអាចក្រោកចេញពីគ្រែបានទេ | |
| ៤ | ស្ត្រីផ្ទុកមេរោគអេដស៍អាយុ៣០ឆ្នាំម្នាក់ មានជំងឺរបេងសួតនិងមានកើត Herpes Zosterលើទ្រូងរបស់នាង | |
| ៥ | ស្ត្រីរកស៊ីផ្លូវភេទផ្ទុកមេរោគអេដស៍អាយុ២៨ឆ្នាំម្នាក់ មានកើត Herpes Zoster លើនៅលើផ្ទៃមុខរបស់នាង និងរមាស់ពងបែកពេញខ្លួនទាំងអស់ | |
| ៦ | បុរសផ្ទុកមេរោគអេដស៍អាយុ៣៨ឆ្នាំម្នាក់ មានដំបៅក្នុងមាត់និងជុំវិញមាត់ និងមានរលាកស្រោមខួរក្បាលដោយមេរោគ Cryptococcal Meningitis | |

## សកម្មភាពទី៦: ធ្វើការងារជាក្រុម: ការចម្លងមេរោគអេដស៍

» អ្នកនឹងត្រូវបានចែកជា៣ក្រុម

» ក្រុមនីមួយៗនឹងធ្វើការរយៈពេល៥នាទី ដើម្បីឆ្លើយនឹងសំណួរដូចតទៅ:

ក្រុមទី១: តើសារធាតុរាវនៃរាងកាយណាខ្លះដែលអាចចម្លងមេរោគអេដស៍?

ក្រុមទី២: តើកត្តាអ្វីខ្លះដែលបង្កើនគ្រោះប្រឈមនឹងការចម្លងមេរោគអេដស៍?

ក្រុមទី៣: រៀបរាប់អំពីវិធីដែលអាចចម្លងនិងវិធីដែលមិនអាចចម្លងមេរោគអេដស៍

» ក្រុមនីមួយៗនឹងឡើងមកបង្ហាញពីការងាររបស់ក្រុមខ្លួន និងសរសេរចម្លើយនៅលើក្តារខៀន

# ការចម្លងមេរោគអេដស៍

វិធីចម្លងមេរោគអេដស៍ដែលមានច្រើនជាងគេបំផុតគឺតាមរយៈ ការរួមភេទ ជាពិសេសការរួមភេទជាមួយភេទផ្ទុយគ្នា។

ស្ត្រីដែលស្ថិតក្នុងវ័យបន្តពូជ ងាយប្រឈមនឹងការឆ្លងមេរោគអេដស៍ណាស់។ វាបណ្តាលមកពីការរួមភេទជាមួយដៃគូមានផ្ទុកមេរោគអេដស៍ដោយមិនបានការពារ។

33

# តើសារធាតុរាវនៃសរីរាង្គណាខ្លះដែលអាចចម្លងមេរោគអេដស៍បាន?

- សារធាតុដែលចម្លងខ្លាំង
  - ឈាម, សារធាតុរាវនៃសរីរាង្គ ជាលិកាសរីរាង្គ
  - ទឹកកាម, ទឹករំអិលទ្វារមាស
  - សារធាតុរាវនៃសរីរាង្គដទៃទៀត (ទឹកភ្លោះ ទឹកឆ្អឹងខ្នង ទឹកស្រោមសួត...)
- សារធាតុដែលចម្លងមធ្យម
  - ទឹកដោះម្តាយ
- សារធាតុដែលមិនឆ្លង
  - ទឹកនោម លាមក ទឹកសំបោរ ទឹកភ្នែក ទឹកមាត់ កំហាក ទឹកក្រពះ ញើស។

34

# កត្តាដែលបង្កើននូវគ្រោះប្រឈមនឹងការចម្លងមេរោគអេដស៍

**ដៃគូដែលមានផ្ទុកមេរោគអេដស៍:**
មានបន្ទុកវីរុសខ្ពស់
មានកោសិកា CD4 ទាប




**ដៃគូដែលគ្មានផ្ទុកមេរោគអេដស៍:**
បុរស: មិនបានកាត់ស្បែកគ្របចុងលិង្គ
ស្ត្រី: ព្រហ្មចារីយ៍

**ដៃគូម្នាក់មានផ្ទុកមេរោគអេដស៍ និងម្នាក់ទៀតគ្មានផ្ទុកមេរោគអេដស៍**

- ស្រទាប់ភ្នាសរលាត់
- មានឈាមនៅពេលរួមភេទ
- មានជម្ងឺកាមរោគ

35

## មេរោគអេដស៍ អាចចម្លងបានតាមរយៈ

ការរួមភេទ
- តាមទ្វារមាស, តាមមាត់, តាមរន្ធគូថ
- ប៉ះពាល់ផ្ទាល់ជាមួយសារធាតុរាវនៃសរីរាង្គ ដែលមានផ្ទុកមេរោគអេដស៍ (ទឹកកាម ទឹករំអិលទ្វារមាស)

ពីម្តាយទៅកូន
- នៅពេលមានផ្ទៃពោះ
- នៅពេលឈឺពោះសំរាល ឬសំរាល ឬ
- នៅពេលបំបៅដោះកូន

ការប៉ះពាល់ឈាម
- ចាក់បញ្ចូលឈាម
- មុតម្ជុល ឬ ការមុតរបួសផ្សេងៗ
- ប្រើម្ជុលសឺរាំងរួមគ្នា នៅពេលចាក់គ្រឿងញៀន

## មេរោគអេដស៍ មិនអាចចម្លងបានតាមរយៈ

ការប៉ះពាល់រាល់ថ្ងៃ
- ទទួលទានបាយឬម្ហូបជាមួយគ្នា
- ប្រើប្រាស់បន្ទប់ទឹករួមគ្នា
- លេង ឬ ធ្វើការជាមួយគ្នា
- ប្រើសំលៀកបំពាក់ចូលគ្នា
- ទៅលេងផ្ទះអ្នកផ្ទុកមេរោគអេដស៍
- និយាយជាមួយអ្នកផ្ទុកមេរោគអេដស៍
- ប៉ះពាល់អ្នកផ្ទុកមេរោគអេដស៍

មូសខាំ

36

## សកម្មភាពទី៧: សំណួរនិងចម្លើយ: សំណួរដែលតែងតែសួរញឹកញាប់

» គ្រូនឹងបង្ហាញសំណួរលើស្លាយទី៣៨

» លាតកន្លែងក្នុងបន្ទប់ឱ្យបានទូលាយ និងអ្នកត្រូវឈរនៅខាងណាមួយនៃបន្ទប់

» ភាគីម្ខាងគឺជាអ្នកឆ្លើយថា " ចាំ ឬ បាទ " និងភាគីម្ខាងទៀតគឺជាអ្នកឆ្លើយថា " ទេ "

» ឆ្លើយសំណួរម្តងម្នាក់ៗ

» ឆ្លើយចម្លើយនៃសំណួរនីមួយៗដោយឈរនៅម្ខាងខ្សែ ដែលជាផ្នែកតំណាងឱ្យចម្លើយរបស់គាត់។

ឧ: ប្រសិនជាអ្នកគិតថាចម្លើយ " ចាំ ឬ បាទ " ១០០ភាគរយ ហើយ អ្នកត្រូវទៅឈរនៅខាងចម្លើយ" ចាំ ឬ បាទ " ។ ផ្ទុយទៅវិញ ប្រសិនជាអ្នកគិតថាចម្លើយ"ទេ" ១០០ភាគរយ ហើយ អ្នកត្រូវទៅឈរនៅខាងចម្លើយ "ទេ "។

ប្រសិនជាអ្នកមិនច្បាស់ក្នុងចិត្ត គិតថាចម្លើយនោះអាស្រ័យទៅនឹងស្ថានភាពជាក់ស្តែង  អ្នកត្រូវឈរនៅត្រង់ចំណុចកណ្តាល ឬនៅក្បែរខាងចុងខ្សែដែលតំណាងឱ្យចម្លើយរបស់អ្នក

» គ្រូសម្របសម្រួលនឹងធ្វើការបង្ហាញឱ្យអ្នកឃើញជាមុន ដើម្បីឱ្យអ្នកអាចយល់បាន

| ស | ស្លាយទី៣៨ | ច |
|---|---|---|
| ១ | តើមនុស្សម្នាក់អាចឆ្លងមេរោគអេដស៍បានដែរឬទេ ប្រសិនជាគាត់ហូបបាយរួមតុជាមួយនឹងអ្នកផ្ទុកមេរោគអេដស៍? | |
| ២ | តើឪបម្នាក់ប្រឈមនឹងការឆ្លងមេរោគអេដស៍ដែរឬទេ ប្រសិនជាគាត់បង្កើតកូនឱ្យស្ត្រីផ្ទុកមេរោគអេដស៍ម្នាក់ដោយមិនប្រើស្រោមដៃ? | |
| ៣ | នៅក្នុងថ្នាក់រៀនមួយ ប្រសិនបើមានកុមារផ្ទុកមេរោគអេដស៍ម្នាក់រៀននៅក្នុងថ្នាក់ តើកុមារដទៃទៀតប្រឈមនឹងការឆ្លងមេរោគអេដស៍ដែរឬទេ? | |
| ៤ | តើបុរសម្នាក់អាចឆ្លងមេរោគអេដស៍បានដែរឬទេ ប្រសិនជាគាត់រួមភេទជាមួយអ្នកផ្ទុកមេរោគអេដស៍តាមរន្ធលាមក? | |
| ៥ | តើស្ត្រីអាចឆ្លងមេរោគអេដស៍ដែរឬទេ ប្រសិនជាបុរសម្នាក់រួមភេទជាមួយស្ត្រីពីរនាក់ក្នុងលក្ខណៈជាក្រុមតែមានពាក់ស្រោមអនាម័យ? | |

## ម៉ូឌុលទី១: ចំណុចគន្លឹះ

- មេរោគអេដស៍គឺជាវីរុសមួយប្រភេទដែលបំផ្លាញប្រព័ន្ធភាពស៊ាំការពាររាងកាយរបស់មនុស្ស ដែលនាំឱ្យងាយឆ្លងនូវជំងឺឱកាសនិយមផ្សេងៗ
- រយៈពេលចាប់ពីការឆ្លងមេរោគអេដស៍រហូតដល់ដំណាក់កាលចុងក្រោយនៃជំងឺអេដស៍ មានការប្រែប្រួលពីមនុស្សម្នាក់ទៅមនុស្សម្នាក់។ ក៏ប៉ុន្តែអ្នកខ្លះអាចរស់នៅរហូតលើស ពី១៥ឆ្នាំ
- វិធីចម្លងមេរោគអេដស៍ដែលមានច្រើនជាងគេនៅទូទាំងពិភពលោក គឺតាមរយៈការរួមភេទ ផ្ទុយគ្នា
- ស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍អាចចម្លងមេរោគអេដស៍ទៅកូនរបស់គាត់
- កុមារកម្ពុជាប្រមាណ៧.០០០ទៅ១០.០០០នាក់ ត្រូវបានប៉ាន់ប្រមាណថា ប្រឈមនឹងការឆ្លងមេរោគអេដស៍ពីម្តាយជារៀងរាល់ឆ្នាំ។

## ឧបសម្ព័ន្ធទី១

## ដំណាក់កាលគ្លីនិកនៃជំងឺអេដស៍របស់អង្គការសុខភាពពិភពលោកនៅលើមនុស្សពេញវ័យ

| ដំណាក់កាលទី១ |
|---|
| ■ គ្មានរោគសញ្ញា<br>■ មានកូនកណ្តុរជាប់ជានិច្ចនិងសាយភាយគ្រប់ទីកន្លែង<br>**លទ្ធភាពអនុវត្តកម្រិត១ (Performant scale ):** គ្មានរោគសញ្ញា មានសកម្មភាពធម្មតា |
| **ដំណាក់កាលទី២** |
| ■ ចុះទម្ងន់តិចជាង១០ភាគរយនៃទម្ងន់ខ្លួន<br>■ មានចេញសញ្ញាលើស្បែកតិចតួច [Seborrheic dermatitis, រមាស់ ,ជំងឺផ្សិតនៅក្រចក (Fungal nail infections) ដំបៅក្នុងមាត់សារចុះសារឡើង (Recurrent oral ulcers), angular cheilitis]<br>■ Herpes Zoster ក្នុងអំឡុង៥ឆ្នាំចុងក្រោយ<br>■ រលាកផ្លូវដង្ហើមផ្នែកខាងលើសារចុះសារឡើង (ឧ:រលាក Sinus ដោយបាក់តេរី )(Bacterial sinusitis)<br>**លទ្ធភាពអនុវត្តកម្រិត២ (Performant scale 2):** មានរោគសញ្ញា (Symptomatic),មានសកម្មភាពធម្មតា (Normal activity) |
| **ដំណាក់កាលទី៣** |
| ■ ចុះទម្ងន់លើសពី១០ភាគរយនៃទម្ងន់ខ្លួន<br>■ រាករ៉ាំរ៉ៃដោយមិនអាចពន្យល់បានមានរយ:ពេលលើសពី១ខែ (Unexplained chronic diarrhea)<br>■ គ្រុនក្តៅអូសបន្លាយមិនអាចពន្យល់បាន ឧ:គ្រុនលោះឬជាប់ជានិច្ច(Intermittent or constant) លើសពី១ខែ<br>■ ជំងឺផ្សិតក្នុងមាត់ [Oral candidiasis (thrush)]<br>■ ជំងឺ Oral hairy leucoplakia<br>■ ជំងឺរបេងសួត<br>■ ជំងឺបង្កដោយបាក់តេរីធ្ងន់ធ្ងរដូចជា ជំងឺហើមសួត ជំងឺរលាកសាច់ដុំមានខ្ទុះ (Pneumonia, Pyomyositis)<br>**លទ្ធភាពអនុវត្តកម្រិត៣ (Performant scale 3) :** ក្នុង១ថ្ងៃសម្រាកជាប់នឹងគ្រែតិចជាង៥០ភាគរយ រយ:ពេល១ខែកន្លងទៅ |

| ដំណាក់កាលទី៤ | |
|---|---|
| ■ ស្គមកំព្រឹងដោយសារជម្ងឺអេដស៍ (HIV Wasting Symdrome)[ក]<br>■ ជម្ងឺហើមសួតដោយ PCP<br>■ ជម្ងឺToxoplasmosisនៅខួរក្បាល (Cerebral toxoplasmosis)<br>■ Cryptosporidiosisនិងមានរាករយៈពេល ១ខែ<br>■ Cryptococcosis extrapulmonary<br>■ ជម្ងឺបង្កឡើងដោយ Cytomegalovirus (CMV,ជម្ងឺសរីរាង្គដទៃទៀតក្រៅពីថ្លើម ក្រលៀនឬកូនកណ្តុរ) ឧ: រលាក retine ភ្នែក<br>■ Herpes Simplex Virus កើតមាននៅលើស្បែកនិងភ្នាស រយៈពេលលើសពី១ខែ ឬកើតនៅលើសរីរាង្គក្នុងពោះ<br>■ Progressive multifocal leucoencephalopathy (PML)<br>■ ជម្ងឺបង្កដោយមេរោគផ្សិតរាលដាលពាសពេញសរីរាង្គ | ■ ជម្ងឺផ្សិតនៅក្នុងបំពង់អាហារ ក្នុងបំពង់ដង្ហើម ទងសួត ឬសួត<br>■ Atypical mycobacteriosis disseminated or pulmonary<br>■ Non-typhoid Salmonella septicaemia<br>■ ជម្ងឺរបេងក្រៅសួត<br>■ ជម្ងឺ Lymphoma<br>■ ជម្ងឺមហារីក (Kaposi's Sarcoma)<br>■ ជម្ងឺរលាកស្រោមខួរក្បាលបណ្តាលមកពីមេរោគអេដស៍[ខ] |
| **លទ្ធភាពអនុវត្តកម្រិត៤** (Performant scale 4): ក្នុង១ថ្ងៃសម្រាកជាប់នឹងគ្រែច្រើនជាង៥០ភាគរយរយៈពេល១ខែកន្លងទៅ | |

[ក] HIV wasting Symdrome: ចុះទម្ងន់លើសពី១០ភាគរយនៃទម្ងន់ខ្លួន រួមផ្សំជាមួយរាករ៉ាំរ៉ៃមិនដឹងមូលហេតុ (មានរយៈពេលលើសពី១ខែ) ឬទន់ខ្សោយជាប្រចាំនិងគ្រុនរ៉ាំរ៉ៃមិនដឹងមូលហេតុ (មានរយៈពេលលើសពី១ខែ)

[ខ] HIV encephalopathy: តាមលទ្ធផលសិក្សាគ្លីនិកបង្ហាញពីការបាត់បង់ភាពចងចាំ និងឬក៏ សកម្មភាពរបស់ប្រព័ន្ធខួរក្បាលដែលធ្វើការរាល់ថ្ងៃបាត់បង់សមត្ថភាពបន្តិចម្តងៗពីច្រើនសប្តាហ៍ទៅច្រើនខែ នៅពេលដែលគ្មានជំងឺណាផ្សេងទៀតកើតមានដំណាលគ្នានឹងជំងឺអេដស៍ទេ។ នោះវាបញ្ជាក់ថា ជំងឺនេះបណ្តាលមកពីមេរោគអេដស៍។

***ឯកសារយោង:*** World Health Organization (WHO). 2004. *Scaling up antiretroviral therapy in resource-limited settings: Treatment guidelines for a public health approach, 2003 Revision,* Appendix D: WHO staging system for HIV infection and disease in adults and adolescents, p. 42.

## ប្រព័ន្ធចំណាត់ថ្នាក់ជំងឺអេដស៍របស់អង្គការសុខភាពពិភពលោកនៅលើកុមារ

| ដំណាក់កាលទី១ |
| --- |
| ■ គ្មានរោគសញ្ញា<br>■ មានកូនកណ្ដុរសាយភាយគ្រប់ទីកន្លែង |
| **ដំណាក់កាលទី២** |
| ■ មានជំងឺរាករ៉ាំរ៉ៃលើសពី៣០ថ្ងៃ ដោយមិនដឹងមូលហេតុ<br>■ មានរោគផ្សិតធ្ងន់ធ្ងរជាប់ជាប្រចាំ ឬ កើតមានជាញឹកញាប់បន្ទាប់ពី១ខែក្រោយសម្រាល<br>■ បាត់បង់ទម្ងន់ ឬមិនមានឡើងទម្ងន់ ដោយមិនដឹងមូលហេតុ<br>■ គ្រុនក្ដៅជាប់លើសពី៣០ថ្ងៃដោយមិនដឹងមូលហេតុ<br>■ មានជំងឺឆ្លងធ្ងន់ធ្ងរដោយពួកបាក់តេរីកើតមានជាញឹកញាប់ក្រៅពីជំងឺ septicaemia ឬ ជំងឺរលាកស្រោមខួរក្បាល ( ឧះ រលាកឆ្អឹង-ខួរឆ្អឹង, ជំងឺហើមសួតដោយសារពួកបាក់តេរី ( មិនមែនជាជំងឺរបេង), បូស )។ |
| **ដំណាក់កាលទី៣** |
| ■ ជំងឺឱកាសនិយមដែលបញ្ជាក់ថាជាជំងឺអេដស៍<br>■ គ្មានការលូតលាស់ (ស្គាំងស្គម) ដោយមិនដឹងពីមូលហេតុ[1]<br>■ មានជំងឺប៉ះពាល់ដល់ខួរក្បាលបន្តិចម្ដងៗ<br>■ ជំងឺមហារីក<br>■ មានជំងឺ septicaemia ឬ រលាកស្រោមខួរក្បាល កើតឡើងញឹកញាប់ |

*ឯកសារយោង:* World Health Organization (WHO). 2004. *Scaling up antiretroviral therapy in resource-limited settings: Treatment guidelines for a public health approach, 2003 Revision,* Appendix E: WHO staging system for HIV infection and disease in children, p. 44

[1] ចុះទម្ងន់ជាប់ជាប្រចាំលើសពី១០%នៃទម្ងន់គោល ឬ តិចជាង៥ដងនៃផលធៀបទម្ងន់និងកម្ពស់ ដោយវាស់ពីរដងផ្ទួនៗគ្នាដោយទុកពេលចន្លោះលើសពី១ខែ ដែលជាការបាត់បង់ទម្ងន់ដោយគ្មានមូលហេតុឬមានជំងឺណាផ្សេងៗទៀត។

# ម៉ូឌុលទី២

## ការរើសអើងនិងមាក់ងាយពាក់ព័ន្ធនឹងមេរោគអេដស៍_ជំងឺអេដស៍

**វត្ថុបំណង**

នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមទាំងអស់អាចនឹង :

១-កំណត់និយមន័យនិងឱ្យឧទាហរណ៍នៃពាក្យការមាក់ងាយនិងការរើសអើង

២-ពន្យល់អំពីបញ្ហាដែលទាក់ទងនឹងមេរោគអេដស៍-ជំងឺអេដស៍និងសិទ្ធិមនុស្ស

៣-ពន្យល់អំពីកត្តានានាដែលជាដើមហេតុនៃការមាក់ងាយនិងការរើសអើង

៤-រៀបរាប់អំពីផលប៉ះពាល់ដែលបណ្តាលមកពីការមាក់ងាយនិងការរើសអើងទាក់ទងជាពិសេសជាមួយ
កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

៥- កំណត់រកមធ្យោបាយដោះស្រាយដើម្បីឆ្លើយតបទៅនឹងការមាក់ងាយនិងការរើសអើង

៦-ពិភាក្សាអំពីតួនាទីរបស់បុគ្គលិកនៃសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
ក្នុងការកាត់បន្ថយការមាក់ងាយនិងការរើសអើង



***រយៈពេលនៃការសិក្សា: ២ម៉ោង៤០នាទី***

*(ក្នុងសកម្មភាពទី១: ល្បែងពាក់ស្លាក- មានជម្រើស)*

*បើមិនលេងល្បែងពាក់ស្លាកទេ រយៈពេលនៃការបង្រៀននឹងមានត្រឹម: ២ម៉ោង២០នាទី*

## សកម្មភាពទី១: ល្បែងពាក់ស្លាក (មានជម្រើស)

### សេចក្តីផ្តើមស្តីពីគំនិតមាក់ងាយនិងរើសអើង

» មេរោគអេដស៍-ជំងឺអេដស៍ មិនគ្រាន់តែនាំមកនូវបញ្ហាដល់សុខភាពរបស់យើងនាពេលបច្ចុប្បន្នតែប៉ុណ្ណោះទេ តែថែមទាំងនាំមកនូវផលប៉ះពាល់ខ្លាំងដល់សិទ្ធិមនុស្សថែមទៀតផង។ ការមាក់ងាយនិងរើសអើងនៅតែជាឧបសគ្គចម្បងក្នុងការបង្ការការចម្លងមេរោគអេដស៍ និងជាឧបសគ្គក្នុងការផ្តល់ការព្យាបាល ថែទាំ និងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ ព្រមទាំងគ្រួសាររបស់គាត់

» ការមាក់ងាយដែលមានទំនាក់ទំនងនឹងមេរោគអេដស៍-ជំងឺអេដស៍ ត្រូវបានទទួលស្គាល់កាន់តែខ្លាំងឡើងថាជាបញ្ហាដ៏លំបាកមួយក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍-ជំងឺអេដស៍ ទាំងនៅថ្នាក់ជាតិអន្តរជាតិនិងក្នុងសហគមន៍

» ការឆ្លើយតបដ៏មានប្រសិទ្ធិភាពទៅនឹងការរីករាលដាលនៃមេរោគអេដស៍-ជំងឺអេដស៍ គឺត្រូវធ្វើការប្រឆាំងនឹងការមាក់ងាយនិងរើសអើង ព្រមទាំងការពារសិទ្ធិមនុស្សដល់អ្នកដែលរស់នៅជាមួយមេរោគអេដស៍និងអ្នកដែលប្រឈមនឹងមេរោគអេដស៍

» អ្នកនឹងចាប់ផ្តើមរៀនម៉ូឌុលនេះ ដោយធ្វើលំហាត់ដែលនិយាយពីផ្នត់គំនិតនិងការមាក់ងាយ

| ល្បែងពាក់ស្លាកឱ្យគ្នាទៅវិញទៅមក | |
|---|---|
| **គោលបំណង** | **ដើម្បីជួយឱ្យដឹងថា តួនាទីរបស់ផ្នត់គំនិតក្នុងការមាក់ងាយ** |
| **សេចក្តីផ្តើម** | ■ អ្នកនឹងត្រូវគេបិទ "ស្លាក" ទៅនឹងខ្នងរបស់អ្នកដោយបង់ស្អិតឬម្ជុលខ្ទាស់-នៅពេលដែលអ្នកដើរចូលក្នុងបន្ទប់។ សូមកុំក្រឡេកមើលស្លាកដែលបិទលើអ្នកឱ្យសោះ។<br>■ ដើរពេញបន្ទប់និងជជែកគ្នាទៅវិញទៅមកជាមួយសិក្ខាកាមដទៃ ដោយបញ្ចេញឥរិយាបថទៅរកអ្នកដែលពាក់ស្លាក ធ្វើដូចជាអ្នកកំពុងតែនៅក្នុងសង្គមនោះមែនទែនអីចឹង ក៏ប៉ុន្តែមិនត្រូវប្រាប់ឱ្យសាមីខ្លួនដឹងថា "ស្លាក" របស់គាត់ជាអ្វីទេ។<br>■ ៥-៧នាទីក្រោយមក អ្នកត្រូវត្រឡប់មកអង្គុយកន្លែងដើមវិញ និងនិយាយប្រាប់អ្នកទាំងអស់គ្នាពីអារម្មណ៍របស់អ្នកនៅពេលនិយាយជាមួយអ្នកដទៃ។<br>■ ព្យាយាមប៉ាន់ស្មានអំពីស្លាកដែលអ្នកកំពុងតែពាក់នៅលើខ្នង ដោយយោងទៅលើសំដីសំដៅនិងឥរិយាបថរបស់អ្នកដទៃដែលមានចំពោះអ្នក។<br>■ យកស្លាកចេញពីខ្នងរបស់អ្នកមកមើល។<br>■ នៅក្នុងការពិភាក្សាក្រុមធំ ចូរផ្លាស់ប្តូរយោបល់គ្នាអំពីសំណួរដូចតទៅនេះ:<br>-តើអ្នកបានទាយដឹងថាអ្នកពាក់ស្លាកអ្វីដែរឬទេ?<br>-តើនៅពេលដែលគេសំដែងឥរិយាបថតាមបែបផ្នត់គំនិតសង្គមដូច្នេះ តើអ្នកមានអារម្មណ៍យ៉ាងណាដែរ?<br>-តើអ្នកគិតថាដូចម្តេចដែរ ចំពោះបទពិសោធន៍បែបនេះ?<br>-តើអ្នកមានឆ្ងល់ឬភ្ញាក់ផ្អើលអ្វីដែរទេ នៅពេលដែលគេប្រព្រឹត្តចំពោះអ្នកដូច្នោះ? |

## សកម្មភាពទី២: តើអ្វីទៅជាការមាក់ងាយ? តើអ្វីទៅជាការរើសអើង?

» គ្រូនឹងសួរអ្នកថា:

តើអ្វីទៅជាការមាក់ងាយ?

តើអ្វីទៅជាការរើសអើង?

» គ្រូទុកពេលឱ្យអ្នកពិភាក្សាចម្លើយ

» ស្លាយទី៦-៨ សង្ខេបពីការមាក់ងាយនិងរើសអើង

### តើដូចម្តេចដែលហៅថា ការមាក់ងាយ?

- ការមាក់ងាយសំដៅទៅលើអាកប្បកិរិយាឬជំនឿអវិជ្ជមាន ឆ្ពោះទៅរកនរណាម្នាក់
- ការមាក់ងាយដែលទាក់ទងនឹងមេរោគអេដស៍-ជម្ងឺអេដស៍មានន័យថា ជាអាកប្បកិរិយា ឬជំនឿអវិជ្ជមាន សំដៅឆ្ពោះទៅរក:
  - អ្នកផ្ទុកមេរោគអេដស៍ ឬអ្នកដែលគេគិតថាមានផ្ទុកមេរោគអេដស៍
  - គ្រួសារ មិត្តភក្ត្រ ក្រុមមនុស្សក្នុងសង្គម សហគមន៍របស់អ្នកផ្ទុកមេរោគអេដស៍

ការមាក់ងាយឆ្លុះបញ្ចាំងអំពីអាកប្បកិរិយា

6

### តើដូចម្តេចដែលហៅថា ការរើសអើង

- ការរើសអើងគឺជាការប្រព្រឹត្តិដោយលំអៀងរបស់បុគ្គល ឬក្រុមមនុស្ស
- អាចឱ្យនិយមន័យបានដោយយោងទៅលើសិទ្ធិមនុស្សឬការផ្តល់សិទ្ធិក្នុង:
  - ការងារ
  - ប្រពន្ធ័ថែទាំសុខភាព
  - ប្រពន្ធ័ច្បាប់
  - ប្រពន្ធ័សុខមាលភាពសង្គម
  - ជីវិតបន្តពូជ និងគ្រួសារ

**ការរើងអើងសំដៅទៅលើ អំពើឬឥរិយាបថដែលបានប្រព្រឹត្ត**

7

### ឧទាហរណ៍នៃការរើសអើង

- បុគ្គលិកសុខាភិបាលម្នាក់បដិសេធផ្តល់សេវាឱ្យអ្នកផ្ទុកមេរោគអេដស៍
- ស្រ្តីម្នាក់មិនអាចរកការងារធ្វើបានដោយគេដឹងថាគាត់មានផ្ទុកមេរោគអេដស៍
- បុរសម្នាក់បាត់បង់ការងារ នៅពេលដែលប្រធានរបស់គាត់ដឹងថាគាត់មានផ្ទុកមេរោគអេដស៍
- ស្រ្តីមេម៉ាយនិងកូននៃបុរសម្នាក់ដែលបានស្លាប់ដោយសារជម្ងឺអេដស៍ត្រូវគេបង្ខំឱ្យចាកចេញពីសហគមន៍
- ស្រ្តីម្នាក់ដែលជ្រើសរើសមិនបំបៅកូនដោយដោះត្រូវបានគេសន្មតថាមានផ្ទុកមេរោគអេដស៍ និងត្រូវម្តាយក្មេកបណ្តេញចេញពីផ្ទះ

មនុស្សដែលត្រូវគេមាក់ងាយអាចត្រូវរងនូវភាពឈឺចាប់ដោយការរើសអើង និង ការរំលោភសិទ្ធិមនុស្ស

8

## សកម្មភាពទី៣: ការរើសអើងនិងសិទ្ធិមនុស្ស

» ស្លាយទី១០-១២

» បុគ្គលមានសិទ្ធិធ្វើការសម្រេចចិត្តដោយខ្លួនឯង អំពីបញ្ហាដែលធ្វើឱ្យប៉ះពាល់ដល់ជីវិតរបស់គេ។

### សិទ្ធិមនុស្សអន្តរជាតិ

- សេរីភាពជៀសផុតពីការរើសអើងគឺជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស
- ការរើសអើងប្រឆាំងនឹងមនុស្សផ្ទុកមេរោគអេដស៍ ឬអ្នកដែលគេគិតថាមានផ្ទុកមេរោគអេដស៍ គឺជាការរំលោភសិទ្ធិមនុស្សយ៉ាងជាក់ច្បាស់។

10

### សេវាបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន និងសិទ្ធិមនុស្ស(១)

ស្ត្រីមានសិទ្ធិ:

- កំណត់ទិសដៅក្នុងជីវិតបន្តពូជ និងការរួមភេទរបស់ខ្លួន
- ជ្រើសរើសការមានកូន ឬមិនចង់មានកូន
- ទទួលបាននូវព័ត៌មានស្ដីអំពីមេរោគអេដស៍-ជម្ងឺអេដស៍
- ទទួលនូវការការពារប្រឆាំងនឹងការឆ្លងមេរោគអេដស៍

កុមារមានសិទ្ធិ:

- រស់រានមានជីវិត អភិវឌ្ឍន៍ និងទទួលបាននូវសុខភាពល្អ

11

### សេវាបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន និងសិទ្ធិមនុស្ស (២)

ស្ត្រីមានសិទ្ធិ:

- ទទួលសេវាផ្ដល់ប្រឹក្សាធ្វើតេស្តឈាមដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់និងមានសិទ្ធិដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ពួកគាត់
- ជ្រើសរើសមិនធ្វើតេស្តឈាម ឬមិនទទួលយកលទ្ធផលតេស្តឈាមរកមេរោគអេដស៍របស់គាត់
- ធ្វើការសំរេចចិត្ត អំពីការចិញ្ចឹមកូន ក្រោយពីបានទទួលព័ត៌មានពេញលេញ និងមានសិទ្ធិទទួលការគាំទ្រចំពោះការសំរេចចិត្តរបស់គាត់។

12

## សកម្មភាពទី៤: ពាក្យគន្លឹះ: តើអ្វីដែលជាមូលហេតុនៃការធ្វើឱ្យមានការមាក់ងាយនិងរើសអើង?

» គ្រូនឹងស្នើឱ្យអ្នករកកត្តាដែលស្ថិតនៅពីក្រោយការមាក់ងាយនិងរើសអើងទាក់ទងនឹងមេរោគអេដស៍ និងសូមគិតថា តើការមាក់ងាយស្តែងចេញយ៉ាងដូចម្តេច?

» ស្លាយទី១៤-១៦ សង្ខេបពីការមាក់ងាយនឹងរើសអើង

### តើមានកត្តាអ្វីខ្លះដែលទាក់ទងទៅនឹងមេរោគអេដស៍_ជម្ងឺអេដស៍ នាំឱ្យមានការមាក់ងាយនិងការរើសអើង?

ការមាក់ងាយនិងរើសអើងទាក់ទងនឹងមេរោគអេដស៍-ជម្ងឺអេដស៍ កើតឡើងបណ្តាលមកពី:

- ការខ្លាចឆ្លងមេរោគអេដស៍
- ខ្វះចំណេះដឹងអំពីមេរោគអេដស៍-ជម្ងឺអេដស៍ ដូចជា:
  - -របៀបចម្លង
  - -អត្ថន័យនៃមេរោគអេដស៍-ជម្ងឺអេដស៍
  - -ការយល់ថា មានផ្ទុកមេរោគអេដស៍ឬជម្ងឺអេដស៍គឺដូចជាការដាក់ទោសប្រហារជីវិត
- ការទាក់ទងគ្នារវាង ការចម្លងមេរោគអេដស៍ និងឥរិយាបថរួមភេទរបស់បុគ្គល
- ខ្លាចរងនូវការមាក់ងាយដោយសារតែសេពគប់ជាមួយអ្នកផ្ទុកមេរោគអេដស៍ 14

### ហេតុអ្វីបានជាការមាក់ងាយដែលទាក់ទងនឹងមេរោគអេដស៍_ជម្ងឺអេដស៍ គឺជាបញ្ហាមួយ?

- អ្នកផ្ទុកមេរោគអេដស៍អាចរងនូវការស្តីបន្ទោសចំពោះការបង្កជម្ងឺដោយខ្លួនឯង
- ការមាក់ងាយអាចសំដៅទៅលើឥរិយាបថដែលនាំឱ្យឆ្លងមេរោគអេដស៍ ។

  ឧទាហរណ៍ : ពេស្យាចារ
- ការមាក់ងាយប្រឆាំងនឹងក្រុមមនុស្សដែលសង្គមមិនសូវនឹកនាដល់អាចមានភាពខ្លាំងក្លា:
  - -អ្នករកស៊ីផ្លូវភេទ អ្នកចាក់គ្រឿងញៀន បុរសដែលរួមភេទជាមួយបុរសដូចគ្នា
  - -ប្រជាជនក្រីក្រ ជនជាតិភាគតិច ។

15

### តើការមាក់ងាយនិងរើសអើងស្តែងចេញឡើងយ៉ាងដូចម្តេច?

- អាកប្បកិរិយា
  - -ការគិតថាអ្នកផ្ទុកមេរោគអេដស៍ ត្រូវទទួលខុសត្រូវចំពោះជម្ងឺរបស់ពួកគេ
  - -ការជឿថា ជម្ងឺនេះគឺជាទណ្ឌកម្មសំរាប់ឥរិយាបថខុសឆ្គង
- សកម្មភាព
  - -ពាក់ស្រោមដៃមុននឹងប៉ះពាល់អ្នកផ្ទុកមេរោគអេដស៍
  - -មិនទិញទំនិញរបស់អ្នកផ្ទុកមេរោគអេដស៍
  - -មិនទៅលេងផ្ទះអ្នកផ្ទុកមេរោគអេដស៍
- ការប្រើប្រាស់ភាសា
  - -សូមគិតដល់ការដាក់ឈ្មោះ ឱ្យអ្នកផ្ទុកមេរោគអេដស៍-អ្នកជម្ងឺអេដស៍ ។ តើពាក្យទាំងនោះជាពាក្យមាក់ងាយដែរឬទេ?

16

## សកម្មភាពទី៥: ធ្វើការជាក្រុម: ឧទាហរណ៍នៃការមាក់ងាយនិងរើសអើង

» គ្រូចែកអ្នកជា៣ក្រុម ដើម្បីគិតពីពាក្យការមាក់ងាយនិងរើសអើង

ក្រុមទី១: នៅសេវាថែទាំសុខភាព

ក្រុមទី២: នៅកន្លែងធ្វើការ

ក្រុមទី៣: នៅក្នុងគ្រួសារនិងសហគមន៍

» ក្នុងក្រុមនីមួយៗ ចូររកឧទាហរណ៍នៃការ"មាក់ងាយនិងរើសអើង"ដែលមានស្របតាមប្រធានបទរបស់ក្រុមខ្លួន

» ស្លាយទី១៨-២០ សង្ខេបពីអត្ថន័យនៃលំហាត់

### ១_នៅសេវាថែទាំសុខភាព

- មិនព្រមឱ្យអ្នកផ្ទុកមេរោគអេដស៍-ជម្ងឺអេដស៍បានទទួលការថែទាំ និងព្យាបាល
- ផ្តល់នូវការថែទាំមិនបានល្អប្រសើរ
- ធ្វើឱ្យបែកការសម្ងាត់
- អនុវត្តការបង្ការជាសកល ចំពោះអ្នកផ្ទុកមេរោគអេដស៍តែប៉ុណ្ណោះ។ មិនអនុវត្តវិធីនេះនៅគ្រប់អ្នកជម្ងឺទាំងអស់ទេ។
- ធ្វើការកៀបសង្កត់ឱ្យអ្នកផ្ទុកមេរោគអេដស៍ធ្វើអ្វីមួយខុសពីអ្នកឯទៀតដែលមិនត្រូវបានសំណូមពរឱ្យធ្វើ។ (ឧទាហរណ៍ ការរំលូតកូន. ការបញ្ឈប់កំណើត)។

18

### ២_នៅកន្លែងធ្វើការ

- តំរូវឱ្យធ្វើតេស្តឈាមរកមេរោគអេដស៍មុននឹងទទួលឱ្យធ្វើការងារ ឬក្នុងពេលកំពុងបំពេញការងារ
- មិនជួលអ្នកផ្ទុកមេរោគអេដស៍ឱ្យធ្វើការ
- បណ្តេញចេញពីការងារដោយសារតែមានផ្ទុកមេរោគអេដស៍
- ធ្វើឱ្យបែកការសម្ងាត់
- បដិសេធធ្វើការជាមួយអ្នកណាម្នាក់ដែលគេដឹងថាមានផ្ទុកមេរោគអេដស៍

19

### ៣_នៅក្នុងគ្រួសារ ឬ សហគមន៍

- បោះបង់ចោលអ្នកផ្ទុកមេរោគអេដស៍ ឬ ដៃគូ និងកូនរបស់គេ ឬ ឱ្យអ្នកទាំងនោះរស់នៅដាច់ឆ្ងាយពីអ្នកដទៃ
- មិនអនុញ្ញាតឱ្យអ្នកផ្ទុកមេរោគអេដស៍ចូលរួមក្នុងកិច្ចការសង្គមដែលមាននៅតាមមូលដ្ឋាន
- មិនអនុញ្ញាតឱ្យកូនរបស់អ្នកផ្ទុកមេរោគអេដស៍-អ្នកជម្ងឺអេដស៍ចូលរៀននៅសាលា
- ប្រើអំពើហឹង្សាប្រឆាំងនឹងអ្នកផ្ទុកមេរោគអេដស៍
- មិនជួយគាំទ្រគ្រួសារដែលមានអ្នកស្លាប់ ឬ កុមារកំព្រា

20

## សកម្មភាពទី៦: បំផុសគំនិត: តើការមាក់ងាយនិងរើសអើងនាំឱ្យមានផលប៉ះពាល់ដល់អ្វីខ្លះ?

» គ្រូស្នើឱ្យអ្នកពិភាក្សាពីផលប៉ះពាល់នៃការមាក់ងាយនិងរើសអើង។

» គិតជាពិសេស អំពី:

១. មនុស្សដែលមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន (ជាពិសេសស្ត្រីមានផ្ទៃពោះ) ប៉ុន្តែគិតថា ខ្លួនមិនមែនជាអ្នកប្រឈមនឹងមេរោគអេដស៍ទេ

» មនុស្សដែលដឹងថាខ្លួនមានផ្ទុកមេរោគអេដស៍

**ផលប៉ះពាល់នៃការមាក់ងាយ និង ការរើសអើង**

ការមាក់ងាយនិងរើសអើង អាចធ្វើឱ្យស្ត្រីមានផ្ទៃពោះ:

- មិនបានមកទទួលសេវាថែទាំផ្ទៃពោះ
- មិនទទួលយកការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់
- មិនបានពិភាក្សាអំពីការធ្វើតេស្តឈាមរកមេរោគអេដស៍ និងមិនបានបង្ហាញលទ្ធផលតេស្តឱ្យគេដឹង
- មិនទទួលយកអន្តរាគមន៍ក្នុងការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- មិនជ្រើសរើសយកវិធីចិញ្ចឹមកូនណាមួយតាមការអប់រំរបស់អ្នកផ្តល់ប្រឹក្សា។

**ការមាក់ងាយនិងរើសអើងអាចនាំអ្នកផ្ទុកមេរោគអេដស៍ឯកោពីគ្រួសារ ឬពីសង្គម និងនាំឱ្យមានការមាក់ងាយដល់កុមារដែលកើតពីម្តាយដែលមានផ្ទុកមេរោគអេដស៍ផងដែរ។**

22

## សកម្មភាពទី៧: ការជជែកវែកញែក: ការឆ្លើយតបទៅនឹងការមាក់ងាយនិងរើសអើង

» គោលបំណងនៃលំហាត់នេះ គឺដើម្បីពិភាក្សារកដំណោះស្រាយឆ្លើយតបទៅនឹងការមាក់ងាយ:

» គ្រូចែកសិក្ខាកាមជា២ក្រុម:
ក្រុមទី១: ការឆ្លើយតបនៅថ្នាក់ជាតិ
ក្រុមទី២: ការឆ្លើយតបនៅថ្នាក់សហគមន៍

» ធ្វើការពិភាក្សាតាមក្រុមដើម្បីដោះស្រាយបញ្ហាលើចំណុចទាំងនោះ

» គ្រូសម្របសម្រួលនឹងដឹកនាំការពិភាក្សាជជែកវែកញែករវាងក្រុមទាំងពីរលើចំណុច:
១. តើថ្នាក់នីមួយៗអាចធ្វើអ្វីបានខ្លះ?
២. តើកិច្ចប្រឹងប្រែងអាចមានប្រសិទ្ធិភាពត្រឹមកម្រិតណា?
៣. តើមានបញ្ហាអ្វីខ្លះដែលអាចជួបប្រទះ នៅពេលលើកកម្ពស់វិធានការណ៍នោះ

**ការឆ្លើយតបទៅនឹងការមាក់ងាយនិងរើសអើង**

កិច្ចប្រឹងប្រែងដើម្បីឆ្លើយតបទៅនឹងការមាក់ងាយនិងរើសអើងចំពោះជម្ងឺអេដស៍ត្រូវឱ្យមាននៅគ្រប់:

- ថ្នាក់ជាតិ
- ថ្នាក់សហគមន៍
- សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- បុគ្គលម្នាក់ៗ

តំរូវការជាគន្លឹះទាំងនោះមាន:

- ផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវអំពីមេរោគអេដស៍-ជម្ងឺអេដស៍
- ដឹងអំពីបញ្ហាដែលទាក់ទងនឹងការមាក់ងាយ
- ពិភាក្សាជាចំហអំពីមេរោគអេដស៍-ជម្ងឺអេដស៍
- ធ្វើការឆ្លើយតបដោយចំហទៅនឹងការមាក់ងាយនិងរើសអើងយ៉ាងសកម្ម
- មានឆន្ទៈទទួលខុសត្រូវ និងធ្វើជាគំរូដល់អ្នកដទៃ

24

| នៅថ្នាក់ជាតិ | នៅថ្នាក់សហគមន៍ |
|---|---|
| ■ ការគាំទ្រនយោបាយកំរិតខ្ពស់ ចំពោះគំនិតផ្តួចផ្តើមនិងគោលនយោបាយសំរាប់ប្រឆាំងមេរោគ អេដស៍-ជម្ងឺអេដស៍<br>■ បុគ្គលដែលមានឋានៈខ្ពស់ត្រូវដើរតួជាគំរូដល់អ្នកដទៃ<br>■ ការតាក់តែងច្បាប់<br>  ■ ប្រឆាំងនឹងការរើសអើង<br>  ■ ការពារសិទ្ធិនារី និងអ្នករស់នៅជាមួយមេរោគអេដស៍<br>■ ការផ្តល់សេវា<br>  ■ សេវាព្យាបាលជម្ងឺឱកាសនិយម និង ព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍<br>  ■ កម្មវិធីអប់រំដល់អ្នករកស៊ីផ្លូវភេទ និងអ្នកចាក់ថ្នាំញៀន<br>  ■ សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន<br>25 | ■ ផ្តល់ការអប់រំនិងបណ្តុះបណ្តាលអំពីមេរោគអេដស៍-ជម្ងឺអេដស៍ ក្នុងបំណងបង្កើនចំណេះដឹងនិង ការយល់ដឹងដល់:<br>  - អ្នកដែលគេជឿទុកចិត្ត និងមេដឹកនាំសាសនា<br>  - ឆ្មបបុរាណ គ្រូបុរាណ<br>  - បុគ្គលិកសុខាភិបាលនៅតាមសហគមន៍<br>  - អ្នកលក់ដូរនៅតាមសហគមន៍<br>■ លើកកំពស់សកម្មភាពនិងធ្វើអន្តរាគមន៍ដល់ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ព្រោះវាជាសមាសភាគមួយនៃសេវាថែទាំសុខភាពដែរ ។<br>■ ភាពជាដៃគូនៅក្នុងសហគមន៍<br>■ ការចូលរួមរបស់អ្នកផ្ទុកមេរោគអេដស៍-អ្នកជម្ងឺអេដស៍នៅគ្រប់ទីកន្លែង<br>■ ទំនាក់ទំនងជាចំហស្តីពីមេរោគអេដស៍-ជម្ងឺអេដស៍មានសារៈសំខាន់ណាស់ ដើម្បីជួយធ្វើឱ្យបញ្ហា មេរោគអេដស៍-ជម្ងឺអេដស៍ទៅជារឿងធម្មតា និងជួយកាត់បន្ថយភាពមាក់ងាយផងដែរ ។<br>26 |

**សកម្មភាពទី៨: ធ្វើការជាក្រុម : ការឆ្លើយតបទៅនឹងការមាក់ងាយនឹងរើសអើងតាមរយៈសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន**

» បន្ទាប់ពីសកម្មភាពទី៧ លំហាត់នេះមានគោលបំណងតាមដានពិនិត្យមើលសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនថាតើអាចរួមចំណែកក្នុងការឆ្លើយតបទៅនឹងការមាក់ងាយនិងរើសអើងបានដែរឬទេ

» គ្រូនឹងចែកសិក្ខាកាមជា២ក្រុមម្តងទៀត ដើម្បីពិភាក្សាលើប្រធានបទដូចតទៅនេះ:

-ក្រុមទី១: តើប្រធានគ្រប់គ្រងអាចធ្វើអ្វីខ្លះដើម្បីឆ្លើយតបទៅនឹងការមាក់ងាយតាមរយៈសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ? តើគាត់មានតួនាទីអ្វី និងទទួលខុសត្រូវលើអ្វីខ្លះ?

-ក្រុមទី២: តើអ្នកផ្តល់ប្រឹក្សា ឬបុគ្គលិកសុខាភិបាលអាចធ្វើអ្វីខ្លះ ដើម្បីកាត់បន្ថយការមាក់ងាយនិងរើសអើងនៅកន្លែងធ្វើការ?

» គ្រូទុកពេល១០នាទី សម្រាប់ឱ្យអ្នកពិភាក្សា

» សិក្ខាកាមម្នាក់ៗក្នុងក្រុមនីមួយៗនឹងឡើងបង្ហាញពីគំនិតរបស់ក្រុមខ្លួន

» សរសេរគំនិតទាំងនោះនៅលើក្តារខៀននិងពិភាក្សាវា

» ស្លាយទី២៨-៣៤ សង្ខេបតួនាទីរបស់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន តួនាទីរបស់អ្នកគ្រប់គ្រងនិងបុគ្គលិកសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ក្នុងការឆ្លើយតបទៅនឹងការមាក់ងាយនិងរើសអើង

## តើសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនអាចឆ្លើយតបទៅនឹងការមាក់ងាយនិងរើសអើងយ៉ាងដូចម្តេច?

អ្នកគ្រប់គ្រងនិងបុគ្គលិកសុខាភិបាលមានតួនាទីធ្វើការប្រឆាំងនឹងបរិយាកាសមាក់ងាយនឹងរើសអើងដែលទាក់ទងទៅនឹងមេរោគអេដស៍-ជម្ងឺអេដស៍ ដើម្បី:

- ផ្លាស់ប្តូរអាកប្បកិរិយានិងការប្រព្រឹត្តិ នៅក្នុងគ្រឹះស្ថានសុខាភិបាល
- ផ្លាស់ប្តូរការប្រព្រឹត្តិរបស់សហគមន៍

ឧទាហរណ៍:

- បណ្តុះបណ្តាលដល់បុគ្គលិកសុខាភិបាល រួមមានការពិភាក្សាពីការមាក់ងាយទាក់ទងនឹងមេរោគអេដស៍-ជម្ងឺអេដស៍
- ការបញ្ជ្រាបសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនទៅក្នុងសេវាថែទាំផ្ទៃពោះជាលក្ខណៈស្តង់ដា
  - ផ្តល់សេវាប្រឹក្សានិងធ្វើតេស្តឈាមដោយស្ម័គ្រចិត្តនិងរក្សាការសំម្ងាត់ដល់គ្រប់ស្ត្រីមានផ្ទៃពោះ ដើម្បីធ្វើឱ្យបញ្ហាមេរោគអេដស៍-ជម្ងឺអេដស៍ក្លាយទៅជារឿងធម្មតា
- បង្កើនការចូលរួមរបស់ដៃគូនិងគ្រួសារ
  - សង្កត់ធ្ងន់ពីសារៈសំខាន់នៃការចូលរួមរបស់ដៃគូក្នុងការធ្វើតេស្តឈាម និងការគាំទ្រពីគ្រួសារ អប់រំអំពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ការព្យាបាលនិងបង្ការដោយឱសថប្រឆាំងមេរោគអេដស៍ ការចិញ្ចឹមកូន
  - ស្វែងរកការបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយក្រុមបុរស ប្រសិនបើគេមិនមកជាមួយប្រពន្ធរបស់គេ
- ឱ្យអ្នកផ្ទុកមេរោគអេដស៍-អ្នកជម្ងឺអេដស៍ ចូលរួមកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនព្រោះ:
  - អ្នកផ្ទុកមេរោគអេដស៍-ជម្ងឺអេដស៍ អាចបណ្តុះបណ្តាលឱ្យក្លាយជាអ្នកផ្តល់ប្រឹក្សាបាន
  - ពួកគេអាចជួយណែនាំអ្នកជម្ងឺដទៃទៀតឱ្យទៅរកសេវាផ្សេងៗដែលមាននៅក្នុងមន្ទីរពេទ្យ

28

## តួនាទីនិងការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

អ្នកគ្រប់គ្រងកម្មវិធី ដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តន៍និងពង្រឹងគោលនយោបាយ និង នីតិវិធីស្តីពី:

- ការពារបុគ្គល ដោយប្រឆាំងនឹងការមាក់ងាយនិងការរើសអើង ដើម្បីធានាបាននូវៈ
  - ភាពស្មើគ្នាក្នុងការទទួលសេវាថែទាំនិងព្យាបាល
  - ភាពយុត្តិធម៌ ក្នុងការជ្រើសរើសបុគ្គលិកធ្វើការងារនិងក្នុងការបំពេញភារកិច្ច
  - ការគាំទ្រដល់បុគ្គលិកសុខាភិបាលដែលឆ្លងជម្ងឺអេដស៍
- ការរក្សាការសម្ងាត់
  - ត្រូវអនុវត្តគោលនយោបាយជាតិ
  - ត្រូវចាត់វិធានការណ៍ឱ្យម៉ឺងម៉ាត់ និងឆ្លើយតបទៅនឹងការធ្វើឱ្យបែកការសម្ងាត់
- ការបង្ការជាសកល
- ការបង្ការក្រោយប្រឈមនឹងការឆ្លងមេរោគអេដស៍ក្នុងការងារ
- រាយការណ៍និងដាក់ពិន័យចំពោះការប្រព្រឹត្តិ ឬ ឥរិយាបថដែលធ្វើឡើងក្នុងន័យប្រមាថមាក់ងាយ ។

29

## ការធ្វើឱ្យបែកការសម្ងាត់

សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន អាចទទួលបានជោគជ័យអាស្រ័យលើការកំណត់ដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ស្ត្រី

- អ្នកផ្ទុកមេរោគអេដស៍និងគ្រួសារត្រូវមានទំនុកចិត្តលើប្រព័ន្ធសុខាភិបាល
- បើសិនជា ស្ត្រីគិតថាការសម្ងាត់មិនត្រូវបានរក្សាឱ្យបានត្រឹមត្រូវទេ នោះការជឿទុកចិត្តនឹងស្ថិតនៅជាមន្ទិល ហើយអតិថិជននឹងមិនមកប្រើប្រាស់សេវានោះទៀតទេ
- គោលនយោបាយសំរាប់ឆ្លើយតបទៅនឹងការធ្វើឱ្យបែកការសម្ងាត់ត្រូវតែរៀបចំឱ្យមាន និង ត្រូវអនុវត្ត
- ត្រូវផ្តល់ព័ត៌មានដល់អតិថិជនពីវិធានការដែលគាត់អាចធ្វើ ដើម្បីឆ្លើយតបទៅនឹងការធ្វើឱ្យបែកការសម្ងាត់

30

## តួនាទីនិងការទទួលខុសត្រូវនៃបុគ្គលិកសុខាភិបាល

បុគ្គលិកសុខាភិបាលត្រូវគោរពសិទ្ធិស្ត្រីនិងបុរសឱ្យបានទូលំទូលាយ ទោះបីជាគាត់មានផ្ទុកមេរោគអេដស៍ក្តី មិនមានផ្ទុកមេរោគអេដស៍ក្តី

- បុគ្គលិកសុខាភិបាលត្រូវៈ
  - ភ្ញាក់រលឹកដោយខ្លួនឯង
  - ទទួលបាននូវព័ត៌មាន និងមានចំណេះដឹងគ្រប់គ្រាន់
  - ចូលរួមយ៉ាងសកម្ម

31

## ១-ការភ្ញាក់រលឹកដោយខ្លួនឯង

បុគ្គលិកសុខាភិបាលត្រូវគោរពសិទ្ធិស្ត្រីនិងបុរសឱ្យបានទូលំទូលាយ ទោះបីជាគាត់មានផ្ទុកមេរោគអេដស៍ក្តី មិនមានផ្ទុកមេរោគអេដស៍ក្តី

- បង្កើនការយល់ដឹងរបស់បុគ្គលពីឥរិយាបថនិងភាសាមាក់ងាយដែលអាចមាន ឬ ការធ្វើឱ្យបែកការសម្ងាត់
- សិក្សាពីអាក្បកិរិយា ការសន្និដ្ឋាន ឬ ភាពលំអៀងរបស់បុគ្គលចំពោះអ្នកផ្ទុកមេរោគអេដស៍-ជម្ងឺអេដស៍

ចំណាំៈ ការរីករាលដាលនៃមេរោគអេដស៍-ជម្ងឺអេដស៍នៅកម្ពុជា បានឆ្លងចូលដល់ក្រុមមនុស្សដែលមិនមែនជាក្រុមប្រឈមខ្ពស់។ ការស្រមៃគិតដល់ប្រភេទមនុស្សដែលរងគ្រោះដោយសារមេរោគអេដស៍-ជម្ងឺអេដស៍ពីមុនមក អាចមិនពិតតទៅទៀតទេ។

32

## ២-ការទទួលបាននូវព័ត៌មាននិងមានចំណេះដឹងគ្រប់គ្រាន់

- កំណត់រក និងកែតំរូវនូវព័ត៌មាន ឬទស្សនៈភ័ន្តច្រឡំអំពីមេរោគអេដស៍-ជម្ងឺអេដស៍
- គោរពគោលនយោបាយជាតិស្តីពីការរក្សាការសម្ងាត់ការព្រមព្រៀងក្រោយពីទទួលបាននូវព័ត៌មានត្រឹមត្រូវ អនុវត្តប្រឆាំងនឹងការរើសអើង ការត្រួតពិនិត្យជម្ងឺឆ្លង
- គាំទ្រសិទ្ធិស្ត្រី ដើម្បីឱ្យគាត់ដឹងថា សិទ្ធិនោះគឺជាអ្វី និង ទទួលជំនួយបានយ៉ាងដូចម្តេច
- ត្រូវដឹងពីអំពើហឹង្សាក្នុងគ្រួសារដែលអាចកើតមានឡើង ត្រូវសួរពីបញ្ហានេះ ត្រូវដឹងពីទីកន្លែងដែលត្រូវបញ្ជូនអ្នកជម្ងឺទៅទទួលសេវា
- ត្រូវដឹងពីសេវាថែទាំសុខភាពនិងគាំទ្រដទៃទៀត សំរាប់អ្នកផ្ទុកមេរោគអេដស៍

33

## ៣-ការចូលរួមយ៉ាងសកម្ម

- កំណត់រកផ្នត់គំនិត និងពាក្យចចាមអារាមទាក់ទងនឹងមេរោគអេដស៍-ជម្ងឺអេដស៍ដែលមានតាមមូលដ្ឋាន
- ពិភាក្សាពីទស្សនៈភ័ន្តច្រឡំនៅពេលណាដែលសមស្របនៅពេលផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។ ឧៈ នៅពេលផ្តល់ការអប់រំនៅថ្នាក់អប់រំម្តាយ
- សំរបសំរួលគាំទ្រដល់ក្រុមមិត្តអប់រំមិត្តនិងសហគមន៍
  - ដឹងថាការមានការគាំទ្រអ្វីខ្លះ
  - ធ្វើការបញ្ជូននិងតាមដាន
  - លើកទឹកចិត្តឱ្យមានការគាំទ្រមិត្តអប់រំមិត្ត គាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ឱ្យប្រាប់ពីស្ថានភាពរបស់គាត់ឱ្យគេដឹង
  - លើកកំពស់ឱ្យកន្លែងធ្វើការផ្តល់ភាពកក់ក្តៅដល់អ្នកផ្ទុកមេរោគអេដស៍

ការកើនឡើងនូវការចេញមុខនៃអ្នកផ្ទុកមេរោគអេដស៍ បញ្ជាក់នូវការទទួលស្គាល់ពីសហគមន៍កាន់តែកើនឡើង

34

## ម៉ូឌុលទី២: ចំណុចគន្លឹះ

- ការមាក់ងាយឆ្លុះបញ្ចាំងអំពីអាកប្បកិរិយា ។ ការរើសអើងស្តែងចេញជាសកម្មភាព
- ការរើសអើងតែងតែត្រូវបានកំណត់ក្នុងនាមសិទ្ធិមនុស្សនិងការផ្តល់សិទ្ធិដល់នរណាម្នាក់
- គំនិតមាក់ងាយអាចនាំឈានទៅរកការរើសអើងនិងការរំលោភសិទ្ធិមនុស្ស
- មនុស្សផ្ទុកមេរោគអេដស៍គ្រប់រូបមានសិទ្ធិសេរីភាពជៀសផុតពីការរើសអើង
- ការមាក់ងាយដែលទាក់ទងនឹងមេរោគអេដស៍-ជំងឺអេដស៍ អាចធ្វើឱ្យអ្នកផ្ទុកមេរោគអេដស៍ មិនហ៊ានមកទទួលសេវាថែទាំ និង:
    - មិនហ៊ានបង្ហាញស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន
    - បន្ថយការទទួលយកវិធីចិញ្ចឹមកូនដោយសុវត្ថិភាព
    - មិនបានទទួលការអប់រំ ការផ្តល់ប្រឹក្សានិងការព្យាបាល ។
- បុគ្គលិកសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន មានភារកិច្ចគោរពនូវសិទ្ធិស្ត្រីនិងបុរស ទោះបីជាអ្នកនោះមានផ្ទុកមេរោគអេដស៍ក្តី ឬមិនមានផ្ទុកមេរោគអេដស៍ក្តី ។

បុគ្គលិកសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន អាចៈ

- ជួយកាត់បន្ថយការមាក់ងាយនិងការរើសអើងដែលមាននៅក្នុងគ្រឹះស្ថានសុខាភិបាល ក្នុងសហគមន៍និងនៅថ្នាក់ជាតិ ។
- ដើរតួជាគំរូដោយព្យាបាលអ្នកផ្ទុកមេរោគអេដស៍-ជំងឺអេដស៍ ឱ្យដូចគ្នានឹងការព្យាបាលជំងឺដល់អ្នកជំងឺដទៃទៀតដែលគ្មានមេរោគអេដស៍ដែរ ។
- ឱ្យអ្នកផ្ទុកមេរោគអេដស៍-ជំងឺអេដស៍ បានចូលរួមក្នុងគ្រប់សកម្មភាពនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- លើកទឹកចិត្តឱ្យមានការចូលរួមពីបុរសដែលជាដៃគូនិងលើកកម្ពស់ឱ្យមានការគាំទ្រពីសហគមន៍ ។

## ម៉ូឌុលទី៣

## ការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន(MTCT)

**វត្ថុបំណង**

នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមទាំងអស់អាចនឹង:

១. ពិភាក្សាអំពីការជាប់ពាក់ព័ន្ធរវាងការមានផ្ទៃពោះនិងស្ត្រីមានផ្ទុកមេរោគអេដស៍

២. ពន្យល់អំពីការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន **(MTCT)**: តើវាជាអ្វី? តើវាកើតឡើងនៅពេលណា? និងតើការប្រឈមនឹងការឆ្លងមេរោគអេដស៍មានទំហំប៉ុណ្ណា?

៣. កំណត់បានអំពីកត្តាប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន



***រយៈពេលនៃការសិក្សា: ១ម៉ោង៤០នាទី***

## សកម្មភាពទី១: សំណួរនិងចម្លើយ: ការមានផ្ទៃពោះនិងការឆ្លងមេរោគអេដស៍

» នៅក្នុងសកម្មភាពនេះ អ្នកនឹងពិភាក្សាលើសំណួរអំពីមេរោគអេដស៍លើស្ត្រីមានផ្ទៃពោះ*

» គ្រូនឹងស្នើឱ្យអ្នកឈរនៅចំកណ្តាលបន្ទប់ ។ ម្ខាងនៃបន្ទប់ត្រូវបានកំណត់ថាជាចម្លើយ (**ត្រឹមត្រូវ**) និងម្ខាងទៀតជាចម្លើយ (**ខុស**)

» អានសំណួរទី១ រួចដើរទៅឈរនៅម្ខាងនៃបន្ទប់ដែលអ្នកគិតថាតំណាងឱ្យចម្លើយដែលត្រឹមត្រូវ

» គ្រូទុកឱកាសដល់អ្នកក្នុងការពិភាក្សាចម្លើយហើយអ្នកអាចផ្លាស់ប្តូរចិត្តទៅឈរនៅខាងម្ខាងទៀតបាន  បើសិនជាអ្នកចង់ដូរ

| | **ស្លាយទី៥** | **ត/ខ** |
|---|---|---|
| ១ | ការមានផ្ទៃពោះជាមូលហេតុដែលធ្វើឱ្យជំងឺអេដស៍មានការវិវត្តន៍ទៅមុខយ៉ាងលឿន | |
| ២ | មេរោគអេដស៍មិនអាចបណ្តាលអោយកូនក្នុងផ្ទៃមានរូបរាងមិនធម្មតាទេ | |
| ៣ | បញ្ហាមេរោគអេដស៍-ជំងឺអេដស៍នៅលើស្ត្រីផ្ទៃពោះមានសភាពអាក្រក់ជាងស្ត្រីដែលគ្មានផ្ទៃពោះ | |
| ៤ | ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ ទំនងជាមានការរលូតកូនឬកូនស្លាប់ក្នុងពោះច្រើនជាងអ្នកជា | |
| ៥ | ស្ត្រីផ្ទុកមេរោគអេដស៍មានលទ្ធភាពបន្តពូជដូចស្ត្រីដែលគ្មានផ្ទុកមេរោគអេដស៍ដែរ | |
| ៦ | ជំងឺអេដស៍មិនទាក់ទងទៅនឹងការសម្រាលមិនគ្រប់ខែឬកូនកើតមិនគ្រប់គីឡូឡើយ | |
| ៧ | ការស្លាប់ជុំវិញកំណើតឬការស្លាប់នៃទារកទើបកើត មានលក្ខណៈដូចគ្នាចំពោះទារកដែលកើតពីម្តាយមានផ្ទុកឬគ្មានផ្ទុកមេរោគអេដស៍ | |
| ៨ | ស្ត្រីមានផ្ទៃពោះអាចចម្លងមេរោគអេដស៍ទៅកូនរបស់គាត់ | |

## សកម្មភាពទី២: ការពិភាក្សា: តើអ្នកធ្លាប់មានបទពិសោធន៍អ្វីខ្លះទាក់ទងនឹងស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍?

លំហាត់នេះផ្សារភ្ជាប់ពីសកម្មភាពមុនៗ ។ គ្រូសម្របសម្រួលនឹងឱ្យអ្នកគិតពីសំណួរខាងក្រោមនិងដឹកនាំក្រុមធ្វើការពិភាក្សា

» តើបទពិសោធន៍អ្វីខ្លះដែលអ្នកធ្លាប់ជួបប្រទះក្នុងការងារជាមួយស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍

» តើអ្នកមានដែលធ្វើការតាមដានស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែរឬទេ? តើលទ្ធផលនៃផ្ទៃពោះរបស់ស្ត្រីយ៉ាងណាដែរ? ចុះចំណែកឯទារកវិញ?

» តើរឿងដែលពួកអ្នកលើកឡើង មានជាប់ទាក់ទងទៅនឹងចម្លើយនៃសំណួរខាងលើដែរឬទេ? ឬក៏មានភាពខុសគ្នា?

» បើសិនជាវាខុសគ្នា តើហេតុអ្វីបានជាវាខុសគ្នាយ៉ាងដូច្នេះ?

» ស្លាយទី៧-៨  សង្ខេបចំណុចស្តីអំពីការឆ្លងមេរោគអេដស៍និងការមានផ្ទៃពោះ ។

## ការមានផ្ទៃពោះនិងការឆ្លងមេរោគអេដស៍(១)

- ការមានផ្ទៃពោះ ហាក់ដូចជាមិនបានធ្វើឱ្យមេរោគអេដស៍មានការវិវត្តន៍ទៅមុខលឿននោះទេ
- មេរោគអេដស៍មិនមែនជាមូលហេតុនៃកំណើតមិនធម្មតាទេ
- បញ្ហាដែលទាក់ទងនឹងមេរោគអេដស៍មានដូចគ្នា ទាំងស្ត្រីមានផ្ទៃពោះ ទាំងស្ត្រីមិនមានផ្ទៃពោះ
- លទ្ធភាពបន្តពូជមិនមានការប៉ះពាល់ទេ លើកលែងតែក្នុងដំណាក់កាលអេដស៍ធ្ងន់ធ្ងរនៅពេលដែលចំណង់នៃការរួមភេទថយចុះ ។

7

## ការមានផ្ទៃពោះនិងការឆ្លងជម្ងឺអេដស៍ (២)

- ស្ត្រីផ្ទុកមេរោគអេដស៍ (ជាពិសេសក្នុងដំណាក់កាលចុងក្រោយនៃជម្ងឺអេដស៍) ប្រឈមនឹងការកើនឡើងនៃ:
  - ការរលូតកូន
  - កូនស្លាប់ក្នុងពោះ
  - ការស្លាប់កូនជុំវិញកំណើត (ស្លាប់មុនក្នុងពេលកំពុងកើតឬក្រោយពេលកើត)
  - កូនកើតមិនគ្រប់ទំងន់
  - សំរាលកូនមិនគ្រប់ខែ
- មេរោគអេដស៍អាចចម្លងពីម្តាយទៅទារកបាន

8

## សកម្មភាពទី៣: សរីរៈរោគសាស្ត្រនៃការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ការប្រឈម និង កត្តាបង្កគ្រោះប្រឈម

ស្លាយទី១០-១៤ ពន្យល់ថា ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន? ពេលវេលានិងរបៀបនៃការចម្លង និង កត្តាដែលនាំឱ្យមានការចម្លងនេះ?

## ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

- ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន គឺនៅពេលដែលកូនឆ្លងមេរោគអេដស៍ពីម្តាយរបស់វា
- ការចម្លងនេះអាចកើតឡើង ក្នុងកំឡុង :
  - ពេលកំពុងមានផ្ទៃពោះ
  - ពេលឈឺពោះសំរាល និង សំរាល
  - ពេលបំបៅដោះកូន
- គេអាចហៅម្យ៉ាងទៀតថា ការចម្លងផ្ទាល់ឬការចម្លងជុំវិញកំណើតនៃមេរោគអេដស៍ចូរចងចាំ :
- ម្តាយអាចមិនដឹងថាខ្លួនគាត់មានផ្ទុកមេរោគអេដស៍ទេ
- ការចម្លងមិនអាចដឹងទុកជាមុនបានទេ
- ត្រូវប្រុងប្រយ័ត្នកុំធ្វើការស្តីបន្ទោស ឬ រើសអើង និងមាក់ងាយចំពោះម្តាយ

10

## តើមេរោគអេដស៍ចម្លងពីម្តាយទៅកូនតាមរបៀបណា?

- **ពេលកំពុងមានផ្ទៃពោះ :**ជាធម្មតា សុកមានតួនាទីជារបាំងការពារមួយរារាំងមិនឱ្យមេរោគអេដស៍ឆ្លងពីម្តាយទៅកូន ។ ក៏ប៉ុន្តែ នៅពេលដែលសុកមានបញ្ហាមេរោគអេដស៍អាចចម្លងទៅកូនបាន
- **ពេលឈឺពោះសំរាលនិងសំរាល :**ការផ្លាស់ប្តូរឈាម ឬ សារធាតុរាវរបស់សរីរៈផ្សេងទៀតក្នុងកំឡុងពេលឈឺពោះសំរាល
- **ពេលបំបៅដោះកូន :**
  នៅក្នុងទឹកដោះម្តាយមានមេរោគអេដស៍ដែលអាចចម្លងទៅទារកបាន ។

*Ref: Transplacental transmission of HIV: a potential role for HIV binding lectins*
*E.J. Soilleux, N. Coleman / The International Journal of Biochemistry & Cell Biology 35 (2003) 283–287*

11

» ស្រមៃថា មានកុមារ១០០នាក់កើតពីម្តាយផ្ទុកមេរោគអេដស៍ ត្រូវបានចិញ្ចឹមដោយដោះម្តាយរយៈពេល២ឆ្នាំ (ស្លាយទី១២)

» បើគ្មានអន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនទេ កុមារចំនួនប្រហែលពី៦៥-៧៥នាក់នឹងមិនឆ្លងមេរោគអេដស៍ទេ គិតតាំងពីកូននៅក្នុងពោះរហូតដល់អាយុ២ឆ្នាំ

» មានកុមារចំនួន៥-១០នាក់នឹងអាចឆ្លងមេរោគអេដស៍នៅពេលមានផ្ទៃពោះ

» កុមារចំនួនប្រហែល១៥នាក់នឹងអាចឆ្លងមេរោគអេដស៍នៅពេលឈឺពោះនិងសម្រាល

» មានកុមារចំនួនពី៥-១៥នាក់នឹងអាចឆ្លងមេរោគអេដស៍នៅពេលបៅដោះម្តាយ (ចំនួននៃការឆ្លងវាអាស្រ័យលើកត្តាផ្សេងៗ រួមទាំងរយៈពេលនៃការចិញ្ចឹមកូនដោយដោះម្តាយ)

» ដូច្នេះចំនួនសរុបនៃកុមារដែលអាចឆ្លងមេរោគអេដស៍មានពី២៥-៤០នាក់។

## លទ្ធផលនៃកូនដែលកើតពីម្តាយមានផ្ទុកមេរោគអេដស៍

ក្នុងចំណោមទារក **១០០នាក់**ដែលកើតពីម្តាយផ្ទុកមេរោគអេដស៍ ហើយត្រូវបានចិញ្ចឹមដោយបៅដោះម្តាយ និង **មិនបាន**ធ្វើអន្តរាគមន៍ ការពារការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

→ ទារក ៦០-៧៥នាក់ **មិនមាន**ឆ្លងមេរោគអេដស៍ទេ

- **៥-១០នាក់** ឆ្លងនៅពេលមានផ្ទៃពោះ
- **ប្រហែល ១៥នាក់** ឆ្លងនៅពេលឈឺពោះ សំរាល និងសំរាល
- **៥-១៥នាក់** ឆ្លងក្នុងកំឡុងពេលបំបៅដោះ រហូត ដល់២ឆ្នាំ

ទារក ២៥-៤០នាក់ **នឹងឆ្លង**មេរោគអេដស៍ពីម្តាយ

12

## តើមានកត្តាប្រឈមអ្វីខ្លះដែលជំរុញឱ្យមានការចម្លងមេរោគអេដស៍ពីម្តាយនៅកូន ?

កត្តាប្រឈមដែលជំរុញឱ្យមានការចម្លងមេរោគអេដស៍ពីម្តាយទៅកូនសំខាន់បំផុត គឺនៅគ្រប់ពេលដែលម្តាយមានបន្ទុកមេរោគអេដស៍ខ្ពស់ក្នុងឈាម។

ម្តាយមានបន្ទុកមេរោគអេដស៍ខ្ពស់អាស្រ័យដោយ

- ម្តាយទើបឆ្លងមេរោគអេដស៍:បន្ទុកមេរោគខ្ពស់នៅរយៈពេល២-៣ខែដំបូងបន្ទាប់ពីការឆ្លង
- ជម្ងឺអេដស៍វិវត្តទៅរកដំណាក់កាលធ្ងន់ធ្ងរ: រួមជាមួយនឹងកោសិកា **CD4** ចុះទាប និងម្តាយស្ថិតក្នុងដំណាក់កាលចុងក្រោយនៃជម្ងឺអេដស៍។

13

## កត្តាប្រឈមដទៃទៀតដែលជំរុញឱ្យមានការចម្លងមេរោគអេដស៍ពីម្តាយនៅកូន

ពេលកំពុងមានផ្ទៃពោះ
- ម្តាយមានជម្ងឺកាមរោគ
- សុកមានការក្លាយរោគ ដូចជាជម្ងឺគ្រុនចាញ់ជាដើម
- ម្តាយមានជម្ងឺខ្វះអាហារូបត្ថម្ភ

ពេលបំបៅដោះ
- រយៈពេលនៃការបំបៅដោះយូរ
- ឆាប់ផ្តល់អាហារចំរុះ
- ប្រេះចុងដោះ រលាកដោះ
- ទារកមានជម្ងឺជ្រាំងមាត់

ពេលសំរាលកូន
- បែកស្រោមទឹកភ្លោះយូរ
- វិធីនៃការសំរាលដោយមានអន្តរាគមន៏
- ការសំរាលកូនទីមួយនៃកូនភ្លោះ( អាចកូនភ្លោះពីរឬ កូនបី)
- ការរលាកស្រោមទឹកភ្លោះឬទឹកភ្លោះមានការបង្ករោគ

វីរុស
- ប្រភេទនៃវីរុស
- ភាពស៊ាំនៃមេរោគជាមួយនឹងឱសថប្រឆាំងមេរោគអេដស៍

14

## សកម្មភាពទី៤: ពិភាក្សាករណី : តើស្ត្រីផ្ទុកមេរោគអេដស៍គួរមានកូនដែរឬទេ?

» គ្រូនឹងឱ្យអ្នកពិភាក្សាលើសារខាងក្រោមនេះ

"ស្ត្រីផ្ទុកមេរោគអេដស៍មិនគួរមានផ្ទៃពោះឬមានកូនទេ?"

» ធ្វើការជជែកវែកញែកគាំទ្រ ឬ ប្រឆាំងចំពោះស្ត្រីផ្ទុកមេរោគអេដស៍ដែលចង់មានកូន

» ឧទាហរណ៍មាននៅខាងក្រោម

### ពិភាក្សា: ទស្សនៈគាំទ្រ និង ទស្សនៈប្រឆាំង

ស្ត្រីមានផ្ទុកមេរោគអេដស៍មិនគួរមានផ្ទៃពោះ ឬ មានកូនទេ។

ចូរពិភាក្សា

16

### ទស្សនៈគាំទ្រឱ្យស្ត្រីផ្ទុកមេរោគអេដស៍មានកូន

- គ្រប់ស្ត្រីទាំងអស់មានសិទ្ធិជ្រើសរើសការមានកូន
- នៅពេលទទួលបាននូវសេវាព្យាបាល ថែទាំ និងគាំទ្រដែលមានគុណភាពខ្ពស់ ស្ត្រីផ្ទុកមេរោគអេដស៍អាចរស់នៅដោយសុខភាពល្អក្នុងរយៈពេលច្រើនឆ្នាំ
- ការមានកូនធ្វើឱ្យស្ត្រីមានអារម្មណ៍រីករាយ ហើយអាចពង្រឹងទំនាក់ទំនងរវាងប្ដី និងប្រពន្ធផងដែរ។
- ការមានកូនជារឿងធម្មជាតិ
- ការគ្មានកូនអាចធ្វើឱ្យគ្រួសារទទួលរងនូវការមាក់ងាយ។

17

### ទស្សនៈប្រឆាំងនឹងការមានកូនរបស់ស្ត្រីផ្ទុកមេរោគអេដស៍

- អេដស៍គឺជាជម្ងឺធ្ងន់ធ្ងរ។ ម្ដាយនឹងធ្លាក់ខ្លួនឈឺ និង មិនអាចថែរក្សាគ្រួសាររបស់គាត់បាន
- អេដស៍ធ្វើឱ្យបន្ទុកថវិកាគ្រួសារធ្លាក់ក្នុងសភាពធ្ងន់ធ្ងរ។ ស្ថានភាពនេះនឹងកាន់តែអាក្រក់ឡើង ប្រសិនបើគាត់មានកូន
- អេដស៍គឺជាជម្ងឺមួយដែលគំរាមដល់ជីវិត។ ម្ដាយនឹងស្លាប់ដោយបន្សល់ទុកនូវកុមារកំព្រា
- សង្គមអាចមិនអនុញ្ញាតឱ្យស្ត្រីផ្ទុកមេរោគអេដស៍មានកូនបានទេ។ ម្ដាយនឹងក្លាយជាមុខសញ្ញានៃការមាក់ងាយ និងរើសអើង

ការរំលូតកូនស្របច្បាប់ គឺជាជំរើសដ៏សមស្របមួយសំរាប់ស្ត្រីផ្ទុកមេរោគអេដស៍។ សេវាពន្យារកំណើតអាចផ្ដល់ព័ត៌មានដល់ស្ត្រី ពីមធ្យោបាយ និងទីកន្លែងដែលស្ត្រីអាចទទួលបាននូវសេវារំលូតកូនដោយស្របច្បាប់និងមានសុវត្ថិភាព។

18

**ម៉ូឌុលទី៣: ចំណុចគន្លឹះ**

- ការមានផ្ទៃពោះមិនមានឥទ្ធិពលអ្វីទៅលើជំងឺអេដស៍ទេ
- ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ ងាយប្រឈមនឹងផលវិបាកខ្លះៗនៅពេលមានផ្ទៃពោះ ដូចជាការរលូតកូន កូនកើតមិនគ្រប់ខែ
- ការឆ្លងមេរោគពីម្តាយទៅកូន អាចកើតឡើងក្នុងអំឡុងពេលមានផ្ទៃពោះ ពេលឈឺពោះសម្រាល និងសម្រាល ឬក៏នៅពេលបំបៅកូនដោយដោះ
- គ្រោះនៃការចម្លងមេរោគអេដស៍ពីម្តាយទៅកូនមានពី២៥%ទៅ៤០% ប្រសិនជាគ្មានអន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនទេ
- កត្តាសំខាន់បំផុតដែលប្រឈមនឹងការចម្លងគ្រប់ពេលវេលា គឺបន្ទុកមេរោគអេដស៍របស់ម្តាយ ។

# ម៉ូឌុលទី៤

## ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

| | |
|---|---|
| **សេចក្តីផ្តើម** | យុទ្ធវិធីគ្រប់ជ្រុងជ្រោយ ដើម្បីបង្ការការឆ្លងមេរោគអេដស៍ចំពោះទារកនិងកុមារ |
| **៤.១** | ការបង្ការបឋមនៃការឆ្លងមេរោគអេដស៍ |
| **៤.២** | ការបង្ការការមានកូនមិនតាមបំណងចំពោះស្ត្រីផ្ទុកមេរោគអេដស៍ |
| **៤.៣** | បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន |
| **៤.៤** | ផ្តល់ការព្យាបាលថែទាំនិងគាំទ្រដល់ស្ត្រីផ្ទុកមេរោគអេដស៍ កូនរបស់គាត់ និងគ្រួសាររបស់ គាត់ |

### វត្ថុបំណង

នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមទាំងអស់នឹងអាចៈ ពន្យល់អំពីយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងការកាត់បន្ថយការឆ្លងមេរោគអេដស៍ចំពោះទារកនិងកុមារ

១. ការបង្ការបឋមនៃការឆ្លងមេរោគអេដស៍

២. ការបង្ការការមានកូនមិនតាមបំណងចំពោះស្ត្រីផ្ទុកមេរោគអេដស៍

៣. បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

៤. ការផ្តល់ការព្យាបាល ថែទាំនិងគាំទ្រដល់ស្ត្រីផ្ទុកមេរោគអេដស៍ កូនរបស់គាត់ និងគ្រួសាររបស់គាត់

## សេចក្តីផ្តើម

**យុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងការបង្ការការចម្លងមេរោគអេដស៍ចំពោះទារកនិងកុមារ**

ការកាត់បន្ថយការឆ្លងមេរោគអេដស៍ចំពោះទារកនិងកុមារត្រូវឱ្យមានយុទ្ធសាស្ត្រមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ រួមមានយុទ្ធវិធីសំខាន់៧៤គឺ:

១. ការបង្ការបឋមនៃការឆ្លងមេរោគអេដស៍

២. ការបង្ការការមានកូនមិនតាមបំណង ចំពោះស្ត្រីផ្ទុកមេរោគអេដស៍

៣. បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

៤. ការផ្តល់ការព្យាបាលថែទាំនិងគាំទ្រដល់ស្ត្រីផ្ទុកមេរោគអេដស៍ កូនរបស់គាត់និងគ្រួសាររបស់គាត់

## ៤.១

# ការបង្ការបឋមនៃការចម្លងមេរោគអេដស៍

## វត្ថុបំណង

នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមទាំងអស់អាចនឹងៈ

១. អធិប្បាយអំពីជម្រើសសម្រាប់បង្ការបឋមនៃការឆ្លងមេរាគអេដស៍

២. ពន្យល់អំពីសារៈសំខាន់នៃការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមសម្រាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

៣. កំណត់បានពីគុណសម្បត្តិនិងគុណវិបត្តិនៃការធ្វើតេស្តឈាមចំពោះស្ត្រីមានផ្ទៃពោះ

៤. អធិប្បាយអំពីការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមនិងរក្សាការសម្ងាត់ដោយស្ម័គ្រចិត្តដល់ស្ត្រីមានផ្ទៃពោះ

៥. រៀបរាប់អំពីគោលការណ៍ណែនាំ ស្តីអំពីការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់

៦. កំណត់បាននូវភាពខុសគ្នារវាងតេស្តរកមេរោគអេដស៍ និងពន្យល់អំពីនីតិវិធីនៃការធ្វើតេស្តឈាម

៧. ពន្យល់អំពីអត្ថន័យនៃលទ្ធផលតេស្ត និងរយៈពេលចំហនៃមេរោគអេដស៍

៨. អធិប្បាយអំពីនីតិវិធីនៃការធ្វើតេស្តឈាមរកមេរោគអេដស៍នៅលើកុមារប្រឈម

*រយៈពេលនៃការសិក្សាៈ ២ម៉ោង៣០នាទី*

**សកម្មភាពទី១: បំផុសគំនិត: ការបង្ការការចម្លងមេរោគអេដស៍**

» គ្រូនឹងឱ្យអ្នកបញ្ចេញគំនិតរកវិធានការណ៍បង្ការការឆ្លងមេរោគអេដស៍នៅក្នុងផ្នែកទី១-៣ ដែលមាននៅក្នុងស្លាយទី៨

» **កំណត់ចំណាំ:** អន្តរាគមន៍ VCCT និង PMTCT នឹងបញ្ជាក់នៅក្នុងម៉ូឌុលបន្ទាប់

## ការបង្ការបឋមនៃការឆ្លងមេរោគអេដស៍ គំនិតផ្តួចផ្តើមអំពីសុខភាពសាធារណៈ

មេរោគអេដស៍មិនអាចចម្លងទៅទារកបានទេ បើសិនជាម្តាយមិនមានផ្ទុកមេរោគអេដស៍ ។

ចំនួនស្ត្រីផ្ទុកមេរោគអេដស៍អាចកាត់បន្ថយបានដោយ :

- យោងទៅលើកត្តាជាច្រើនដូចជា ភាពក្រីក្រ ភាពអវិជ្ជា ការបំពានផ្លូវភេទ និង តាមរយៈគំនិតផ្តួចផ្តើមផ្នែកសុខភាពសាធារណៈរួមមាន :
  - ១. បង្ការការចម្លងតាមឈាម
  - ២. ផ្តួចផ្តើមឱ្យមានការផ្លាស់ប្តូរឥរិយាបថ
  - ៣. គ្រប់គ្រងជម្ងឺកាមរោគ
  - ៤. ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់
  - ៥. អន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (វគ្គទី៣)

8

## ១. បង្ការការចម្លងមេរោគអេដស៍តាមឈាម

- ស្រាវជ្រាវរកមេរោគអេដស៍នៅលើគ្រាប់ឈាម និងផលិតផលដែលផលិតពីឈាម ទាំងអស់
- ត្រូវអនុវត្តជានិច្ចនូវការបង្ការជាសកល

9

## ២. ផ្តួចផ្តើមឱ្យមានការផ្លាស់ប្តូរឥរិយាបថ (១) យុទ្ធវិធី A B C

- (A): តមការរួមភេទ
  - -មិនត្រូវរួមភេទ ឬ
  - -មិនត្រូវឆាប់ប្រឡូកក្នុងការរួមភេទ
- (B): ស្មោះស្ម័គ្រមួយទល់នឹងមួយ

10

## ផ្តួចផ្តើមឱ្យមានការផ្លាស់ប្តូរឥរិយាបថ (២)

(C): ប្រើស្រោមអនាម័យ

- ស្រោមអនាម័យគួរតែ:
  - ប្រើរាល់ពេលរួមភេទ
  - ប្រើជាមួយគ្រប់ដៃគូទាំងអស់
  - ត្រៀមមានជាស្រេចគ្រប់ពេលវេលា
  - ប្រើឱ្យបានជាប់ជាប្រចាំ ទោះបីជាអិថិជនកំពុងតែព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ក៏ដោយ ឬ ក៏ដៃគូទាំងពីរមានផ្ទុកមេរោគអេដស៍ដូចគ្នាក៏ដោយ *។
- ផ្តល់ប្រឹក្សាអំពី:
  - ការប្រើស្រោមអនាម័យឱ្យបានត្រឹមត្រូវ
  - ជំនាញក្នុងការចរចាជាមួយដៃគូឱ្យប្រើប្រាស់ស្រោមអនាម័យ

*ដើម្បីបង្ការការចម្លងមេរោគដែលស៊ាំនឹងឱសថប្រឆាំងមេរោគអេដស៍ ឬ បង្ការការឆ្លងបន្ថែមទៀតនូវប្រភេទមេរោគដទៃទៀត

11

## ផ្តួចផ្តើមឱ្យមានការផ្លាស់ប្តូរឥរិយាបថ (៣)

(D): កុំ

- មិនត្រូវប្រើប្រាស់រួមគ្នានូវ:
  - ម្ជុល
  - ឡាម
  - ម្ជុលសាក់ស្បែក
- មិនត្រូវប៉ះមុខរបួសដោយផ្ទាល់
  - **ផ្ទុយទៅវិញ:** ត្រូវប្រើស្រោមដៃ និង ថ្នាំសំលាប់មេរោគ
- មិនត្រូវបោះចោលវត្ថុមុតស្រួចផ្តេសផ្តាស
  - **ផ្ទុយទៅវិញ:** ត្រូវបោះចោលនៅក្នុងប្រអប់សុវត្ថិភាព
- មិនត្រូវប្រើគ្រឿងញៀន
  - មិនត្រូវប្រើម្ជុលសឺរ៉ាំងរួមគ្នាទេ

12

## ផ្តួចផ្តើមឱ្យមានការផ្លាស់ប្តូរឥរិយាបថ (៤)

(E): ជៀសវាង

- រួមភេទដោយមិនបានប្រើស្រោមអនាម័យការពារ
- ឥរិយាបថប្រឈម ដូចជា:
  - ប្រើគ្រឿងស្រវឹងច្រើនហួស
  - ប្រើគ្រឿងញៀន
  - ការបំពាន ឬរំលោភផ្លូវភេទ

(F): ផែនការគ្រួសារ

- សំរួលឱ្យស្ត្រីបានទទួលសេវាផែនការគ្រួសារ

13

## ៣.គ្រប់គ្រងព្យាបាលជម្ងឺកាមរោគ

- បើសិនជាដៃគូរួមភេទណាម្នាក់មានជម្ងឺកាមរោគ ឱកាសឆ្លងមេរោគអេដស៍ខ្ពស់នៅពេលរួមភេទ
- ព្យាបាលជម្ងឺកាមរោគអាចកាត់បន្ថយការប្រឈមនឹងការឆ្លងមេរោគអេដស៍
- អប់រំពីការបង្ការជម្ងឺកាមរោគ
- ជំរុញឱ្យស្ត្រីមកទទួលសេវាថែទាំព្យាបាលជម្ងឺកាមរោគ ដើម្បីធ្វើរោគវិនិច្ឆ័យនិងព្យាបាលជម្ងឺកាមរោគបានទាន់ពេល

14

### ៤.ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់

- ការយល់ដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ជាកត្តាសំខាន់ណាស់ក្នុងការបង្ការការរីករាលដាលនៃមេរោគអេដស៍
- អ្នកឆ្លងមេរោគអេដស៍ភាគច្រើនមិនបានដឹងពីស្ថានភាពរបស់ខ្លួនទេ
- ការអាចទទួលបាននូវការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ធ្វើឱ្យបុគ្គលនិងសហគមន៍ទទួលបាននូវផលប្រយោជន៍ពីការធ្វើតេស្តឈាមរកមេរោគអេដស៍

15

## សកម្មភាពទី២: ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ សម្រាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

» ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម គឺជាអន្តរាគមន៍ដ៏សំខាន់មួយសម្រាប់ជោគជ័យក្នុងការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

» ស្ត្រីមានផ្ទៃពោះនិងដៃគូ ត្រូវតែដឹងអំពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនជាមុនសិន មុននឹងទទួលបាននូវសេវាថែទាំបន្តដទៃទៀត

### ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍សំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ គឺជាអន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនមួយដែលផ្តល់ឱកាសដល់ស្ត្រីមានផ្ទៃពោះ និងដៃគូបានដឹងពីស្ថានភាព

ផ្ទុកមេរោគអេដស៍ និងទទួលបាននូវសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន PMTCT

ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ សំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

- អាចកំណត់បាននូវស្ត្រីមានផ្ទៃពោះនិងដៃគូដែលមានផ្ទុកមេរោគអេដស៍
- ផ្តល់នូវការចាប់ផ្តើម ការថែទាំ ព្យាបាលនិងគាំទ្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនៃអ្នកផ្ទុកមេរោគអេដស៍
- ជួយស្ត្រីនិងដៃគូរបស់គាត់ឱ្យបានដឹង និងផ្លាស់ប្តូរឥរិយាបថដែលប្រឈមទៅនឹងការឆ្លងមេរោគអេដស៍។

18

### ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍សំរាប់ស្ត្រីមានផ្ទៃពោះ

ស្ត្រីមានផ្ទៃពោះដែលមិនបានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន :

- ត្រូវបានចាត់ទុកថាប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និង គួរតែទទួលបាននូវការផ្តល់ប្រឹក្សា
- គួរតែដឹងថា ការធ្វើតេស្តឈាមអាចធ្វើបាននៅពេលដែលគាត់មកពិនិត្យផ្ទៃពោះ
- គួរតែត្រូវបានរំលឹកពីផលប្រយោជន៍នៃការដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន
- ត្រូវដឹងថា ការថែទាំនិងព្យាបាលដល់អ្នកផ្ទុកមេរោគអេដស៍-ជម្ងឺអេដស៍ អាចធ្វើឱ្យស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍មានជីវិតកាន់តែប្រសើរឡើង

19

### ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់ និងការចូលរួមរបស់ដៃគូ

ដើម្បីឱ្យសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមមានប្រសិទ្ធភាពល្អតាមដែលអាចធ្វើបាន ដៃគូទាំងពីរត្រូវតែចូលរួមទាំងអស់គ្នានិង:

- គួរតែទទួលការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម និងដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន
- គួរតែដឹងថា មានអន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងអាចទទួលបាននូវសេវាទាំងនោះ
- ត្រូវតែយល់ពីសារៈសំខាន់នៃការរួមភេទដែលមានសុវត្ថិភាព ទាំងនៅពេលមានផ្ទៃពោះ និងពេលបំបៅដោយទឹកដោះម្តាយ

មេរោគអេដស៍-ជម្ងឺអេដស៍ប៉ះពាល់ដល់គ្រួសារទាំងស្រុង ដៃគូទាំងពីរគួរតែត្រូវបានលើកទឹកចិត្តគ្រប់ឱកាសទាំងអស់ ក្នុងការមកទទួលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់

20

## សកម្មភាពទី៣: លំហាត់: គាំទ្រនិងប្រឆាំង: ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់ សម្រាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

- » គ្រូនឹងឱ្យអ្នកពិចារណាពីការផ្តល់ប្រឹក្សានិងធ្វើតេស្តរកមេរោគអេដស៍ ។ តើអ្នកគិតថា ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដល់បុគ្គល ជាគំនិតមួយល្អដែរឬទេ? ឬមួយក៏វាជាបញ្ហា?
- » គ្រូនឹងចែកសិក្ខាកាមជា២ក្រុមស្មើគ្នា ។ មួយក្រុមនឹងដើរតួជាអ្នកគាំទ្រ និងមួយក្រុមទៀត ដើរតួជាអ្នកប្រឆាំងចំពោះការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម
- » បញ្ចេញមតិគាំទ្រគំនិតរបស់ក្រុមអ្នក ទោះជាអ្នកគាំទ្រក្តីឬ អ្នកប្រឆាំងក្តី ចំពោះការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម
- » គ្រូសម្របសម្រួលនឹងធ្វើការពិភាក្សាចំពោះមតិរបស់ក្រុមទាំងពីរ
- » សូមពិនិត្យមើល តើវាមានភាពខុសគ្នារវាងគុណសម្បត្តិនិងគុណវិបត្តិយ៉ាងដូចម្តេចដែរ បើយោងទៅលើលទ្ធផលតេស្តវិជ្ជមានឬអវិជ្ជមាន

### គុណសម្បត្តិនៃការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់សំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

**ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ ផ្តល់ឱ្យស្ត្រីដែលគ្មានផ្ទុកមេរោគអេដស៍បានទទួលនូវ:**

- ព័ត៌មាននិងការអប់រំអំពីមេរោគអេដស៍-ជម្ងឺអេដស៍
- ចំណេះដឹងស្តីពីស្ថានភាពផ្ទុកមេរោគអេដស៍របស់គាត់
- ឱកាសកែប្រែឥរិយាបថប្រព្រឹត្តដែលប្រកបដោយគ្រោះថ្នាក់
- យុទ្ធសាស្ត្រសំរាប់ថែរក្សាខ្លួនឱ្យនៅតែគ្មានផ្ទុកមេរោគអេដស៍ជានិច្ច ។

22

### គុណសម្បត្តិនៃការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់សំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

**ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ អនុញ្ញាតឱ្យស្ត្រីដែលមានផ្ទុកមេរោគអេដស៍បានទទួលនូវៈ**

- ព័ត៌មាននិងការអប់រំអំពីមេរោគអេដស៍-ជម្ងឺអេដស៍
- ចំណេះដឹងស្តីពីស្ថានភាពផ្ទុកមេរោគអេដស៍របស់គាត់
- ទទួលព័ត៌មានស្តីពីការបង្ការ ធ្វើយ៉ាងណាកុំឱ្យចម្លងមេរោគអេដស៍ទៅអ្នកដទៃ
- អន្តរាគមន៍កាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

23

### គុណវិបត្តិនៃការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់សំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

ស្ត្រីនិងដៃគូអាចជួបប្រទះនូវៈ

- អារម្មណ៏មិនល្អនៅពេលដែលត្រូវបានយកឈាមទៅពិនិត្យ
- មានប្រតិកម្មផ្លូវចិត្ត ដូចជាៈ សោកសៅ មានកំហឹង ភ័យខ្លាច អស់សង្ឃឹម ។ល។ នៅពេលដែលគាត់ដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន
- ការប្រឈមនឹងការមាក់ងាយ និងរើសអើងពីសំណាក់ប្តី សមាជិកគ្រួសារ សហគមន៍ និយោជិក បុគ្គលិកសុខាភិបាល ។ល។

24

## សកម្មភាពទី៤ៈ តើការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍នៅសេវាថែទាំផ្ទៃពោះប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ?

### តើការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍នៅសេវាថែទាំផ្ទៃពោះប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ?

| | |
|---|---|
| តើត្រូវផ្តល់ប្រឹក្សាដល់អ្នកណាខ្លះ? | ■ គ្រប់ស្ត្រីមានផ្ទៃពោះ និងដៃគូរបស់គាត់ |
| តើអ្នកណាជាអ្នកផ្តល់ប្រឹក្សា? | ■ អ្នកផ្តល់ប្រឹក្សាដែលបានទទួលការបណ្តុះបណ្តាលរួច |
| នៅពេលណា? | ■ នៅពេលមកពិនិត្យផ្ទៃពោះលើកដំបូង បើសិនជាអាច<br>■ នៅពេលក្រោយៗទៀត |
| ផ្តល់ឱ្យយ៉ាងដូចម្តេច? | ■ ផ្តល់ប្រឹក្សាជាក្រុមនៅក្នុងបន្ទប់អប់រំម្តាយ (មុនធ្វើតេស្តឈាម)<br>■ ផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធ (មុន ឬក្រោយធ្វើតេស្តឈាម)<br>■ ផ្តល់ប្រឹក្សាជាលក្ខណៈបុគ្គល (មុន ឬក្រោយធ្វើតេស្តឈាម) |
| នៅទីកន្លែងណា? | ■ នៅក្នុងបន្ទប់អប់រំម្តាយ ឬ<br>■ នៅក្នុងបន្ទប់ផ្តល់ប្រឹក្សាជាលក្ខណៈឯកជននៃសេវាថែទាំផ្ទៃពោះ |

26

## សកម្មភាពទី៥: ពាក្យគន្លឹះ: គោលការណ៍ណែនាំស្តីអំពីការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់

» គ្រូនឹងប្រាប់អ្នកឱ្យគិតអំពីគោលការណ៍សំខាន់បំផុតសម្រាប់ VCCT

**គោលការណ៍ណែនាំសំរាប់ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម រកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់**

ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមត្រូវ:

- ធ្វើឡើងដោយមានការស្ម័គ្រចិត្ត
- ការរក្សាការសម្ងាត់

អតិថិជនត្រូវ:

- មានការព្រមព្រៀង
- ទទួលបាននូវការគាំទ្រក្រោយពេលធ្វើតេស្តឈាម

28

## សកម្មភាពទី៦: ធ្វើការជាក្រុម: គោលការណ៍ណែនាំស្តីអំពីការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់

» គោលបំណងនៃលំហាត់នេះ គឺដើម្បីសិក្សាស៊ីជម្រៅពីគោលការណ៍ណែនាំសម្រាប់ VCCT

» គ្រូចែកសិក្ខាកាមជា៤ក្រុម: ក្រុមទី១: ការស្ម័គ្រចិត្ត
ក្រុមទី២: ការរក្សាការសម្ងាត់
ក្រុមទី២: កិច្ចព្រមព្រៀងរបស់អតិថិជន
ក្រុមទី៣: ការគាំទ្រក្រោយធ្វើតេស្តឈាម

» ធ្វើការនៅក្នុងក្រុមរបស់អ្នក គិតដល់ចំណុចសំខាន់ៗដែលទាក់ទងនឹងប្រធានបទ រួចហើយសរសេរកត់ត្រា

» សិក្ខាកាមម្នាក់ក្នុងចំណោមក្រុមនីមួយៗនឹងឡើងមកបង្ហាញពីលទ្ធផលរបស់ក្រុមខ្លួន

» ពិភាក្សាលើប្រធានបទបន្ទាប់ពីធ្វើការបង្ហាញ

**១.ការស្ម័គ្រចិត្ត**

- គ្មាននរណាម្នាក់ត្រូវបានបង្ខំឱ្យទទួលការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ទេ
- ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមត្រូវបានផ្តល់ជូនដល់គ្រប់ស្ត្រីមានផ្ទៃពោះទាំងអស់ ព្រោះវាជាផ្នែកមួយនៃការថែទាំផ្ទៃពោះ
- ស្ត្រីអាចជ្រើសរើសមិនធ្វើតេស្តឈាមបាន

30

## ២. ការរក្សាការសម្ងាត់ (១)

- ការរក្សាការសម្ងាត់មានសារៈសំខាន់ណាស់ សំរាប់ធ្វើឱ្យអតិថិជនមានទំនុកចិត្ត
- កាលណាបើគ្មានទំនុកចិត្តទេ ស្ត្រីអាចនឹងបដិសេធការធ្វើតេស្តឈាម
- ការធានាបាននូវការសម្ងាត់ គឺជាគន្លឹះសំខាន់ក្នុងការទទួលជោគជ័យសំរាប់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ។

31

## ២. ការរក្សាការសម្ងាត់ (២)

- បន្ទប់ផ្តល់ប្រឹក្សាប្រើសំរាប់ផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធ ឬជាបុគ្គល ត្រូវតែមានលក្ខណៈឯកជន
- ព័ត៌មានដែលអតិថិជនផ្តល់ឱ្យ អ្នកផ្តល់ប្រឹក្សាត្រូវរក្សាទុកជារឿងសម្ងាត់
- រាល់កំណត់ត្រាវេជ្ជសាស្ត្រនិងបញ្ជីឈ្មោះ ត្រូវរក្សាទុកជាសម្ងាត់ និងត្រូវរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព ។

ព័ត៌មានរបស់អតិថិជន (រាប់បញ្ចូលទាំងលទ្ធផលតេស្តឈាម) អាចឱ្យបុគ្គលិកថែទាំដទៃទៀតដឹងបាន ដើម្បីធានាថា ស្ត្រីបានទទួលការថែទាំតាមបែបវេជ្ជសាស្ត្រដ៏ត្រឹមត្រូវ ។ ក៏ប៉ុន្តែករណីទាំងនេះអាចធ្វើបាន លុះណាតែមានការអនុញ្ញាតពីសាមីខ្លួនផងដែរ ។

32

## ៣. កិច្ចព្រមព្រៀង

បុគ្គលម្នាក់ៗមានសិទ្ធិ:

- ទទួលព័ត៌មានច្បាស់លាស់និងត្រឹមត្រូវអំពីការធ្វើតេស្តឈាមរកមេរោគអេដស៍មុនពេលយល់ព្រមធ្វើតេស្តឈាម ដូច្នេះពួកគេនឹងយល់ច្បាស់ពី:
  - គោលបំណង និង គុណប្រយោជន៍នៃការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម
  - គោលបំណង និង គុណប្រយោជន៍នៃសេវាផ្សេងៗទៀតដែលគាត់អាចទទួលបានក្នុងករណីដែលលទ្ធផលតេស្តបញ្ជាក់ ថាវិជ្ជមាន
  - ដំណើរការនៃការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម
- បដិសេធការធ្វើតេស្តឈាម
- ទទួលបាននូវការគោរពចំពោះការសំរេចចិត្តក្នុងការធ្វើតេស្តឈាមរបស់ពួកគាត់

33

## ៤. ការផ្តល់ការគាំទ្រក្រោយពេលធ្វើតេស្តឈាម

លទ្ធផលតេស្តឈាមត្រូវតែផ្តល់ឱ្យអតិថិជននៅក្នុងបន្ទប់មួយដាច់ដោយឡែក ។ បើសិនជាអាចការផ្តល់លទ្ធផលគួរតែផ្តល់ឱ្យដោយអ្នកផ្តល់ប្រឹក្សាដែលបានផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម ។

អ្នកផ្តល់ប្រឹក្សាត្រូវតែ:

- ធានាអះអាងចំពោះអ្នកជម្ងឺថា រាល់ការផ្តល់ប្រឹក្សានិងលទ្ធផលតេស្តឈាមនឹងត្រូវបានរក្សាជាការសម្ងាត់
- ផ្តល់ព័ត៌មានទៅអ្នកជម្ងឺអំពីសេវាព្យាបាល ថែទាំ និង គាំទ្រដែលមាន និងធ្វើការបញ្ជូនគាត់ទៅរកសេវាទាំងនោះក្នុងករណីចាំបាច់
- ផ្តល់ការគាំទ្រដល់អតិថិជនដើម្បីឱ្យគាត់ហ៊ានប្រាប់ប្តី និងគ្រួសារគាត់ឱ្យដឹងពីលទ្ធផលតេស្តរបស់គាត់នៅពេលដែលចាំបាច់ ។

34

## សកម្មភាពទី៧: ការធ្វើតេស្តឈាម

### តេស្តរកមេរោគអេដស៍: តេស្តរកអង្គបដិបក្ខប្រាណ (១)

- បន្ទាប់ពីមនុស្សម្នាក់បានឆ្លងមេរោគអេដស៍ សរីរាង្គកាយរបស់ពួកគេបានបង្កើតអង្គបដិបក្ខប្រាណដើម្បីប្រឆាំងនឹងមេរោគអេដស៍នេះ*
- អង្គបដិបក្ខប្រាណនេះ ជាធម្មតាលេចឡើងក្នុងចន្លោះពេលពី ៤ទៅ ៦សប្តាហ៍បន្ទាប់ពីការឆ្លងមេរោគ ។
  តែករណីខ្លះការបង្កើតអង្គបដិបក្ខប្រាណអាចពន្យាររហូតដល់ទៅ៣ខែ ។

**តេស្តរកមេរោគអេដស៍តាមស្តង់ដា គឺរកអង្គបដិបក្ខប្រាណប្រឆាំងមេរោគអេដស៍**

*សំគាល់: វាខុសប្លែកគ្នាពីជម្ងឺដទៃៗទៀត ដោយសារអង្គបដិបក្ខប្រាណប្រឆាំងមេរោគអេដស៍មិនមែនជាសារធាតុសំរាប់ការពាររាងកាយនោះទេ ។

37

### តេស្តរកមេរោគអេដស៍: ការធ្វើតេស្តដោយរកអង្គបដិបក្ខប្រាណ (២)

- បើសិនជាមនុស្សម្នាក់មិនបានឆ្លងមេរោគអេដស៍ទេ លទ្ធផលតេស្តនឹងបង្ហាញនូវសញ្ញា អវិជ្ជមាន
- បើសិនជាមនុស្សឆ្លងមេរោគអេដស៍ម្នាក់ ចាប់ផ្តើមបង្កើតអង្គបដិបក្ខប្រាណនៅក្នុងខ្លួន នោះ លទ្ធផលតេស្តនឹងបង្ហាញសញ្ញា វិជ្ជមាន

តែទោះជាយ៉ាងណាក៏ដោយ

- បើសិនជាធ្វើតេស្តឈាមលើបុគ្គលដែលស្ថិតក្នុងអំឡុងពេលនៃ "រយៈពេលចំហ" ក្រោយពីបានឆ្លងមេរោគអេដស៍ នោះលទ្ធផលនៃការធ្វើតេស្តអាចនឹង អវិជ្ជមាន
- ក្នុងករណីដែលមានការប្រឈមនឹងការឆ្លងថ្មីៗ ការធ្វើតេស្តឈាមរកមេរោគអេដស៍ គួរតែធ្វើឡើងជាថ្មីម្តងទៀតក្នុងអំឡុងពេល៣ខែបន្ទាប់ពីការប្រឈមនឹងការឆ្លង ។

38

### ប្រភេទតេស្តរកអង្គបដិបក្ខប្រាណមេរោគអេដស៍

| | តេស្តរហ័ស | ELISA | Western Blot |
|---|---|---|---|
| ភាពត្រឹមត្រូវ | ខ្ពស់យ៉ាងខ្លាំង | ខ្ពស់យ៉ាងខ្លាំង | ល្អសំរាប់គំរូឈាមដែលមិនច្បាស់លាស់ |
| តម្លៃ | + | ++ | ++ |
| រយៈពេលនៃការចេញលទ្ធផល | ៣០ នាទី | មានរយៈពេលជាច្រើនថ្ងៃរហូតដល់ច្រើនសប្តាហ៍ | មានរយៈពេលជាច្រើនថ្ងៃរហូតដល់ច្រើនសប្តាហ៍ |
| តំរូវការឧបករណ៍មន្ទីរពិសោធន៍ | ទេ | ត្រូវការ | ត្រូវការ |
| តំរូវការបុគ្គលិកជំនាញខ្ពស់ក្នុងមន្ទីរពិសោធន៍ | ទេ | ត្រូវការ | ត្រូវការ |

### តេស្តរកមេរោគអេដស៍ : វិភាគទៅលើមេរោគ

ធ្វើតេស្តទាំងនេះគឺ

- ដើម្បីពិនិត្យរកមេរោគអេដស៍ដែលមាននៅក្នុងឈាមរបស់បុគ្គលដែលបានឆ្លងមេរោគអេដស៍
- ត្រូវតែធ្វើឡើងដោយបុគ្គលិកមន្ទីរពិសោធន៍ ដែលបានបណ្តុះបណ្តាល
- ត្រូវការធ្វើនៅក្នុងមន្ទីរពិសោធន៍
- មានតម្លៃថ្លៃ និងមិនត្រូវបានធ្វើជាប្រចាំទេ

P24 antigen តេស្តវាស់ស្ទង់គីរតប្រូតេអ៊ីនដែលរកឃើញនៅក្នុងការធ្វើតេស្តឈាម

រកមេរោគអេដស៍តាម PCR*:

- DNA PCR ពិនិត្យមើលវត្តមាននៃមេរោគនៅក្នុងឈាម ហើយវាត្រូវបានគេប្រើសំរាប់ធ្វើរោគវិនិច្ឆ័យរកមើលមេរោគអេដស៍ក្នុងខ្លួនទារក ដែលមានអាយុក្រោម១៨ខែ
- RNA PCR ពិនិត្យមើលនិងវាស់ស្ទង់នូវបរិមាណនៃមេរោគនៅក្នុងឈាម (បន្ទុកមេរោគអេដស៍)

*មាននៅទីក្រុងភ្នំពេញ

40

## សកម្មភាពទី៨: បំផុសគំនិតឬល្បែងដើរតួ * :គោលការណ៍នៃការធ្វើតេស្តឈាមរកមេរោគអេដស៍

### បំផុសគំនិត

- គ្រូឱ្យសិក្ខាកាមរៀបរាប់ឱ្យត្រូវតាមលំដាប់ អំពីការធ្វើតេស្តឈាមក្រោយពីការផ្តល់ប្រឹក្សាមុនតេស្ត

### ល្បែងដើរតួ

- គ្រូនឹងសុំឱ្យសិក្ខាកាមពីរនាក់ស្ម័គ្រចិត្តដើរតួជាអ្នកផ្តល់ប្រឹក្សា និងជាអតិថិជនដែលទើបនឹងទទួលការប្រឹក្សាមុនពេលធ្វើតេស្តឈាម
- អ្នកផ្តល់ប្រឹក្សាត្រូវធ្វើតេស្តឈាមទៅតាមដំណាក់កាលនីមួយៗ

*ជ្រើសរើសទម្រង់សកម្មភាពណាមួយដែលអ្នកចូលចិត្តឬគិតថាល្អបំផុត

### នីតិវិធីនៃការធ្វើតេស្តឈាមរកមេរោគអេដស៍

ក្រោយពីផ្តល់ការប្រឹក្សាមុនធ្វើតេស្តឈាម អ្នកផ្តល់ប្រឹក្សានៃសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនគួរតែ:

១- ទទួលបាននូវការព្រមព្រៀងពីស្ត្រីមានផ្ទៃពោះនិងប្តីរបស់គាត់ ( ប្រសិនជាប្តីត្រូវធ្វើតេស្តឈាមផងដែរ)

២- ពាក់ស្រោមដៃ ហើយបូមឈាមដាក់ទៅក្នុងទីបឈាម ។

៣- ដោះស្រោមដៃចោល

៤- បិទលេខកូដរបស់អតិថិជននៅលើទីបឈាម និងកត់ត្រាចូលក្នុងសៀវភៅរបាយការណ៍ នូវលេខកូដ ថ្ងៃ ខែ ឆ្នាំ ដែលអតិថិជនចូលរួម

៥- បញ្ជូនទីបឈាមទៅកាន់មន្ទីរពិសោធន៍ដើម្បីធ្វើតេស្តឈាម

៦- បញ្ជាក់ប្រាប់អតិថិជនអំពីពេលវេលាដែលត្រូវមកទទួលលទ្ធផល

42

### លេខកូដសំរាប់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

- ស្ត្រីដែលបានទទួលការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាមនឹងត្រូវចុះលេខកូដ និងត្រូវបានចុះឈ្មោះក្នុងបញ្ជីនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- លេខកូដនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននេះនឹងត្រូវបិទនៅលើប័ណ្ណវិភាគសំរាប់ភ្ជាប់ជាមួយទីបឈាមយកទៅកាន់មន្ទីរពិសោធន៍។

43

## សកម្មភាពទី៩: តើលទ្ធផលតេស្តឈាម មានន័យយ៉ាងដូចម្តេច? ការធ្វើតេស្តឈាមនៅមន្ទីរពិសោធន៍

» ស្លាយទី៤៥ នឹងពន្យល់អំពីដំណាក់កាលធ្វើតេស្តឈាមដែលត្រូវធ្វើនៅមន្ទីរពិសោធន៍ ។

» ត្រូវចំណាំថា លទ្ធផលតេស្តដែលវិជ្ជមាន ត្រូវត្រួតពិនិត្យម្តងទៀតជាលើកទីពីរ

» ប្រសិនជាលទ្ធផលលើកទីពីរមិនដូចគ្នានឹងលទ្ធផលលើកទីមួយទេ សំណាកឈាមត្រូវយកមកពិនិត្យជាថ្មីម្តងទៀតជាមួយនឹងតេស្តរហ័សពីរមុខ

» ប្រសិនជាលទ្ធផលតេស្តនៅតែមិនត្រូវគ្នាទៀត ត្រូវណាត់ឱ្យមកម្តងទៀតនៅរយៈពេល១៥ថ្ងៃក្រោយពីការធ្វើតេស្តលើកទី១ ដើម្បីយកសំណាកឈាមអតិថិជនទៅពិនិត្យម្តងទៀត

### តើនឹងមានអ្វីកើតឡើងខ្លះនៅក្នុងមន្ទីរពិសោធន៍?




គោលនយោបាយជាតិ VCCT (២០០២)
HIV testing algorithm

45

### តើលទ្ធផលតេស្តឈាមរកមេរោគអេដស៍ទាំងនេះមានអត្ថន័យយ៉ាងដូចម្តេច?

**លទ្ធផលតេស្តឈាមវិជ្ជមាន:**

- មានន័យថាបុគ្គលរូបនេះ **គឺ** បានឆ្លងមេរោគអេដស៍
- សំណាកឈាមត្រូវបានធ្វើតេស្តជាលើកទី២ដោយតេស្តឆាប់រហ័ស( ឬតេស្ត ELISA ) ដើម្បីធានាថាលទ្ធផលនេះ គឺពិតជាត្រឹមត្រូវ

**លទ្ធផលតេស្តឈាមអវិជ្ជមាន:**

- មានន័យថាបុគ្គលរូបនេះ **គឺមិនបាន** ឆ្លងមេរោគអេដស៍នោះទេ ឬ
- បានឆ្លងមេរោគអេដស៍រួចហើយ ក៏ប៉ុន្តែស្ថិតនៅក្នុងរយៈពេលចំហ ។ អតិថិជនគួរមកធ្វើតេស្តឈាមម្តងទៀតក្នុងអំឡុងពេល៣ខែក្រោយ ។

46

### លទ្ធផលតេស្តដែលមិនច្បាស់លាស់

ប្រសិនបើលទ្ធផលតេស្តដំបូង **វិជ្ជមាន** និង លទ្ធផលទី២ **អវិជ្ជមាន** មន្ទីរពិសោធន៍នឹងធ្វើតេស្តទាំងពីរនេះឡើងវិញម្តងទៀត នៅលើសំណាកឈាមដើមដដែល ។ លទ្ធផលនៃការធ្វើតេស្តឡើងវិញ:

**តេស្តទាំងពីរគឺ វិជ្ជមាន** មានន័យថាបុគ្គលរូបនេះ **បាន** ឆ្លងមេរោគអេដស៍

**តេស្តទាំងពីរគឺ អវិជ្ជមាន**

- មានន័យថាបុគ្គលរូបនេះ **មិនបាន** ឆ្លងមេរោគអេដស៍ទេ

**តេស្តមួយវិជ្ជមាន និងតេស្តមួយអវិជ្ជមាន**

- ចាត់ទុកថាជាលទ្ធផលដែលមិនច្បាស់លាស់
- គេត្រូវប្តូមយកឈាមអតិថិជនជាលើកទី២ ( យ៉ាងហោច១៥ថ្ងៃក្រោយ ) ហើយដំណើរការនៃការធ្វើតេស្តនឹងធ្វើដូចមុនម្តងទៀត ដោយចាប់ផ្តើមពីចំណុចដំបូងមក ។

47

» **សកម្មភាពទី១០: ការធ្វើតេស្តឈាមនៅលើកុមារ** ស្លាយទី៤៩-៥១

ពន្យល់អំពីការធ្វើតេស្តឈាមនៅលើកុមារ

» ចំណាំថា ការវិភាគរកមេរោគអេដស៍ អាចធ្វើរោគវិនិច្ឆ័យពីការឆ្លងមេរោគអេដស៍បានរហ័ស ប្រសិនជាតេស្តនោះអាចរកបាន និងកុមារអាចទទួលការធ្វើតេស្តបាន

## តេស្តរកអង្គបដិបក្ខប្រាណមេរោគអេដស៍ ដល់ទារកនិងកុមារដែលប្រឈមនឹងការឆ្លងមេរោគអេដស៍

គ្រប់ទារកដែលកើតពីម្តាយដែលមានផ្ទុកមេរោគអេដស៍មិនមែនសុទ្ធតែបានឆ្លងមេរោគអេដស៍នោះទេ ប៉ុន្តែ:

ប្រសិនបើ **ធ្វើតេស្តរកមេរោគអេដស៍រកអង្គបដិបក្ខប្រាណ**លើទារកទាំងឡាយណាដែលកើតពីម្តាយដែលមានផ្ទុក មេរោគអេដស៍លទ្ធផល តេស្តនឹងបង្ហាញសញ្ញាវិជ្ជមាន:

- សូម្បីតែទារករូបនេះមិនបានឆ្លងមេរោគអេដស៍ពីម្តាយក៏ដោយ
- ព្រោះអង្គបដិបក្ខប្រាណនៃមេរោគអេដស៍របស់ម្តាយបានឆ្លងចូលទៅក្នុងខ្លួនទារកតាមរយៈសុក

**អង្គបដិបក្ខប្រាណមេរោគអេដស៍របស់ម្តាយអាចស្ថិតនៅក្នុងខ្លួនទារករហូតដល់១៨ខែ**

49

## ការវិភាគរកវីរុសអេដស៍ (PCR)

- ពិនិត្យរកមេរោគអេដស៍ពិត
- អាចអនុវត្តចំពោះទារកដែលប្រឈមនឹងការឆ្លងមេរោគអេដស៍ ចាប់ពីទារកមានអាយុ៦សប្តាហ៍

ប្រសិនបើ PCR អាចធ្វើទៅបាន ត្រូវធ្វើតេស្តរក PCR នេះនៅសប្តាហ៍ទី៦

- ប្រសិនបើតេស្ត PCR មានលទ្ធផល វិជ្ជមាន
  មានន័យថាទារកបានឆ្លងមេរោគអេដស៍ហើយ
- ប្រសិនបើតេស្ត PCR មានលទ្ធផល អវិជ្ជមាន
  មានន័យថាទារកមិនបានឆ្លងមេរោគអេដស៍នោះទេ

បើសិនជាទារកដែលចិញ្ចឹមដោយទឹកដោះម្តាយមានលទ្ធផលតេស្តឈាមអវិជ្ជមាន ការធ្វើតេស្ត PCR ត្រូវធ្វើឡើងសាជាថ្មីម្តងទៀតក្នុងអំឡុងពេល៣ខែបន្ទាប់ពីការបំបៅដោះត្រូវបានបញ្ឈប់ទាំងស្រុង ដើម្បីធានាថាទារកនេះមិនបានឆ្លងមេរោគអេដស៍ពីម្តាយតាមរយៈការបំបៅដោះទេ។

50

## គោលនយោបាយសំរាប់ធ្វើតេស្តឈាមលើទារកដែលប្រឈមនឹងការឆ្លងមេរោគអេដស៍

ទារកដែលប្រឈមនឹងការឆ្លងមេរោគអេដស៍ គួរតែពិនិត្យតាមដាននៅសេវាសុខភាពសំរាប់កុមារ OI/ART * ដែលនៅជិតបំផុតហើយ:

- កូនត្រូវធ្វើតេស្តរកអង្គបដិបក្ខប្រាណនៃមេរោគអេដស៍នៅពេលដែលមានអាយុ១៨ខែ ដោយមានការយល់ព្រមពីម្តាយ
- ទទួលការធ្វើតេស្តដោយការវិភាគរកវីរុសអេដស៍ PCR មេរោគនៅពេលដែលកុមារនៅមានអាយុតិច ក្នុងករណីដែលមានលទ្ធភាពអាចធ្វើទៅបាន
  - ធ្វើរោគវិនិច្ឆ័យអំពីការឆ្លងមេរោគអេដស៍ឱ្យបានច្បាស់លាស់
  - ក្នុងករណីលទ្ធផលវិជ្ជមាន ទារកមានសិទ្ធិទទួលបានសេវា ART
  - ក្នុងករណីលទ្ធផលអវិជ្ជមាន ការបង្ការរោគ Cotrimoxazole OI ត្រូវបញ្ឈប់

*បើសិនជាគ្មានទេ ត្រូវបញ្ជូនទៅសេវាព្យាបាលជម្ងឺកុមារ នៅក្នុងមន្ទីរពេទ្យបង្អែកដែលនៅជិតបំផុត

51

## ម៉ូឌុលទី៤.១: ចំណុចគន្លឹះ

- កាបង្ការបឋមនៃការចម្លងមេរោគអេដស៍ គឺជាវិធីដ៏មានប្រសិទ្ធិភាពក្នុងការកាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- ស្ត្រីមានផ្ទៃពោះគ្រប់រូបនិងដៃគូ គួរតែទទួលបាននូវព័តិមានមុនពេលធ្វើតេស្ត ការធ្វើតេស្តឈាមរកមេរោគអេដស៍ និងការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត
- ការធ្វើតេស្តឈាមដល់ដៃគូនិងការផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធ ត្រូវបានលើកទឹកចិត្តឱ្យធ្វើ
- អ្នកផ្តល់ប្រឹក្សានិងបុគ្គលិកសុខាភិបាលទាំងអស់ត្រូវរក្សាឱ្យបាននូវការសម្ងាត់របស់អតិថិជន
- ការធ្វើតេស្តរហ័សអាចទទួលបានលទ្ធផលនៅថ្ងៃតែមួយ ហើយនីតិវិធីនេះត្រូវបានណែនាំឱ្យធ្វើនៅសេវាថៃទាំផ្ទៃពោះ
- ការធ្វើរោគវិនិច្ឆ័យអំពីជំងឺអេដស៍ចំពោះទារកមានភាពស្មុគស្មាញ តែវាមានសារៈសំខាន់សម្រាប់ការគ្រប់គ្រងផ្នែកគ្លីនិក
- ការធ្វើរោគវិនិច្ឆ័យអំពីជំងឺអេដស៍លើទារកតាមស្តង់ដារ ត្រូវអនុវត្តតាមរយៈការធ្វើតេស្តរកអង្គបដិបក្ខប្រាណនៅខណៈពេលដែលទារកមានអាយុ១៨ខែ

**ការធ្វើរោគវិនិច្ឆ័យអាចធ្វើបានឆាប់ជាងនេះ បើសិនជាមានតេស្ត PCR ។**

# ៤.២ ការបង្ការការមានកូនមិនតាមបំណងចំពោះស្ត្រីផ្ទុកមេរោគអេដស៍

**វត្ថុបំណង**

នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមទាំងអស់អាចនឹង:

១. ពន្យល់អំពីសារៈសំខាន់នៃសេវាផែនការគ្រួសារ

២. រៀបរាប់អំពីមធ្យោបាយផែនការគ្រួសារដែលសមស្របសម្រាប់ស្ត្រីផ្ទុកមេរោគអេដស៍



*រយៈពេល: ៣០នាទី*

## សកម្មភាពទី១: ការបង្ការការមានផ្ទៃពោះមិនតាមបំណងនៅលើស្ត្រីផ្ទុកមេរោគអេដស៍

| ការបង្ការការមានផ្ទៃពោះមិនតាមបំណងនៅលើស្ត្រីផ្ទុកមេរោគអេដស៍ | សេវាផែនការគ្រួសារ |
|---|---|
| ចំនួនស្ត្រីផ្ទុកមេរោគអេដស៍មានផ្ទៃពោះមិនតាមបំណង អាចកាត់បន្ថយបានតាមរយៈការទទួលបាននូវ:<br>■ សេវាផ្តល់ប្រឹក្សាស្តីពីសុខភាពបន្តពូជដែលមានគុណភាពខ្ពស់<br>■ វិធីពន្យារកំណើតដែលមានប្រសិទ្ធិភាពនិងសុវត្ថិភាព<br><br>ការទាក់ទងគ្នារវាងសេវាថែទាំផ្ទៃពោះ ផែនការគ្រួសារ និងសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់មានសារៈសំខាន់ណាស់ ដោយសារតែមានស្ត្រីជាច្រើនដែលមក ទទួលសេវាថែទាំផ្ទៃពោះនិងសេវាផែនការគ្រួសារមិនបានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់គាត់[6] | ■ ការបង្ការការមានផ្ទៃពោះមិនតាមបំណង និងផែនការពន្យារកំណើត អាចរួមចំណែកកាត់បន្ថយ<br>- អត្រាស្លាប់របស់មាតា និងកុមារ<br>- ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន<br>- បញ្ហាផ្លូវចិត្ត<br>■ ការទទួលបាននូវព័តិមាននិងសេវាសំរាប់ស្ត្រីនិងដៃគូស្តីពីផែនការគ្រួសារដែលមានគុណភាពខ្ពស់មានសារៈសំខាន់ណាស់<br>■ យុវវ័យ ស្ត្រីដែលមិនទាន់រៀបការ និងក្រុមដទៃទៀត ដូចជាស្ត្រីជនជាតិភាគតិច ស្ត្រីរកស៊ីផ្លូវភេទ ។ល។ ត្រូវមានសិទ្ធិទទួលបាននូវសេវាទាំងអស់នោះស្មើៗគ្នា[7] |

## សកម្មភាពទី២: បំផុសគំនិត: ផែនការគ្រួសារសម្រាប់ស្ត្រីផ្ទុកមេរោគអេដស៍

» គ្រូនឹងឱ្យសិក្ខាកាមធ្វើការជាគូ ដើម្បីកំណត់រកវិធីពន្យារកំណើតដែលសមស្រប និងដែលមិនសមស្របសម្រាប់ស្ត្រីផ្ទុកមេរោគអេដស៍

» គ្រូសរសេរចំណងជើងពីរនៅលើក្តារខៀន

**"វិធីពន្យារកំណើតដែលសមស្រប" "វិធីពន្យារកំណើតដែលមិនសមស្រប"**

» គ្រូនឹងឱ្យសិក្ខាកាមឆ្លើយម្តងម្នាក់អំពីវិធីពន្យារកំណើតនីមួយៗ និងឱ្យបញ្ជាក់ថា វិធីណាមួយដែលត្រូវជាមួយនឹងចំណងជើងនីមួយៗ

» សម្រាប់វិធីនីមួយៗ តើអ្នកអាចពន្យល់បានឬទេថា ហេតុអ្វីបានជាវិធីនោះសមស្រប ឬមិនសមស្របសម្រាប់ស្ត្រីផ្ទុកមេរោគអេដស៍

## មធ្យោបាយផែនការគ្រួសារ

ស្រោមអនាម័យ (សំរាប់បុរស ឬស្ត្រី)៖ មានតួនាទីពីរ បើសិនជាប្រើប្រាស់វាឱ្យបានត្រឹមត្រូវ និងជាប្រចាំ

- បង្ការការមានផ្ទៃពោះ
- បង្ការជម្ងឺកាមរោគ និងការឆ្លងមេរោគអេដស៍ ឬ ការឆ្លងជាថ្មីថែមទៀត

ស្ត្រីផ្ទុកមេរោគអេដស៍ទាំងអស់គួរតែទទួលនូវការផ្តល់ប្រឹក្សាអំពី៖

- ការប្រើស្រោមអនាម័យឱ្យបានត្រឹមត្រូវ
- ជំនាញចរចាជាមួយដៃគូពីការប្រើស្រោមអនាម័យ
- សារៈសំខាន់នៃការអនុវត្តន៏ការរួមភេទដែលមានសុវត្ថិភាព

ដៃគូគួរតែចូលរួមគ្រប់ទិដ្ឋភាពទាំងអស់នៃការផ្តល់ប្រឹក្សាជាលក្ខណៈបុគ្គលក្តី ឬជាមួយប្តីប្រពន្ធក្តី បើសិនចាំបាច់

9

## ការប្រើស្រោមអនាម័យដើម្បីបង្ការការឆ្លងជាថ្មីថែមទៀត

ស្រោមអនាម័យគួរតែប្រើទោះបី៖

- ដៃគូទាំងពីរមានផ្ទុកមេរោគអេដស៍ហើយក៏ដោយ ដើម្បីកាត់បន្ថយគ្រោះប្រឈម នឹងការចម្លងមេរោគអេដស៍ថ្មីផ្សេងទៀតដែលអាច៖
  - ❖ មានឥទ្ធិពលសាហាវខ្លាំងជាងមេរោគអេដស៍មុន
  - ❖ ស៊ាំជាមួយនឹងឱសថប្រឆាំងមេរោគអេដស៍
- អ្នកជម្ងឺកំពុងតែប្រើឱសថប្រឆាំងមេរោគអេដស៍ក៏ដោយ

10

## មធ្យោបាយផែនការគ្រួសារដទៃទៀត

មធ្យោបាយដូចខាងក្រោមនេះសមស្របសំរាប់ស្ត្រីផ្ទុកមេរោគអេដស៍ និងត្រូវបានប្រើបន្ថែមពីលើការប្រើស្រោមអនាម័យ៖

- ថ្នាំគ្រាប់ពន្យារកំណើត (បើសិនមិនទាន់ប្រើឱសថប្រឆាំងមេរោគអេដស៍ទេ)

  កំណត់ចំណាំ៖ ឱសថប្រឆាំងមេរោគអេដស៍ខ្លះបន្ថយប្រសិទ្ធិភាពថ្នាំគ្រាប់ពន្យារកំណើត។ ស្ត្រីកំពុងតែប្រើឱសថប្រឆាំងមេរោគអេដស៍ដែលមិនចង់មានផ្ទៃពោះត្រូវប្រើមធ្យោបាយផ្សេងទៀត ឬប្រើមធ្យោបាយពន្យារកំណើតបន្ថែមផ្សេងទៀត
- ថ្នាំចាក់ពន្យារកំណើត
- កងដាក់ក្រោមស្បែកដៃ
- មធ្យោបាយបញ្ឈប់កំណើតកូន (ការចងបំពង់ទឹកបង្ហូរមេជីវិតឈ្មោល ឬចងបំពង់ដៃស្បូន)

11

## មធ្យោបាយផែនការគ្រួសារដែលមិនត្រូវប្រើនៅលើស្ត្រីផ្ទុកមេរោគអេដស៍

កងដាក់ក្នុងស្បូន

- វាបង្កើនគ្រោះប្រឈមនឹងការរលាកអាងត្រគាក
- ធ្វើឱ្យឈាមរដូវបាត់បង់ច្រើន
- អាចបង្កើនការប្រឈមនឹងការចម្លងមេរោគអេដស៍

សារជាតិគីមីប្រើសំរាប់សម្លាប់មេជីវិតឈ្មោល

- អាចបណ្តាលឱ្យក្រហល់ក្រហាយនិងរលាករន្ធទ្វារមាស (allergy)
- អាចបង្កើនគ្រោះប្រឈមនឹងការចម្លងគ្នាទៅវិញទៅមករវាងដៃគូទាំងពីរ

12

### ម៉ូឌុលទី៤.២៖ ចំណុចគន្លឹះ

- ការទទួលបាននូវការប្រឹក្សាអំពីសុខភាពបន្តពូជ និងការពន្យារកំណើតដែលមានសុវត្ថិ-ភាព អាចកាត់បន្ថយចំនួនផ្ទៃពោះដែលមិនតាមបំណងនៅលើស្ត្រីផ្ទុកមេរោគអេដស៍
- ស្រោមអនាម័យអាចប្រើដើម្បីបង្ការការមានផ្ទៃពោះផង និង បន្ថយគ្រោះប្រឈមនឹងការឆ្លងមេរោគអេដស៍និងជំងឺកាមរោគផង
- ស្ត្រីផ្ទុកមេរោគអេដស៍និងដៃគូរបស់គាត់ គួរតែទទួលបាននូវការប្រឹក្សាស្តីអំពីការប្រើស្រោមអនាម័យឱ្យបានត្រឹមត្រូវ
- ស្ត្រីផ្ទុកមេរោគអេដស៍អាចប្រើមធ្យោបាយពន្យារកំណើតដទៃទៀតដែលសមស្របបន្ថែមពីលើការប្រើស្រោមអនាម័យ ដូចជា ថ្នាំគ្រាប់សម្រាប់លេបពន្យារកំណើត ថ្នាំចាក់ពន្យារកំណើត ការចងដៃស្បូន ឬបំពង់បង្ហូរមេជីវិតឈ្មោល
- កងដាក់ក្នុងស្បូននិងជាតិគីមីសម្រាប់សម្លាប់មេជីវិតឈ្មោល មិនត្រូវប្រើនៅលើស្ត្រីផ្ទុកមេរោគអេដស៍ទេ

## ៤.៣

# ការបង្ការការចម្លងមេរោគអេដស៍ពីស្ត្រីផ្ទុកមេរោគអេដស៍ទៅកូនរបស់គាត់ (PMTCT)

| | |
|---|---|
| ៤.៣.១ | សេវា **PMTCT**<br>ការព្យាបាលនិងការបង្ការដោយឱសថប្រឆាំងមេរោគអេដស៍ **(ART/ARV)** |
| ៤.៣.២ | ការថែទាំនៅពេលមានផ្ទៃពោះ ពេលឈឺពោះសម្រាលនិងសម្រាល<br>ការថែទាំក្រោយសម្រាលនិងការតាមដានបន្ត |
| ៤.៣.៣ | ការចិញ្ចឹមកូនក្នុងបរិបទនៃមេរោគអេដស៍ |
| ៤.៣.៤ | សុវត្ថិភាពនៅកន្លែងធ្វើការ |

## ៤.៣.១

## សេវា (PMTCT)

## ការព្យាបាលនិងការបង្ការដោយឱសថប្រឆាំងមេរោគអេដស៍

**វត្ថុបំណង**

នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមទាំងអស់អាចនឹងៈ

១. ពន្យល់អំពីហេតុផលដែលនាំឱ្យមានសេវា **PMTCT** និងរៀបរាប់អន្តរាគមន៍ពិសេសសម្រាប់ **PMTCT**

២. ពិភាក្សាអំពីប្រសិទ្ធិភាពនៃអន្តរាគមន៍ **PMTCT**

៣. កំណត់និយមន័យនៃពាក្យ **ARVs** និង **ART** និងពន្យល់អំពីតួនាទីរបស់ **ART** នៅក្នុងការព្យាបាលគ្រប់គ្រងជំងឺអេដស៍

៤. អធិប្បាយអំពីការបង្ការនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ នៅលើស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍

៥. ពន្យល់អំពីរបបឱសថប្រឆាំងមេរោគអេដស៍ប្រើសម្រាប់បង្ការ ដែលត្រូវបានណែនាំឱ្យប្រើប្រាស់នៅកម្ពុជា

៦. ពន្យល់អំពីសារៈសំខាន់នៃការប្រកាន់ខ្ជាប់នូវការប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍សម្រាប់បង្ការនិងព្យាបាល



*រយៈពេលៈ ២ម៉ោង៤០នាទី*

## សកម្មភាពទី១: សេវា PMTCT

ចំណុចសម្គាល់:

នៅកម្ពុជា បើគ្មានអន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនទេ កុមារប្រមាណជា៣,០០០ នាក់ក្នុង១ឆ្នាំ អាចឆ្លងមេរោគអេដស៍ពីម្តាយរបស់គេ

ចំនួនកុមារឆ្លងនេះ អាចកាត់បន្ថយបានប្រហែល៤០% (ប្រហែល ១,៨០០នាក់ក្នុង១ឆ្នាំ) ប្រសិនជាស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍បានទទួលអន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។

### ហេតុអ្វីបានជាយើងត្រូវការសេវា PMTCT ?

- នៅកម្ពុជាចំនួនកុមារកើតរស់ដែលបានប៉ាន់ប្រមាណនៅឆ្នាំ ២០០៥មានចំនួន ៤៦១,០០០*
- គេបានប៉ាន់ប្រមាណថាមានទារកទើបនឹងកើតប្រមាណពី ៩,០០០-១០,០០០នាក់ ប្រឈមមុខទៅនឹងការឆ្លងមេរោគអេដស៍ពីម្តាយរបស់ពួកគេជារៀងរាល់ឆ្នាំ។
- បើគ្មានអន្តរាគមន៍ណាមួយទេ អត្រាចម្លងមេរោគអេដស៍ពីម្តាយទៅកូនមានប្រហែល៣០% ដូច្នេះទារករហូតដល់ជាង ៣,០០០នាក់អាចឆ្លងមេរោគអេដស៍ ពីម្តាយរបស់ពួកគេជារៀងរាល់ឆ្នាំ
- ម្តាយភាគច្រើនមិនបានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនទេ និងមានស្ត្រីមួយចំនួនមិនបានទទួល ឬប្រើប្រាស់សេវា **PMTCT** ទេ។

**សេវា PMTCT ផ្តល់ឱកាសយ៉ាងសំខាន់ក្នុងការកាត់បន្ថយនូវចំនួនកុមារឆ្លងមេរោគអេដស៍ថ្មី**

7

### ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

គោលបំណងនៃសេវា **PMTCT:** គឺដើម្បីកាត់បន្ថយចំនួនឆ្លងមេរោគអេដស៍នៃកុមារដែលកើតពីម្តាយដែលមានផ្ទុកមេរោគអេដស៍។

គោលបំណងនេះអាចសំរេចបានតាមរយៈ

- ការរកឃើញស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ ជាពិសេស ស្ត្រីដែលមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនពីមុនមក
- ជួយស្ត្រីឱ្យទទួលបាននូវសេវា **PMTCT** និងសេវាថែទាំនិងព្យាបាលបន្ត (**CoC**)។

គ្រប់ឱកាសទាំងអស់ គួរតែរកឱ្យឃើញនូវអ្នកផ្ទុកមេរោគអេដស៍ដើម្បីឱ្យពួកគេព្រមទាំងគ្រួសាររបស់ពួកគេបានទទួលនូវសេវាថែទាំនិងគាំទ្រ

8

# សេវា PMTCT ៖ តើវាជាអ្វី?

អន្តរាគមន៍សំខាន់ៗសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនមាន៖

១. ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម (វគ្គទី១ នៃម៉ូឌុលនេះ)៖
ដើម្បីឱ្យស្ត្រីមានផ្ទៃពោះមានឱកាសដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន

២. ការបង្ការ ឬការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍៖
ដើម្បីកាត់បន្ថយបន្ទុកមេរោគអេដស៍និង កាត់បន្ថយការចម្លងពីម្តាយទៅកូន

៣. អនុវត្តការសំរាលកូនដែលមានសុវត្ថិភាព៖
ដើម្បីកាត់បន្ថយការប្រឈមរបស់ទារក នៅពេលឈឺពោះសំរាល និងសំរាល

៤. អនុវត្តការចិញ្ចឹមកូនដែលមានសុវត្ថិភាពជាង៖ ដើម្បីកាត់បន្ថយការប្រឈមរបស់ទារកនៅពេលបំបៅ

9

# ប្រសិទ្ធិភាពនៃអន្តរាគមន៍កាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

អន្តរាគមន៍រួមបញ្ចូលគ្នាអាចកាត់បន្ថយការប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ៖

- បានរហូតដល់ ៤០%* ក្នុងចំណោមស្ត្រីដែលបំបៅកូនដោយដោះ
  (ដូច្នេះមានអត្រា= ១៥-២៥%).
- បានរហូតដល់ ៧០% * ក្នុងចំណោមស្ត្រីដែលមិនបំបៅកូនដោយដោះ
  (ដូច្នេះមានអត្រា= ៥-១៥%)

* ការថយចុះពិតប្រាកដអាស្រ័យទៅនឹងកត្តាមួយចំនួន ដូចជា អន្តរាគមន៍លំអិតនៃការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងបន្ទុកមេរោគអេដស៍របស់ម្តាយ

10

# លទ្ធផលនៃកូនដែលកើតពីម្តាយផ្ទុកមេរោគអេដស៍ ក្រោយពីបានទទួលអន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

**ក្នុងចំណោមកុមារ ១០០នាក់** ដែលកើតពីម្តាយផ្ទុកមេរោគអេដស៍* ហើយត្រូវបានចិញ្ចឹមដោយទឹកដោះម្តាយ (រហូតដល់២ឆ្នាំ) ក្រោយពីបានទទួលអន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

→ កុមារចំនួនពី ៧៥-៨៥ នាក់**នឹងមិន**ឆ្លងមេរោគអេដស៍ទេ

↓ កុមារចំនួនពី ១៥-២៥នាក់ នឹងឆ្លងមេរោគអេដស៍ពីម្តាយ **

*ទារកដែលប្រឈមនឹងការឆ្លងមេរោគអេដស៍
**ទារកដែលឆ្លងមេរោគអេដស៍

11

# ទារកដែលប្រឈមនឹងការឆ្លងមេរោគអេដស៍ ឬ ទារកដែលឆ្លងមេរោគអេដស៍

**ទារកដែលប្រឈមនឹងការឆ្លងមេរោគអេដស៍** គឺជាទារកដែលកើតពីម្តាយមានផ្ទុកមេរោគអេដស៍

**ទារកដែលឆ្លងមេរោគអេដស៍** គឺជាទារកកើតពីម្តាយផ្ទុកមេរោគអេដស៍ ដែលបានឆ្លងមេរោគអេដស៍ នៅពេលកំពុងមានគភ៌ ឬពេលឈឺពោះសំរាលនិងសំរាល ឬតាមរយៈការបំបៅកូនដោយទឹកដោះម្តាយ

**គួរចងចាំថា ៖**ទារកប្រឈមនឹងមេរោគអេដស៍ភាគច្រើន មិនឆ្លងមេរោគអេដស៍ទេ។ ក៏ប៉ុន្តែ ទារកទាំងនោះត្រូវការតាមដានយ៉ាងប្រុងប្រយ័ត្ន ដើម្បីងាយស្រួលក្នុងការរកឃើញបញ្ហាបានទាន់ពេលវេលា។

12

## សកម្មភាពទី២: ARVs និង ART: តើវាជាអ្វី?

| តើ ARV ជាអ្វី? | តើ ART ជាអ្វី? |
| --- | --- |
| ▪ **ARV** or **A**nti**R**etro**V**iral គឺជាឱសថដែលមានសកម្មភាពប្រឆាំងមេរោគអេដស៍<br>■ ឱសថនេះមានសកម្មភាពបង្អាក់ការបំបែកខ្លួនរបស់មេរោគអេដស៍ និងកាត់បន្ថយចំនួនមេរោគអេដស៍នៅក្នុងខ្លួនមនុស្ស ។<br>15 | ឱសថប្រឆាំងមេរោគអេដស៍មានសកម្មភាពល្អនៅពេលដែលគេប្រើវា ៣-៤មុខ ចូលគ្នា<br>**ART** or **A**nti **R**etroviral **T**herapy<br>គឺជាការព្យាបាលដោយប្រើឱសថប្រឆាំងមេរោគអេដស៍ ៣-៤មុខ ចូលគ្នា<br>ការព្យាបាលនេះគេអាចហៅម្យ៉ាងទៀតថា:<br>**HAART or Highly Active Anti Retroviral Therapy:**<br>ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍សកម្មបំផុត<br>=ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍៣មុខចូលគ្នាយ៉ាងតិច<br>16 |

## សកម្មភាពទី៣: តើ ART ប្រើសម្រាប់ធ្វើអ្វី? តើវាមានប្រសិទ្ធិភាពត្រឹមកម្រិតណា?

» គ្រូនឹងសួរសិក្ខាកាមថាតើ **ART** អាចធ្វើអ្វីបានខ្លះ?

» តើមានបញ្ហាអ្វីខ្លះទាក់ទងនឹងការប្រើ **ART** ដែលអ្នកបានដឹង?

### តើART ប្រើសំរាប់ធ្វើអ្វី?

■ ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART) អាចទប់មិនឱ្យមេរោគអេដស៍បំបែកខ្លួន និងធ្វើឱ្យ:

-ប្រព័ន្ធការពាររាងកាយរបស់មនុស្សបានល្អប្រសើរឡើងវិញ និង

-ធ្វើឱ្យរោគសញ្ញាជម្ងឺអេដស៍បានធូរស្រាលឡើងវិញ ។

■ ដូច្នេះ (ART) អាចៈ

-បង្កើនគុណភាពនៃជីវិតបានល្អប្រសើរឡើងវិញ ដោយកាត់បន្ថយជម្ងឺទាក់ទងនឹងមេរោគអេដស៍ (ជម្ងឺឱកាសនិយមតិចតួច)

-ពន្យារជីវិតអ្នកជម្ងឺអេដស៍ និងកាត់បន្ថយការស្លាប់ដែលទាក់ទងនឹងជម្ងឺអេដស៍

-បង្ការការចម្លងមេរោគដេស៍ពីម្តាយទៅកូន ។

18

## តើ ART មិនអាចធ្វើអ្វីខ្លះ?

ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍មិនអាចព្យាបាល អ្នកជម្ងឺអេដស៍ឱ្យជាបានទេ

- វាគ្រាន់តែទប់មិនឱ្យមេរោគអេដស៍បំបែកខ្លួនបាន តែនៅពេលដែលប្រើវាតែប៉ុណ្ណោះ
- បើសិនបញ្ឈប់ការព្យាបាល មេរោគអេដស៍នឹងធ្វើការបំបែកខ្លួនជាថ្មីឡើងវិញយ៉ាងរហ័ស

ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍មិនអាចកំចាត់មេរោគអេដស៍បានទាំងស្រុងទេ

- អ្នកជម្ងឺដែលព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅតែអាចចម្លងមេរោគអេដស៍ ទៅឱ្យដៃគូស្នេហារបស់ខ្លួន។ ដូច្នេះអ្នកជម្ងឺត្រូវតែប្រើស្រោមអនាម័យដើម្បីបង្ការការចម្លងនេះ។

19

## តើ ART បណ្តាលឱ្យមានបញ្ហាអ្វីខ្លះ?

បញ្ហាដែលទាក់ទងទៅនឹងការប្រើឱសថប្រឆាំងមេរោគអេដស៍:

- ■ របបឱសថមានភាពស្មុគស្មាញពិបាកលេប
- ■ ឱសថនេះមានផលប៉ះពាល់បន្ទាប់បន្សំ ដែលអាចកាន់តែធ្វើឱ្យជម្ងឺមានភាពធ្ងន់ធ្ងរ

ការប្រកាន់ខ្ជាប់នូវការប្រើប្រាស់ឱសថ:

- ■ ត្រូវតែឱ្យបានខ្លាំងបំផុត ដើម្បីទទួលផលពីការព្យាបាលឱ្យបានក៏រិតអតិបរិមា
- ■ ត្រូវតែប្រើរហូតអស់មួយជីវិត

ការមិនប្រកាន់ខ្ជាប់នូវការប្រើប្រាស់ឱសថ

- ■ ធ្វើឱ្យមេរោគអេដស៍ស៊ាំទៅនឹងឱសថហើយ មេរោគនេះអាចនឹងត្រូវបានចម្លងទៅអ្នកដទៃទៀត។

20

## សកម្មភាពទី៤: បំផុសគំនិត: ការព្យាបាលនិងការបង្ការដោយឱសថប្រឆាំងមេរោគអេដស៍

» គ្រូនឹងស្នើឱ្យអ្នកគិតអំពី

១. តើអ្វីទៅជា **ARV** សម្រាប់បង្ការ? តើគេប្រើវាសម្រាប់ធ្វើអ្វី?

២. តើ**ARV**សម្រាប់បង្ការខុសគ្នាយ៉ាងដូចម្តេចពី **ART**?

» អ្នកនឹងមានឱកាសនឹងបង្ហាញ ព្រមទាំងពិភាក្សាលើចម្លើយរបស់អ្នក

## ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ART

**ART** : គឺជាការព្យាបាលជម្ងឺអេដស៍ដោយឱសថប្រឆាំងមេរោគអេដស៍ដែលមានរយៈពេលយូរ រហូតអស់មួយជីវិត។

ការប្រើ **ART** នៅពេលមានផ្ទៃពោះ ពេលឈឺពោះសំរាលនិងសំរាល ពេលបំបៅកូនដោយទឹកដោះម្តាយ និងបន្ទាប់មកប្រើរហូតអស់មួយជីវិតអាចៈ

- ■ ធ្វើឱ្យសុខភាពម្តាយកាន់តែប្រសើរ ដោយធ្វើឱ្យគាត់អាចថែរក្សាកូនរបស់គាត់ និង គ្រួសាររបស់គាត់បានប្រសើរជាងមុន
- ■ បន្ថយនូវគ្រោះប្រឈមនឹងការចម្លងមេរោគអេដស៍ទៅទារកបាន ដោយកាត់បន្ថយ នូវបន្ទុកវីរុសដែលនៅក្នុងឈាមរបស់ម្តាយ

**ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍**
និងអ្នកដែល**ត្រូវព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍**ដើម្បីសុខភាពរបស់គាត់
គួរតែមកទទួលការព្យាបាលនេះ។

22

## ការព្យាបាលបង្ការដោយឱសថប្រឆាំងមេរោគអេដស៍

ការព្យាបាលបង្ការ គឺជាការប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ ក្នុងរយៈពេលខ្លី ដើម្បីកាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ។

**ការព្យាបាលបង្ការដោយឱសថប្រឆាំងនឹងមេរោគអេដស៍នេះ :**

- មិនអាចព្យាបាលម្តាយដែលមានផ្ទុកមេរោគអេដស៍បានទេ
- មិនអាចការពារការចម្លងមេរោគអេដស៍ដល់ទារក នៅពេលបំបៅដោះបានឡើយ
- មិនអាចការពារការចម្លងមេរោគអេដស៍ដល់ទារកបានយូរអង្វែងបានឡើយ ។

> ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេសដស៍ ដែលមិនទាន់គ្រប់លក្ខខ័ណ្ឌក្នុងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ **ART** ទេ គួរតែបានទទួលនូវឱសថប្រឆាំងមេរោគអេដស៍ **ARV** សំរាប់បង្ការការចម្លងដល់កូនរបស់គាត់ ។

23

## តើស្ត្រីណាខ្លះដែលគ្រប់លក្ខខ័ណ្ឌអាចទទួលបាននូវការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART)?

ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលៈ

- ស្ថិតក្នុងដំណាក់កាលទី៤នៃចំណាត់ថ្នាក់ជម្ងឺអេដស៍របស់អង្គការសុខភាពពិភពលោក ឬ
- ចំនួនកោសិកា **CD4** តិចជាងឬស្មើ ២៥០ក្នុង ១មម$^{៣}$ ឈាម

គួរទទួលបាននូវការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ **ART** *

> ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេសដស៍ ដែលស្ថិតក្នុងដំណាក់កាលអេដស៍ធ្ងន់ធ្ងរ ត្រូវព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ **ART** ដើម្បីសុខភាពខ្លួន និងដើម្បីបង្ការការចម្លងមេរោគអេដស៍ទៅកូនរបស់គាត់ ។

* គោលការណ៍ណែនាំជាតិសំរាប់កម្មវិធីបង្ការការចម្លងមេរោគអដស៍ពីម្តាយទៅកូន -២០០៥

24

## តើស្ត្រីណាខ្លះដែលគួរទទួលការព្យាបាលបង្ការដោយឱសថប្រឆាំងមេរោគអេដស៍ ARV ?

ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលៈ

- ស្ថិតក្នុងដំណាក់កាលទី១, ទី២, ឬ ទី៣ នៃចំណាត់ថ្នាក់ជម្ងឺអេដស៍របស់អង្គការសុខភាពពិភពលោក
- ឬ ដែលមានកោសិកា CD4 ច្រើនជាង ២៥០ក្នុង ១មម$^{៣}$ ឈាម
- មិនទាន់គ្រប់ល័ក្ខខ័ណ្ឌទទួលនូវការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍គួរទទួលបាន នូវការព្យាបាលបង្ការដោយឱសថប្រឆាំងមេរោគអេដស៍ ដើម្បីការពារកូនរបស់គាត់ ។

> ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ ដែលមិនទាន់ស្ថិតក្នុងដំណាក់កាលអេដស៍ធ្ងន់ធ្ងរ គួរទទួលបាន នូវការព្យាបាលបង្ការដោយឱសថប្រឆាំងមេរោគអេដស៍ (ARV)ដើម្បីការពារកូនរបស់គាត់ ។

25

## តើឱសថប្រឆាំងមេរោគអេដស៍គួរចាប់ផ្តើមប្រើនៅពេលណាចំពោះស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍?

ART: ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

- ត្រូវចាប់ផ្តើមព្យាបាលភ្លាមៗបើអាចធ្វើបាន ជាពិសេសបើសិនជាស្ត្រីនោះធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ
- ត្រូវពន្យារពេលផ្តល់ឱសថដល់ស្ត្រីរហូតដល់ចូលត្រីមាសទី២នៃផ្ទៃពោះ និងប្រសិនបើស្ត្រីនោះ មិនមានជម្ងឺធ្ងន់ធ្ងរទេ

ARV Prophylaxis: ការព្យាបាលបង្ការដោយឱសថប្រឆាំងមេរោគអេដស៍ត្រូវចាប់ផ្តើមប្រើនៅសប្តាហ៍ទី២៨នៃអាយុផ្ទៃពោះ ឬអាចប្រើភ្លាមបន្ទាប់ពីដឹងថាស្ត្រីមានផ្ទៃពោះលើសពី២៨សប្តាហ៍ហើយ ។

26

**សម្គាល់: ពន្យល់ពាក្យនៃអក្សរកាត់**

ឱសថប្រឆាំងមេរោគអេដស៍

» NVP ណេវីរ៉ាពីន Nevirapine

» AZT ហ្ស៊ីដូវុយឌីន Zidovudine

» 3TC ឡាមីវុយឌីន Lamivudine

» Hb អេម៉ូក្លូប៊ីន Haemoglobin

នេះសម្រាប់ស្ទង់មើល ថាតើម្តាយមានឈាមច្រើនប៉ុណ្ណា ។ ប្រសិនជា **Hb**នេះទាប នោះមានន័យថាម្តាយស្លេកស្លាំងហើយ ។ គាត់អាចមើលទៅឃើញមានស្លេកស្លាំង អស់កម្លាំង និងដកដង្ហើមខ្សោយ ។

## តើរបបឱសថអ្វីខ្លះដែលគួរយកមកប្រើ?

**ART:**

■ គេឱ្យរបបឱសថជាលក្ខណៈស្តង់ដារ*

**ARV** សំរាប់បង្ការ:

■ មុនឆ្នាំ 2006: ផ្តល់ណេវីរ៉ាពីន (NVP) មួយកំរិតទៅម្តាយនិងទារក

■ ចាប់ពីឆ្នាំ 2006: ប្តូរទៅប្រើ AZT និង NVP និង 3TC ពីព្រោះរបបឱសថនេះ មានប្រសិទ្ធិភាពជាង

27

**សម្គាល់:** របបឱសថប្រឆាំងមេរោគអេដស៍

ប្រសិនជាម្តាយបានទទួល **NVP**នៅពេលឈឺពោះសម្រាល ត្រូវផ្តល់ **3TC**និង **AZT** ក្រោយពេលសម្រាលដល់គាត់ ដោយសារតែប្រឈមនឹងការស៊ាំរបស់មេរោគអេដស៍ទៅនឹងឱសថ **NVP**(សូមអានព័តិមានជាមូលដ្ឋាន) ។

ប្រសិនជាម្តាយមកយឺតពេកមិនបានទទួល **NVP**នៅពេលសម្រាលទេ មិនចាំបាច់ផ្តល់ **3TC** និង **AZT** ក្រោយពេលសម្រាលដល់គាត់ទេ ដោយសារតែវាមិនទាក់ទងនឹងភាពស៊ាំរបស់មេរោគទៅនឹងឱសថ **NVP**(ស្លាយទី៣០) ។

## ម្តាយដែលកំពុងប្រើ ART: របបឱសថ

ម្តាយត្រូវទទួល:

- AZT + 3TC + NVP (កំរិតស្តង់ដារ):បើសិនជាម្តាយមិនមានស្លេកស្លាំង(Hb> 9g/dl)
- D4T + 3TC + NVP (កំរិតស្តង់ដារ): បើសិនជាម្តាយមានស្លេកស្លាំង ( Hb< 9g/dl )

បន្តប្រើចាប់ពីមានផ្ទៃពោះរហូតដល់ពេលឈឺពោះសំរាលទារកត្រូវទទួល:

- NVP មួយកំរិតបន្ទាប់ពីសំរាលក្នុងកំឡុងពេល៧២ម៉ោង
- AZT (4mg/kg) ២ដងក្នុង១ថ្ងៃ រយៈពេល៧ថ្ងៃ*

*ប្រសិនបើម្តាយបានទទួល AZT តិចជាង ៤ សប្តាហ៍ក្នុងកំឡុងពេលមានផ្ទៃពោះ ទារកនឹងទទួល AZTរយៈពេល៤សប្តាហ៍

28

## ARVសំរាប់បង្ការៈ របបឱសថ

គោលការណ៏ណែនាំជាតិសំរាប់កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ឆ្នាំ២០០៥

ដំណាក់កាលគ្លីនិកទី១ ២ ឬ៣ របស់អង្គការសុខភាពពិភពលោក ឬ **CD4** ច្រើនជាង ២៥០ក្នុង ១មម³

ឬសេវា **PMTCT** ឆ្ងាយមិនអាចទទួលបាននូវសេវា **OI/ART** បាន

ម្តាយត្រូវទទួលៈ

- AZT(300mg) ២ដងក្នុង១ថ្ងៃ ចាប់ពី ២៨សប្តាហ៏នៃផ្ទៃពោះ
- AZT(300mg) នៅពេលឈឺពោះសំរាល ឱ្យរៀងរាល់៣ម៉ោងម្តងរហូតដល់សំរាល
- NVP(200mg) មួយកំរិតពេលកំពុងឈឺពោះសំរាល
- AZT(300mg) និង 3TC(150mg) ២ដងក្នុង១ថ្ងៃ រយៈពេល៧ថ្ងៃ បន្ទាប់ពីសំរាល

ទារកត្រូវទទួលៈ

- NVP(2mg/kg) មួយដូសគត់បន្ទាប់ពីសំរាលក្នុងកំឡុងពេល៧២ម៉ោង*
- AZT(4mg/kg) ២ដងក្នុង១ថ្ងៃ រយៈពេល៧ថ្ងៃ *

* ប្រសិនបើម្តាយបានទទួល **AZT តិចជាង ៤សប្តាហ៏** ក្នុងកំឡុងពេលមានផ្ទៃពោះ ទារកនឹងទទួល **AZTរយៈពេល៤សប្តាហ៏**

* ប្រសិនបើម្តាយសំរាលកូនតិចជាង២ម៉ោងក្រោយប្រើ **NVP** ទារកត្រូវទទួល **NVP** ភ្លាមក្រោយពីកើត ។

29

## ARVសំរាប់បង្ការដល់ទារកដែលម្តាយផ្ទុកមេរោគអេដស៍មិនបានទទួល ARV សោះ

- នៅពេលមានផ្ទៃពោះ ឬសំរាល និង
- មកដល់មន្ទីរពេទ្យដែលមានសេវា **PMTCT** ក្នុងកំឡុងពេល២ម៉ោងនៃការសំរាល

ទារកត្រូវទទួលៈ

- NVP(2mg/kg) មួយកំរិតគត់បន្ទាប់ពីសំរាលឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន ( មិនត្រូវឱ្យហួសពី៧២ម៉ោងក្រោយសំរាលទេ)
- AZT(4mg/kg) ២ដងក្នុង១ថ្ងៃ រយៈពេល៤សប្តាហ៏

ម្តាយដែលមិនបានទទួលឱសថប្រឆាំងមេរោគអេដស៏សោះ នៅពេលដែលទារកកើត មិនបាច់ព្រួយបារម្ភពីការស៊ាំរបស់មេរោគអេដស៏ជាមួយនឹង **NVP** ទេ

30

## ក្នុងស្ថានភាពពិសេស

ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលកំពុងព្យាបាលដោយថ្នាំរបេងៈ

- អាចទទួលការព្យាបាល **ART**ឬបង្ការដោយ **ARV**បាន
- ត្រូវឱ្យ **ART** រួមនឹងការតាមដានការព្យាបាលបន្ថែមជាចាំបាច់ ។

ស្ត្រីដែលកំពុងព្យាបាលដោយ **ART** តែក្រោយមកមានផ្ទៃពោះៈ

- គួរបន្តព្យាបាលដោយ **ART**
- ប្រសិនជានាងកំពុងប្រើរបប **ART** ដែលមាន **Efavirenz** ត្រូវប្តូរថ្នាំនេះទៅជា **NVP** វិញ ពីព្រោះវាអាចធ្វើឱ្យប៉ះពាល់ដល់ទារកក្នុងផ្ទៃ ។

31

## ភាពពុលនៃឱសថទាក់ទងទៅនឹងការព្យាបាលដោយ ARTពេលមានផ្ទៃពោះ

- ស្លេកស្លាំង **(AZT)**
- ផលប៉ះពាល់ដល់ផ្ទៃពោះ
  - កូនកើតមិនគ្រប់ទំងន់
  - សំរាលមិនគ្រប់ខែ
  - កូនកើតស្លាប់

ផលប៉ះពាល់ (outcomes)ដែលកើតមានឡើងទាំងអស់នេះ ទាក់ទងជាមួយនឹងភាពធ្ងន់ធ្ងរនៃជម្ងឺអេដស៏របស់ម្តាយ ។ ជោគជ័យនៃការព្យាបាលដោយ **ART** អាចកាត់បន្ថយនូវគ្រោះប្រឈមបាន ។

32

## សកម្មភាពទី៥: ពិភាក្សា: ការប្រកាន់ខ្ជាប់នូវការប្រើឱសថ ARV ឱ្យបានត្រឹមត្រូវ

» គ្រូនឹងស្នើសិក្ខាកាមឱ្យគិតអំពីពាក្យ "ការប្រកាន់ខ្ជាប់" តើវាមានន័យបែបណា? តើវាមានសារៈសំខាន់យ៉ាងដូចម្តេចខ្លះ?

» គ្រូនឹងដឹកនាំការពិភាក្សាស្តីអំពីការប្រកាន់ខ្ជាប់នូវការប្រើឱសថឱ្យបានត្រឹមត្រូវ និង អំពីសារៈសំខាន់របស់វា

### ការប្រកាន់ខ្ជាប់នូវការប្រើ ARV (១)

ការប្រកាន់ខ្ជាប់នូវការប្រើ **ARV** មានន័យថា ត្រូវលេបថ្នាំទាំងអស់

- តាមវេជ្ជបញ្ជា
- ឱ្យបានទៀងទាត់តាមពេលវេលា
- ឱ្យត្រូវតាមកំរិត

ការប្រកាន់ខ្ជាប់នូវការព្យាបាល ជាកត្តាគន្លឹះ ដើម្បីទទួលជោគជ័យក្នុងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ **ART**និងការបង្ការដោយ **ARV**

បើសិនជាការលេបថ្នាំមានការខកខានមិនត្រឹមត្រូវ អាចបណ្តាលឱ្យៈ

- ចំនួនមេរោគអេដស៍កើនឡើងនៅក្នុងឈាម និង
- វិវត្តទៅរកជម្ងឺអេដស៍
- បង្កើននូវការប្រឈមនឹងការចម្លងមេរោគអេដស៍
- បង្កើនការប្រឈមនឹងភាពស៊ាំរបស់មេរោគអេដស៍ជាមួយនឹងឱសថ

34

### ការប្រកាន់ខ្ជាប់នូវការប្រើ ARV (២)

- ការប្រកាន់ខ្ជាប់នូវការប្រើ **ARV** គឺជាការសំខាន់ណាស់ ហើយគប្បីលើកទឹកចិត្តអតិថិជនគិតដល់បញ្ហានេះ មុនពេលចាប់ផ្តើម **ARV** និងត្រូវពង្រឹងការប្រកាន់ខ្ជាប់នូវការព្យាបាល នេះជាពិសេស ចំពោះបុគ្គល គ្រួសារ និងនៅសហគមន៍ ។
- អ្នកផ្តល់សេវាគួរតែពិភាក្សាអំពីផលប៉ះពាល់នៃឱសថប្រឆាំងមេរោគអេដស៍ដែលគាត់បាន ដឹង និងពីសារៈសំខាន់នៃការប្រកាន់ខ្ជាប់នូវការប្រើឱសថ **ARV** ដើម្បីជួយស្ត្រីៈ
  - ឱ្យដឹងជាមុននូវផលប៉ះពាល់
  - ដឹងពីរបៀបគ្រប់គ្រងផលប៉ះពាល់បន្តិចបន្តួចដែលអាចកើតមានឡើង
  - មិនបញ្ឈប់ការព្យាបាលដោយឥតហេតុផល
- បន្ទាប់ពីចាប់ផ្តើមព្យាបាល **ART** មក ស្ត្រីគួរតែមកជួបនឹងគ្រូពេទ្យឱ្យបានញឹកញាប់ ដើម្បីទទួលបាននូវការគាំទ្រទាក់ទងនឹងការប្រកាន់ខ្ជាប់នូវការប្រើប្រាស់ឱសថឱ្យបានត្រឹមត្រូវ និង ទៀងទាត់ និងដើម្បីធ្វើការវាយតម្លៃនិងគ្រប់គ្រងផលប៉ះពាល់របស់ឱសថនោះ ។

35

### ការប្រកាន់ខ្ជាប់នូវការប្រើឱសថ ARV ក្នុងកំឡុងពេលមានផ្ទៃពោះនិងក្រោយពេលសំរាល

ការប្រកាន់ខ្ជាប់នូវការប្រើឱសថ ARV អាចជាការពិបាកណាស់សំរាប់ស្ត្រីមានផ្ទៃពោះនិងស្ត្រី ក្រោយសំរាលដោយសារតែៈ

- ការចាញ់កូនដែលអាចធ្វើទុក្ខចង្អោរកាន់តែខ្លាំងនៅពេលប្រើឱសថប្រឆាំងមេរោគអេដស៍
- ការព្រួយបារម្ភ ថាការឱ្យឱសថប្រឆាំងមេរោគអេដស៍អាចបង្កគ្រោះថ្នាក់ដល់ទារក
- ការផ្លាស់ប្តូររាងកាយក្រោយសំរាល គួបផ្សំនឹងស្រ្តេសនិងតំរូវការថែទាំដល់ទារកដែលទើបនឹងកើត ។

ផ្តល់ការគាំទ្របន្ថែមដល់អតិថិជនដើម្បីឱ្យគាត់បានប្រកាន់ខ្ជាប់នូវការប្រើឱសថប្រឆាំងមេរោគអេដស៍បានត្រឹមត្រូវនិងទៀងទាត់ ទាំងនៅពេលមុននិងក្រោយសំរាល ។ ធ្វើដូច្នេះស្ត្រីនឹងមិនបញ្ឈប់ការព្យាបាលមុនពេលកំណត់ ទោះបីជាមានផលប៉ះពាល់បន្តិចបន្តួចពីឱសថ ក៏ដោយ ។

36

## សកម្មភាពទី៦ : លំហាត់: ARV សម្រាប់បង្ការដល់កុមារ: គណនាបរិមាណ

- » នៅក្នុងលំហាត់នេះ អ្នកត្រូវគិតបរិមាណនៃស៊ីរ៉ូប NVP និង AZT ដើម្បីផ្តល់ឱ្យទារកដែលមានទម្ងន់ខុសៗគ្នា
- » កម្រិតឱសថដែលត្រូវការ មានបង្ហាញនៅក្នុងស្លាយ
- » ចូរពិនិត្យទម្ងន់របស់ទារកនីមួយៗ ។ បន្ទាប់មកឱ្យសិក្ខាកាមគិតថា តើកូនម្នាក់ៗត្រូវទទួលបានស៊ីរ៉ូបប៉ុន្មាន?

**គណនាពីតំរូវការកំរិតឱសថស៊ីរ៉ូប NVP និង AZT សំរាប់ទារក**

| ទារក | ទំងន់ពេលកើត | កំរិត NVP (ml) 0.2ml/kg ១កំរិតគត់ | កំរិត AZT (ml) 0.4ml/kg ២ដង/១ថ្ងៃ |
|---|---|---|---|
| ១ | ២២៥០ ក្រ | ០. ៥ មល | ១.០ មល |
| ២ | ២.៥ គក្រ | ០. ៥ មល | ១.០ មល |
| ៣ | ២.៧ គក្រ | ០. ៥ មល | ១.១ មល |
| ៤ | ៣០១០ក្រ | ០. ៦ មល | ១.២ មល |
| ៥ | ៣២៤០ក្រ | ០. ៧ មល | ១.៣ មល |

38

# ការណែនាំសំរាប់ម្តាយ (១)

- ត្រូវចាក់ស៊ីរ៉ូបទៅក្នុងដបស្អាតគ្មានមេរោគ ដើម្បីឱ្យម្តាយយកទៅផ្ទះ
  - ត្រូវដាក់ ២០ម.ល ស៊ីរ៉ូប **AZT** សំរាប់១សប្តាហ៍
  - ត្រូវ១ដប ស៊ីរ៉ូប **AZT** សំរាប់៤សប្តាហ៍
- បើសិនជាដបមិនមានគំរបដំណក់ទេ ត្រូវឱ្យសឺរ៉ាំងចំណុះ ១ម.ល ទៅម្តាយ
- ប្រើប៊ិចដែលមិនចេះរលប់ សរសេរលើសឺរ៉ាំង ដើម្បីបង្ហាញម្តាយពីបរិមាណឱសថដែលត្រូវផ្តល់ឱ្យកូន
- ម្តាយត្រូវលាងសឺរ៉ាំងក្រោយពេលប្រើម្តងៗ ដោយបាញ់លាងជាច្រើនដងជាមួយនឹងទឹកឆ្អិន
- បើដបមានគំរបដំណក់ហើយ មិនចាំបាច់លាងវាទេ

39

# ការណែនាំសំរាប់ម្តាយ (២)

- កំរិត: ០.៤ម.ល ក្នុង១គីឡូក្រាម សំរាប់កូនទំងន់ ២.៥គីឡូ= ១ម.ល ស៊ីរ៉ូប
- ឱ្យ២កំរិតក្នុង១ថ្ងៃ ឱ្យ១២ម៉ោងម្តង
- ទុកឱសថក្នុងដបស្ងួតស្អាត កុំឱ្យត្រូវពន្លឺថ្ងៃ
- បើសិនជាទារកក្អួតក្នុងរវាង១០នាទីក្រោយពីផឹកឱសថ ត្រូវផ្តល់ឱ្យកូន១កំរិតទៀត
- ត្រូវប្រាកដថា កូនផឹកម្តងតែមួយកំរិតទេ
- បើសិនជាភ្លេចឱ្យឱសថលើសពី៦ម៉ោងមិនបាច់ឱ្យកំរិតនោះទេ
- មិនត្រូវចែកឱសថនេះទៅឱ្យទារកណាផ្សេងទេ ព្រោះបើប្រើឱសថមិនត្រឹមត្រូវនាំឱ្យមានមេរោគអេដស៍មានភាពស៊ាំទៅនឹងឱសថ

40

## ម៉ូឌុលទី៤.៣.១: ចំណុចគន្លឹះ

- ការទទួលបាននូវសេវា **PMTCT** អាចកាត់បន្ថយចំនួនកុមារឆ្លងមេរោគអេដស៍ថ្មី
- បើគ្មានអន្តរាគមន៍ទេ គ្រោះប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូនមានពី២៥-៤០% ។ ការធ្វើអន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនរួមគ្នា អាចកាត់បន្ថយអាត្រាឆ្លងរហូតដល់ទៅ៤០% ចំពោះម្តាយដែលបំបៅកូនដោយដោះ
- អន្តរាគមន៍សំខាន់ៗនៃការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន មាន:

  ១. ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម (វគ្គទីមួយនៃម៉ូឌុលនេះ)

  ២. ការបង្ការនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

  ៣. ការអនុវត្តន៍ការសម្រាលដែលមានសុវត្ថិភាព

  ៤. ការអនុវត្តន៍ការចិញ្ចឹមកូនដែលមានសុវត្ថិភាព
- **ART** គឺជាការព្យាបាលម្តាយដែលមានផ្ទុកមេរោគអេដស៍ ។ វាអាចកាត់បន្ថយគ្រោះប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- **ARV** ជាឱសថសម្រាប់បង្ការមិនអាចព្យាបាលម្តាយបានទេ តែអាចកាត់បន្ថយគ្រោះចម្លងមេរោគអេដស៍ពីម្តាយទៅកូនបាន
- ការប្រកាន់ខ្ជាប់នូវការប្រើឱសថ**ARV** គឺជាកត្តាគន្លឹះសម្រាប់ជោគជ័យនៃការបង្ការនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

## ម្តាយទទួលការព្យាបាល ART : របបឱសថ

| របបឱសថ | មុនសំរាល | រយៈពេលឈឺពោះសំរាល | ក្រោយសំរាលភ្លាមៗ | ក្រោយសំរាល |
|---|---|---|---|---|
| ART (ម្តាយ) | **ម្តាយ:** **ART** | **ម្តាយ:** **ART** | **ម្តាយ:** **ART** | **ទារក:** **NVP** (2mg/kg) ឱ្យទារកផឹកភ្លាម ក្រោយសំរាល<br><br>**AZT** (4mg/kg) ឱ្យទារកផឹកពីរដង ក្នុង១ថ្ងៃ រយៈពេល៧ ថ្ងៃ* |

*ប្រសិនបើម្តាយបានទទួល AZT តិចជាង ៤សប្តាហ៍ក្នុងកំឡុងពេលមានផ្ទៃពោះ ទារកនឹងទទួល AZTរយៈពេល ៤សប្តាហ៍

## របបឱសថសំរាប់បង្ការប្រឆាំងមេរោគអេដស៍

| របបឱសថ | មុនសំរាល | រយៈពេលឈឺពោះសំរាល | ក្រោយសំរាលភ្លាមៗ | ក្រោយសំរាល |
|---|---|---|---|---|
| Zidovudine (AZT) និង Nevirapine (NVP) និង Lamivudine 3TC | ម្តាយ:<br>AZT (300mg) ពីរដងក្នុង១ថ្ងៃចាប់ពី ២៨សប្តាហ៍នៃផ្ទៃពោះ ឬ ផ្តល់ឱ្យភ្លាមបន្ទាប់ពីដឹងថាមានផ្ទៃពោះ ក្រោយពី ២៨ សប្តាហ៍ ឡើងទៅ។ | ម្តាយ:<br>AZT (300mg) ១គ្រាប់នៅពេលឈឺពោះសំរាលនិងរៀងរាល់៣ ម៉ោងម្តងរហូតដល់សំរាល និង NVP (200mg) តែម្តង គត់ នៅពេលឈឺពោះ សំរាល | ម្តាយ:<br>AZT (300mg) និង 3TC (150mg) លេបពីរដងក្នុង១ថ្ងៃ សំរាប់ រយៈពេល៧ ថ្ងៃក្រោយសំរាល | ទារក:<br>NVP (2mg/kg) ឱ្យទារកផឹកភ្លាម ក្រោយសំរាល<br><br>AZT (4mg/kg) ឱ្យទារកផឹកពីរដងក្នុង១ថ្ងៃ រយៈពេល៧ ថ្ងៃ |

*ប្រសិនបើម្តាយបានទទួល **AZT < **៤សប្តាហ៍ ក្នុងកំឡុងពេលមានផ្ទៃពោះ ទារកនឹងទទួល **AZT**រយៈពេល ៤សប្តាហ៍

## ឱសថបង្ការប្រឆាំងមេរោគអេដស៍សំរាប់ទារក

| របបឱសថ | មុនសំរាល | រយៈពេលឈឺពោះសំរាល | ក្រោយសំរាលភ្លាម | ក្រោយសំរាល |
|---|---|---|---|---|
| **AZT និង/ឬ NVP សំរាប់ទារក** (ពេលដែលម្តាយមិនបានទទួលនូវឱសថបង្ការប្រឆាំងមេរោគអេដស៍នៅពេលមានផ្ទៃពោះ) | **ម្តាយ:** **គ្មាន** | **ម្តាយ:** **គ្មាន** | **ម្តាយ:** **គ្មាន** | **ទារក:** **NVP (2mg/kg)** ឱ្យទារកផឹកភ្លាម ក្រោយសំរាល **AZT** (4mg/kg) ឱ្យទារកផឹកពីរដង ក្នុង១ថ្ងៃរយៈពេល ៤ សប្តាហ៍ |

## សង្ខេប: ការប្រើឱសថព្យាបាលប្រឆាំងមេរោគអេដស៍សំរាប់ស្ត្រី (១)

| **ស្ត្រីមានផ្ទៃពោះ** | |
|---|---|
| ស្ត្រីមានផ្ទៃពោះដែលក្នុងពេលថ្មីៗ រោគវិនិច្ឆ័យបញ្ជាក់ថាមានផ្ទុកមេរោគអេដស៍ អាចទទួលបាននូវការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ | ផ្តល់ប្រឹក្សា និងចាប់ផ្តើមប្រើឱសថព្យាបាលប្រឆាំងមេរោគអេដស៍ភ្លាមបើអាចធ្វើបាន |
| ស្ត្រីមានផ្ទៃពោះដែលក្នុងពេលថ្មីៗ រោគវិនិច្ឆ័យបញ្ជាក់ថាមានផ្ទុកមេរោគអេដស៍ មិនអាចទទួលបាននូវការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ | ផ្តល់ឱសថបង្ការប្រឆាំងមេរោគអេដស៍ចាប់ពី ២៨សប្តាហ៍នៃផ្ទៃពោះ |
| ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ ដែលមិនបានទទួលការព្យាបាលដោយឱសថ ប្រឆាំងមេរោគអេដស៍ ឬ ឱសថបង្ការប្រឆាំងមេរោគអេដស៍នៅពេលមានផ្ទៃពោះ ឬ នៅពេលឈឺពោះសំរាល ហើយបានមកដល់មន្ទីរពេទ្យដែលមានសេវា PMTCTក្នុងរយៈពេល២ម៉ោងបន្ទាប់ពីសំរាល។ | ផ្តល់ NVP និង AZT ទៅទារក។ |
| ស្ត្រីមានផ្ទុកមេរោគអេដស៍ ដែលទើបនឹងរកឃើញរោគវិនិច្ឆ័យថ្មីៗ នៅពេលសំរាល។ | ផ្តល់ NVP និង AZT ទៅទារក។ ផ្តល់ប្រឹក្សា និង លើកទឹកចិត្តឱ្យធ្វើតេស្តឈាមរកមេរោគអេដស៍។ |

## សង្ខេប: ការប្រើឱសថព្យាបាលប្រឆាំងមេរោគអេដស៍សំរាប់ស្ត្រី (២)

| | |
|---|---|
| **ស្ត្រីមានផ្ទៃពោះ** | |
| ស្ត្រីផ្ទុកមេរោគអេដស៍ដែលកំពុងតែព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ហើយក្រោយមកមានផ្ទៃពោះ។ | បន្តប្រើឱសថព្យាបាលប្រឆាំងមេរោគអេដស៍ ដោយផ្លាស់ប្តូររបបថ្នាំ (ឧទាហរណ៍ពី **EFV**ទៅ **NVP**) |
| **ស្ត្រីគ្មានផ្ទៃពោះ** | |
| ស្ត្រីមានផ្ទុកមេរោគអេដស៍ដែលទើបនឹងធ្វើរោគវិនិច្ឆ័យថ្មីៗ អាចទទួលបាននូវការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ហើយអាចមានផ្ទៃពោះនៅពេលក្រោយ។ | ផ្តល់ការប្រឹក្សា និង ចាប់ផ្តើមប្រើឱសថព្យាបាលប្រឆាំងមេរោគអេដស៍ ដោយប្រើ **NVP**។ ជៀសវាងប្រើ **EFV** |

## ព័ត៌មានស្តីពីឱសថ– Zidovudine (AZT)

- មានការបឺតស្រូបយកល្អបន្ទាប់ពីលេប
- ទារកអាចទ្រាំទ្របាន ទាំងមុនសំរាលនិងក្រោយសំរាល
- អាចលេបបានជាមួយអាហារ ឬ ដោយគ្មានអាហារបាន

ផលវិបាកបន្ទាប់បន្សំ :(ជាទូទៅកើតមានក្រោយប្រើពី ៣-៦សប្តាហ៍)

- ចង្អោរ
- វិលមុខ ជាពិសេសនៅពេលងើបឈរ
- ស្លេកស្លាំង*(រួមជាមួយនឹងភាពអស់កំលាំង ពិបាកដកដង្ហើម សម្បុរស្លាំង)។ ធម្មតាផលវិបាកទាំងនេះ នឹងបាត់ទៅវិញក្រោយឈប់លេបថ្នាំ។

*ភាពស្លេកស្លាំងនេះគឺបណ្តាលមកពីការប៉ះពាល់ទៅលើខួរឆ្អឹងខ្នង និង មិនអាចព្យាបាលបានដោយថ្នាំជាតិដែក និង folate បាន។

## ការពិចារណាលើការផ្តល់ឱសថ AZT

១. បុគ្គលិកសុខាភិបាលត្រូវតែទទួលការបណ្តុះបណ្តាលពីការប្រើប្រាស់ឱសថ
- AZT
- Iron and Folate supplements

២. បុគ្គលិកមន្ទីរពិសោធន៍នៅកន្លែងដែលមានសេវា PMTCT ត្រូវទទួលមើលតេស្ត Hb

៣. ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ត្រូវ
- ពិនិត្យមើលតេស្ត Hb មុននឹងចាប់ផ្តើមប្រើ AZT
- មកពិនិត្យតាមដានបន្តរៀងរាល់២សប្តាហ៍ម្តង សំរាប់ខែទីមួយ និង មួយខែម្តងរហូតដល់ពេលសំរាល រួមជាមួយនឹងការតាមដានតេស្ត Hb ផង
- យល់ពីសារៈសំខាន់នៃការប្រើប្រាស់ឱសថទៀងទាត់និងត្រឹមត្រូវ និងមានបំណងអនុវត្តតាមការព្យាបាល
- បានលើកទឹកចិត្តឱ្យមកសំរាលកូននៅមន្ទីរពេទ្យដែលមានសេវា PMTCT ។

## ព័ត៌មានស្តីពីឱសថ — Lamivudine (3TC)

- មានការបឺតស្រូបល្អបន្ទាប់ពីលេប
- អាចប្រើដោយសុវត្ថិភាពជាមួយឱសថផ្សេងទៀតដែលប្រើសំរាប់ព្យាបាលរោគសញ្ញាទាក់ទងនឹងជម្ងឺអេដស៍
- អាចលេបបានជាមួយអាហារ ឬ មិនបាច់មានអាហារក៏បាន

ផលវិបាកបន្ទាប់បន្សំ

- កម្រឱ្យមានផលវិបាកបន្ទាប់បន្សំ

## ព័ត៌មានស្ដីពីឱសថ - Nevirapine (NVP)

- មានការបឹតស្រូបល្អបន្ទាប់ពីលេប
- មានរយៈពេលយូរ ដែលប្រសិទ្ធិភាពជាអំណោយផលដល់កូន
- អាចលេបបានជាមួយអាហារឬ មិនបាច់មានអាហារក៏បាន

ការប្រើ Nevirapineតែមួយក៏រិត កំរមានកើតឡើងនូវផលរំខានបន្ទាប់បន្សំណាស់

ផលរំខានបន្ទាប់បន្សំអាចកើតមាននៅពេលប្រើវា
ក្នុងលក្ខណៈព្យាបាលដែលមានរយៈពេលយូរ
- រមាស់កន្ទួលក្រហម
- ពុលថ្លើម (ចង្អោរ ពិសាមិនបាន ស្បែកលឿង ឈឺពោះ អស់កំលាំង ក្ដៅខ្លួន

ផលប៉ះពាល់ទាំងនេះជួនកាលមានលក្ខណៈធ្ងន់ធ្ងរដែលតំរូវអោយប្ដូរថ្នាំ។
ការផ្ដើមព្យាបាលជម្ងឺអេដស៏ ដោយប្រើ **NVP**ដែលមានក៏រិតទាប (២០០ម.ក្រ/១ថ្ងៃ) ក្នុងរយៈពេល២អាទិត្យ ដំបូងកាត់បន្ថយនូវគ្រោះប្រឈម នឹងផលវិបាកធ្ងន់ធ្ងរ។

## ហេតុអ្វីបានជាបញ្ហាភាពស៊ាំនឹងឱសថមានចំពោះតែ NVP ហើយមិនមានលើ AZT

- AZT អាចត្រូវបានផ្ដល់ដល់ស្រ្តីរហូតដល់ប្រហែល ៣ខែ នៅពេលប្រើវាសំរាប់បង្ការនៅពេលមានផ្ទៃពោះ
- ARTត្រូវឱ្យរយៈពេលវែងដែលមានយ៉ាងហោចណាស់ឱសថបីមុខរួមគ្នា ដើម្បីកាត់បន្ថយភាពស៊ាំរបស់មេរោគអេដស៏ជាមួយនឹងថ្នាំ
- ភាពស៊ាំទៅនឹង AZT :
- ធ្វើឱ្យមានការប្រែប្រួលទាំងចំនួន និងការវិវត្តន៏របស់វីរុសយឺត
- វាមិនធ្វើឱ្យមានភាពស៊ាំទាំងអស់ទេ ដូចជា:
    - AZT អាចមានអំណោយផលដែរ ទោះបីជាមានការផ្លាស់ប្ដូរនូវភាពស៊ាំខ្លះក៏ដោយ
- ភាពស៊ាំទៅនឹង NVP
    - ត្រូវការតែមួយក៏រិតទេ ធ្វើឱ្យវីរុសអេដស៏មានការប្រែប្រួលយ៉ាងឆាប់រហ័ស
    - មានភាពស៊ាំទាំងអស់តែម្ដង
    - មានលទ្ធផលផ្ទុយពី EFV

## ឱសថប្រឆាំងមេរោគអេដស៏ក្រុមទី១: ផលរំខានបន្ទាប់បន្សំ

### ផលវិបាកនេះតែងតែកើតឡើងនៅខែដំបូងនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៏

ផលរំខានបន្តិចបន្តួចដែលកើតមានជាធម្មតា:
- ចង្អោរ រាក ឈឺក្បាល ហត់ ឈឺពោះ គេងមិនលក់

ផលរំខានធ្ងន់ធ្ងរ:
- 3TC: កំរឱ្យមានផលរំខានធ្ងន់ធ្ងរណាស់
- D4T: peripheral neuropathy: ស្ពឹកឬ ចាក់ឆ្អៀបៗនៅ ដៃ ឬ ជើង
- NVP: រមាស់កន្ទួលក្រហម ពុលថ្លើម (ស្បែកលឿង ចង្អោរ ឈឺពោះ អស់កំលាំង ក្ដៅខ្លួន )
- AZT: ស្លេកស្លាំងខ្លាំង (អស់កំលាំង ហត់ ស្លាំង)
- EFV: រមាស់កន្ទួលក្រហមខ្លាំង ពុលថ្លើម វង្វេងវង្វាន់ឬក្រៀមក្រំក្នុងចិត្តមិនដឹងមូលហេតុ។ ហាមប្រើចំពោះស្ត្រីមានផ្ទៃពោះ (ធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់របស់ទារកក្នុងផ្ទៃ)

> ស្ត្រីមានផ្ទៃពោះដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៏ហើយមានចេញនូវរោគសញ្ញា គ្រូពេទ្យនៅសេវា OI/ARTគួរតែពិនិត្យឡើងវិញ ដើម្បីធ្វើការវាយតំលៃ ថាតើរោគសញ្ញានោះបណ្ដាលមកពីការប្រើ ឱសថប្រឆាំងមេរោគអេដស៏ ឬ ឱសថព្យាបាលជម្ងឺឱកាសនិយម ឬ បណ្ដាលមកពីមានផ្ទៃពោះ។

# ជំងឺឱកាសនិយមមួយចំនួន និង ការបង្ការជំងឺឱកាសនិយម

## *Pneumocystis carinii* Pneumonia (PCP)

- គឺជាជម្ងឺសួតធ្ងន់ធ្ងរគំរាមកំហែងដល់ជីវិត បណ្តាលមកពីមេរោគផ្សិតឈ្មោះ Pneumocystis Carinii (គេហៅម្យ៉ាងទៀតថា Pneumocystis Jirovecii)។
- វាធ្វើអោយប៉ះពាល់ធ្ងន់ធ្ងរដល់អ្នកជម្ងឺអេដស៍ដែលមាន CD4 ទាប (តិចជាង ២០០ /មម$^{៣}$) ដែល មិនបានប្រើឱសថបង្ការជម្ងឺ PCP
- វាបង្ហាញឡើងដោយមានក្អកស្ងួតបន្តិចម្តងៗ ក្តៅខ្លួន និង ហត់ខ្លាំងពេលខំប្រឹង
- ជម្ងឺនេះមិនឆ្លើយតបទៅនឹងការព្យាបាលដោយប្រើអង់ទីប៊ីយ៉ូទីកទេ
- គេព្យាបាលជម្ងឺនេះដោយប្រើ កូទ្រីម៉ុកសាសុល ក៏រិតខ្ពស់រយៈពេល ៣អាទិត្យ រួមជាមួយ Steroide បើសិនជា អ្នកជម្ងឺអេដស៍មានសភាពធ្ងន់ធ្ងរខ្លាំង។
- ការព្យាបាលនឹងទទួលជោគជ័យបាន លុះត្រាតែគោរពតាមការបង្ការទី២ ដើម្បីជៀសវាងនូវការលាប់ឡើងវិញ។

## ការបង្ការជម្ងឺ PCP

- **ការបង្ការទី១:** ត្រូវផ្តល់ឱ្យអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ ដែលមាន:
  - ជម្ងឺអេដស៍វិវត្តទៅមុខ (ដំណាក់កាលទី ២, ៣ ឬ ៤ របស់អង្គការសុខភាពពិភពលោក)
  - កោសិកា CD4 តិចជាង ២០០/មម$^{៣}$ ឈាម
- **ការបង្ការទី២:** ត្រូវផ្តល់ឱ្យអ្នកជម្ងឺដែលកំពុងតែព្យាបាលជម្ងឺ PCP
- ការបង្ការគឺការផ្តល់ cotrimozaxol ៩៦០ mg ក្នុង១ថ្ងៃ។ cotrimozaxol អាចបង្ការផងដែរនូវជម្ងឺ ឆ្លងដែលបង្កឡើងដោយ Bacteria ខ្លះៗ និង toxoplasmosis
- ការបង្ការត្រូវធ្វើរហូតអស់១ជីវិត ឬរហូតដល់អ្នកជម្ងឺអេដស៍ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍ មាន CD4>២០០ /មម$^{៣}$ ឈាមក្នុងរយៈពេល៦ខែយ៉ាងតិច
- ជម្ងឺ PCP នឹងមិនអាចកើតមានបានទេ បើសិនជាអ្នកជម្ងឺបានទទួលការព្យាបាលបង្ការត្រឹមត្រូវ។

## ជម្ងឺរលាកស្រោមខួរបង្កដោយមេរោគ Cryptocoque

- គឺជាជម្ងឺបង្កឡើងដោយមេរោគផ្សិតដែលគំរាមកំហែងដល់ជីវិតរបស់អ្នកជម្ងឺអេដស៍ញឹកញាប់ជាងគេបំផុត។
- វាកើតនៅលើអ្នកជម្ងឺអេដស៍ដែលមានការវិវត្តន៏ទៅមុខ ជាទូទៅ CD4< ៥០ /មម$^{៣}$ ឈាម។
- ប្រហែល៩០% នៃករណីជម្ងឺឆ្លងដោយសារមេរោគ Cryptocoque នេះ សែ្តងចេញជាជម្ងឺរលាក ស្រោមខួរក្បាល, រួមជាមួយនឹងឈឺក្បាលជាប់ជាប្រចាំ កើនឡើងជាលំដាប់ ឈឺច្រើនថ្ងៃ ច្រើន អាទិត្យ ឬច្រើនជាងនេះទៅទៀត, មានក្អួត និង ជួនមានស្មារតី ជួនបាត់ស្មារតី។
- គេព្យាបាលជម្ងឺនេះដោយ Amphotericin B ចាក់តាមសរសៃ ក្នុងរយៈពេល ២-៣ សប្តាហ៍ រួមជា មួយនឹង Fluconazole គ្រាប់ក្នុងរយៈពេល៨សប្តាហ៍។
- ការព្យាបាលទទួលបានជោគជ័យលុះត្រាតែគោរពតាមការបង្ការទី២ដើម្បីជៀសវាងនូវការលាប់ឡើងវិញ។

## ការបង្ការជម្ងឺ PCP

- **ការបង្ការទី១:** ត្រូវផ្តល់ឱ្យអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ ដែលមាន:
  - ❖ ជម្ងឺអេដស៍វិវត្តទៅមុខ (ដំណាក់កាលទី ២, ៣ ឬ ៤ របស់អង្គការសុខភាពពិភពលោក)
  - ❖ កោសិកា CD4 តិចជាង ២០០/មម$^{៣}$ ឈាម
- **ការបង្ការទី២:** ត្រូវផ្តល់ឱ្យអ្នកជម្ងឺដែលកំពុងតែព្យាបាលជម្ងឺ PCP
- ការបង្ការគឺការផ្តល់ cotrimozaxol ៩៦០ mg ក្នុង១ថ្ងៃ។ cotrimozaxol អាចបង្ការផងដែរនូវជម្ងឺ ឆ្លងដែលបង្កឡើងដោយ Bacteria ខ្លះៗ និង toxoplasmosis
- ការបង្ការត្រូវធ្វើរហូតអស់១ជីវិត ឬរហូតដល់អ្នកជម្ងឺអេដស៍ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍ មាន CD4>២០០ /មម$^{៣}$ ឈាមក្នុងរយៈពេល៦ខែយ៉ាងតិច
- ជម្ងឺ PCP នឹងមិនអាចកើតមានបានទេ បើសិនជាអ្នកជម្ងឺបានទទួលការព្យាបាលបង្ការត្រឹមត្រូវ។

**សម្គាល់: ជំងឺ** *Pneumocystis carinii* គេហៅម្យ៉ាងទៀតថា *Pneumocystis jirovecii*

# ជំងឺឱកាសនិយមមួយចំនួន និង ការបង្ការជំងឺឱកាសនិយម (ត)

## ជំងឺរបេង (TB)

- ជំងឺរបេងជាជំងឺឱកាសនិយមដែលកើតមានញឹកញាប់ និង ជាមូលហេតុចំបងនៃការស្លាប់របស់អ្នកផ្ទុកមេរោគអេដស៍ ទាំងនៅលើពិភពលោក និង នៅប្រទេសកម្ពុជា។
- មេរោគអេដស៍មិនទាក់ទងទៅនឹងអត្រាខ្ពស់នៃជំងឺរបេងឡើយ ។ក៏ប៉ុន្តែ ការថយចុះនូវភាពស៊ាំដែលបណ្តាលមកពីមេរោគអេដស៍ ធ្វើឱ្យអ្នកជំងឺដែលមានផ្ទុកមេរោគអេដស៍ប្រឈមមុខយ៉ាងខ្លាំងទៅរកការវិវត្តន៍ជាជំងឺរបេងសកម្ម ។
- ជំងឺរបេងអាចកើតមានគ្រប់ដំណាក់កាលនៃជំងឺអេដស៍ ។ ប៉ុន្តែការចេញរោគសញ្ញាគ្លីនិកមានភាពប្រែប្រួល និង ឆ្លុះបញ្ចាំងពីកំរិតចុះខ្សោយនៃប្រព័ន្ធភាពស៊ាំ ។
- ការព្យាបាលដូចគ្នានឹងការព្យាបាលរបស់អ្នកដែលមិនមានផ្ទុកមេរោគអេដស៍ដែរ ។ ប៉ុន្តែ អត្រានៃផលរំខាន បន្ទាប់បន្សំ ការលាប់ឡើងវិញ ការឆ្លងជំងឺឡើងវិញ និង ការស្លាប់ មានកំរិតខ្ពស់ជាងអ្នកដែលមិនមានផ្ទុកមេរោគអេដស៍ ។

## ការចេញរោគសញ្ញាគ្លីនិក (១)

- ជំងឺរបេងសួត (PTB) ស្តែងចេញដោយមានក្តៅខ្លួនលើសពី ៣សប្តាហ៍ រួមនិងក្អក និង ចុះទំងន់ រសាប់រសល់ បែកញើសពេលយប់ បាយមិនបាន ។
- រោគវិនិច្ឆ័យពឹងផ្អែកទៅលើការរាវរកនូវ Acid Fast bacill(AFB) នៅក្នុងកំហាក

នេះគឺជា Smear-positive របស់ជំងឺរបេងសួត

(ចូរចាំថា ចំពោះអ្នកជំងឺអេដស៍ ករណីនៃ Smear-negative របស់ជំងឺរបេងសួតមានចំនួនកើនឡើង) ។

## ការចេញរោគសញ្ញាគ្លីនិក (២)

- **ជំងឺរបេងក្រៅសួត** តែងជួបប្រទះញឹកញាប់លើអ្នកជំងឺអេដស៍ជាពិសេស នៅពេលដែល CD4 ធ្លាក់ចុះទាប ។
- សណ្ឋានជំងឺរបេងក្រៅសួតដែលជួបប្រទះញឹកញាប់ជាងគេគឺជាជំងឺរបេងកូនកណ្តុរ
  - កូនកណ្តុរនៅសងខាងសរសៃទឹករងៃៈមានកូនកណ្តុរ និងក្តៅខ្លួន និងមានស្រកទំងន់
  - កូនកណ្តុរនៅពោះ: ឈឺពោះ ក្តៅខ្លួនស្រកទំងន់ និង ពេលខ្លះមានរាក
- ទំរង់ផ្សេងទៀត រួមមាន: ទឹកក្នុងស្រោមសួត និង រលាកស្រោមខួរក្បាល ឬក៏អាចប៉ះពាល់របូត ដល់ខួរក្បាល បេះដូង ឆ្អឹងខ្នង ឬឆ្អឹងដទៃទៀត និង សន្លាក់
- ជាទូទៅគេធ្វើរោគវិនិច្ឆ័យដោយសន្និដ្ឋាន ពីព្រោះវាមានការពិបាកនឹងរក AFBs ។

## ការព្យាបាលជំងឺរបេង

- **ការព្យាបាល:** តម្រូវឱ្យមានឱសថច្រើនមុខសំរាប់រយៈពេលព្យាបាលយូរ ធម្មតាឱសថ ៤មុខសំរាប់រយៈពេល២ខែ ហើយបន្តមកទៀត គឺឱសថ២មុខ សំរាប់រយៈពេល ៤ខែ ។
  - របបឱសថនេះគឺប្រើដូចគ្នាសំរាប់ព្យាបាលអ្នកផ្ទុកមេរោគអេដស៍និងអ្នកគ្មានផ្ទុកមេរោគអេដស៍
  - វាអាចកើតមាននូវភាពប្រឆាំងគ្នារវាងឱសថព្យាបាលជំងឺរបេង និងឱសថ ARV
  - បើសិនជាអ្នកជំងឺកំពុងទទួលការព្យាបាលជំងឺរបេង អាចផ្អាក ART ឬក៏ប្តូរឱសថ ARV *

*EFV អាចប្រើបានជាមួយនឹងការព្យាបាលជំងឺរបេង ការព្យាបាលស្ត្រីមានផ្ទៃពោះ ហើយមានជំងឺរបេងមានការពិបាកក្នុងការផ្តល់នូវការណែនាំពិសេសសំរាប់ធ្វើ ART

# ជំងឺឱកាសនិយមមួយចំនួន និង ការបង្ការជំងឺឱកាសនិយម (ត)

## សញ្ញានិងរោគសញ្ញាដែលកើតមានញឹកញាប់លើកុមារផ្ទុកមេរោគអេដស៍

រោគសញ្ញាទាំងនេះអាចឃើញមានចំពោះកុមារដែលមិនឆ្លងមេរោគអេដស៍ដែរ:

- មានទម្ងន់ទាប និងមិនសូវមានការលូតលាស់
- មានជម្ងឺអំបៅអំបែកជារឿយៗ
- រាកជាប្រចាំ
- មានជម្ងឺរបេង

រោគសញ្ញាដែលមិនសូវឃើញមានចំពោះកុមារធម្មតា:

- ជម្ងឺរលាកសាច់សួត (PCP)
- ជម្ងឺផ្សិតក្នុងមាត់
- ហើមកូនកណ្ដុរ
- ហើមក្រពេញចំរូទឹត

## ការផ្តល់កូទ្រីម៉ុកសាសុលដល់កុមារផ្ទុកមេរោគអេដស៍ដើម្បីបង្ការ

កូទ្រីម៉ុកសាសុលប្រើបង្ការជម្ងឺឱកាសនិយមដើម្បីប្រឆាំងនឹង:

- ជម្ងឺរលាកសាច់សួត (PCP)
- ជម្ងឺខួរក្បាលដោយ Cerebral Toxoplasmosis
- ជម្ងឺឆ្លងដោយពួកបាក់តេរីផ្សេងៗ

ជម្ងឺរលាកសាច់សួត (PCP)

- ជម្ងឺរលាកសាច់សួតនៃមេរោគអេដស៍បណ្ដាលមកពី Pneumocystis Carinii
- ជាមូលហេតុនៃការស្លាប់របស់កុមារដែលផ្ទុកមេរោគអេដស៍ ដែលបង្ហាញជារោគសញ្ញា ក្អក គ្រុន និងដកដង្ហើមញាប់ហើយខ្លីៗ
- មិនអាចព្យាបាលដោយពួកអង់ទីប៊ីយ៉ូទិកដែលធ្លាប់ប្រើជាធម្មតាបានឡើយ

ជម្ងឺខួរក្បាលដោយ Cerebral Toxoplasmosis

- ជាជម្ងឺខួរក្បាលបណ្ដាលមកពី Toxoplasma Gondii
- មានរោគសញ្ញាប្រកាច់ និងសញ្ញាជម្ងឺខួរក្បាលសំខាន់ៗដទៃទៀត

## ការផ្តល់កូទ្រីម៉ុកសាសុលដល់កុមារផ្ទុកមេរោគអេដស៍ដើម្បីបង្ការ

| កំរិតនៃកូទ្រីម៉ុសាសុល | ចាប់ផ្តើម | បញ្ឈប់នៅពេលណា |
|---|---|---|
| គ្រាប់ = 480mg<br>ស៊ីរ៉ូ = 240 mg/5ml<br>ឱ្យម្តងក្នុងមួយថ្ងៃ<br><br>5-9kg ½ គ្រាប់ ឬ 5ml<br>10-14kg 1 គ្រាប់ ឬ 10ml<br>15-24kg 1½ គ្រាប់ ឬ 15ml<br>>25kg 2 គ្រាប់ ឬ 20ml | ការបង្ការដំបូង | |
| | ១-កុមារប្រឈមមានអាយុ៦ខែ<br>២-កុមារផ្ទុកមេរោគអេដស៍<br>មាន CD4<15% | ១-បើសិនជាលទ្ធផល(-)<br>២-អាយុ១២ខែ បើសិនគ្មានរោគសញ្ញា<br>៣-បើ CD4>15% ២ដងក្នុងចន្លោះពេល៦ខែម្តង |
| | ការបង្ការបន្ទាប់: បន្ទាប់ពីធ្វើរោគវិនិច្ឆ័យឃើញមាន PCP ត្រូវឱ្យអស់មួយជីវិត | |

# ៤.៣.២

# ការថែទាំនៅពេលមានផ្ទៃពោះ  ពេលឈឺពោះសម្រាលនិងសម្រាល ការថែទាំក្រោយសម្រាល  និងការតាមដានថែទាំបន្ត

## វត្ថុបំណង

នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមទាំងអស់អាចនឹង:
១. ពិភាក្សាការគ្រប់គ្រងស្ត្រីផ្ទុកមេរោគអេដស៍នៅពេលមានផ្ទៃពោះ
២. អធិប្បាយអំពីនីតិវិធីនៃការបញ្ជូនស្ត្រីទៅសេវាផ្សេងៗ
៣. ពន្យល់អំពីការគ្រប់គ្រងស្ត្រីផ្ទុកមេរោគអេដស៍នៅពេលឈឺពោះសម្រាលនិងសម្រាល
៤. ពិភាក្សាអំពីការគ្រប់គ្រងស្ត្រីដែលមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍នៅពេលឈឺពោះសម្រាល និង សម្រាល
៥. អធិប្បាយអំពីសមាសភាគសំខាន់ៗនៃការថែទាំភ្លាមៗដល់ទារកដែលទើបនឹងកើត
៦. រៀបរាប់និងអធិប្បាយអំពីសមាសភាគសំខាន់ៗនៃការថែទាំក្រោយពេលសម្រាលដល់ម្តាយនិងកូនរបស់គាត់



*រយៈពេល: **៣ម៉ោង២០នាទី***

# សកម្មភាពទី១: ពាក្យគន្លឹះ: អន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននិងការថែទាំផ្ទៃពោះ

» គ្រូនឹងស្នើឱ្យសិក្ខាកាមធ្វើការជាគូនិងរៀបរាប់អំពីសារៈសំខាន់នៃព័ត៌មានដែលស្ត្រីមានផ្ទៃពោះគួរទទួលបាននៅថ្នាក់អប់រំម្តាយនៅឯសេវាថែទាំផ្ទៃពោះ

## ការបញ្ជ្រាបសេវាថែទាំផ្ទៃពោះ

- សេវាថែទាំផ្ទៃពោះ គឺជាប្រភពថែទាំសុខភាពមួយដ៏សំខាន់ និងផ្តល់នូវគុណប្រយោជន៍នៃសុខភាពដល់ម្តាយនិងគ្រួសាររបស់គាត់ ។
- គ្រប់ស្ត្រីមានផ្ទៃពោះ ងាយប្រឈមនឹងការឆ្លងមេរោគអេដស៍ណាស់
- ការដាក់រួមបញ្ចូលសេវា PMTCT ចូលទៅក្នុងសេវាថែទាំផ្ទៃពោះអាចផ្តល់ប្រយោជន៍ដល់ស្ត្រីមានផ្ទៃពោះព្រមទាំងកូនរបស់គាត់ឱ្យទទួលបាននូវសេវាថែទាំសុខភាពកាន់តែប្រសើរឡើង
- ស្ត្រីមានសុខភាពល្អអាចថែរក្សាកូនរបស់គាត់បានយ៉ាងប្រសើរ ។

7

## សមាសភាគនៃការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅផ្នែកថែទាំផ្ទៃពោះ

គ្រប់ស្ត្រីមានផ្ទៃពោះទាំងអស់ដែលបានមកទទួលសេវាថែទាំផ្ទៃពោះ គួរតែទទួលបាននូវៈ

- ព័ត៌មាននិងការអប់រំសុខភាព
- ការអប់រំស្តីអំពីសុវត្ថិភាពនៃការរួមភេទនិងមេរោគអេដស៍-ជម្ងឺអេដស៍
- ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍-រួមទាំងដៃគូ
- អន្តរាគមន៍ដើម្បីកាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ប្រសិនបើចាំបាច់
- ការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូន
- ការធ្វើរោគវិនិច្ឆ័យនិងព្យាបាលជម្ងឺកាមរោគ
- ព័ត៌មានស្តីពីផែនការគ្រួសារ
- គំនិតផ្តួចផ្តើមស្តីពីមាតុភាពគ្មានគ្រោះថ្នាក់រួមទាំងការព្យាបាលជម្ងឺរបេង និងជម្ងឺគ្រុនចាញ់ ( នៅតំបន់រាតត្បាត ) ផង ។

8

## ការគ្រប់គ្រងស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍នៅសេវាថែទាំផ្ទៃពោះ

- បើសិនដឹងថាស្ត្រីម្នាក់មានផ្ទុកមេរោគអេដស៍ ត្រូវបញ្ជូនស្ត្រីនោះទៅរកសេវាព្យាបាលជម្ងឺឱកាសនិយម និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (OI-ARV) ដើម្បីវាយតម្លៃពីភាពអាចទទួលបាននូវការព្យាបាល ART នេះឱ្យបានឆាប់បើអាចធ្វើបាន
- បើសិនជាស្ត្រីគ្រប់ល័ក្ខខ័ណ្ឌនឹងទទួលបានឱសថប្រឆាំងមេរោគអេដស៍, សេវា (OI/ART) ត្រូវផ្តល់ការព្យាបាលដល់ស្ត្រី រួមជាមួយនឹងការតាមដានការប្រើប្រាស់ឱសថផង និងផ្សារភ្ជាប់ជាមួយសេវាថែទាំបន្តដទៃទៀត
- បើសិនជាមិនទាន់គ្រប់ល័ក្ខខ័ណ្ឌនឹងទទួលបានការព្យាបាលទេ សេវា OI/ART ឬអតីតមន្ទីរពេទ្យស្រុក ត្រូវផ្តល់ជូនឱសថ ARV ដើម្បីបង្ការដល់ស្ត្រីមានផ្ទៃពោះ ចាប់ពីពេលដែលផ្ទៃពោះមានអាយុ២៨សប្តាហ៍ឡើងទៅ និងផ្សារភ្ជាប់ជាមួយនឹងសេវាថែទាំបន្តដទៃទៀត
- គ្រប់ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ទាំងអស់ ត្រូវបានណែនាំឱ្យទៅសំរាលកូននៅកន្លែងដែលមានសេវា PMTCT

9

## សកម្មភាពទី២: ករណីសិក្សា: ការផ្តល់សេវា PMTCTដល់ស្ត្រីមានផ្ទៃពោះ

- គោលបំណងនៃសកម្មភាពនេះ គឺដើម្បីរំលឹកឡើងវិញអំពីការគ្រប់គ្រងថែទាំផ្ទៃពោះ ក្នុងបរិបទនៃស្ត្រីផ្ទុកមេរោគអេដស៍
- គ្រូនឹងចែកក្រដាសថតចម្លងនៃករណីសិក្សាឱ្យទៅអ្នកសម្រាប់អាន
- អ្នកស្ម័គ្រចិត្តម្នាក់ត្រូវឡើងអានករណីសិក្សាមួយភាគម្តង១ បន្ទាប់មកសិក្ខាកាមទាំងអស់ជាអ្នកឆ្លើយសំណួរ
- ត្រូវពិភាក្សានូវសំណួរនីមួយ១
- ចូរអ្នកគិតថា តើមានដែលជួបបទពិសោធន៍ស្រដៀងគ្នាដែរឬទេ នៅកន្លែងធ្វើការរបស់អ្នក?
- តើវិធានការណ៍នៃការគ្រប់គ្រងបានធ្វើដូចគ្នានឹងករណីសិក្សាដែរឬទេ?

| ករណីសិក្សាលើស្ត្រីមានផ្ទៃពោះ | |
|---|---|
| ភាគ ១ | "ណាណា" អាយុ២២ឆ្នាំមានផ្ទៃពោះជាលើកទី១ ។<br>នាងបានមកសេវាថែទាំផ្ទៃពោះនៅពេលដែលគភ៌មានអាយុ២៤អាទិត្យ ។<br>បន្ទាប់ពីស្តាប់ការអប់រំនៅបន្ទប់អប់រំម្តាយមក នាងបានសម្រេចចិត្តទទួលការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ។ |
| ស ១ | តើអ្នកផ្តល់ប្រឹក្សាត្រូវចាត់វិធានការយ៉ាង ដូចម្តេចខ្លះ? |
| ភាគ ២ | "ណាណា" បានត្រឡប់មកទទួលការផ្តល់ប្រឹក្សាក្រោយតេស្តនៅថ្ងៃបន្ទាប់ ។ នាងមានផ្ទុកមេរោគអេដស៍ ។ |
| ស២ | តើវិធានការអ្វីដែលគួរធ្វើ ដើម្បីគ្រប់គ្រងថែទាំស្ត្រីនៅពេលមានផ្ទៃពោះក្នុងពេលបច្ចុប្បន្ននេះ? |
| ភាគ ៣ | " ណាណា" បានទៅទទួលសេវា OI/AR ។ កោសិកា CD4 របស់នាងមាន៣៥០/មម៣ |
| ស ៣ | តើ "ណាណា" គួរទទួលបាននូវការណែនាំអ្វីខ្លះ? |

## សកម្មភាពទី៣: លំហាត់: នីតិវិធីបញ្ជូននិងទម្រង់បែបបទ

- គោលបំណងនៃលំហាត់នេះ គឺដើម្បីអនុវត្តបំពេញ:

១- ក្រដាសកត់ត្រាការផ្តល់ប្រឹក្សា

២- កាតសម្រាប់ណាត់ជួប

៣- កាតសម្រាប់បញ្ជូន ( VCCT, PMTCT និង របេង)

៤- ទម្រង់បែបបទមន្ទីរពិសោធន៍

( មាននៅក្នុងឧបសម្ព័ន្ធនៃម៉ូឌុលនេះ)

- គ្រូនឹងចែកក្រដាសថតចម្លងនៃទម្រង់បែបបទនិងកាតទៅអ្នក ។អ្នកត្រូវធ្វើការជាក្រុមដែលមានគ្នាពី៤-៥ នាក់ ដើម្បីបំពេញទម្រង់ទាំងនោះ

## សកម្មភាពទី៤: ករណីសិក្សា: ការគ្រប់គ្រងស្ត្រីផ្ទុកមេរោគអេដស៍

- គោលបំណងនៃលំហាត់នេះគឺដើម្បីពិនិត្យឡើងវិញពីការគ្រប់គ្រងស្ត្រីផ្ទុកមេរោគអេដស៍នៅពេលសម្រាល
- ការពិភាក្សាត្រូវយោងតាមករណីសិក្សាដែលបានចែកជូន
- អ្នកស្ម័គ្រចិត្តនឹងអានប្រយោគនីមួយ១និងសំណួរនីមួយ១
- គ្រូនឹងសួរទៅក្រុមឱ្យឆ្លើយនឹងសំណួរនិងឱ្យចូលរួមក្នុងការពិភាក្សា

## ករណីសិក្សា: នៅអគារសម្ភព

| ផ្នែកសម្ភព : ករណីសិក្សា:១ | |
|---|---|
| ភាគ១ | "ណាណា" បានមកដល់ផ្នែកសម្ភពនៅពេលឈឺពោះសម្រាល ។ អ្នកបានពិនិត្យបញ្ជីកត់ត្រាឃើញថា នាងមានផ្ទុកមេរោគអេដស៍និងបានទទួល**AZT** ដែលជាឱសថបង្ការប្រឆាំងមេរោគអេដស៍ ។ នាងនិយាយថា នាងឈឺពោះកាន់តែខ្លាំងឡើងៗ និងឈឺម្តងៗមានរយៈពេលប្រហែល៤នាទី ។អ្នកបានពិនិត្យមាត់ស្បូននិងធ្វើការសន្និដ្ឋានថា យ៉ាងហោចណាស់ក៏ជាង២ម៉ោងទៀតដែរទើប "ណាណា" សម្រាលកូន ។ អ្នកផ្តល់ថ្នាំ **NVP**១កម្រិតទៅឱ្យនាងនៅពេលកំពុងឈឺពោះ ។ |
| ស ១.១ | តើអ្នកត្រូវប្រើស្រោមដៃដែរឬទេ នៅពេលពិនិត្យអ្នកជំងឺដែលមានផ្ទុកមេរោគអេដស៍? តាមគោលការណ៍បង្ការជាសកល តើតម្រូវឱ្យអ្នកប្រើស្រោមដៃសម្រាប់ពិនិត្យគ្រប់ស្ត្រីដែលមកសម្រាល ដូចៗគ្នាដែរឬទេ គិតទាំងពេលកំពុងឈឺពោះសម្រាលនិងសម្រាល ដោយមិនគិតអំពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ស្ត្រី? |
| ស ១.២ | តើនៅទីកន្លែងធ្វើការរបស់អ្នកមានផ្គត់ផ្គង់ស្រោមដៃបានគ្រប់គ្រាន់ដែរឬទេ? តើស្រោមដៃទាំងនោះមានទំហំផ្សេងៗស្របទៅនឹងទំហំដៃដែរឬទេ? |
| ស ១.៣ | តើយើងអាចដឹងអំពីទំនាក់ទំនងរវាងការចម្លងមេរោគអេដស៍ពីម្តាយទៅកូននិងការពិនិត្យមាត់ស្បូនយ៉ាងដូចម្តេចខ្លះ ចំពោះស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ ? |
| ភាគ២ | "ណាណា"បានបែកស្រោមទឹកពោះភ្លោះអស់រយៈពេលជាង៤ម៉ោងមកហើយ ។ នាងអស់កម្លាំងជាខ្លាំង ។ បន្ទាប់ពីការពិនិត្យតាមរយៈ Partogram របស់នាងគ្រូពេទ្យបានសម្រេចចិត្តប្រើOxytocin ដើម្បីឱ្យនាងឆាប់បានសម្រាលកូន ។ |
| ស ២.១ | តើហេតុអ្វីបានជាចាំបាច់បង្រួញពេលវេលានៃការសម្រាល គិតចន្លោះពីពេលបែកស្រោមទឹកភ្លោះនិងការសម្រាលចំពោះស្ត្រីមានផ្ទុកមេរោគអេដស៍? |
| ភាគ៣ | ឥឡូវនេះមាត់ស្បូន"ណាណា"បានបើកទាំងស្រុងត្រៀមនឹងសម្រាលហើយ ។ នៅពេលដែលក្បាលកូនលូនចេញមក អ្នកបានយកស្បៃជូតទឹករំអិលក្នុងមាត់និងរន្ធច្រមុះកូនយ៉ាងប្រុងប្រយ័ត្ន ។ បន្ទាប់ពីប្រឹងជាលើកចុងក្រោយ កូនក៏បានសម្រាលចេញមក ។ អ្នកបានហុចកូនទៅអ្នកជំនួយការដែលមានពាក់ស្រោមដៃដែលជាអ្នកជូតសំងួតនឹងថែទាំទារកបន្ត ។ បន្ទាប់មកសុកក៏ធ្លាក់ចេញ ។ |
| ស ៣.១ | ចូររាប់សំលៀកបំពាក់ការពារដែលសមស្របសម្រប់ប្រើនៅផ្នែកសម្រាល ។ |
| ស ៣.២ | សូមត្រិះរិះពិចារណាអំពីការបោះចោលវត្ថុមុតស្រួចនៅផ្នែកសម្រាលដែលបានប្រើរួចហើយ ។ តើនៅមន្ទីរពេទ្យរបស់អ្នកមានប្រអប់សុវត្ថិភាពឬធុងសម្រាប់ទុកដាក់វត្ថុទាំងនេះដែរឬទេ.? |
| ស ៣.៣ | តើនៅមន្ទីរពេទ្យរបស់អ្នកមានគោលការណ៍ស្តីអំពីការបោះចោលសម្រាមដែរឬទេ? តើអ្នកត្រូវបោះចោលសុកនិងសម្ភារៈដទៃទៀតយ៉ាងដូចម្តេច? |
| ភាគ៤ | "ណាណា" គឺជាស្ត្រីទី៨ហើយដែលអ្នកបានសម្រាលកូនឱ្យក្នុងរយៈពេល២៤ម៉ោងកន្លងទៅនេះ ។ អ្នកត្រូវត្រឡប់ទៅផ្ទះនិងជួបជុំគ្រួសារ ។ ក៏ប៉ុន្តែ អ្នកដែលត្រូវបន្តវេនពីអ្នកមិនទាន់មកដល់ ។ អ្នកបាននិយាយស្នើទៅកាន់ប្រធានរបស់អ្នកឱ្យជួយរកអ្នកណាម្នាក់មកជំនួសអ្នក ។ |
| ស ៤.១ | តើអ្នកមានអារម្មណ៍យ៉ាងណាដែរ នៅពេលដែលប្រធានរបស់អ្នកថាអ្នកអាចទៅផ្ទះបាន? |
| ស ៤.២ | នៅកន្លែងធ្វើការរបស់អ្នក តើមានអ្នកណាដែលអាចជួយអ្នកក្នុងការរកបុគ្គលិកមកជំនួសការងារអ្នកដែរឬទេ ប្រសិនជាមានការចាំបាច់? |

# សកម្មភាពទី៥៖ រំលឹកឡើងវិញ៖ ការគ្រប់គ្រងស្ត្រីផ្ទុកមេរោគអេដស៍នៅពេលឈឺពោះសម្រាល

» ស្លាយទី១៤-២០ ដែលរំលឹកអំពីនីតិវិធីសម្រាប់គ្រប់គ្រងដល់ស្ត្រីនៅពេលឈឺពោះសម្រាល

## ការចម្លងមេរោគអេដស៍នៅពេលឈឺពោះសំរាលនិងសំរាល

- គ្រោះប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅពេលឈឺពោះសំរាល និង សំរាល មានប្រហែល១៥ភាគរយ
- ការចម្លងនេះកើតឡើងបាននៅពេលដែលទារកប៉ះផ្ទាល់នឹងឈាមនិងសារធាតុរាវរបស់ម្តាយ
- ការប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូនក្នុងកំឡុងពេលឈឺពោះសំរាល និង សំរាល អាចកាត់បន្ថយបានដោយ:
  - អនុវត្តជាប្រចាំនូវការបង្ការជាសកល
  - អនុវត្តការសំរាលដែលប្រកបដោយសុវត្ថិភាពដល់គ្រប់ស្ត្រីទាំងអស់ ។

14

## ការបង្ការជាសកលនៅពេលឈឺពោះសំរាលនិងសំរាល(១)

- បិទមុខរបួសនៅលើស្បែក ឬមុខរបួសចំហ * ដោយបង់ស្អិតដែលមិនជ្រាបទឹក
- ពាក់ស្រោមដៃនៅពេលដែលធ្វើការប៉ះពាល់នឹងឈាម ឬសារធាតុរាវរបស់សរីរាង្គ
- ពាក់អាវប្លាស្ទិកដែលមិនជ្រាបទឹកនៅពេលធ្វើការសំរាល
- ប្រសិនបើមានឈាមខ្ទាតប្រឡាក់លើស្បែក ត្រូវប្រញាប់លាងនឹងទឹកនិងសាប៊ូ ។ ប្រសិនជាខ្ទាតចូលភ្នែក ត្រូវលាងភ្នែកជាមួយនឹងទឹកតែប៉ុណ្ណោះ ។
- បោះចោលកាកសំណល់រឹង ( ឧ: ក្រណាត់ប្រឡាក់ឈាមជោក និង សុក) ឱ្យមានសុវត្ថិភាព ដោយអនុវត្តទៅតាមគោលការណ៍នៃមូលដ្ឋាន

* អ្នកមានជម្ងឺសើស្បែក មិនគួរធ្វើការនៅផ្នែកសម្ភពឡើយ

15

## ការបង្ការជាសកលនៅពេលឈឺពោះសំរាលនិងសំរាល (២)

- ពាក់វ៉ែនតាសំរាប់ការពារភ្នែកនៅពេលធ្វើការសំរាលដោយវះកាត់ និងនៅពេលដេរទ្វារ (episiotomy)
- ប្រើស្រោមដៃកវែង នៅពេលធ្វើការសំអាតសុក
- ក្នុងករណីចាំបាច់ដែលត្រូវធ្វើ Episiotomy ត្រូវប្រើម្ជុលកោងដែលមានទំហំល្មម (លេខ២១ ប្រវែង៤ ស.ម) នៅពេលដេរសាឡើងវិញ
- ប្រើប្រដាប់សំរាប់ចាប់ម្ជុល មិនត្រូវចាប់ដោយដៃទេ
- រាល់វត្ថុមុតស្រួចដែលហុចទៅអ្នកទទួល មិនត្រូវហុចដោយដៃផ្ទាល់ទេ

16

## អនុវត្តការសំរាលកូនដែលមានសុវត្ថិភាព

- ប្រើឱសថ **ARV** ដើម្បីបង្ការឬព្យាបាលនៅពេលឈឺពោះសំរាលដោយយោងទៅតាមពិធីសារ
- កាត់បន្ថយការពិនិត្យមាត់ស្បូនឱ្យបានកំរិតអប្បបរមា
- ជៀសវាងការទុកឱ្យស្ត្រីឈឺពោះសំរាលយូរ
- ជៀសវាងការបំបែកស្រោមទឹកភ្លោះជាប្រចាំ
- ជៀសវាងការធ្វើឱ្យប៉ះទង្គិចខ្លាំងនៅពេលសំរាល
- កាត់បន្ថយគ្រោះប្រឈមនឹងការធ្លាក់ឈាមក្រោយសំរាលឱ្យបានកំរិតអប្បបរមា
- ផ្តល់ឈាមឱ្យស្ត្រីតែនៅពេលណាចាំបាច់ និងប្រើតែឈាមណាដែលបានពិនិត្យរកមេរោគអេដស៍រួចប៉ុណ្ណោះ

17

## វិធីសំរាលកូន

ការសំរាលកូនដោយវះកាត់ អាចកាត់បន្ថយគ្រោះប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន បើសិនជា:

- បន្ទុកមេរោគរបស់ម្តាយខ្ពស់
- បានធ្វើមុនពេលឈឺពោះសំរាល

ក៏ប៉ុន្តែមានការប្រឈមនឹងគ្រោះថ្នាក់ដែលទាក់ទងទៅនឹងការដាក់ថ្នាំសណ្តំ និងការវះកាត់

<u>កំណត់ចំណាំ</u>: នៅកម្ពុជាបច្ចុប្បន្ន ការសំរាលកូនដោយវះកាត់មិនបានណែនាំឱ្យធ្វើជាស្តង់ដាទេ។ គេធ្វើតែក្នុងករណីដែលមានបញ្ហាខាងសម្ភពតែប៉ុណ្ណោះ។

18

## ស្ត្រីដែលមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍នៅពេលឈឺពោះសំរាល (១)

ស្ត្រីខ្លះដែលមកសំរាលកូននៅមន្ទីរពេទ្យ:

- មិនដែលបានមកពិនិត្យផ្ទៃពោះ
- បានសំរេចចិត្តមិនធ្វើតេស្តឈាម
- មិនបានមកទទួលលទ្ធផលតេស្តឈាម
- បានទៅទទួលសេវាថែទាំផ្ទៃពោះនៅកន្លែងផ្សេង តែមកដោយមិនបានយកលិខិតស្នាមមកជាមួយ

ស្ត្រីទាំងនោះនឹងបាត់បង់ឱកាសទទួលសេវា PMTCT

**ការប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅពេលឈឺពោះសំរាលនិងសំរាលមានប្រហែល ១៥%**

19

## ស្ត្រីដែលមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍នៅពេលឈឺពោះសំរាល (២)

ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ទាំងអស់ ដែលមិនបានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួននឹង:

- មិនទទួលបានឱសថ **ARV** សំរាប់បង្ការដល់កូនរបស់គាត់
- មិនបានទទួលការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូនបានសមស្រប

ការលំបាកក្នុងការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមនៅពេលឈឺពោះសំរាលមានដូចជា:

- មិនមានពេលវេលាគ្រប់គ្រាន់ ខ្វះខាតបុគ្គលិក និងមិនមានទីកន្លែងសមស្រប
- មានការពិបាកក្នុងការផ្តល់ប្រឹក្សា ដោយសារតែស្ត្រីកំពុងតែឈឺពោះខ្លាំង

លើកទឹកចិត្តឱ្យស្ត្រីទទួលសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមក្រោយសំរាលឱ្យបានឆាប់តាមដែលអាចធ្វើបាន។ ធ្វើដូច្នេះ ទារកអាចទទួលបាននូវការបង្ការដោយឱសថប្រឆាំងមេរោគអេដស៍ (ក្នុងកំឡុងពេល៧២ម៉ោងក្រោយសំរាល) បើសិនជាម្តាយមានផ្ទុកមេរោគអេដស៍។

20

» **សកម្មភាពទី៦: ពាក្យគន្លឹះ: ការថែទាំភ្លាមៗដល់ទារកទើបនឹងកើត**
គ្រូនឹងស្នើឱ្យអ្នកគិតអំពីតម្រូវការដែលត្រូវធ្វើជាបន្ទាន់ បន្ទាប់ពីសម្រាលកូនរួច

» តើដំបូងអ្នកត្រូវធ្វើអ្វី នៅពេលដែលទារកកើតចេញមក តើត្រូវបង្ការដូចម្តេចខ្លះ នៅពេលធ្វើការងារនោះ

» សរសេរចម្លើយទាំងនេះនៅលើក្តារខៀន

» តើបន្ទាប់មកត្រូវធ្វើអ្វីទៀតនិងត្រូវបង្ការយ៉ាងដូចម្តេចខ្លះ?

» សរសេរបន្ថែមចំណុចនានានៅក្នុងបញ្ជីដែលមាននៅលើក្តារខៀន

» បន្តធ្វើដូច្នេះរហូតដល់អស់យោបល់

## ការថែទាំភ្លាមៗដល់ទារកទើបនឹងកើត

- រក្សាឱ្យបាននូវការបង្ការជាសកល នៅពេលថែទាំទារក
- ពាក់ស្រោមដៃនិងវ៉ែនតាការពារភ្នែក នៅពេលប៉ះពាល់ទារកដែលទើបនឹងកើត
- គៀបទងសុកឱ្យបានឆាប់ក្រោយពេលកើត ។ មិនត្រូវច្បូតរឹតទងសុកទេ ។ គ្របទងសុក នឹង ស្បៃមុនពេលកាត់ ដើម្បីជៀសវាងការខ្ទាតឈាម
- ជូតមាត់និងច្រមុះរបស់ទារកដោយស្បៃនៅពេលដែលក្បាលវាកើតចេញមកផុត
- កុំទំលាប់បឺតស្លេស្មទារកជាប្រចាំ ។ ប្រើប្រដាប់បឺតស្លេស្មទារក បើសិនជាទារកមានឈ្លក់ទឹកភ្លោះ ( amniotique fluide)
- សំងួតទារកនឹងកន្សែងស្អាត
- បញ្ជាក់ជាមួយម្តាយឱ្យបានច្បាស់ពីជំរើសនៃការចិញ្ចឹមកូនរបស់គាត់
- ផ្តល់វីតាមីន K 1mg ចាក់សាច់ដុំនិងបន្តក់ថ្នាំភ្នែកប្រាក់នីត្រាតចូលក្នុងភ្នែកកូន

**សកម្មភាពទី៧: បំផុសគំនិត: សមាសភាគនៃការថែទាំក្រោយសម្រាល**

» គ្រូនឹងស្នើឱ្យអ្នកធ្វើការជាគូ ដើម្បីបញ្ចេញគំនិតរៀបរាប់នូវអ្វីៗទាំងអស់ដែលគួរបញ្ចូលក្នុងការថែទាំដល់ស្ត្រីផ្ទុកមេរោគអេដស៍ក្រោយពេលសម្រាល

» ស្លាយទី២៧ សង្ខេបការគ្រប់គ្រងស្ត្រីដែលមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន

## ការថែទាំក្រោយសំរាល

ទោះបីជាស្ត្រីមានស្ថានភាពផ្ទុកមេរោគអេដស៍យ៉ាងណាក៏ដោយ មុនពេលចេញពីមន្ទីរពេទ្យត្រូវផ្តល់ប្រឹក្សាដល់ស្ត្រីអំពី:

១. ការចិញ្ចឹមកូន

២. អាហារូបត្ថម្ភ

៣. ការចាក់ថ្នាំបង្ការជម្ងឺ៧មុខ

៤. ផែនការគ្រួសារ និងផ្តល់ព័ត៌មានសមស្របអំពីរបៀបទទួលបាននូវសេវាថែទាំបន្តពេលវេលា និង ទីកន្លែងដើម្បីទទួលសេវាទាំងនោះ ។

ម្តាយផ្ទុកមេរោគអេដស៍ត្រូវការការថែទាំតាមដាននិងគាំទ្របន្ត ដែលត្រូវបានសំរបសំរួល តាមរយៈបណ្តាញបញ្ជូនរវាងសេវានីមួយៗនៅក្នុងមន្ទីរពេទ្យ និងនៅតាមសហគមន៍

25

## ការថែទាំក្រោយសំរាលដល់ស្ត្រីផ្ទុកមេរោគអេដស៍និងកូនរបស់គាត់

**នៅមុនពេលចាកចេញពីមន្ទីរពេទ្យ ម្តាយត្រូវទទួលព័ត៌មានដូចខាងក្រោម:**

១. ការព្យាបាលបង្ការដោយឱសថប្រឆាំងមេរោគអេដស៍សំរាប់ម្តាយនិងកូន

២. ការចិញ្ចឹមថែទាំទារកដែលទើបនឹងកើត

៣. ការចាក់ថ្នាំបង្ការជម្ងឺ៧មុខដល់ទារក

៤. ការអប់រំទូទៅ

៥. ផែនការគ្រួសារ (សូមអានវគ្គទី២នៃម៉ូឌុលនេះ)

៦. សញ្ញានិងរោគសញ្ញានៃការក្លាយរោគក្រោយសំរាល

៧. ការព្យាបាល ថែទាំ និង គាំទ្របន្ត ដល់ស្ត្រីផ្ទុកមេរោគអេដស៍ និងកូនរបស់គាត់

៨. បន្តការគាំទ្រផ្លូវចិត្ត

26

## ស្ត្រីដែលមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍និងកូនរបស់គាត់

ស្ត្រីដែលមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ ត្រូវតែ:

- ទទួលបាននូវការថែទាំដូចគ្នានឹងស្ត្រីផ្ទុកមេរោគអេដស៍ដែរ
- ទទួលបាននូវព័ត៌មាននិងការអប់រំអំពីមេរោគអេដស៍-ជម្ងឺអេដស៍ និងការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមពីអ្នកផ្តល់ប្រឹក្សានៅផ្នែកសម្ភព ឬអគារក្រោយសំរាល
- បានលើកទឹកចិត្តក្នុងការទទួលបាននូវសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមជាមួយដៃគូ នៅក្នុងកំឡុងពេល ៧២ម៉ោងក្រោយសំរាលដើម្បីឱ្យ:
  - កូនបានទទួលការបង្ការដោយឱសថប្រឆាំងមេរោគអេដស៍ បើសិនជាម្តាយ មានផ្ទុកមេរោគអេដស៍
  - ម្តាយបានទទួលការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូនរបស់គាត់ និងកូនរបស់គាត់ ត្រូវតែទទួលបាននូវការចាក់ថ្នាំបង្ការជម្ងឺ៧មុខដូចទារកដទៃទៀតដែរ។

27

## សកម្មភាពទី៨: ធ្វើការជាក្រុម: សមាសភាគនៃការថែទាំក្រោយសម្រាល

» គោលបំណងនៃសកម្មភាពនេះ គឺដើម្បីពិនិត្យលំអិតអំពីសមាសភាគនៃការ ថែទាំស្ត្រី

» សិក្ខាកាមត្រូវបានចែកជា៤ក្រុម និងចែកប្រធានបទដូចតទៅ:

ក្រុមទី១: ARVសម្រាប់បង្ការដល់ម្តាយនិងទារក
ក្រុមទី២: ការចិញ្ចឹមទារកនិងការចាក់ថ្នាំបង្ការ
ក្រុមទី៣: អប់រំសុខភាពទូទៅសម្រាប់ម្តាយ
ក្រុមទី៤: ការគាំទ្រផ្លូវចិត្ត

» ធ្វើការពិភាក្សានៅក្នុងក្រុម ដើម្បីសរសេរចំណុចសំខាន់ៗនៃប្រធានបទរបស់អ្នក

» ក្រុមនីមួយៗត្រូវចាត់តំណាងម្នាក់ដើម្បីឡើងមកបង្ហាញកិច្ចការរបស់ក្រុមខ្លួន

## ១. ឱសថបង្ការប្រឆាំងមេរោគអេដស៍

**សំរាប់ស្ត្រីផ្ទុកមេរោគអេដស៏ ដែលបានប្រើឱសថ ARVសំរាប់បង្ការ:**

- ត្រូវប្រាកដថាម្តាយបានទទួល:

  AZT (300mg) + 3TC (150mg) លេប២ដងក្នុង១ថ្ងៃ រយៈពេល៧ថ្ងៃបន្ទាប់ពីសំរាល

- ពន្យល់គាត់អំពីសារៈសំខាន់នៃការលេបថ្នាំឱ្យបានត្រឹមត្រូវ

បើសិនជាស្ត្រីកំពុងទទួលការព្យាបាល ART ត្រូវរំលឹកគាត់ឱ្យ:

- បន្តប្រើរបបឱសថព្យាបាលរបស់គាត់តទៅទៀត
- ត្រឡប់ទៅសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៏ OI-ART តាមការកំណត់របស់គ្រូពេទ្យ ដើម្បីធ្វើការតាមដានបន្ត និងទទួលឱសថបន្ថែមទៀត ។

29

## ហេតុអ្វីបានជាម្តាយត្រូវលេប AZT និង 3TC បន្ទាប់ពីសំរាល?

- ឱសថប្រឆាំងមេរោគអេដស៏ Nevirapine (NVP) មានប្រសិទ្ធភាពពាក់កណ្តាលនៃរយៈពេលពី២៥-៣០ម៉ោង
- នេះមានន័យថានៅពេលឈឺពោះសំរាល ការឱ្យឱសថNVP ១ ដូស វាអាចស្ថិតនៅក្នុងខ្លួនម្តាយជាច្រើនថ្ងៃ(៣-៧ថ្ងៃ)
- មានភស្តុតាងបង្ហាញថា មេរោគអេដស៏អាចវិវត្តខ្លួនឱ្យស៊ាំនឹងឱសថNVP នៅកំឡុងពេលនេះ
- មេរោគអេដស៏ស៊ាំនឹងថ្នាំអាចៈ
  - ជះឥទ្ធិពលអាក្រក់ទៅដល់ម្តាយនៅពេលព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៏ ART នៅពេលអនាគត
  - រាលដាលភាពស៊ាំនេះ ទៅដល់កូន និង ប្តីរបស់គាត់
- ការលេបAZT និង 3TC រួមផ្សំគ្នារយៈពេល៧ថ្ងៃក្រោយពេលសំរាល អាចកាត់បន្ថយកុំឱ្យមេរោគអេដស៏ ឆាប់ស៊ាំនឹងថ្នាំពេកក្នុងកំឡុងពេលដែល NVP ស្ថិតនៅក្នុងខ្លួនរបស់ម្តាយនៅឡើយ ។

30

## ការប្រើឱសថប្រឆាំងមេរោគអេដស៍ ARV សំរាប់បង្ការដល់ទារក

ឱសថ **ARV** សំរាប់បង្ការ:

- ទារកត្រូវទទួល NVP ១កំរិត ក្នុងកំឡុងពេល៧២ម៉ោងក្រោយសំរាល
- ត្រូវប្រាកដថាកូនបានទទួល AZT សំរាប់រយៈពេល៧ថ្ងៃ * (ឬ២៨ថ្ងៃ) ក្រោយសំរាល
- ត្រូវប្រាកដថា ម្តាយបានយល់ពីគោលបំណងនៃការឱ្យឱសថ AZT ទៅកូន និងដឹងពីរបៀបឱ្យថ្នាំទៅកូន

> * ប្រសិនបើម្តាយបានទទួលការបង្ការ **ARV**ឬព្យាបាល **ART** ដោយឱសថប្រឆាំងមេរោគអេដស៏ មុនពេលសំរាលតិចជាង៤សប្តាហ៍ ។

31

## ហេតុអ្វីចាំបាច់ឱ្យ AZT ទៅទារកក្រោយកើត?

- ត្រូវផ្តល់ AZT ដល់ទារកក្រោយពេលកើត សំរាប់រយៈពេល៧ថ្ងៃ ដើម្បីឱ្យប្រាកដថាមេរោគអេដស៏ដែលបានចូលទៅក្នុងឈាមរបស់កូននៅត្រីមាសចុងក្រោយ នៅពេលឈឺ ពោះសំរាល ឬពេលសំរាល មិនអាចបង្កការចម្លងដល់ទារកបាន
- ត្រូវផ្តល់ **AZT** ដល់ទារកក្រោយពេលកើតរយៈពេល២៨ថ្ងៃ បើសិនជាម្តាយប្រើឱសថ **ARV** ឬ **ART** មិនបានគ្រប់៤សប្តាហ៍មុនពេលសំរាលកូនទេ ពីព្រោះគ្រោះប្រឈមនឹងការចម្លងមេរោគអេដស៏ទៅកូនមានសភាពខ្ពស់

> ព្យាយាមស្ទាបស្ទង់ជំនឿនិងការយល់ដឹងរបស់ម្តាយអំពីឱសថ និងការព្យាបាលមុនពេលពន្យល់គាត់ពីការប្រើ **AZT**

32

## ២. ការចិញ្ចឹមទារកទើបនឹងកើត

ក្រោយពេលសំរាល និងមុនពេលចេញពីមន្ទីរពេទ្យ អ្នកផ្តល់ប្រឹក្សាត្រូវធានាថាម្តាយផ្ទុកមេរោគអេដស៏ :

- បានទទួលការផ្តល់ប្រឹក្សាអំពីជំរើសផ្សេងៗពីការចិញ្ចឹមកូន
- អាចសំរេចចិត្តជ្រើសរើសវិធីចិញ្ចឹមកូនដែលមានសុវត្ថិភាពជាង
- បានទទួលការបង្រៀនពីរបៀបចិញ្ចឹមកូន និងត្រូវបានសង្កេតថាគាត់អាចធ្វើបាន
- បានទទួលព័តិមានអំពីសេវាផ្សេងទៀតដែលត្រូវទទួល និងអ្នកដែលត្រូវទំនាក់ទំនងជាមួយដើម្បីបានទទួលសេវានោះបើសិនជាគាត់ត្រូវការ
- ត្រូវបានបញ្ជូនទៅក្រុមថែទាំអ្នកជម្ងឺអេដស៏តាមផ្ទះ ឬក្រុមគាំទ្រដល់អ្នកផ្ទុកមេរោគអែដស៏ បើសិនជាគាត់មានចិត្តចង់ចូលរួម

33

## ការចាក់ថ្នាំបង្ការជម្ងឺ៧មុខ

- ត្រូវផ្តល់ការចាក់ថ្នាំបង្ការដល់ទារកប្រឈមនឹងមេរោគអេដស៏ ដូចទារកដទៃទៀតដែរ ដោយផ្តើមចាក់ BCG* និង HepB(0) ភ្លាមក្រោយពេលកើត
- នៅពេលទារកអាយុបាន៦សប្តាហ៏ ត្រូវយកទារកទៅមណ្ឌលសុខភាពដើម្បីទទួល DTP និង HepB(1) និង Polio (1)
- កាលបរិឆ្ឆេទនេះ គឺដូចគ្នានឹងទារកដទៃទៀតដែរ

* មិនត្រូវផ្តល់ BCG ដល់ទារកដែលមានរោគសញ្ញាមេរោគអេដស៏ទេ

34

## ៤. ការអប់រំនូនៅ

ណែនាំម្តាយអំពីៈ

- ការថែទាំផ្ទៃទ្វារ និងដោះរបស់គាត់
- វិធានការណ៏ដែលគាត់ត្រូវធ្វើជាមួយសំភារៈឆ្លង ដូចជាៈ ក្រណាត់ប្រឡាក់ឈាម ឬសំឡីអនាម័យ
- សារៈសំខាន់នៃចំណីអាហារគ្រប់គ្រាន់សំរាប់ម្តាយ ការធ្វើលំហាត់ប្រាណ ការសំរាកអនាម័យល្អ ។ល ។
- ឥទ្ធិពលអាក្រក់នៃគ្រឿងស្រវឹង ការជក់បារី ការសេពគ្រឿងញៀន ។ល ។
- សញ្ញានិងរោគសញ្ញានៃជម្ងឺកាមរោគ សារៈសំខាន់នៃការព្យាបាលជម្ងឺកាមរោគបានទាន់ពេល និងទីកន្លែងដែលត្រូវទទួលសេវាទាំងនោះ

35

## យុទ្ធសាស្ត្រនៃអាហារូបត្ថម្ភសំរាប់ម្តាយផ្ទុកមេរោគអេដស៏

**ផឹកសារជាតិរាវឱ្យបានញឹកញាប់ ដូចជា :**

- ទឹកដែលមានជាតិប្រូតេអ៊ីននិងផ្តល់ថាមពលខ្ពស់ ( ឧៈ ទឹកសណ្តែក) សំរាប់ពេលមានគ្រុនក្តៅនិងអស់កំលាំង
- ផឹកទឹកផ្លែឈើលាយគ្នា បើសិនជាមានការក្អួតចង្អោរ ឬរាក
- ប្រើប្រាស់បំពង់បឺតបើសិនជាឈឺមាត់
- ទឹកស៊ុប ។ល ។

**បរិភោគអាហារតិចតួច និង អាហារសំរន់ឱ្យបានញឹកញាប់ :**

- ក្នុងនោះមានអាហារទន់ៗដែលគាត់ចូលចិត្ត
- បង្កើនការបរិភោគអាហារឱ្យបាន៥០០គីឡូកាឡូរីក្នុងមួយថ្ងៃ បើសិនជាបំបៅកូនដោយទឹកដោះ
- ជៀសវាងការបរិភោគម្ហូបឆា បើសិនជាមានរាក ឬពោះវៀនបឺតស្រួបមិនបានល្អ
- បរិភោគបបរខាប់ បើសិនជាមានឈឺមាត់ ក្អួត ចង្អោរ ឬ រាក
- បរិភោគចេក បើសិនជាមានជម្ងឺរាក

នៅតាមតំបន់មួយចំនួន មានអង្គការធ្វើការក្នុងសហគមន៏ខ្លះ
អាចជួយផ្គត់ផ្គង់អាហារដល់ស្ត្រីបាន ។

36

## ៥. ផែនការគ្រួសារ

■ មានបញ្ជាក់នៅក្នុងម៉ូឌុលទី៤ វគ្គទី២

37

## ៦. ការក្លាយរោគក្រោយសំរាល

អ្នកផ្តល់ប្រឹក្សាត្រូវពិនិត្យរកសញ្ញានិងរោគសញ្ញានៃរោគឆ្លង និងផ្តល់ព័ត៌មានអំពីទីកន្លែងដែលត្រូវទទួលការព្យាបាលរោគសញ្ញាទាំងនោះ ដូចជា:

- ■ នោមក្រហាយ
- ■ គ្រុនក្តៅ
- ■ ឡូស៊ី ( Lochia ) ធុំក្លិនស្អុយ
- ■ ក្អកមានកំហាក ដកដង្ហើមញាប់ខ្លីៗ
- ■ ស្នាមមុខរបួសនៅពោះ ឬនៅទ្វារ ឡើងក្រហម ឈឺចាប់ខ្លាំង និងមានហូរខ្ទុះ
- ■ ផ្ទៃកខាងក្រោមនៃពោះឡើងរឹងខ្លាំង

38

## ៧. ការព្យាបាល ថែទាំ និងគាំទ្រ

■ ស្ត្រីផ្ទុកមេរោគអេដស៍ដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ **ART** គួរតែត្រូវបានតាមដានបន្តពីការព្យាបាលរបស់គាត់ក្រោយពេលសំរាលដោយសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ **OI-ART** ម្តាយផ្ទុកមេរោគអេដស៍ដែលទទួលការបង្ការដោយឱសថប្រឆាំងមេរោគអេដស៍ **ARV** ត្រូវត្រឡប់មកទទួលសេវា **OI-ART** វិញដើម្បីតាមដានជម្ងឺរបស់គាត់ ទោះបីជាគាត់មិនមានរោគសញ្ញាក៏ដោយ ក៏កោសិកា CD4 របស់គាត់អាចធ្លាក់ចុះដល់ចំណុចដែលគាត់ត្រូវទទួល **ART** ដែរ

■ ស្ត្រីផ្ទុកមេរោគអេដស៍គួរទទួលបាននូវសេវាថែទាំបន្តក្រោយសំរាល

39

## ការតាមដានបន្តដោយសេវា OI-ART

- ■ ការបង្ការនិងគ្រប់គ្រងជម្ងឺឱកាសនិយម
- ■ ការព្យាបាលនិងតាមដានជម្ងឺរបេង
- ■ ការបង្ការនិងព្យាបាលជម្ងឺគ្រុនចាញ់ នៅក្នុងតំបន់ឆ្លង
- ■ ការតាមដានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍
- ■ វាយតម្លៃពីល័ក្ខខ័ណ្ឌទទួលបាននូវ ART ជាថ្មី
- ■ ថែទាំនិងគាំទ្រដោយក្រុមថែទាំអ្នកជម្ងឺអេដស៍តាមផ្ទះ ក្រុមអ្នកផ្ទុកមេរោគអេដស៍ និងក្រុមថែទាំគាំទ្រដទៃទៀតដែលនៅតាមសហគមន៍
- ■ មណ្ឌលមិត្តជួយមិត្ត

40

## ការតាមដានកុមារនៅមណ្ឌលសុខភាព

ការតាមដានកុមារនៅមណ្ឌលសុខភាពរួមមាន:

- ការចាក់ថ្នាំបង្ការជម្ងឺ៧មុខ
- វាយតម្លៃពីអាហារូបត្ថម្ភ
  - តារាងតាមដានការលូតលាស់នៃកុមារ
  - រំលឹកពីការចិញ្ចឹមកូន
  - តំរូវការប្តូរវិធីចិញ្ចឹមកូន
- ពិនិត្យសុខភាព
  - រោគសញ្ញានិងចង្អោមរោគសញ្ញានៃជម្ងឺ ដូចជាជម្ងឺអេដស៍ជាដើម
  - ការបញ្ជូនទៅសេវាជម្ងឺអេដស៍កុមារ បើចាំបាច់
- ការបញ្ជូនទៅសេវាគាំទ្រនៅតាមសហគមន៍ បើសិនជាស្ត្រីមានបំណង

41

## ការតាមដានកុមារនៅសេវាជម្ងឺអេដស៍កុមារ (១)

កុមារប្រឈមនឹងមេរោគអេដស៍ទាំងអស់ត្រូវបញ្ជូនទៅសេវាជម្ងឺអេដស៍កុមារដើម្បីតាមដាន ចាប់៦សប្តាហ៍នៃជីវិត រហូតដល់អាយុ១៨ខែ

ការតាមដានមាន:

- ពិនិត្យរកមើលសញ្ញានិងរោគសញ្ញានៃជម្ងឺអេដស៍
- ពិនិត្យមើលពីការលូតលាស់និងការវិវត្តន៍
- ព្យាបាលជម្ងឺឱកាសនិយម (PCP)
- ស្រាវជ្រាវរកមេរោគរបេង និងព្យាបាល
- បង្ការនិងព្យាបាលជម្ងឺគ្រុនចាញ់
- គ្រប់គ្រងជម្ងឺ រួមមានជម្ងឺឱកាសនិយម
- ធ្វើតេស្តឈាមនៅពេលកុមារមានអាយុ១៨ខែ
- ផ្តល់ ART បើសិនជាគ្រប់ល័ក្ខខ័ណ្ឌដែលត្រូវផ្តល់ឱ្យ*

* គោលការណ៍ណែនាំជាតិស្តីពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅលើកុមារ

42

## ការតាមដានកុមារនៅសេវាជម្ងឺអេដស៍កុមារ (២)

ការព្យាបាលបង្ការជម្ងឺឱកាសនិយម:

កូទ្រីម៉ុកសាសុលសំរាប់បង្ការ ត្រូវផ្តល់ឱ្យកុមារចាប់ពីអាយុ៦សប្តាហ៍ រហូតដល់:

- រកឃើញថាកុមារគ្មានផ្ទុកមេរោគអេដស៍
- កុមារគ្មានរោគសញ្ញា នៅពេលមានអាយុ១២ខែ

ការធ្វើតេស្តឈាម:

គ្រប់កុមារប្រឈមទាំងអស់ត្រូវធ្វើតេស្តឈាមរកមេរោគអេដស៍នៅពេលដែលកុមារមានអាយុ១៨ខែ ដោយមានការយល់ព្រមពីម្តាយ ឬអាណាព្យាបាល

43

## ការតាមដានកុមារនៅសេវាជម្ងឺអេដស៍កុមារ (៣)

សេវាព្យាបាលជម្ងឺអេដស៍កុមារ:

- ត្រូវផ្សារភ្ជាប់ជាមួយក្រុមថែទាំអ្នកជម្ងឺអេដស៍តាមផ្ទះនិងក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៍ ដើម្បី
  - តាមដានកុមារប្រឈមនៅតាមសហគមន៍ (ដោយមានយល់ព្រមពីគ្រួសារ)
  - កំណត់បាន និងបញ្ជូនកុមារប្រឈមដែលមិនបានដឹងពីមុននៅក្នុងសហគមន៍ទៅទទួលសេវាថែទាំ និងធ្វើតេស្តឈាម
- ផ្តល់ព័ត៌មានអំពីសេវាគាំទ្រផ្សេងទៀត **ដូចជាមណ្ឌលមិត្តជួយមិត្តតូចៗ**

44

# ការគាំទ្រផ្លូវចិត្ត

ការគាំទ្រផ្លូវចិត្តដល់ម្តាយក្រោយសំរាលមានសារៈសំខាន់ណាស់ ពីព្រោះ:

- ម្តាយខ្លះទើបតែដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនថ្មីៗ ហើយគាត់មិនទាន់អាចសំរបខ្លួនបានភ្លាមៗទេ
- ម្តាយខ្លះផ្សារភ្ជាប់ជីវិតទៅនឹងលំនៅស្ថានដែលគាត់រស់នៅ ដូច្នេះការគាំទ្រពីក្រុមថែទាំអ្នកផ្ទុកមេរោគអេដស៍-ជម្ងឺអេដស៍ និងពីសហគមន៍មានសារៈសំខាន់ខ្លាំងណាស់
- បច្ចុប្បន្ននេះ នាងមានកូន ដូច្នេះនាងកាន់តែពិបាកចិត្តដោយសារតែនាងគិតពីកូនរបស់នាង

45

# ជំរើសក្នុងការគាំទ្រផ្លូវចិត្ត

- ផ្តល់ការប្រឹក្សាក្រោយសំរាលដោយបុគ្គលិក **PMTCT**
- បញ្ជូនទៅអង្គការដែលមាននៅតាមសហគមន៍
  - ក្រុមថែទាំតាមផ្ទះ
  - ក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៍
  - អង្គការសាសនា
  - អង្គការនៅតាមសហគមន៍ផ្សេងទៀត
- មណ្ឌលមិត្តជួយមិត្ត ដែលទទួលបានតាមរយៈសេវា OI-ART

អង្គការខ្លះអាចជួយឧបត្ថម្ភដល់តំរូវការពិសេសខ្លះៗ ដូចជា: ផ្ទះ មធ្យោបាយធ្វើដំណើរ ម្ហូបអាហារ និងការប្រកបមុខរបរដើម្បីបង្កើនប្រាក់ចំណូល

46

## ម៉ូឌុលទី៤.៣.២: ចំណុចគន្លឹះ

- ការសម្រាលដែលមានសុវត្ថិភាពមានដូចជា ការជៀសវាងនូវវិធីសម្រាលណាដែលបង្កឱ្យមាន ការប៉ះទង្គិច និងអនុវត្តជានិច្ចនូវការបង្ការជាសកល
- ការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកុមារ គួរផ្តើមធ្វើនៅពេលស្ត្រីមកពិនិត្យផ្ទៃពោះ និងបន្តរហូតដល់ពេលឈឺពោះសម្រាលនិងក្រោយសម្រាល
- ការថែទាំក្រោយសម្រាលនិងតាមដានដល់ម្តាយនិងកូន ត្រូវមានសមាសភាគដូចតទៅ:

  ១. ការផ្តល់ឱសថ**ARV**សម្រាប់បង្ការដល់ម្តាយនិងទារក

  ២. ការចិញ្ចឹមកូនដែលទើបនឹងកើត

  ៣. ការចាក់ថ្នាំបង្ការដល់ទារក

  ៤. ការអប់រំសុខភាពទូទៅ

  ៥. ផែនការគ្រួសារ

  ៦. សញ្ញានិងរោគសញ្ញានៃការក្លាយរោគក្រោយសម្រាល

  ៧. ការព្យាបាលថែទាំនិងគាំទ្រដល់ម្តាយផ្ទុកមេរោគអេដស៍និងកូនរបស់គាត់

  ៨. ការគាំទ្រផ្លូវចិត្តជាបន្ត

# ឧបសម្ព័ន្ធ

## សកម្មភាពទី៣: ក្រដាសបញ្ជីសម្រាប់ផ្តល់ប្រឹក្សា: ទំព័រទី១



ប័ណ្ណចុះឈ្មោះអតិថិជនមកទទួលសេវាផ្តល់ប្រឹក្សា ( Counseling Registration Sheet )

1. កាលបរិច្ឆេទ : ថ្ងៃ.......... ខែ.......... ឆ្នាំ 200......
2. ឈ្មោះមណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្ត ..........
3. លេខរៀងពេលផ្តល់ប្រឹក្សា .......... លេខកូដអតិថិជន (PMTCT) ..........

4. ភេទ : 1: ប្រុស ☐ 2: ស្រី ☐ 5. អាយុ ..........
6. ស្ថានភាពអាពាហ៍ពិពាហ៍ : 1: នៅលីវ ☐ 2: រៀបការហើយ ☐ 3: ពោះម៉ាយ/មេម៉ាយ ☐
7. មុខរបរ : ..........
8 : កំរិតសិក្សា 1: មិនដែលរៀន ☐ 2: បឋមសិក្សា ☐ 4: អនុវិទ្យាល័យ ☐ 5: វិទ្យាល័យ ☐ 6: ក្រោយវិទ្យាល័យ ☐
9. អាសយដ្ឋាន : .......... ខេត្ត/ក្រុង..........
10 : ប្រទេសកំណើត 1: កម្ពុជា ☐ 2: វៀតណាម ☐ 3: ថៃ ☐ 4: ប្រទេសផ្សេងៗ..........

11 : មូលហេតុរកសេវា:
1: ស្ម័គ្រចិត្តដោយមានរោគសញ្ញា ☐ 2: ស្ម័គ្រចិត្តដោយគិតថាមានការប្រឈមមុខ ☐ 3: គោលបំណងរៀបការ ☐
4: ស្ត្រីមកពិនិត្យផ្ទៃពោះ/មានគភ៌ ☐ 5: ដៃគូផ្ទុកមេរោគអេដស៍ ☐ 6: ឪពុកម្តាយផ្ទុកមេរោគអេដស៍ ☐
7: មកទទួលការផ្តល់ប្រឹក្សាបន្ត ☐ 8: បារម្ភពីជំងឺអេដស៍ ☐ 9: ដៃគូមានផ្ទៃពោះ ☐
10: ផ្សេងទៀត :..........

12 : បញ្ជូនមកពី:
1: មកដោយខ្លួនឯង ☐ 2: គ្លីនិកកាមរោគ ☐ 3: ក្រុមថែទាំតាមផ្ទះ ☐ 4: កម្មវិធីរបេង ☐ ឈ្មោះ HC/RH:__________
5: សេវាពិនិត្យផ្ទៃពោះមុនពេលសំរាល ☐ 6: ផ្នែកជំងឺរួម ☐ 7: មន្ទីរពេទ្យ/គ្លីនិកឯកជន ☐
8: កន្លែងផ្សេងទៀត(បញ្ជាក់) ..........

13. ការវាយតំលៃការប្រឈមមុខ :
1. រួមភេទជាមួយដៃគូច្រើនមិនប្រើស្រោមអនាម័យក្នុងកំឡុង ៣ខែកន្លងទៅ ☐ បើមានថ្ងៃខែចុងក្រោយ..........
2. រួមភេទជាមួយស្ត្រីរកស៊ីផ្លូវភេទដោយមិនប្រើប្រាស់ស្រោមអនាម័យ ☐ បើមានថ្ងៃខែចុងក្រោយ..........
3. ដៃគូរមានដៃគូរួមភេទច្រើន ☐ 4. ដៃគូរធ្វើការឆ្ងាយពីផ្ទះ ☐ 5. ដៃគូរមានផ្ទុកមេរោគអេដស៍ ☐ 6. ដៃគូរមុនស្លាប់ដោយជំងឺអេដស៍ ☐
7. ធ្លាប់បញ្ចូលឈាម ☐ បើមានថ្ងៃខែចុងក្រោយ.......... 8. ធ្លាប់មានកាមរោគ ☐ 9. ក្រោយរំលោភផ្លូវភេទ ☐
10. ធ្លាប់ប្រើម្ជុលរួមគ្នា ៦ ខែកន្លងទៅ ☐ 11. ចាក់ថ្នាំញៀន ☐ 12. បុរសរួមភេទដូចគ្នា ☐ 13. មិនមានការប្រឈមមុខ ☐
14. ការប្រឈមមុខផ្សេងៗទៀត (សូមបញ្ជាក់)..........

ប្រវត្តិសម្ភព (PMTCT) ចំនួនកូនកើតគ្រប់ខែ ☐ ចំនួនកូនកើតមិនគ្រប់ខែ ☐ ចំនួនកូនរលូតពីរលូត ☐ ចំនួនកូននៅរស់សព្វថ្ងៃ ☐
ផ្ទៃពោះទី Gestation ☐ រដូវចុងក្រោយ Last Menstrual Peroid ☐
ថ្ងៃខែសំរាល E.D.D ☐ ចំនួនកូនស្លាប់ # of children ☐

14. ប្រវត្តិធ្វើតេស្ត: មិនធ្លាប់ធ្វើតេស្ត ☐ ធ្លាប់ធ្វើតេស្ត ☐ 1.វិជ្ជមាន ☐ 2.អវិជ្ជមាន ☐ 3.មិនអាចកំណត់បាន ☐
4.ធ្លាប់ធ្វើតេស្តតែមិនបានមកទទួលលទ្ធផល ☐

15. ផ្តល់ការធ្វើតេស្ត: មិនយល់ព្រមធ្វើតេស្ត ☐ យល់ព្រមធ្វើតេស្ត ☐ 1.វិជ្ជមាន ☐ 2.អវិជ្ជមាន ☐ 3.មិនអាចកំណត់បាន ☐

16. ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត មិនបានផ្តល់ប្រឹក្សា ☐ បានផ្តល់ប្រឹក្សា ☐ ថ្ងៃ.......... ខែ.......... ឆ្នាំ..........

17 : បញ្ជូនទៅកាន់:
1: គ្លីនិកកាមរោគ ☐ 2: ក្រុមថែទាំតាមផ្ទះ ☐ 3: កម្មវិធីរបេង ☐ ឈ្មោះ HC/RH:__________
4: សេវាពិនិត្យផ្ទៃពោះមុនពេលសំរាល ☐ 5: ផ្នែកជំងឺរួម ☐ 6: មន្ទីរពេទ្យ/គ្លីនិកឯកជន ☐
7: សេវា OI/ART ☐ 8: កន្លែងផ្សេងទៀត(បញ្ជាក់) ..........

ឈ្មោះអ្នកផ្តល់ប្រឹក្សា .......... ហត្ថលេខា ..........

1 / 2

## តារាងជំនួយសំរាប់ការផ្ដល់ប្រឹក្សាមុនពេលធ្វើតេស្ត PMTCT

**ការពិនិត្យមើលរូបរាងខាងក្រៅ:** សុខភាពល្អ ☐ សុខភាពមិនល្អ ☐ មានការព្រួយបារម្ភ ☐ រីករាយ ☐

**ប្រធានបទនៃការផ្ដល់ប្រឹក្សា:**

1. ពន្យល់អំពីការរក្សាការសំងាត់ ☐ 2. វាយតំលៃចំណេះដឹងអំពី HIV/AIDS របស់អតិថិជន ☐ 3. ពិភាក្សាអំពីជំរើសផ្សេងៗសំរាប់កាត់បន្ថយការប្រឈមមុខ ☐
4. ពិភាក្សាអំពីផលប្រយោជន៍នៃការចូលរួមក្នុងកម្មវិធី PMTCT ដោយរួមបញ្ចូល ការការពារការចំលងពីម្ដាយទៅកូន និងជំរើសផ្សេងៗក្នុងការបង្ការ ☐
5. ការបង្ហាញពីការប្រើប្រាស់ស្រោមអនាម័យ ☐ 6. ពិភាក្សាអំពីការរួមភេទដែលមានសុវត្ថិភាព នៅក្នុងពេលមានផ្ទៃពោះ និងក្រោយសំរាល ☐
7. ពិភាក្សាអំពីជំរើសក្នុងការផ្ដល់អាហារដល់ទារក ☐ 8. ពិភាក្សាអំពីផែនការគ្រួសារ ☐
9. ពិភាក្សាដំណើរការនៃការធ្វើតេស្តឈាមរកមេរោគអេដស៍ និងរយៈពេលចំហរ ☐
10. ពិភាក្សាអំពីការប្រឈមមុខផ្សេងៗ និងអត្ថប្រយោជន៍នៃការធ្វើតេស្តឈាមរបស់ដៃគូ ☐
11. ពិភាក្សាសេវាសុខភាពផ្សេងៗដែលមានសំរាប់អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ☐

**ចំណុចផ្សេងៗទៀត និងកំណត់សំគាល់**

## តារាងជំនួយសំរាប់ការផ្ដល់ប្រឹក្សាក្រោយពេលធ្វើតេស្តសំរាប់ PMTCT

**ប្រធានបទនៃការផ្ដល់ប្រឹក្សាសំរាប់អតិថិជនទូទៅ:**

1. ពិនិត្យឡើងវិញនូវព័ត៌មានដែលបានផ្ដល់អោយក្នុងពេលផ្ដល់ប្រឹក្សាមុនពេលធ្វើតេស្ត ☐
2. ពិភាក្សាអំពីអត្ថន័យរបស់ពាក្យ លទ្ធផលវិជ្ជមាន លទ្ធផលអវិជ្ជមាន និងរយៈពេលចំហរ ☐
3. វាយតំលៃនៅលើការយល់របស់អតិថិជនទាក់ទងទៅនឹងលទ្ធផលវិជ្ជមាន រឺអវិជ្ជមាន ☐

**ប្រសិនបើលទ្ធផលអវិជ្ជមាន**

1. ពន្យល់ឡើងវិញអំពីរយៈពេលចំហរ និងតំរូវការនៃការធ្វើតេស្តម្ដងទៀត ☐
2. ពន្យល់អំពីការការពារខ្លួនដើម្បីកុំអោយឆ្លងមេរោគអេដស៍ ☐
3. ជំរុញដល់ស្ត្រីអោយបំបៅកូនដោយទឹកដោះម្ដាយសុទ្ធក្នុងរយៈពេល ៦ខែដំបូងបន្ទាប់ពីសំរាល ☐
4. ពិភាក្សាអំពីអត្ថប្រយោជន៍នៃការការពារខ្លួនកុំអោយឆ្លងមេរោគអេដស៍ នៅពេលមានផ្ទៃពោះ និងការបំបៅកូនដោយទឹកដោះ ☐
5. ជំរុញដល់ម្ដាយអោយយកកូនទៅចាក់ថ្នាំបង្ការ ☐
6. ពិភាក្សាអំពីអនាម័យ និងអាហារូបត្ថម្ភ ☐
7. ជំរុញលើកទឹកចិត្តអតិថិជនក្នុងការមកម្ដងទៀតនៅពេលត្រូវការ ☐

**ប្រសិនបើលទ្ធផលវិជ្ជមាន**

1. បញ្ជាក់អោយបានច្បាស់ថាអតិថិជនយល់អំពីលទ្ធផលតេស្ត ☐
2. ជួយផ្ដល់ប្រឹក្សាដល់អតិថិជនអំពីផ្លូវដោះស្រាយចំពោះបញ្ហាផ្សេងៗដែលកើតឡើងភ្លាមៗ និងការតាមដានផ្សេងៗទៀត ☐
3. ពិភាក្សាអំពីគុណសម្បត្តិ និងគុណវិបត្តិចំពោះការបង្ហាញលទ្ធផលឱ្យគេដឹង ☐
4. ពិនិត្យមើលឡើងវិញអំពីផែនការក្នុងការកាត់បន្ថយការប្រឈមមុខ ☐
5. បញ្ជូនអតិថិជនទៅកាន់សេវាថែទាំ និងគាំទ្រ ☐
6. ពិភាក្សាអំពីជំរើសក្នុងការបំបៅកូន ដោយរួមមាន គ្រោះថ្នាក់ និងអត្ថប្រយោជន៍ផ្សេងៗដែលបណ្ដាលមកពីការបំបៅដោយទឹកដោះគោ ☐
7. ជំរុញដល់ដៃគូក្នុងការប្រើប្រាស់សេវាពន្យាកំណើត ☐
8. ជំរុញដល់ម្ដាយអោយយកកូនទៅចាក់ថ្នាំបង្ការ ☐
9. ពិភាក្សាអំពីអនាម័យ និងអាហារូបត្ថម្ភ ☐
10. ពន្យល់អំពីជំរើសក្នុងការព្យាបាលរបស់ PMTCT ☐
11. ពិភាក្សាអំពីសារៈសំខាន់ក្នុងការសំរាលកូននៅកន្លែងផ្ដល់សេវាសុខភាពដែលមានកម្មវិធី PMTCT ☐

ឈ្មោះអ្នកផ្ដល់ប្រឹក្សា .............................................. ហត្ថលេខា ..............................

2 / 2

## កាតណាត់ជួប

**ក្រសួងសុខាភិបាល**

**ប័ណ្ណសំរាប់ណាត់ជួបអតិថិជនដើម្បីផ្តល់ប្រឹក្សាលើកទីពីរ**

សេវា: VCCT ☐ PMTCT ☐ TB ☐ សេវាផ្សេងៗទៀត(បញ្ជាក់): ____________

លេខរៀងពេលផ្តល់ប្រឹក្សា ☐☐☐☐☐☐

លេខកូដមណ្ឌលធ្វើតេស្ត ☐☐☐ ឈ្មោះមណ្ឌល ____________

| | ថ្ងៃ | ខែ | ឆ្នាំ |
|---|---|---|---|
| ថ្ងៃខែឆ្នាំនៃការផ្តល់ប្រឹក្សា | ☐☐ | ☐☐ | ☐☐☐☐ |
| ថ្ងៃខែឆ្នាំត្រូវមកជួបម្តងទៀត | ☐☐ | ☐☐ | ☐☐☐☐ |
| ថ្ងៃខែឆ្នាំត្រូវមកបូមឈាមលើកទី២ | ☐☐ | ☐☐ | ☐☐☐☐ |
| ថ្ងៃខែឆ្នាំត្រូវមកបូមឈាមលើកទី៣ | ☐☐ | ☐☐ | ☐☐☐☐ |

ហត្ថលេខាអ្នកផ្តល់ប្រឹក្សា

## កាតបញ្ជូន (សម្រាប់សេវា VCCT PMTCTនិងរបេង)

លេខរៀង: ..................................

### លិខិតបញ្ជូន(REFERRAL CARD)

១.លេខកូដ រឺឈ្មោះអតិថិជន ........................................................ ភេទ................ អាយុ.................

២.បញ្ជូនមកពី (Refer from): ឈ្មោះកន្លែង: ..........................................................................................

មណ្ឌលផ្ដល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ (VCCT) ☐ សេវា OI/ART ☐ ក្រុមថែទាំតាមផ្ទះ ☐

កម្មវិធីការពារការចំលងពីម្ដាយទៅកូន (PMTCT) ☐ កម្មវិធីរបេង (TB) ☐ គ្លីនិកកាមរោគ ☐

សេវាព្យាបាលជំងឺកុមារ ☐ ផ្នែកព្យាបាលជំងឺធ្ងន់ (ជំងឺទូទៅ ☐ ផ្នែកព្យាបាលជំងឺសើស្បែក ☐ ផ្នែកសម្ភព ☐

សេវាពន្យារកំណើត ☐ ផ្នែកវះកាត់ ☐ សេវាព្យាបាលជំងឺមាត់ធ្មេញ ☐

សេវាព្យាបាលផ្សេងទៀត (សូមបញ្ជាក់ ..................................................................

៣.បញ្ជូនទៅកាន់ (Refer to): ឈ្មោះកន្លែង: ..........................................................................................

មណ្ឌលផ្ដល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ (VCCT) ☐ សេវា OI/ART ☐ ក្រុមថែទាំតាមផ្ទះ ☐

កម្មវិធីការពារការចំលងពីម្ដាយទៅកូន (PMTCT) ☐ កម្មវិធីរបេង (TB) ☐ គ្លីនិកកាមរោគ ☐

Pediatric AIDS Care ☐ សេវាព្យាបាលផ្សេងទៀត (សូមបញ្ជាក់ ..................................................................

ហត្ថលេខានិង ឈ្មោះអ្នកបញ្ជូន ថ្ងៃ..........ខែ..............ឆ្នាំ....................

**សំរាប់ PMTCT តែប៉ុណ្ណោះ**

1. រដូវចុងក្រោយ: ថ្ងៃ..........ខែ..............ឆ្នាំ....................
2. ថ្ងៃប្រហាក់ប្រហែលសំរាល: ថ្ងៃ..........ខែ..............ឆ្នាំ....................
3. ការព្យាបាល:

បង្ការដោយ ARV ☐ ថ្ងៃខែឆ្នាំចាប់ផ្ដើមប្រើ: ....................................

ART ☐ ថ្ងៃខែឆ្នាំចាប់ផ្ដើមប្រើ: ....................................

## ទម្រង់សម្រាប់មន្ទីរពិសោធន៍

**ក្រសួងសុខាភិបាល**

**ប័ណ្ណទំនាក់ទំនងរវាងការិយាល័យផ្តល់ប្រឹក្សានិងមន្ទីរពិសោធន៍**

សេវា: VCCT ☐ PMTCT ☐ TB ☐ សេវាផ្សេងៗទៀត ( បញ្ជាក់ ) :..........................................

លេខរៀងពេលផ្តល់ប្រឹក្សា ☐☐☐☐☐☐

លេខកូដមណ្ឌលធ្វើតេស្ត ☐☐☐ ឈ្មោះមណ្ឌល ________

ថ្ងៃខែឆ្នាំនៃការផ្តល់ប្រឹក្សា ថ្ងៃ ☐☐ ខែ ☐☐ ឆ្នាំ ☐☐☐☐

ហត្ថលេខាអ្នកផ្តល់ប្រឹក្សា

| | | |
|---|---|---|
| តេស្ត | Serodia ☐ Determine ☐ តេស្តElisa ☐ | - / + / + - |
| តេស្តត្រួតពិនិត្យ | Uni-Gold ☐ Statpak ☐ Determine ☐ | ទេ / - / + / + - |
| **លទ្ធផលនៃការធ្វើតេស្ត** | | - / + / SC ធ្វើតេស្តម្តងទៀតក្នុងរយៈពេល១៥ថ្ងៃ |

លេខរៀងនៅមន្ទីរពិសោធន៍ ☐☐☐☐☐☐

ហត្ថលេខាគ្រូពេទ្យមន្ទីរពិសោធន៍

# ៤.៣.៣

# ការចិញ្ចឹមកូនក្នុងបរិបទនៃមេរោគអេដស៍_ជំងឺអេដស៍

**វត្ថុបំណង**

នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមទាំងអស់អាចនឹងៈ

១. ពន្យល់អំពីគោលការណ៍ណែនាំ ស្តីអំពីការចិញ្ចឹមកូននៅក្នុងបរិបទនៃមេរោគអេដស៍

២. ពន្យល់អំពីគោលបំណងនិងការផ្តល់ប្រឹក្សា ស្តីអំពីការចិញ្ចឹមកូនសម្រាប់សេវា **PMTCT**

៣. ពិភាក្សាអំពីជម្រើសសំខាន់បំផុតនៃការចិញ្ចឹមកូនដែលមាននៅកម្ពុជា និងពន្យល់អំពីគុណសម្បត្តិ និងគុណវិបត្តិរបស់វា

៤. ពិភាក្សាអំពីការជាប់ពាក់ព័ន្ធនៃជម្រើសនៃការចិញ្ចឹមកូនផ្សេងៗទៅនឹងការប្រាប់អំពីស្ថានភាពផ្ទុកមេរោគអេដស៍ទៅអ្នកដទៃ



*រយៈពេលៈ* ***៣ម៉ោង***

## សកម្មភាពទី១: បំផុសគំនិត: ទស្សនៈជាមូលដ្ឋានក្នុងការចិញ្ចឹមកូន

» គ្រូនឹងស្នើឱ្យអ្នកគិតអំពីការចិញ្ចឹមកូនក្នុងន័យទូទៅ និងការចិញ្ចឹមកូនដែលមានទំនាក់ទំនងជាមួយស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍

» គិតពីគោលបំណងនៃការចិញ្ចឹមកូន អំពីវិធីចិញ្ចឹមកូនខុសៗគ្នា អំពីសារៈសំខាន់នៃការឆ្លងមេរោគអេដស៍ ដែលមានទំនាក់ទំនងទៅនឹងការអនុវត្តន៍ក្នុងការចិញ្ចឹមកូន

### យុទ្ធសាស្ត្រសកលសំរាប់ចិញ្ចឹមទារកនិងកុមារតូចៗ*

- កង្វះអាហារូបត្ថម្ភទទួលខុសត្រូវដោយផ្ទាល់ឬដោយប្រយោលចំពោះការស្លាប់ជាង ៥០% នៃកុមារអាយុក្រោម៥ឆ្នាំ ក្នុងចំណោមកុមារស្លាប់ ១០.៩លាននាក់នៅទូទាំងពិភពលោក
- ក្នុងចំណោមកុមារដែលស្លាប់ មានកុមារជាង១លាននាក់អាយុក្រោម១ឆ្នាំ
- យុទ្ធសាស្ត្រសកលសំរាប់ចិញ្ចឹមទារកនិងកុមារតូចៗ បានរៀបចំដោយអង្គការសុខភាពពិភពលោក និងអង្គការសហប្រជាជាតិមូលនិធិដើម្បីកុមារ ដើម្បីធ្វើឱ្យប្រទេសទាំងអស់យកចិត្តទុកដាក់ចំពោះផលប៉ះពាល់នៃការចិញ្ចឹមទារកនិងកុមារតូចៗ

* សូមអានព័ត៌មានលំអិតក្នុងឧបសម្ព័ន្ធដែលមាននៅក្នុងម៉ូឌុលនេះ

7

### ផលប៉ះពាល់នៃការចិញ្ចឹមកូន

- ការចិញ្ចឹមកូនមិនបានត្រឹមត្រូវ នាំឱ្យមានកង្វះអាហារូបត្ថម្ភ ឬមានជម្ងឺរាក។ ទាំងនេះគឺជាមូលហេតុចំបងនៃជម្ងឺនិងការស្លាប់របស់ទារកនិងកុមារតូចៗ
- ចំពោះម្តាយផ្ទុកមេរោគអេដស៍ ក៏មានការប្រឈមនឹងការចម្លងមេរោគអេដស៍ទៅកូនដែរ

ការផ្តល់ប្រឹក្សានិងការគាំទ្រអំពីការចិញ្ចឹមកូនអាចធ្វើឱ្យ:

-ការចិញ្ចឹមកូនបានល្អប្រសើរ

-បង្ការជម្ងឺកង្វះអាហារូបត្ថម្ភនិងការស្លាប់

-និងកាត់បន្ថយគ្រោះប្រឈមនឹងការចម្លងមេរោគអេដស៍ទៅកូនបាន

8

## សកម្មភាពទី២: ការលេងល្បែង: អនុវត្តការចិញ្ចឹមកូននិងការចម្លងមេរោគអេដស៍

» គោលបំណងនៃលំហាត់នេះគឺគិតអំពីការប្រឈមនឹងការចម្លងមេរោគអេដស៍ ដែលមានទំនាក់ទំនងទៅនឹងការបំបៅដោះកូន និងរកវិធីកាត់បន្ថយការចម្លងនេះ

» គ្រូនឹងឱ្យអ្នកខិតកៅអីទៅម្ខាង  រួចហើយឈរជារង្វង់ចំកណ្តាលបន្ទប់

» គ្រប់គ្នានឹងត្រូវបានសួរឱ្យគិតអំពីកត្តាដែលអាចបង្កើនការប្រឈមនឹងការចម្លងមេរោគអេដស៍ នៅពេលចិញ្ចឹមកូនដោយដោះ

» អ្នកដែលឆ្លើយត្រូវៗទៅឈរនៅចំកណ្តាលរង្វង់

» អ្នកនឹងត្រូវបានសួរផងដែរអំពីវិធីដែលអាចកាត់បន្ថយការចម្លងនេះ បើអ្នកឆ្លើយត្រូវនឹងត្រូវបានឱ្យមកចូលរួមក្នុងក្រុមធំវិញ

» អ្នកត្រូវធ្វើដូច្នោះរហូតទាល់តែអស់សំណួរ

» ពិនិត្យមើល ថាតើក្រុមដែលនៅខាងក្នុងអាចទៅចូលរួមជាមួយក្រុមធំម្តងទៀតបានដែរឬទេ។

### អនុវត្តការចិញ្ចឹមកូននិងការចម្លងមេរោគអេដស៍

**ការចិញ្ចឹមកូនដោយទឹកដោះម្តាយ**

- ផ្តល់នូវសារធាតុចិញ្ចឹមបានសមស្របបំផុតសំរាប់ទារក ក៏ប៉ុន្តែវាអាចប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយចន្លោះពី ៥-១៥%

**ការចិញ្ចឹមកូនដោយទឹកដោះគោម្សៅជំនួសទឹកដោះម្តាយ**

- អាចបង្កឱ្យមានជម្ងឺរាក ជម្ងឺផ្លូវដង្ហើម និងកង្វះអាហារូបត្ថម្ភ បើសិនជាអាហារមិនបានរៀបចំឱ្យមានសុវត្ថិភាពនិងត្រឹមត្រូវទេ ក៏ប៉ុន្តែវាមិនប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូនទេ

10

### តើបញ្ហានៃការចម្លងមេរោគអេដស៍តាមរយៈ ការបំបៅដោះមានទំហំប៉ុណ្ណា?

- ប្រេវ៉ាឡង់នៃអ្នកឆ្លងមេរោគអេដស៍នៅកម្ពុជា មានប្រហែល ២% ។ ក្នុងចំណោមស្ត្រី១000នាក់ មានស្ត្រីប្រហែល២0នាក់មានផ្ទុកមេរោគអេដស៍
- ការប្រឈមនឹងការចម្លងមេរោគអេដស៍តាមរយៈការបំបៅដោះមានប្រហែល១៥%

**ក្នុងចំណោមស្ត្រីផ្ទុកមេរោគអេដស៍ ចំនួន២0នាក់ ជាមួយនឹងកូន២0នាក់:**

- មានទារកប្រហែល៤នាក់នឹងឆ្លងមេរោគអេដស៍ពីម្តាយនៅពេលមានផ្ទៃពោះ ពេលឈឺពោះសំរាល និងសំរាល
- មានទារកប្រហែល៣នាក់នឹងឆ្លងនៅពេលបំបៅដោយដោះម្តាយ

11

## កត្តាប្រឈមនឹងការចម្លងមេរោគអេដស៍នៅពេលបំបៅកូនដោយដោះម្តាយ

ការប្រឈមនឹងការចម្លងមេរោគអេដស៍តាមរយៈការបំបៅកូនដោយដោះម្តាយ កើនឡើងនៅពេលដែល:

- ម្តាយមានបន្ទុកមេរោគអេដស៍ខ្ពស់
  - ដោយសារតែទើបនឹងឆ្លងថ្មី (នៅត្រីមាសចុងក្រោយនៃការមានផ្ទៃពោះ ឬនៅពេលបំបៅកូនដោយដោះម្តាយ)
  - ដោយសារតែជម្ងឺអេដស៍វិវត្តទៅមុខ
- បំបៅកូនដោយដោះម្តាយរយៈពេលយូរ
- ចិញ្ចឹមកូនដោយអាហារចំរុះ
- រលាកដោះ ឬប្រេះចុងដោះ
- កូនមានផ្សិតក្នុងមាត់ ឬដំបៅមាត់

12

## ការចិញ្ចឹមកូនដោយដោះម្តាយ ការបង្ការដោយប្រើឱសថ ARV និង ការព្យាបាលដោយ ART

- ការបង្ការដោយឱសថ ARV មិនបានផ្តល់នូវការការពារដល់ទារកនៅក្នុងពេលបំបៅដោះទេ
- ការព្យាបាលដោយ ART ផ្តល់ការការពារដល់ទារកពីការចម្លងមេរោគអេដស៍ជារៀងរហូត ក្នុងកំឡុងពេលកំពុងបំបៅកូនដោយដោះម្តាយ ដោយធ្វើឱ្យបន្ទុកមេរោគអេដស៍របស់ម្តាយនៅទាប

13

## គ្រោះប្រឈមនៃការចិញ្ចឹមកូនដោយអាហារចំរុះ

- កូនដែលចិញ្ចឹមដោយដោះម្តាយ មិនត្រូវផ្តល់អាហារឬភេសជ្ជៈផ្សេងទៀតក្រៅពីទឹកដោះម្តាយទេ ដោយសារតែមានភស្តុតាងបង្ហាញថា គ្រោះប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយមានកំរិតខ្ពស់ ដែលបណ្តាលមកពី:
  - ប៉ះពាល់ដល់ពោះវៀនរបស់កូន
  - ការប្រឈមនឹងការរាករូស

ដែលជាហេតុនាំឱ្យមេរោគអេដស៍ចូលទៅក្នុងខ្លួនរបស់ទារកបានយ៉ាងស្រួល

14

## សកម្មភាពទី៣: ការពិភាក្សា: គោលនយោបាយជាតិស្តីអំពីការចិញ្ចឹមកូន

» ស្លាយទី១៦-១៧ រៀបរាប់អំពីការណែនាំរបស់អង្គការសុខភាពពិភពលោក ស្តីអំពីការចិញ្ចឹមកូន

» ស្លាយទី១៨ អធិប្បាយអំពីគោលការណ៍ណែនាំជាតិ ស្តីអំពីការចិញ្ចឹមកូនសម្រាប់ស្រ្តីផ្ទុកមេរោគអេដស៍

### គោលនយោបាយជាតិស្តីពីការចិញ្ចឹមកូន

“ជាគោលការណ៍ទូទៅ សំរាប់គ្រប់ប្រជាជនទាំងអស់ដោយមិនគិតពីអាត្រាឆ្លងមេរោគអេដស៍ ការចិញ្ចឹមកូនដោយដោះត្រូវបានការពារ លើកកំពស់ និងគាំទ្រ”

សេចក្តីថ្លែងការណ៍នៃគោលនយោបាយជាតិស្តីពីមេរោគអេដស៍និងការចិញ្ចឹមកូន បានរៀបរៀងឡើងដោយ UNAIDS, WHO, UNICEF, 1997

16

### ការចិញ្ចឹមកូន ការណែនាំសំរាប់ស្ត្រីដែលមិនមានផ្ទុកមេរោគអេដស៍ (១)

ស្ត្រីដែលគ្មានផ្ទុកមេរោគអេដស៍ឬស្ត្រីដែលមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនត្រូវបានលើកទឹកចិត្តនិងគាំទ្រឱ្យ:

- បំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ក្នុងអំឡុងពេល៦ខែដំបូងនៃជីវិតទារក
- បន្តបំបៅដោះកូនរហូតដល់កុមារមានអាយុ២ឆ្នាំ
- ចាប់ផ្តើមផ្តល់អាហារបន្ថែមដែលមានតុល្យភាពអាហារូបត្ថម្ភដល់កូន នៅពេលដែលកូនមានអាយុ៦ខែឡើងទៅ

ប្តីប្រពន្ធគួរតែយល់ដឹងពីការប្រឈមរបស់ទារក បើសិនជាម្តាយមានផ្ទុកមេរោគអេដស៍ ក្នុងពេលបំបៅដោះ និងអនុវត្តសុវត្ថិភាពនៃការរួមភេទ ដើម្បីកាត់បន្ថយការប្រឈមនឹងការចម្លង និងប្រឈមនឹងការឆ្លងមេរោគអេដស៍នេះ។ 17

### ការចិញ្ចឹមកូន ការណែនាំសំរាប់ស្ត្រីដែលមានផ្ទុកមេរោគអេដស៍ (២)

- ស្ត្រីដែលមានផ្ទុកមេរោគអេដស៍ត្រូវបានលើកទឹកចិត្តឱ្យបំបៅកូនដោយទឹកដោះម្តាយរយ:ពេល៦ ខែដំបូងនៃជីវិត
- ការបំបៅកូនដោយទឹកដោះម្តាយគួរតែបញ្ឈប់ឱ្យបានឆាប់ ហើយម្តាយត្រូវផ្តាច់ដោះកូន ក្នុងរវាងពី២-៣ថ្ងៃ ទៅ២-៣សប្តាហ៍
- ស្ត្រីផ្ទុកមេរោគអេដស៍អាចចិញ្ចឹមកូនដោយទឹកដោះគោម្សៅ បើសិនជា អាចទទួលយកបាន អាចធ្វើបាន អាចលៃលករកបាន មាននិរន្តរភាព និងមានសុវត្ថិភាព
- ម្តាយផ្ទុកមេរោគអេដស៍ទាំងអស់គួរទទួលការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូន

18

### និយមន័យ

**អាចទទួលយកបាន(Acceptable):** ការចិញ្ចឹមកូនដោយទឹកដោះគោម្សៅអាចទទួលយកបានពីគ្រួសារ មិត្តភ័ក្តិ សហគមន៍ ឬពីសង្គម

**អាចធ្វើបាន(Feasible):** ម្តាយនិងសមាជិកគ្រួសារមានចំណេះដឹង ជំនាញ ពេលវេលា និងធនធាន សំរាប់ជួយក្នុងការរៀបចំទឹកដោះគោម្សៅសំរាប់កូន

**អាចលៃលករកបាន(Affordable):** គ្រួសារអាចលៃលកទិញទឹកដោះគោម្សៅបាន (រួមទាំងសំភារ:បន្ថែម ទឹកនិងប្រេងសំរាប់ដាំទឹក) ដើម្បីចិញ្ចឹមទារកដោយមិនឱ្យប៉ះពាល់ដល់តំរូវការចាំបាច់ក្នុងគ្រួសារ

**មាននិរន្តរភាព(Sustainable):** ការផ្គត់ផ្គង់ ទឹកដោះគោម្សៅ គឺគ្រប់គ្រាន់និងអាចជឿជាក់បាន

**មានសុវត្ថិភាព(Safe):** គ្រួសារអាចទទួលបាននូវទឹកស្អាតសំរាប់លាយទឹកដោះគោម្សៅ និងសំរាប់ លាងសំអាតសំភារ:ផ្សេងៗ ហើយនិងអាចទទួលបាននូវសេវាថែទាំសុខភាពដែលនៅជិតផ្ទះ

19

សិក្ខាកាមគួរអាន“ ១០ដំណាក់កាលដើម្បីទទួលជោគជ័យក្នុងការចិញ្ចឹមកូនដោយទឹកដោះម្តាយ (WHO, UNICEF) នៅក្នុងឧបសម្ព័ន្ធនៃម៉ូឌុលនេះ

## សកម្មភាពទី៤: ការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូន

» ចំណាំ: ម្តាយគឺជាមនុស្សតែម្នាក់គត់ដែលជាអ្នកសម្រេចចិត្តក្នុងការជ្រើសរើសវិធីចិញ្ចឹមកូន

### គោលបំណងនៃការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូន

លើកកំពស់ការអនុវត្តន៍វិធីចិញ្ចឹមកូនដែលប្រកបដោយសុវត្ថិភាពនិងដើម្បីកាត់បន្ថយ:

- គ្រោះប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- អត្រាស្លាប់និងអត្រាឈឺរបស់កុមារដែលបណ្តាលមកពីកង្វះអាហារូបត្ថម្ភនិងជម្ងឺឆ្លង
- ការប្រឈមនឹងការមាក់ងាយដែលមានទៅលើម្តាយនិងក្រុមគ្រួសាររបស់គាត់

អនុវត្តការចិញ្ចឹមកូនឱ្យបានត្រឹមត្រូវតាមការណែនាំអាចកាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងកាត់បន្ថយការស្លាប់របស់កូនដែលបណ្តាលមកពីជម្ងឺរាកនិងជម្ងឺឆ្លង

21

### ការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូន

ការផ្តល់ប្រឹក្សាត្រូវតែដាក់បញ្ចូលនូវព័ត៌មាននិងការអប់រំដូចជា:

- គ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ពីម្តាយទៅកូនតាមរយៈការបំបៅកូនដោយដោះម្តាយ
- សារៈសំខាន់នៃការចិញ្ចឹមកូន ដើម្បីឱ្យកុមារមានសុខភាពល្អ, ទទួលបាននូវអាហារូបត្ថម្ភគ្រប់គ្រាន់ ការធំធាត់និងការលូតលាស់បានល្អ
- វិធីចិញ្ចឹមកូនផ្សេងៗ គុណសម្បត្តិនិងគុណវិបត្តិនៃវិធីទាំងនោះ

ការផ្តល់ប្រឹក្សាត្រូវគិតដល់ការអនុវត្តន៍ ជំនឿ និង ទំនៀមទំលាប់នៃតំបន់នីមួយៗ

22

### ការសំរេចចិត្តពីការចិញ្ចឹមកូន

ម្តាយដែលមានផ្ទុកមេរោគអេដស៍:

- មានសិទ្ធិជ្រើសរើសវិធីចិញ្ចឹមកូនដែលខ្លួនពេញចិត្ត
- ត្រូវទទួលការផ្តល់ប្រឹក្សាដើម្បីធ្វើការសំរេចចិត្តជ្រើសរើសវិធីចិញ្ចឹមកូន

អ្នកផ្តល់ប្រឹក្សា:

- មានតួនាទីលើកកំពស់និងគាំទ្រការចិញ្ចឹមកូន
- ត្រូវធ្វើជាមគ្គុទេសក៏ដល់ម្តាយដែលផ្ទុកមេរោគអេដស៍ ក្នុងការជ្រើសរើសវិធីចិញ្ចឹមកូនឱ្យបានត្រឹមត្រូវតាមស្ថានភាពរស់នៅរបស់គាត់

23

## សកម្មភាពទី៥: តើការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូនត្រូវធ្វើឡើងនៅពេលណានិងផ្តល់ប្រឹក្សាដោយអ្នកណា?

**កំណត់សម្គាល់:**

» ការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូនត្រូវធ្វើឱ្យបានច្រើនដងតាំងពីមានផ្ទៃពោះ រហូតដល់ក្រោយសម្រាល

» គឺជាការសំខាន់ណាស់ដែលម្តាយត្រូវមានទំនុកចិត្តលើជម្រើសរបស់ខ្លួន និងប្រសិនជាអាចទៅរួច ការសម្រេចចិត្តរបស់ម្តាយគួរទទួលបាននូវការគាំទ្រពីគ្រួសារនិងពីសហគមន៍

### តើការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូនត្រូវធ្វើឡើងនៅពេលណា?

■ **មុនពេលសំរាល**

■ ផ្តល់ព័ត៌មាន និង ការអប់រំ ដើម្បីជួយឱ្យម្តាយជ្រើសរើសវិធីចិញ្ចឹមកូនរបស់គាត់

■ **ក្រោយពេលសំរាល**

■ ផ្តល់ការណែនាំនិងគាំទ្រម្តាយ ក្នុងការអនុវត្តន៍វិធីចិញ្ចឹមកូនដែលគាត់បានជ្រើសរើស

25

### តើអ្នកណាជាអ្នកផ្តល់ប្រឹក្សាពីការចិញ្ចឹមកូន?

គ្រប់បុគ្គលិកសុខាភិបាលដែលបានបណ្តុះបណ្តាលពីកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន នៅសេវាថែទាំផ្ទៃពោះ សំរាលនិងក្រោយសំរាល មានតួនាទីយ៉ាងសំខាន់ក្នុងការ :

■ ផ្តល់ព័ត៌មានអំពីវិធីចិញ្ចឹមកូនដល់ស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍ និង

■ ផ្តល់ការណែនាំនិងគាំទ្រដល់ស្ត្រី ទាំងក្នុងអំឡុងពេលមានផ្ទៃពោះ និងក្រោយពេលសំរាល ។

សេវាព្យាបាលជម្ងឺអេដស៍កុមារមានតួនាទីយ៉ាងសំខាន់ក្នុងការវាយតម្លៃពីអាហារូបត្ថម្ភ និង តាមដានទារកនិងកុមារដែលប្រឈមចាប់ពីអាយុ៦សប្តាហ៍ឡើងទៅ ។

26

### ការគាំទ្រនៅតាមសហគមន៍

■ ការអប់រំនៅតាមសហគមន៍ និងសកម្មភាពចល័តអាចជួយជំរុញឱ្យលទ្ធផលនៃការផ្តល់ប្រឹក្សាពីការចិញ្ចឹមកូននៅតាមមណ្ឌលសុខភាពកាន់តែប្រសើរឡើង

■ ក្រុមថែទាំតាមផ្ទះ ក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៍-អ្នកជម្ងឺអេដស៍ និងអង្គការនានា មានតួនាទីយ៉ាងសំខាន់ក្នុងការជួយគាំទ្រស្ត្រីនៅតាមផ្ទះ

អ្នកផ្តល់ប្រឹក្សានៃសេវា **PMTCT** ត្រូវឱ្យប្រាកដថា ស្ត្រីផ្ទុកមេរោគអេដស៍នឹងទទួលបាននូវការគាំទ្រពីសហគមន៍បើសិនជាមាន ដោយមានការយល់ព្រមពីសាមីខ្លួនផង ។

27

## សកម្មភាពទី៦: ពាក្យគន្លឹះ វិធីចិញ្ចឹមកូន

» គ្រូនឹងរៀបរាប់ប្រាប់អ្នកពីកត្តាមួយចំនួនដែលត្រូវលើកយកមកពិចារណា នៅពេលធ្វើការប្រៀបធៀបពីជម្រើសនៃការចិញ្ចឹមកូនផ្សេងៗគ្នា

### វិធីចិញ្ចឹមកូន    កត្តានាំឱ្យរាយដែលត្រូវពិចារណា

បន្ថែមពីលើគ្រោះប្រឈមនឹងការចម្លងមេរោគអេដស៍ទៅកូន នៅពេលជ្រើសរើសវិធីចិញ្ចឹមកូន កត្តាដែលត្រូវពិចារណាមាន:

- សមាសភាគនៃសារជាតិចិញ្ចឹមនៅក្នុងអាហារ
- គ្រោះប្រឈមនឹងការឆ្លងរោគបង្កដោយបាក់តេរី
- ការចំណាយ
- លទ្ធផលនៃការពន្យារកំណើត
- លើកកម្លាំងចិត្ត
- កត្តាសង្គម និងវប្បធម៌

29

## សកម្មភាពទី៧: ការងារជាក្រុម: ជម្រើសវិធីចិញ្ចឹមកូន

» គោលបំណងនៃសកម្មភាពនេះគឺដើម្បីពិនិត្យពីជម្រើសនៃវិធីចិញ្ចឹមកូនខុសៗគ្នា ព្រមទាំងគុណសម្បត្តិនិងគុណវិបត្តិរបស់វា

» គ្រូនឹងចែកសិក្ខាកាមជា៤ក្រុម និងឱ្យក្រុមនីមួយៗនូវប្រធានបទដូចតទៅនេះ:

ក្រុមទី១: ស្លាយទី៣២-៣៨
ការចិញ្ចឹមកូនដោយទឹកដោះម្តាយតែមួយមុខគត់និងការផ្តាច់ដោះភ្លាមៗ

ក្រុមទី២: ស្លាយទី៣៩-៤៥
ការចិញ្ចឹមកូនដោយទឹកដោះគោម្សៅជំនួសទឹកដោះម្តាយ

ក្រុមទី៣: ស្លាយទី៤៦-៤៨
ការចិញ្ចឹមកូនដោយទឹកដោះកម្តៅ (ទឹកដោះរឹតពីដោះម្តាយ)

» គិតអំពីជម្រើសនៃការចិញ្ចឹមកូន និងសរសេរអំពីគុណសម្បត្តិនិងគុណវិបត្តិរបស់វិធីនីមួយៗ និងចំណុចផ្សេងៗទៀតដែលអ្នករកឃើញតាមដែលអាចធ្វើបាន

» ក្រុមនីមួយៗនឹងឡើងមកសង្ខេបគំនិតរបស់ក្រុមខ្លួន

» សរសេរចម្លើយពីក្រោមប្រធានបទនៅលើក្តារខៀនឱ្យបានសមស្រប

» ក្រោយពីក្រុមនីមួយៗធ្វើការបង្ហាញពីកិច្ចការរបស់ខ្លួនរួចហើយ អ្នកត្រូវពិភាក្សាលើជម្រើសនៃការចិញ្ចឹមកូននីមួយៗ ដោយផ្តោតទៅលើគុណសម្បត្តិ និងគុណវិបត្តិនៃជម្រើសនីមួយៗ និងរិះរកវិធីកាត់បន្ថយគ្រោះប្រឈមទាំងនោះ

## ការជ្រើសរើសវិធីចិញ្ចឹមកូនៈ  រយៈពេល៦ខែដំបូងនៃជីវិត

១. ការចិញ្ចឹមកូនដោយដោះម្តាយតែមួយមុខគត់ និងការផ្តាច់ដោះភ្លាមៗ ជាជំរើសមួយដែលត្រូវបានណែនាំសំរាប់ម្តាយដែលផ្ទុកមេរោគអេដស៍នៅក្នុងប្រទេសកម្ពុជា

២. ការចិញ្ចឹមដោយទឹកដោះគោម្សៅជំនួសទឹកដោះម្តាយ

៣. ការចំអិនទឹកដោះម្តាយ

គ្រប់កុមារទាំងអស់ត្រូវការអាហារបន្ថែមគ្រប់គ្រាន់ ចាប់ពីអាយុ៦ខែឡើងទៅ 31

## ការចិញ្ចឹមកូនដោយទឹកដោះម្តាយតែមួយគត់  និងការឆាប់ផ្តាច់ដោះ

ការចិញ្ចឹមកូនដោយទឹកដោះម្តាយតែមួយមុខគត់ មានន័យថាឱ្យទារកបៅដោះម្តាយតែមួយមុខប៉ុណ្ណោះ

- គ្មានភេសជ្ជៈ ឬអាហារបន្ថែមទេ ( សូម្បីតែទឹកក៏មិនចាំបាច់ដែរ)
- ឱសថ ឬ វីតាមីនជំនួយបន្ថែមមួយចំនួនអាចផ្តល់ឱ្យបាន ប្រសិនជាចាំបាច់

**ការឆាប់ផ្តាច់ដោះ** មានន័យថា ត្រូវបញ្ឈប់ការបំបៅកូនដោយដោះឱ្យបានឆាប់ នៅពេលដែលមានអាហារជំនួសទឹកដោះម្តាយសមស្របហើយ : នៅពេលទារកមានអាយុ គ្រប់៦ខែឬតិចជាង

* សមស្របមានន័យថាៈអាចទទួលយកបាន អាចធ្វើបាន អាចលៃលករកទិញបាន មាននិរន្តរភាព និងមានសុវត្ថិភាព "ស្វាយទី៨"

32

## គុណសម្បត្តិនៃទឹកដោះម្តាយ

ទឹកដោះម្តាយៈ

- ផ្តល់គ្រប់ជីវជាតិ និងទឹកគ្រប់គ្រាន់ដល់តំរូវការរបស់ទារក
- ងាយស្រួលក្នុងការរំលាយ
- មានអង្គបដិបក្ខប្រាណការពាររាងកាយ និងការពារទារកពីជម្ងឺមួយចំនួនពិសេសជម្ងឺ រាករូស និង ជម្ងឺរលាកផ្លូវដង្ហើម
- មិនចាំបាច់ចំណាយ មានទឹកដោះជានិច្ច និងមិនចាំបាច់មានការរៀបចំពិសេសអ្វីឡើយ

33

## គុណសម្បត្តិនៃការចិញ្ចឹមកូនដោយទឹកដោះម្តាយ

ទឹកដោះម្តាយៈ

- បង្កើនភាពស្និទ្ធស្នាលរវាងម្តាយនិងកូន
- ជួយក្នុងការពន្យារកំណើត
- ការពារសុខភាពម្តាយ
- ក៏រិតនៃការចម្លងមេរោគអេដស៍ពីម្តាយទៅកូនមានក៏រិតទាបជាងការចិញ្ចឹមកូនដោយអាហារចំរុះ
- ចំណាយតិចជាងការប្រើទឹកដោះគោម្សៅ
- ត្រូវបានគេនិយមអនុវត្ត ដូច្នេះគេនឹងមិនសួរថាហេតុអ្វីបានជាបំបៅកូនដោយដោះ

34

## គុណវិបត្តិនៃការចិញ្ចឹមកូនដោយទឹកដោះម្ដាយ

- ទារកប្រឈមនឹងការឆ្លងមេរោគអេដស៍ពីម្ដាយជានិច្ចក្នុងរយៈពេលបំបៅដោះ ហើយគ្រោះប្រឈមកាន់តែខ្ពស់នៅពេលដែលៈ
  - ដោះម្ដាយមានបញ្ហាដូចជា ប្រេះចុងដោះឬរលាកដោះ ។ ដូច្នេះការថែរក្សាដោះមានសារៈសំខាន់ណាស់ នៅក្នុងរយៈពេលបំបៅកូន
  - មានជ្រាំងនៅក្នុងមាត់ទារក-ម្ដាយត្រូវបញ្ជូនកូនទៅកាន់គ្លីនិកកុមារដើម្បីធ្វើការព្យាបាល
- ម្ដាយដែលបំបៅកូនដោយដោះ ត្រូវបរិភោគអាហារបន្ថែម៥០០គីឡូកាល់ឡូរីក្នុងមួយថ្ងៃ ដើម្បីទ្រទ្រង់ការចិញ្ចឹមកូនដោយទឹកដោះម្ដាយតែមួយមុខគត់
- ការបំបៅកូនមានការលំបាកប្រសិនបើម្ដាយត្រូវទៅប្រកបការងារ ឬនៅពេលដែលម្ដាយឈឺ

*see WHO IYCF Counselling training course, session 19

35

## ការផ្ដាច់ផ្ដាច់ដោះ

- មេរោគអេដស៍អាចឆ្លងទៅកូននៅគ្រប់ពេលនៃការបំបៅកូនដោយដោះ
- ការផ្ដាច់ផ្ដាច់ដោះកាត់បន្ថយការប្រឈមនឹងការចម្លងដោយកាត់បន្ថយពេលវេលាដែលទារកត្រូវប្រឈមនឹងមេរោគអេដស៍ដែលនៅក្នុងទឹកដោះម្ដាយ
- ការបំបៅដោះអាចបញ្ឈប់បានគ្រប់ពេលវេលា និងឆាប់រហ័សនៅពេលដែលមានអាហារជំនួសគ្រប់គ្រាន់
- ចន្លោះពេលនៃការជំនួសទឹកដោះម្ដាយដោយទឹកដោះគោម្សៅ ធ្វើពី២-៣ថ្ងៃ ទៅ ២-៣សប្ដាហ៍
- មុនពេលប្ដូររបៀបចិញ្ចឹមកូន ស្ត្រីផ្ទុកមេរោគអេដស៍ ត្រូវទទួលៈ
  - ការផ្ដល់ប្រឹក្សានិងការណែនាំពីរបៀបបញ្ឈប់ការបំបៅកូនដោយដោះម្ដាយ និងធ្វើយ៉ាងណាឱ្យដោះនៅមានសុខភាពល្អ
  - គាំទ្រផ្លូវចិត្ត
  - គាំទ្រអាហារូបត្ថម្ភដល់កុមារ

36

## គុណសម្បត្តិនៃការផ្ដាច់ផ្ដាច់ដោះ

ការប្រឈមនឹងការឆ្លងមេរោគអេដស៍របស់ទារកតាមរយៈការបៅទឹកដោះម្ដាយ ត្រូវបានបញ្ចប់នៅពេលឈប់ឱ្យកូនបៅ *

ជំរើសនៃការចិញ្ចឹមកូននេះៈ

- ទទួលបាននូវគុណប្រយោជន៍ពីទឹកដោះម្ដាយរយៈពេល៦ខែនៃជីវិតទារកដែលនៅពេលនោះវាផ្ដល់នូវផលចំណេញច្រើនបំផុត និង
- បញ្ចប់ការប្រឈមរបស់ទារកទៅនឹងមេរោគអេដស៍ នៅពេលដែលទឹកដោះម្ដាយលែងជាវត្ថុសំខាន់ខ្លាំងសំរាប់សុខភាពរបស់កូនតទៅទៀត

* បើសិនជាដឹងថាកុមារឆ្លងមេរោគអេដស៍ហើយ មិនត្រូវបញ្ឈប់ការបំបៅដោះទេ

37

## គុណវិបត្តិនៃការផ្ដាច់ផ្ដាច់ដោះ

ការផ្ដាច់ផ្ដាច់ដោះៈ

- ធ្វើឱ្យទារកប្រឈមនឹងគ្រោះថ្នាក់ផ្សេងៗដែលបណ្ដាលមកពីអាហារជំនួសក្រោយអាយុ៦ខែ
- ត្រូវការមានយន្ដកម្មនានាដើម្បីធានាពីសុវត្ថិភាពនៃអាហារជំនួសទឹកដោះម្ដាយមុនពេលបញ្ឈប់ការបំបៅកូន

ការត្រិះរិះពិចារណាផ្សេងៗទៀតៈ

- ការប្ដូរមកចិញ្ចឹមកូនដោយប្រើពែងវិញអាចមានការពិបាកសំរាប់ម្ដាយនិង កូន
- ដោះម្ដាយអាចឡើងតឹងឈឺនិងមានបង្ករោគដែលទាមទារឱ្យមានការគាំទ្រនៅចន្លោះពេលនៃការផ្ដាច់ដោះនោះ
- ប្រសិទ្ធិភាពពន្យារកំណើតនៃការបំបៅដោះកូនត្រូវបានបញ្ចប់

38

## ការចិញ្ចឹមអាហារជំនួសទឹកដោះម្ដាយដល់កូន ដោយប្រើទឹកដោះគោម្សៅ (១)

ការចិញ្ចឹមអាហារជំនួសទឹកដោះម្ដាយដល់កូនក្នុងរយៈពេល៦ខែដំបូងមានន័យថាផ្ដល់ទឹកដោះគោម្សៅដែលមានជីវជាតិគ្រប់គ្រាន់សមស្របដល់ទារក

> ការប្រឈមនៃអាហារជំនួសទឹកដោះម្ដាយ ត្រូវឱ្យតិចជាងការប្រឈមនឹងការឆ្លងមេរោគអេដស៍ បើមិនដូច្នេះទេ វានឹងមិនមានផលប្រយោជន៍អ្វីទេ

39

## ការចិញ្ចឹមអាហារជំនួសទឹកដោះម្ដាយដល់កូន ដោយប្រើទឹកដោះគោម្សៅ (២)

ការចិញ្ចឹមដោយអាហារជំនួសទឹកដោះម្ដាយ ត្រូវបានចាត់ទុកថាជាជំរើសនៃការចិញ្ចឹមកូនមួយ បើសិនជាគ្រួសារ:

- ទទួលបានទឹកដោះគោម្សៅគ្រប់គ្រាន់ដែលគួរឱ្យជឿទុកចិត្តបានយ៉ាងហោចណាស់ក៏ ៦ខែដែរ និង
- មានធនធានសំរាប់រៀបចំផ្ដល់ឱ្យកូនបានត្រឹមត្រូវ និងមានសុវត្ថិភាពដូចជា:
  - ទឹក និងប្រេង
  - គ្រឿងចានឆ្នាំង
  - ជំនាញនិងពេលវេលា

40

## គុណសម្បត្តិនៃទឹកដោះគោម្សៅ

ទឹកដោះគោម្សៅ:

- មិនប្រឈមនឹងការចម្លងមេរោគអេដស៍ទេ
- ផលិតជាពិសេសសំរាប់កុមារ ដោយមានដាក់បញ្ចូលនូវសារជាតិសំខាន់ៗដែលចាំបាច់សំរាប់កុមារ
- ជាទូទៅ កូនត្រូវបានពង្រឹងដោយមានជីវជាតិដែកដែលចាំបាច់ និងមីក្រូសារជាតិផ្សេងៗទៀត
- ទារកអាចត្រូវបានចិញ្ចឹមដោយអ្នកផ្សេងទៀតបាន :ដើម្បីជួយម្ដាយ ឬនៅពេលម្ដាយធ្លាក់ខ្លួនឈឺ ។

41

## គុណវិបត្តិនៃការប្រើទឹកដោះគោម្សៅ (១)

ទឹកដោះគោម្សៅ:

- ពុំមានផ្ទុកនូវអង្គបដិបក្ខប្រាណការពាររាងកាយទេ
- ប្រឈមខ្ពស់នឹងជម្ងឺរាករូស ជម្ងឺរលាកសួត កង្វះអាហារូបត្ថម្ភ និងមានប្រតិកម្ម
- មិនអាចជួយការពារកុំឱ្យមានផ្ទៃពោះបានទេ
- ត្រូវរៀបចំឱ្យបានត្រឹមត្រូវ:
  - បើលាយខាប់ពេក នាំឱ្យមានជាតិអំបិលច្រើន
  - បើរាវពេក នាំឱ្យកង្វះអាហារូបត្ថម្ភ

42

## គុណវិបត្តិនៃការប្រើទឹកដោះគោម្សៅ (២)

- ម្តាយត្រូវបញ្ឈប់ការបំបៅដោះទាំងស្រុង បើមិនដូច្នេះទេការប្រឈមនឹងការចម្លងនឹងនៅតែបន្ត
- ការរៀបចំដោយពែងឬដបត្រូវការពេលវេលា ត្រូវធ្វើឱ្យបានត្រឹមត្រូវ និងត្រូវឱ្យមានទឹកស្អាតគ្រប់គ្រាន់ ភ្លើងនិងសាប៊ូ
- ទឹកដោះគោត្រូវលាយថ្មីៗសំរាប់មួយដងៗ បើសិនជាម្តាយមិនមានទូទឹកកកទេ
- សមាជិកគ្រួសារឬអ្នកជិតខាងអាចសួរពីមូលហេតុនៃការប្រើទឹកដោះគោម្សៅ
- ទឹកដោះគោម្សៅមានតម្លៃថ្លៃ។ ការផ្គត់ផ្គង់ទឹកដោះគោម្សៅដល់កូន ត្រូវតែគួរឱ្យទុកចិត្តបាននិងត្រូវតែមានជាប់ជានិច្ច

43

## តំរូវការនៅក្នុងការចិញ្ចឹមទារកដោយអាហារជំនួសទឹកដោះម្តាយ

ទារកមានអាយុតិចជាង៦ខែ ត្រូវការទឹកដោះគោម្សៅ

១៥០ មល/គក្រ នៃទំងន់/ ២៤ ម៉ោង

បើគិតជាសរុបក្នុងរយៈពេល៦ខែ ទារកត្រូវការៈ

- ៤០កំប៉ុង × ៥០០g កំប៉ុងនៃទឹកដោះគោម្សៅ
- តម្លៃក្នុងមួយកំប៉ុងគឺ ២ដុល្លារ

សរុបទាំងអស់ ៨០ ដុល្លារ សំរាប់៦ខែ

44

## ភេសជ្ជៈដែលមិនសមស្របសំរាប់ទារក

ម្តាយមិនគួរឱ្យកូនទទួលទាននូវភេសជ្ជៈមួយចំនួនដូចខាងក្រោមៈ

- ទឹកដោះសត្វដែលត្រូវបានគេពង្រាវរួចហើយ
- ទឹកដោះគោម្សៅដែលគ្មានជាតិក្រែម ឬ ទឹកដោះគោម្សៅដែលមានជាតិខ្លាញ់តិច
- ទឹកដោះគោខាប់ ឬ ទឹកដោះគោផ្អែម
- បបររាវៗពីធញ្ញជាតិ
- ទឹកផ្លែឈើ តែ និង សូដា

45

## ទឹកដោះម្តាយដែលច្របាច់យកមកកំដៅសំលាប់មេរោគ (១)

ទឹកដោះម្តាយដែលច្របាច់យកមកកំដៅសំលាប់មេរោគ គឺជាជំរើសមួយដែលត្រូវយកមកពិចារណាៈ

- បើសិនជាម្តាយចង់ឱ្យកូនផឹកទឹកដោះរបស់ខ្លួន
- បើសិនជាទឹកដោះគោម្សៅថ្លៃពេក ឬមិនអាចរកបាន
- សំរាប់កូនឈឺឬទំងន់មិនគ្រប់គីឡូនៅពេលកើត ទឹកដោះត្រូវកំដៅឱ្យពុះ និងទុកឱ្យត្រជាក់

46

## ទឹកដោះម្តាយដែលច្របាច់យកមកកំដៅសំលាប់មេរោគ (២)

គុណសម្បត្តិ:

- មេរោគអេដស៏ត្រូវបានសំលាប់ដោយកំដៅ
- សារធាតុការពារក្នុងទឹកដោះ អាចរក្សាបាននូវគុណប្រយោជន៏ ក្នុងការការពារទារក*
- ទឹកដោះម្តាយនៅតែមានរហូត
- សមាជិកដទៃទៀតក្នុងគ្រួសារអាចជួយម្តាយក្នុងការបំបៅទារកបាន

* អង្គបដិបក្សប្រាណមួយចំនួនអាចនឹងបាត់បង់ដោយសារកំដៅ

47

## គុណវិបត្តិនៃទឹកដោះដែលកំដៅ

គុណវិបត្តិនៃទឹកដោះកំដៅ:

- ទឹកដោះដែលបានកំដៅសំលាប់មេរោគមិនមានមេរោគអេដស៏មែន ប៉ុន្តែវាអាចមិនមានលក្ខណ:ល្អ ក្នុងការការពារនឹងជម្ងឺផ្សេងៗទៀតឱ្យបានប្រសើរដូចទឹកដោះដែលមិនកំដៅទេ

គុណវិបត្តិ ក្នុងការផ្គត់ផ្គង់ដទៃទៀត:

- ត្រូវការទឹកស្អាតសំរាប់លាងសំអាតសម្ភារ:សំរាប់ដាក់ទឹកដោះឱ្យទារកបៅ និង ប្រេងឥន្ធន: សំរាប់ដុតកំដៅទឹកដោះ
- ចំណាយពេលវេលា: ច្របាច់យកទឹកដោះ កំដៅសំលាប់មេរោគ បញ្ចុកទារកដោយប្រើពែង
- ទឹកដោះដែលបានកំដៅរួចត្រូវថែរក្សាទុកនៅកន្លែងត្រជាក់ និង ត្រូវបញ្ចុកទារកឱ្យអស់ក្នុងរយ:ពេល១ម៉ោងក្រោយកំដៅ
- អាចនឹងមានចោទជាសំណួរថា ហេតុអ្វីម្តាយត្រូវច្របាច់យកទឹកដោះខ្លួនឯង។ 48

# សកម្មភាពទី៨: ការប្រាប់អំពីស្ថានភាពផ្ទុកមេរោគអេដស៍ទៅអ្នកដទៃ និងអនុវត្តជម្រើសនៃការចិញ្ចឹមកូន

» គោលបំណងនៃលំហាត់នេះគឺដើម្បីពិនិត្យមើលអំពីការចិញ្ចឹមកូន និងការប្រាប់អំពីស្ថានភាពផ្ទុកមេរោគអេដស៍ដល់អ្នកដទៃ

» គ្រូនឹងដឹកនាំការពិភាក្សាដោយពិនិត្យមើលអំពីទំនាក់ទំនងរវាងជម្រើសនៃការចិញ្ចឹមកូន និងការប្រាប់អំពីស្ថានភាពផ្ទុកមេរោគដល់អ្នកដទៃ

» គិតអំពីវិធីចិញ្ចឹមកូនផ្សេងៗដែលត្រូវបានមើលឃើញដោយសង្គមកម្ពុជា

» តើស្ថានភាពផ្ទុកមេរោគអេដស៍ មានពាក់ព័ន្ធទៅនឹងការជ្រើសរើសវិធីចិញ្ចឹមកូនរបស់ម្តាយនិងគ្រួសាររបស់គាត់ដែរឬទេ?

» តើទស្សនៈរបស់អ្នកនៅទីក្រុងភ្នំពេញនិងអ្នកនៅទីជនបទ មានភាពខុសគ្នាយ៉ាងដូចម្តេចខ្លះ?

» តើមានកត្តាណាផ្សេងទៀត ដែលមានឥទ្ធិពលលើទស្សនៈនៃការចិញ្ចឹមកូនដែរឬទេ?

» តើអ្នកមានឧទាហរណ៍ដែលធ្លាប់ជួបប្រទះនៅក្នុងកន្លែងធ្វើការដែរឬទេ ដែលការជ្រើសរើសវិធីចិញ្ចឹមកូនជាពិសេស នាំឱ្យម្តាយត្រូវរងនូវការសួរសំណួរដែលពិបាកនឹងឆ្លើយ ឬត្រូវរងនូវការនិយាយដើម ថាមានជំងឺអេដស៍?

» តើអ្នកត្រូវគ្រប់គ្រងស្ថានភាពបែបនេះរបៀបណា? តើអាចវិធីដោះស្រាយផ្សេងទៀតដែរឬទេ?

» តើអ្នកមានយោបល់យ៉ាងណា ដើម្បីឆ្លើយតបទៅនឹងស្ថានភាពបែបនោះ?

» ត្រូវសម្គាល់អំពីសារៈសំខាន់នៃការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូន ដែលអាចជួយម្តាយឱ្យយល់ដឹង និងគិតអំពីការពាក់ព័ន្ធ ជាពិសេសអំពីជម្រើសនៃការចិញ្ចឹមកូន

» ការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូន អាចផ្តល់ឱកាសច្រើនក្នុងការជជែកអំពីការបើកចំហស្ថានភាពផ្ទុកមេរោគអេដស៍ឱ្យអ្នកដទៃដឹង ។

## ការប្រាប់ឱ្យគេដឹងអំពីស្ថានភាពរបស់ខ្លួន និង អនុវត្តវិធីចិញ្ចឹមកូន (១)

- វិធីចិញ្ចឹមកូនដែលម្តាយបានជ្រើសរើស អាចទាក់ទងគ្នាទៅនឹងការប្រាប់ពីស្ថានភាពផ្ទុកមេរោគ អេដស៍របស់ខ្លួន ទៅអ្នកដទៃ ក្នុងករណីដែលបញ្ហានេះមិនមែនជាករណីធម្មតាក្នុងគ្រួសារ និង សហគមន៍របស់គាត់
- ប្រជាជនរួមទាំងសមាជិកគ្រួសារ
  - អាចនឹងសួរនូវសំណួរជាច្រើន
  - ធ្វើការគិតស្មានផ្សេងៗ
  - និយាយដើមពីស្ត្រីរូបនេះ
- បញ្ហាទាំងនេះនាំឱ្យមានការលំបាកក្នុងការអនុវត្តន៍ឱ្យបានត្រឹមត្រូវនិងស្ថេរភាពលើវិធីចិញ្ចឹមកូនដែល ត្រូវបានជ្រើសរើស
- ស្ត្រីជាម្តាយនិងក្រុមគ្រួសាររបស់គាត់នឹងអាចត្រូវគេមាក់ងាយ
- វិធីចិញ្ចឹមកូនដែលគាត់បានជ្រើសរើសនឹងត្រូវបោះបង់ចោលទាំងស្រុង
- ទារកអាចប្រឈមនឹងការឆ្លងមេរោគអេដស៍ពីម្តាយកាន់តែខ្លាំងឡើង

50

## ការប្រាប់ឱ្យគេដឹងអំពីស្ថានភាពរបស់ខ្លួន និង អនុវត្តវិធីចិញ្ចឹមកូន (២)

តើយើងអាចធ្វើអ្វីបានខ្លះ?

មុនពេលសំរាល:
- លើកទឹកចិត្តប្តីឱ្យចូលរួមក្នុង:
  - ការទទួលការផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត
  - ការសំរេចចិត្តជ្រើសរើសរកវិធីចិញ្ចឹមកូន
- ផ្តល់ការប្រឹក្សាម្តងហើយម្តងទៀត ពីវិធីសាស្ត្រចិញ្ចឹមកូនដែលមានគុណភាពល្អ
  - ស្វែងយល់ពីការពាក់ព័ន្ធគ្នាក្នុងការជ្រើសរើសវិធីចិញ្ចឹមកូន
  - ប្រាប់ទុកជាមុន នូវការចោទសួររបស់គ្រួសារ ឬ សហគមន៍
  - ត្រូវឱ្យប្រាកដថា វិធីចិញ្ចឹមកូនត្រូវបានជ្រើសរើសដោយស្ត្រីជាម្តាយ ហើយនោះគឺជាការតាំងចិត្តរបស់គាត់
  - ស្វែងរកយន្តការគាំទ្រនៅក្នុងគ្រួសារនិងសហគមន៍

ក្រោយពេលសំរាល:
- បន្តផ្តល់ប្រឹក្សានៅគ្រប់ពេលដែលមានឱកាសល្អ
- រៀបចំឱ្យមានការតាមដានគាំទ្រជាប្រចាំពីសហគមន៍ប្រសិនបើមាន និងបើអាចទទួលយកបាន ។

51

## ម៉ូឌុលទី៤.៣.៣: ចំណុចគន្លឹះ

- រាល់ស្ត្រីផ្ទុកមេរោគអេដស៍ទាំងអស់ត្រូវទទួលការផ្តល់ប្រឹក្សានិងការគាំទ្រ ស្តីអំពីការចិញ្ចឹមកូនៈ
  - ដើម្បីឱ្យកូនរបស់គាត់បានធំធាត់និងលូតលាស់បានប្រសើរឡើង
  - ដើម្បីកាត់បន្ថយគ្រោះប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ក្នុងអំឡុងពេលបំបៅកូនដោយដោះម្តាយ ។
- ស្ត្រីជាម្តាយមានសិទ្ធិជ្រើសរើសវិធីចិញ្ចឹមកូនរបស់គាត់ ។ អ្នកផ្តល់ប្រឹក្សាមានតួនាទីផ្តល់ការគាំទ្រដល់ការជ្រើសរើសរបស់សាមីខ្លួន ។
- ការចិញ្ចឹមកូនដោយទឹកដោះម្តាយតែមួយមុខគត់និងការផ្តាច់ដោះភ្លាមៗ ជាជម្រើសមួយដែលត្រូវបានណែនាំឱ្យអនុវត្តសម្រាប់ស្ត្រីដែលផ្ទុកមេរោគអេដស៍នៅកម្ពុជា ។
- ស្ត្រីផ្ទុកមេរោគអេដស៍គួរជៀសវាងការបំបៅកូនដោយដោះ ប្រសិនជាអាចចិញ្ចឹមកូនដោយអាហារជំនួសទឹកដោះម្តាយបាន ហើយការចិញ្ចឹមនោះ អាចទទួលយកបាន អាចអនុវត្តបាន អាចលៃលករកបាន មាននិរន្តរភាព និង មានសុវត្ថិភាព ។
- ការផ្តល់ប្រឹក្សា ការអប់រំ និង ការគាំទ្រ គឺជាគន្លឹះសំខាន់ក្នុងការអនុវត្តន៍វិធីចិញ្ចឹមកូនឱ្យកាន់តែមានសុវត្ថិភាព ។

## ឧបសម្ព័ន្ធ: ព័ត៌មានជាមូលដ្ឋាន

| | |
|---|---|
| **យុទ្ធសាស្ត្រជាសកលៈ គោលដៅអនុវត្តន៍**<br>រៀបរៀងដោយអង្គការសុខភាពពិភពលោកនិងមូលនិធិរបស់អង្គការសហប្រជាជាតិដើម្បីកុមារ | |
| ១ | តែងតាំងឱ្យមានអ្នកសម្របសម្រួលកម្មវិធីចិញ្ចឹមកូនដោយទឹកដោះម្តាយ |
| ២ | ត្រូវប្រាកដថា គ្រប់គ្រឹះស្ថានដែលមានសេវាសម្រាលកូនត្រូវអនុវត្ត "ជំហានទាំង១០ដើម្បីជោគជ័យនៃការចិញ្ចឹមកូនដោយទឹកដោះម្តាយ" ដែលរៀបរៀងដោយអង្គការសុខភាពពិភពលោក និងមូលនិធិរបស់អង្គការសហប្រជាជាតិដើម្បីកុមារ |
| ៣ | អនុវត្តច្បាប់ទីផ្សារអន្តរជាតិស្តីអំពីការលក់ផលិតផលជំនួសទឹកដោះម្តាយ |
| ៤ | អនុវត្តនីតិវិធីការពារសិទ្ធិចិញ្ចឹមកូនដោយទឹកដោះម្តាយ ចំពោះស្ត្រីធ្វើការងារ |
| ៥ | បង្កើត  អនុវត្ត តាមដាននិងវាយតម្លៃ លើគោលនយោបាយគ្រប់ជ្រុងជ្រោយ ស្តីអំពីការចិញ្ចឹមទារកនិងកុមារតូចៗ**(IYCF)** |
| ៦ | ត្រូវធានាឱ្យបានថា គ្រប់ផ្នែកទាំងអស់គាំទ្រដល់ការចិញ្ចឹមកូនដោយទឹកដោះម្តាយតែមួយមុខគត់រយៈពេល៦ខែនិងបន្តបំបៅដោះរហូតដល់២ឆ្នាំ |
| ៧ | លើកកម្ពស់ការចិញ្ចឹមកូនដោយអាហារបន្ថែម រួមជាមួយនឹងការបំបៅដោះកូនឱ្យបានត្រឹមត្រូវតាមពេលវេលាគ្រប់គ្រាន់ មានសុវត្ថិភាពនិងសមស្រប |
| ៨ | ផ្តល់ការណែនាំស្តីពីការចិញ្ចឹមទារកនិងកុមារតូចៗដោយឡែកនៅក្នុងកាលៈទេសៈលំបាក |
| ៩ | ត្រូវពិចារណាអំពីតម្រូវការនីតិកម្ម សម្រាប់អនុវត្តច្បាប់ទីផ្សារអន្តរជាតិក្នុងការលក់ផលិតផលជំនួសទឹកដោះម្តាយ |

**ជំហានទាំង១០ ដើម្បីជោគជ័យក្នុងការចិញ្ចឹមកូនដោយទឹកដោះម្តាយ***

| ជំហានទាំង១០ ដើម្បីជោគជ័យក្នុងការចិញ្ចឹមកូនដោយទឹកដោះម្តាយ | |
|---|---|
| **គ្រប់សេវាសម្រាលកូនទាំងអស់ត្រូវ:** | |
| ១ | មានសៀវភៅគោលនយោបាយស្តីអំពីការចិញ្ចឹមកូនដោយទឹកដោះម្តាយ |
| ២ | បណ្តុះបណ្តាលដល់គ្រប់បុគ្គលិកទាំងអស់អំពីគោលនយោបាយនេះ |
| ៣ | ផ្តល់ព័ត៌មានដល់ស្ត្រីមានផ្ទៃពោះអំពីផលចំណេញនៃការចិញ្ចឹមកូនដោយទឹកដោះម្តាយ |
| ៤ | ជួយបង្រៀនម្តាយឱ្យចេះបំបៅដោះកូន ក្នុងអំឡុងពេល១ម៉ោងក្រោយសម្រាល |
| ៥ | បង្ហាញម្តាយអំពីរបៀបបំបៅដោះកូន និងអំពីរបៀបរក្សាដោះឱ្យនៅតែមានទឹកដោះនៅពេលដែលអ្នកទាំងពីរនៅបែកពីគ្នា |
| ៦ | មិនត្រូវឱ្យចំណីអាហារ ឬ ភេសជ្ជៈអ្វីដល់ទារកក្រៅពីទឹកដោះម្តាយឡើយ លើកលែងតែថ្នាំព្យាបាល |
| ៧ | ឱ្យម្តាយនិងទារករស់នៅជាមួយគ្នាឱ្យបាន២៤ម៉ោងក្នុង១ថ្ងៃ |
| ៨ | លើកទឹកចិត្តម្តាយឱ្យបំបៅដោះតាមតម្រូវការរបស់កូន |
| ៩ | មិនត្រូវឱ្យក្បាលដោះសិប្បនិម្មិតឬសន្តិភាពករ (របស់លួងក្មេងឱ្យឈប់យំ) ទៅទារកជញ្ជក់លេងទេ ចំពោះទារកដែលបៅដោះម្តាយ |
| ១០ | លើកកម្ពស់ឱ្យមានក្រុមគាំទ្រការចិញ្ចឹមកូនដោយទឹកដោះម្តាយនិងបញ្ជូនម្តាយទៅជួបក្រុមទាំងនោះ នៅពេលដែលម្តាយចេញពីមន្ទីរពេទ្យ |

* " ជំហានទាំង១០នៃការចិញ្ចឹមកូនដោយទឹកដោះម្តាយ គឺជាសេចក្តីសង្ខេបណែនាំសំខាន់ៗនៃសេចក្តីថ្លែងការណ៍រួមមួយដែលហៅថា " ការការពារ លើកកម្ពស់ និងគាំទ្រការចិញ្ចឹមកូនដោយទឹកដោះម្តាយ: តួនាទីពិសេសនៃសេវាសម្រាលកូន" ចេញផ្សាយដោយអង្គការសុខភាពពិភពលោក និងមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ នៅឆ្នាំ១៩៨៩

## ៤.៣.៤

## សុវត្ថិភាពនៅកន្លែងធ្វើការងារ

**វត្ថុបំណង**

នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមទាំងអស់អាចនឹង:

១. ពន្យល់អំពីសារៈសំខាន់នៃការអនុវត្តន៍ការងារប្រកបដោយសុវត្ថិភាពនៅផ្នែកសម្ភព

២. កំណត់បាននូវសមាសធាតុសំខាន់ៗក្នុងការអនុវត្តន៍ការងារដោយសុវត្ថិភាព

៣. ពិភាក្សាអំពីការគ្រប់គ្រងការងារដែលប្រឈមនឹងមេរោគអេដស៍:

ក) - ឱ្យនិយមន័យនៃពាក្យ**PEP**

ខ) - កំណត់បាននូវប្រភេទការងារខុសគ្នាដែលប្រឈមនឹងមេរោគអេដស៍

គ) - រៀបរាប់អំពីដំណើរការប៉ាន់ប្រមាណ និងអំពីការគ្រប់គ្រងការងារដែលងាយប្រឈមនឹងមេរោគ ទៅតាមដំណាក់កាលនីមួយៗ

ឃ) -អធិប្បាយអំពីដំណើរការគ្រប់គ្រងដំណាក់កាលនីមួយៗ



*រយៈពេល:* ***៣ម៉ោង***

## សកម្មភាពទី១: សុវត្ថិភាពក្នុងកន្លែងការងារ

| ការចម្លងមេរោគអេដស៍ | សុវត្ថិភាពបរិស្ថានការងារ |
|---|---|
| ការចម្លងមេរោគអេដស៍:<br>■ អាចកើតឡើងតាមរយៈការប៉ះពាល់ឈាម និងសារធាតុរាវនៃរាងកាយដោយផ្ទាល់ជាមួយនឹងមុខរបួសដែលចំហ ឬដោយមុតនឹងម្ជុល<br>■ បញ្ហានេះកើតឡើងញឹកញាប់បំផុតចំពោះអ្នកធ្វើការថែទាំសុខភាពដោយសារការមុតម្ជុល ក្នុងអំឡុងពេលថែទាំអ្នកផ្ទុកមេរោគអេដស៍<br>■ ការឆ្លងពីអ្នកជំងឺម្នាក់ទៅម្នាក់ទៀត អាចការពារបានដោយការកំចាត់មេរោគចេញពីឧបករណ៍ប្រើប្រាស់ឱ្យបានត្រឹមត្រូវតាមរយៈការប្រើសារជាតិគីមី ឬការរំងាប់មេរោគទាំងស្រុង។<br>7 | ការចម្លងភ្នាក់ងារបង្ករោគនៅក្នុងមន្ទីរពេទ្យ អាចការពារបានដោយៈ<br>■ អនុវត្តការបង្ការជាសកល<br>■ គ្រប់គ្រងបរិស្ថានការងារ<br>■ បណ្តុះបណ្តាលអប់រំបន្ថែមដល់បុគ្គលិកទាំងអស់អំពីការបង្ការរោគឆ្លង<br>8 |

## សកម្មភាពទី២: ធ្វើការជាក្រុមៈ អ្វីទៅជាការបង្ការជាសកល

» គោលបំណងនៃលំហាត់នេះគឺដើម្បីសង្ខេបអំពីសមាសភាគសំខាន់ៗ និងចំណុចទាក់ទងនឹងការបង្ការជាសកល

» គ្រូចែកសិក្ខាកាមជា៥ក្រុម និងចែកក្រុមនីមួយៗនូវប្រធានបទដូចតទៅ:

ក្រុមទី១: ការលាងសំអាតនិងការទុកដាក់សំរាម

ក្រុមទី២: ការកំចាត់មេរោគចេញពីសម្ភារៈប្រើប្រាស់

ក្រុមទី៣: ការចាប់កាន់វត្ថុមុតស្រួចឱ្យមានសុវត្ថិភាព

ក្រុមទី៤: របាំងការពារ

ក្រុមទី៥: គោលនយោបាយ នីតិវិធី និងការបណ្តុះបណ្តាល

» ក្រុមនីមួយៗត្រូវសរសេរឱ្យបានរហ័សនូវអ្វីដែលទាក់ទងនឹងប្រធានបទរបស់ក្រុមខ្លួន

» សិក្ខាកាមម្នាក់ៗនៃក្រុមនីមួយៗ ត្រូវឡើងមកបង្ហាញពីលទ្ធផលរបស់ក្រុមខ្លួនដល់ក្រុមធំ

## ការបង្ការជាសកល

ការបង្ការជាសកល គឺជាការអនុវត្តន៍ការត្រួតពិនិត្យជម្ងឺឆ្លងដ៏មានប្រសិទ្ធិភាព ហើយសាមញ្ញមួយត្រូវបានគេយកមកប្រើក្នុងការថែទាំៈ

- អ្នកជម្ងឺទាំងអស់
- គ្រប់ពេលវេលាទាំងអស់

ដើម្បីការពារដល់អ្នកថែរក្សាអ្នកជម្ងឺនិងអ្នកជម្ងឺ ឱ្យជៀសផុតពីការឆ្លងមេរោគទាំងឡាយរួមមានមេរោគដែលរស់នៅក្នុងឈាម ដូចជាៈ

- មេរោគអេដស៏
- មេរោគរលាកថ្លើមប្រភេទ B
- មេរោគរលាកថ្លើមប្រភេទ C

> កិរិតនៃការអនុវត្តន៏ការបង្ការជាសកល ស្ថិតនៅលើនិតិវិធីនៃការអនុវត្តន៏ មិនមែនស្ថិតនៅលើរោគវិនិច្ឆ័យរបស់អ្នកជម្ងឺទេ។

## អនុវត្តការបង្ការជាសកល

អនុវត្តការបង្ការជាសកល តំរូវឱ្យមានៈ

- គោលការណ៏ណែនាំសំរាប់បង្ការនិងត្រួតពិនិត្យជម្ងឺឆ្លង
- ការបណ្តុះបណ្តាលដល់គ្រប់បុគ្គលិកទាំងអស់ ស្តីពីការប្រើប្រាស់និងបោះចោលសំភារៈដែលមានបង្ករោគ
- ផ្គត់ផ្គង់ឧបករណ៏ និងសំភារៈត្រូវការចាំបាច់ដូចជា : សំភារៈសំរាប់អប់រំ ស្រោមដៃ និងម្ហូលសឺរ៉ាំង ព្រមទាំងប្រអប់សុវត្ថិភាពផង
- យន្តកម្មតាមដានត្រួតពិនិត្យ ដើម្បីធានាថាការបង្ការជាសកលត្រូវបានអនុវត្តត្រឹមត្រូវល្អ។

11

## ការបង្ការជាសកលៈ ការលាងសំអាតនិងការទុកដាក់សំរាម

- ការលាងសំអាតដៃ គឺជាយុទ្ធសាស្រ្តមួយដ៏សំខាន់ក្នុងចំណោមយុទ្ធសាស្រ្តដទៃទៀត ក្នុងការទប់ស្កាត់ការរាលដាលនៃជម្ងឺឆ្លង។ ត្រូវលាងជាមួយនឹងសាប៊ូនិងទឹកដែលហូរ យ៉ាងហោចណាស់ ១៥វិនាទី :
  - ~ មុននិងក្រោយ ការប៉ះពាល់ផ្ទាល់ជាមួយអ្នកជម្ងឺ ឬ របស់របរដែលមានផ្ទុកមេរោគ
  - ~ មុននិងក្រោយ សកម្មភាពណាដែលប៉ះផ្ទាល់ជាមួយឈាម ឬសារធាតុរាវនៃរាងកាយ
  - ~ មុននឹងបរិភោគអាហារ និងក្រោយចេញពីបន្ទប់ទឹក
- ត្រូវប្រើម្សៅសាប៊ូនិងទឹកក្តៅដើម្បីលាងសំអាត ឥដ្ឋ គ្រែ បន្ទប់ទឹក ជញ្ជាំង និង កំរាលជ័រ
- លាងសំអាតឈាមឬសារធាតុរាវនៃរាងកាយដែលខ្ចាតប្រឡាក់លើផ្ទៃផ្សេងៗជាមួយទឹកថ្នាំសំលាប់មេរោគដែលមានជាតិក្លរីនឱ្យបានឆាប់រហ័ស និងដោយប្រុងប្រយ័ត្ន និងពាក់ស្រោមដៃជ័រក្រាស់
- អនុវត្តការប្រមូលសំរាមឱ្យមានសុវត្ថិភាព ដោយដាក់ក្នុងថង់ជាប់ល្អមិនធ្លាយចេញ ទឹក ឬក្នុងធុង ឬដុតក្នុងឡសុវត្ថិភាព ឬ កប់។

12

## ការបង្ការជាសកលៈ ការកំចាត់មេរោគពីឧបករណ៏ប្រើប្រាស់ Decontamination

- ការកំចាត់មេរោគ (Decontamination)ៈ គឺជាដំណាក់កាលដំបូងក្នុងការធ្វើឱ្យឧបករណ៏ប្រើប្រាស់មានសុវត្ថិភាព។ ត្រូវត្រាំឧបករណ៏ប្រើប្រាស់ក្នុងទឹកដែលមានជាតិក្លរីន0.៥% រយៈពេល១0នាទី ។ ដំណាក់កាលនេះសំខាន់ណាស់ ព្រោះវា អាចសំលាប់មេរោគរលាកថ្លើមប្រភេទបេ និងមេរោគអេដស៏បាន
- **ការលាងសំអាត** (Cleaning) ការលាងសំអាតសំភារៈឱ្យបានស្អាតជាមួយសាប៊ូនិងទឹកក្តៅ គឺជាដំណាក់កាលមួយដ៏សំខាន់មុននឹងឈានទៅដល់ការប្រើជាតិគីមី ឬ ស្ងោររំងាប់មេរោគៈ
  - ~ បំផ្លាញឱ្យអស់នូវអតិសុខុមប្រាណដែលមានបរិមាណខ្ពស់
  - ~ យកសារធាតុកខ្វក់ការពារមេរោគចេញឱ្យអស់ដូចជា ធូលីដី ជាតិអំបិល និងសារធាតុផ្សេងៗទៀត
- **ការរំងាប់មេរោគ** (Desinfection) ជាវិធីកំចាត់អតិសុខុមប្រាណមួយចំនួនធំ ដោយប្រើប្រាស់ជាតិគីមី។
  ក៏ប៉ុន្តែវិធីនេះមិនអាចបំផ្លាញអស់រាល់សណ្ឋាននៃមេរោគទេ (ឧៈ ស្ព័រនៃបាក់តេរី)
- **ការរំងាប់មេរោគ** (Sterilization) កំទេចអស់នូវរាល់អតិសុខុមប្រាណតែម្តង

13

## ការបង្ការជាសកលៈ ការប្រើប្រាស់វត្ថុមុតស្រួចឱ្យមានសុវត្ថិភាព

- ជៀសវាងការគ្របគំរបម្ជុលដោយដៃទាំងពីរ
- ប្រសិនបើចាំបាច់ត្រូវគ្របម្ជុលទៅក្នុងគំរបវិញ ត្រូវប្រើតែដៃម្ខាងតាមវិធីស្កូប (Scoop)
  - ~ ដាក់គំរបម្ជុលនៅលើផ្ទៃរាបស្មើហើយរឹង បន្ទាប់មកត្រូវដកដៃចេញ
  - ~ ប្រើដៃម្ខាងកាន់ស៊ីរ៉ាំងដែលមានភ្ជាប់ម្ជុល ហើយប្រើម្ជុលនោះដោតចូលក្នុងគំរបម្ជុល
  - ~ នៅពេលដែលម្ជុលចូលក្នុងគំរបម្ជុលស៊ុបរួចហើយ ត្រូវប្រើដៃម្ខាងទៀតរុញគំរបម្ជុល
  - ~ បញ្ចូលឱ្យកិបទៅនឹងដងម្ជុល
- ប្រើប្រាស់ម្ជុលស៊ីរ៉ាំង និង កូនកាំបិតសំរាប់វះកាត់ថ្មីជានិច្ច ហើយប្រើរបស់ទាំងនេះសំរាប់តែអ្នកជម្ងឺម្នាក់តែប៉ុណ្ណោះ
- បោះចោលម្ជុល( សំរាប់ចាក់ក្រោមស្បែកនិងសំរាប់ដេរ) និងវត្ថុមុតស្រួចដទៃទៀត ( កាំបិតវះកាត់ ឡាម )ទៅក្នុងប្រអប់សុវត្ថិភាព
- ត្រូវយកប្រអប់សុវត្ថិភាពទាំងនោះទៅដុតបំផ្លាញចោលក្នុងឡ ឬកប់ចោល ហើយមិនត្រូវយកមកប្រើប្រាស់ម្តងទៀតទេ។

14

## ការបង្ការជាសកលៈ របាំងការពារ

- ប្រើប្រាស់ស្រោមដៃនៅពេលប៉ះផ្ទាល់ជាមួយសារធាតុរាវនៃរាងកាយ ស្បែករបួស ឬស្រទាប់ភ្នាសរបស់អ្នកជំងឺ
- ប្រើប្រាស់ម៉ាស់ការពារ វ៉ែនតាការពារភ្នែក អាវការពារ ( អាវវែងធ្វើអំពីជាតិប្លាស្ទិក) និង ស្បែកជើងកវែងជ័រ ដើម្បីការពារឈាមឬ សារធាតុរាវនៃរាងកាយដែលខ្ទាតប៉ះ
- ប្រើក្រណាត់/បង់ស្អិតស្អាតដែលមិនជ្រាបទឹកគ្របឬបិតលើ មុខរបួស ឬស្បែករលាត់
- ប្រើប្រាស់នូវធនធានសមស្រមនិងមានប្រសិទ្ធិភាពៈ ប្រើប្រាស់សំភារៈការពារជាអាទិភាពសំរាប់ធ្វើការបង្កើតកូន និងសំរាប់ដេររបួស។

15

## ការគ្រប់គ្រងបរិស្ថានការងារ

- បង្កើតនិងអនុវត្ត នូវគោលនយោបាយនិងនិតិវិធី សំរាប់រាយការណ៍និងព្យាបាលបង្ការដល់អ្នកដែលប្រឈមនឹងមេរោគអេដស៏
- ថែទាំនិងការពារដល់បុគ្គលិកគ្រប់ជាន់ថ្នាក់ឱ្យបានសមស្រប
- អនុវត្តវិធានការគាំទ្រ ដែលអាចជួយកាត់បន្ថយនូវ **Stress** ភាពឯកោ និង **Burn out**
- ទទួលដឹងឮនិងឆ្លើយតបទៅនឹងតំរូវការរបស់បុគ្គលិកសុខាភិបាលដែលឆ្លងមេរោគអេដស៏
- ផ្តល់នូវសំភារៈនិងការផ្គត់ផ្គង់ដែលចាំបាច់សំរាប់អនុវត្តការបង្ការជាសកលៈ សំលៀកបំពាក់ និងសំភារៈសំរាប់ការពារ ផលិតផលសំលាប់មេរោគដែលសមស្រប និងប្រអប់សុវត្ថិភាព
- ត្រូវធានាឱ្យបាននូវការបំផ្លាញចោលរាល់ប្រអប់សុវត្ថិភាព និងសំភារៈទាំងអស់ដែលប្រើប្រាស់រួចឱ្យបានត្រឹមត្រូវ

16

## ការអប់រំជាប្រចាំពីការបង្ការជម្ងឺឆ្លង

- ណែនាំបុគ្គលិកទាំងអស់ រួមទាំង អ្នកអប់រំសុខភាពដល់អ្នករួមការងារ អ្នកផ្តល់ប្រឹក្សា និង អ្នកសំអាត ឱ្យបានយល់ដឹងពីគោលការណ៏នៃការបង្ការជាសកល
- ធានាថា រាល់បុគ្គលិកទាំងអស់ដែលធ្វើការប្រឈមនឹងឈាមនិងសារធាតុរាវនៃរាងកាយជាប្រចាំ ( វេជ្ជបណ្ឌិត ឆ្មប គិលានុបដ្ឋាក និង គិលានុបដ្ឋាយិកា និងអ្នកសំអាត) ទទួលបានការបណ្តុះបណ្តាលតាំងពីដំបូង និងជាបន្តអំពីការប្រើប្រាស់សំភារៈ និងគ្រឿងបរិក្ខារទាំងអស់ឱ្យមានសុវត្ថិភាព
- តំរូវឱ្យអ្នកគ្រប់គ្រងធ្វើការចុះពិនិត្យជាទៀងទាត់ និងធ្វើការវាយតម្លៃលើការអនុវត្តន៏ ដោយសុវត្ថិភាព និងផ្គត់ផ្គង់នូវការខ្វះខាតជាចាំបាច់។

17

## សកម្មភាពទី៣: ពាក្យគន្លឹះ និយមន័យនៃពាក្យ PEP

» គ្រូនឹងសួរអ្នកពីអ្វីដែលអ្នកបានដឹង ឬបានយល់អំពីការព្យាបាលបង្ការក្រោយប្រឈមនឹងការឆ្លងមេរោគអេដស៍ ឬ PEP

### តើ PEP ជាអ្វី?

PEP:

- គឺជាការព្យាបាលដោយប្រើឱសថប្រឆាំងមេរោគមេរោគអេដស៍
- ត្រូវបានផ្តល់ឱ្យតែចំពោះអ្នកដែលគ្មានផ្ទុកមេរោគអេដស៍តែប៉ុណ្ណោះ
- ផ្តល់ឱ្យបន្ទាប់ពីមានគ្រោះថ្នាក់ក្នុងការងារដែលប្រឈមនឹងការឆ្លងមេរោគអេដស៍
- គឺដើម្បីបង្ការការឆ្លងមេរោគអេដស៍ដល់បុគ្គលិកសុខាភិបាល

20

## សកម្មភាពទី៤: បំផុសគំនិត: ប្រភេទការងារដែលងាយប្រឈមទៅនឹងការឆ្លងមេរោគអេដស៍

» គ្រូសួរសិក្ខាកាម ឱ្យរកប្រភេទគ្រោះថ្នាក់នៃការងារប្រឈមនឹងការឆ្លងមេរោគអេដស៍ដែលអាចកើតមានឡើង

» ព្យាយាមធ្វើការប៉ាន់ស្មានពីកម្រិតប្រឈមក្រោយគ្រោះថ្នាក់ (ឧ: ទាប មធ្យម ឬខ្ពស់) និងកត្តាផ្សេងៗទៀតដែលអាចធ្វើឱ្យការប្រឈមមានកម្រិតកាន់តែខ្ពស់

» បន្ទាប់មកចូររកមើលថា តើសារធាតុរាវនៃរាងកាយប្រភេទណាខ្លះដែលមានផ្ទុកមេរោគអេដស៍

» សរសេរចម្លើយនៅលើក្តារខៀន និងគូសជាតារាងដែលមានប្រភេទនៃគ្រោះថ្នាក់ និងកម្រិតនៃការប្រឈម

### តើប្រភេទនៃការងារអ្វីខ្លះដែលងាយប្រឈមមុខទៅនឹងការឆ្លងមេរោគអេដស៍?

| **ប្រភេទនៃការប្រឈម** | **ឧទាហរណ៍** |
|---|---|
| **មានរបួសលើស្បែក** | ការមុតម្ជុល/របួសដោយកូនកាំបិតវះកាត់ |
| **ការប៉ះពាល់ជាមួយភ្នាស** | ឈាមខ្ទាតចូលភ្នែក |
| **ស្បែកដែលមានរបួស** | ឈាមខ្ទាតទៅប៉ះនឹងស្បែកដែលដាច់រហែក ឬមានរបួស ឬស្បែកដែលមានរលាក |

គ្រោះថ្នាក់ទាំងនេះ ប្រឈមមុខទៅនឹងការឆ្លងជម្ងឺរលាកថ្លើមប្រភេទបេ និងប្រភេទសេ ព្រមទាំងមេរោគអេដស៍ផងដែរ ។

## តើគ្រោះប្រឈមនឹងការឆ្លងមានកំរិតធ្ងន់ធ្ងរត្រឹមណា?

| ប្រភេទនៃការប្រឈម | ការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ | ការពន្យល់ |
|---|---|---|
| **ការមុតម្ជុលសើស្បែក** | 0.3% | ៣នាក់/១០០០ នៃគ្រោះថ្នាក់ |
| **លើភ្នាស** | 0.09% | ៩នាក់/១០,០០០ នៃគ្រោះថ្នាក់ |
| **ស្បែកដែលមានរបួស** | <0.09° | < ៩នាក់/១០,០០០ នៃគ្រោះថ្នាក់ |

23

## របួសដោយមុតម្ជុល

គ្រោះប្រឈមនឹងការឆ្លងមេរោគអេដស៍តាមរយៈរបួសដោយមុតម្ជុលមានកំរិតខ្ពស់ ប្រសិនបើ:

- របួសមុតជ្រៅដោយម្ជុលមានប្រហោង
- មានឈាមប្រឡាក់ជាប់ម្ជុល
- ម្ជុលនោះជាម្ជុលចាក់ក្នុងសរសៃឈាម
- អ្នកដែលជាប្រភពដើមស្ថិតក្នុងដំណាក់កាលចុងក្រោយនៃជំងឺអេដស៍ (ពីព្រោះអត្រាមេរោគអេដស៍នៅក្នុងឈាមរបស់អ្នកដែលជាប្រភពដើមមានកំរិតខ្ពស់)

24

## តើសារធាតុរាវនៃរាងកាយណាខ្លះដែលអាចចម្លងរោគ?

**គ្រោះថ្នាក់ខ្ពស់ :**

- ឈាម

**គ្រោះថ្នាក់មធ្យម :** (អាចមានគ្រោះថ្នាក់ខ្ពស់បើសិនមានលាយឈាម)

- ខួរឆ្អឹងខ្នង ទឹកភ្លោះ ទឹកស្រោមបេះដូង ទឹកស្រោមពោះ ទឹកស្រោមសួត ទឹកក្នុងសន្លាក់ឆ្អឹង

**គ្មានគ្រោះថ្នាក់ :** (មានគ្រោះថ្នាក់លុះត្រាតែមានបរិមាណឈាមគ្រប់គ្រាន់)

- ទឹកសំបោរ ទឹកមាត់ ទឹកភ្នែក ញើស ទឹករងៃ ទឹកក្រពះ ទឹកនោម លាមក

25

## តើ PEP មានប្រសិទ្ធិភាពយ៉ាងដូចម្តេច?

ប្រសិនបើលេបបានត្រឹមត្រូវPEPអាចកាត់បន្ថយគ្រោះប្រឈមនឹងការចម្លងមេរោគអេដស៍បានប្រហែល២/៣

**នោះមានន័យថា :**

- ប្រសិនបើមិនបានអនុវត្ត PEP ទេ ការប្រឈមនឹងការឆ្លងមេរោគអេដស៍អាចមាន ៣ករណី ក្នុងចំណោមអ្នកមុតរបួស១០០០ករណី
- ដូច្នេះបើបានអនុវត្តPEPការប្រឈមនឹងការឆ្លងមេរោគអេដស៍អាចកាត់បន្ថយមកនៅត្រឹម ១ករណីក្នុងចំណោមអ្នកមុតរបួស១០០០ករណី

26

## សកម្មភាពទី៥ : តើចាំបាច់ត្រូវធ្វើអ្វីខ្លះ បន្ទាប់ពីមានករណីប្រឈមនឹងការឆ្លងមេរោគអេដស៍ក្នុងការងារ

» ស្លាយទី២៧-៣៧ រៀបរាប់អំពីដំណាក់កាលផ្សេងៗដែលត្រូវធ្វើបន្ទាប់ពីមានការប្រឈមនឹងគ្រោះថ្នាក់ក្នុងការងារ

» គោលបំណងនៃដំណើរការនេះ គឺដើម្បីធានាថា នៅពេលណាដែលត្រូវធ្វើការព្យាបាលបង្ការ**PEP** ។ ត្រូវផ្តល់ជូនដល់បុគ្គលិកសុខាភិបាលដែលរងគ្រោះភ្លាមៗ ក៏ប៉ុន្តែមិនត្រូវព្យាបាល **PEP**ដែលមិនសមស្របនោះទេ។

**ចំណុចសំខាន់ៗមាន៖**

» កំណត់ឱ្យបានថាតើ គ្រោះប្រឈមនោះវាធ្ងន់ធ្ងរហួតដល់ត្រូវព្យាបាល**PEP**ដែរឬទេ?

» កំណត់ឱ្យបានថាតើប្រភពជនបង្កមានផ្ទុកមេរោគអេដស៍ដែរឬទេ ?

» កំណត់ថាតើបុគ្គលិកសុខាភិបាលដែលរងគ្រោះមានផ្ទុកមេរោគអេដស៍ដែរឬទេ?

### ការគ្រប់គ្រងករណីប្រឈមនឹងការឆ្លងមេរោគអេដស៍ក្នុងការងារ

- បន្ទាប់ពីមានការប្រឈមនឹងការឆ្លងមេរោគអេដស៍ បុគ្គលិកសុខាភិបាលផ្នែកថែទាំសុខភាពត្រូវទៅរកសេវា OI-ART ភ្លាមបើសិនជាអាច។
- ប្រសិនបើអ្នកផ្តល់សេវា OI-ART មិនអាចទទួលបានភ្លាមៗទេ ត្រូវទៅរកសេវាសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យបង្អែកដែលនៅជិតនោះឱ្យបានឆាប់ជាទីបំផុត
- ផ្នែកសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យត្រូវមានភារៈកិច្ចបណ្តុះបណ្តាលបុគ្គលិករបស់ខ្លួនអំពីគោលការណ៍ណែនាំអំពី PEP និងមានឱសថប្រឆាំងមេរោគអេដស៍គ្រប់គ្រាន់សំរាប់បង្ការផងដែរ។

28

### តើយើងត្រូវធ្វើអ្វីខ្លះ បន្ទាប់ពីមានការប្រឈមនឹងមេរោគអេដស៍ក្នុងការងារ?

១. ធ្វើការថែទាំជាបឋម លើកន្លែងដែលមានមុខរបួស
២. ប៉ាន់ប្រមាណពីសភាពនៃការប្រឈម
  ក) - តើការប្រឈមនឹងការឆ្លងមេរោគអេដស៍នោះ មានលក្ខណៈយ៉ាងដូចម្តេច?
  ខ) - តើគ្រោះថ្នាក់នោះកើតឡើងយូរប៉ុណ្ណាហើយ?
  គ) - តើអ្នកដែលជាប្រភពនៃគ្រោះថ្នាក់នោះ មានផ្ទុកមេរោគអេដស៍ដែរឬទេ?
៣. ប៉ាន់ប្រមាណពីសភាពរបស់បុគ្គលិកថែទាំសុខភាព
៤. កំណត់ថាតើ ត្រូវផ្តល់ **PEP** ដល់បុគ្គលិកដែលមានគ្រោះថ្នាក់ដែរឬទេ?
៥. ធ្វើការតាមដានបន្ត និងផ្តល់ការប្រឹក្សាដល់អ្នករងគ្រោះ
៦. រៀបចំរបាយការណ៍

29

## ១. ការថែទាំជាបឋមលើកន្លែងដែលមានមុខរបួស

កន្លែងមុខរបួសនិងស្បែក :

- លាងសំអាតមុខរបួសដោយសាប៊ូនិងទឹករយៈពេល៣នាទី

ភ្នាសដែលប្រឈម :

- ត្រូវលាងសំអាតជាមួយនឹងទឹកស្អាត បង្ហូរឱ្យបាន១០នាទី

▶▶ ការច្របាច់មុខរបួសឱ្យចេញឈាមមិនបានណែនាំឱ្យអនុវត្តទេ

30

## ២.ក.តើការប្រឈមនឹងមេរោគអេដស៍នោះមានលក្ខណៈយ៉ាងដូចម្តេច?

**ប្រភេទ និងបរិមាណនៃសារធាតុរាវ ឬ ជាលិកា**

- ឈាម
- សារធាតុរាវដែលមើលទៅមានលាយឈាម
- សារធាតុរាវ ឬកោសិកាដែលអាចបង្ករោគដទៃៗទៀត

**ប្រភេទ និងភាពធ្ងន់ធ្ងរនៃការប្រឈមនឹងការឆ្លងមេរោគអេដស៍:**

- ការប្រឈមនឹងគ្រោះថ្នាក់នៅពេលមុតម្ជុលលើស្បែក
  - ជំរៅនៃមុខរបួស?
  - ប្រភេទម្ជុលដែលមុត ( ប្រហោងនិងមានមុខធំ? )
  - ឃើញមានឈាមជាប់នឹងម្ជុលឬគ្មាន?
  - ម្ជុលដែលចាក់សរសៃឈាម
- ភ្នាសដែលប្រឈមនឹងគ្រោះថ្នាក់
- ស្បែកមានរបួសដែលប្រឈមនឹងគ្រោះថ្នាក់

} បរិមាណឈាមដែលប៉ះពាល់ច្រើនឬតិច?

- ស្បែកដែលគ្មានរបួស-មិនមានគ្រោះថ្នាក់ទេ

**ត្រូវបញ្ជាក់ឱ្យបានច្បាស់ថា បុគ្គលិកដែលប្រឈមតិចតួច មិនតំរូវឱ្យធ្វើ** PEP **ទេ។**

31

## ២.ខ. តើគ្រោះថ្នាក់កើតឡើងមានរយៈពេលយូរប៉ុណ្ណាហើយ?

**បើសិនជាករណៈទេសៈហុចឱ្យៈ ការព្យាបាលបន្ទាប់ក្រោយប្រឈមនឹងគ្រោះថ្នាក់ PEP គួរចាប់ផ្តើមផ្តល់ឱ្យក្នុងចន្លោះពេល៤ម៉ោងក្រោយពីការមុតរបួស**

- PEPគួរចាប់ផ្តើមធ្វើអោយបានឆាប់ កាន់តែប្រសើរ ដើម្បីឱ្យការបង្ការមានប្រសិទ្ធិភាពខ្ពស់
- ការព្យាបាល PEP ដែលចាប់ផ្តើមក្នុងរយៈពេល៣៦ម៉ោង ក្រោយគ្រោះថ្នាក់ បានបង្ហាញ ថាបានកាត់បន្ថយគ្រោះប្រឈមនឹងការឆ្លងមេរោគអេដស៍
- មិនត្រូវពន្យារពេលព្យាបាលទេ នៅពេលកំពុងរង់ចាំលទ្ធផលតេស្តឈាមឬបំពេញបែបបទឯកសារក្តី។

32

## ២.គ.តើប្រភពនៃជនដែលបង្កគ្រោះថ្នាក់មានផ្ទុកមេរោគអេដស៍ដែរឬទេ?(១)

- កំណត់ស្ថានភាពផ្ទុកមេរោគអេដស៍របស់បុគ្គលដែលបង្កគ្រោះថ្នាក់ តាមរយៈការធ្វើតេស្តរហ័សរកអង្គបដិបក្ខប្រាណ :

**កំណត់សំគាល់:** មុននឹងធ្វើតេស្តឈាម អ្នកត្រូវតែ:

- បានទទួលការព្រមព្រៀងជាមុនសិន
- រក្សាការសម្ងាត់ឱ្យបាន
- គោរពសិទ្ធិស្របច្បាប់របស់អតិថិជនក្នុងការបដិសេធធ្វើតេស្តឈាម
- ប្រសិនជាអាច ត្រូវធ្វើតេស្តរកមេរោគ + រលាកថ្លើមប្រភេទ B និង C និងអង្គបដិបក្ខប្រាណប្រភេទ C (HBsAg, HCV)

- ប្រសិនបើបុគ្គលដែលបង្កគ្រោះថ្នាក់ បដិសេធការធ្វើតេស្តឬមិនអាចធ្វើតេស្តបានត្រូវវាយតម្លៃពី :
  - សញ្ញាគ្លីនិកណាមួយដែលសង្ស័យថាជាសញ្ញារបស់ជម្ងឺអេដស៍
  - ប្រវត្តិនៃការប្រព្រឹត្តិរបស់គេដែលប្រឈមនឹងការឆ្លងមេរោគអេដស៍
- ប្រសិនបើអ្នកដែលទទួលគ្រោះថ្នាក់មិនបានដឹងច្បាស់លាស់ពីការប្រឈមមុខត្រូវវាយតម្លៃពី :
  - ប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍ ( រលាកថ្លើមប្រភេទ B និង C ) នៅក្នុងសហគមន៍ ដើម្បីធ្វើការប៉ាន់ស្មានអំពីលទ្ធភាពដែលអាចប្រឈមនឹងការឆ្លងមេរោគអេដស៍ពីអ្នកជម្ងឺ

**▶▶ មិនត្រូវធ្វើតេស្តលើម្ជុលដែលប្រឡាក់ឈាម សំរាប់រកមេរោគដែលរស់នៅក្នុងឈាមទេ។**

33

## ២.គ.តើប្រភពជនដែលបង្កគ្រោះថ្នាក់មានផ្ទុកមេរោគអេដស៍ដែរឬទេ?(២)

**ប្រភពជនដែលបង្កគ្រោះថ្នាក់គ្មានផ្ទុកមេរោគអេដស៍:**

បុគ្គលិកសុខាភិបាល**មិនចាំបាច់** :

- ធ្វើតេស្តឈាមរកមេរោគអេដស៍ទេ
- ធ្វើការព្យាបាលបង្ការ PEPទេ
- តាមដានបន្តទេ

តែរាល់របាយការណ៏នៃរបួសត្រូវតែបំពេញ ។

**ប្រភពជនដែលបង្កគ្រោះថ្នាក់មានផ្ទុកមេរោគអេដស៍:**

ប៉ាន់ប្រមាណលើអ្នកដែលជាប្រភពចម្លងនោះ

- ដំណាក់កាលនៃជម្ងឺអេដស៍
- រាប់ចំនួនកោសិកា CD4
- ប្រវត្តិនៃការព្យាបាល ART នៅពេលបច្ចុប្បន្ន និងពីអតីតកាល
- (បន្ទុកមេរោគ/ការស៊ាំរបស់មេរោគអេដស៍ទៅនឹងឱសថ ARV

ព័តិមាននេះ គឺត្រូវបានប្រើប្រាស់ដើម្បីធ្វើការសំរេចចិត្តក្នុងការព្យាបាល PEPឱ្យបានសមស្របបំផុត ។

34

## ៣.ការប៉ាន់ប្រមាណលើបុគ្គលិកថែទាំ: ព័ត៌មានជាមូលដ្ឋាន

ត្រូវយកព័តិមានដែលទាក់ទងអំពី :

- ការចាក់ថ្នាំបង្ការជម្ងឺរលាកថ្លើមប្រភេទបេ និងស្ថានភាពឆ្លើយតបនៃវ៉ាក់សាំង
- ការប្រើប្រាស់ថ្នាំនាពេលបច្ចុប្បន្ន
- ស្ថានភាពវេជ្ជសាស្ត្រនាពេលបច្ចុប្បន្ន ឬពីមុនមក ឬ ស្ថានភាពផ្សេងៗទៀត

ឧទាហរណ៏: មានផ្ទៃពោះ បំបៅកូនដោយដោះ ជម្ងឺថ្លើម តំរងនោម ជាដើម (គោលបំណងដើម្បីពិចារណា ឬជ្រើសរើសរបបព្យាបាល PEP

**ត្រូវ :**

- កំណត់លទ្ធផលតេស្តឈាមទុកជាគោល ដោយមើល serostatus របស់អ្នកប្រឈមនៅពេល ដែលមានគ្រោះថ្នាក់
- ធ្វើ HBsAg + HCV antibody tests ប្រសិនជាមានលទ្ធភាព

35

## ៣.ការប៉ាន់ប្រមាណលើបុគ្គលិកថែទាំ: តេស្តរកមេរោគអេដស៍

- ការធ្វើតេស្តឈាមរកមេរោគអេដស៍ត្រូវតែធ្វើក្នុងបន្ទប់មួយដែលអាចលាក់ការសម្ងាត់ដល់អតិថិជនបាន
- ប្រសិនបើបុគ្គលិកថែទាំ ចង់ធ្វើតេស្តឈាមនៅកន្លែង VCCT ត្រូវគោរពការសំរេចចិត្តរបស់គាត់
- ប្រសិនបើចាំបាច់ត្រូវផ្តល់ការព្យាបាល PEPត្រូវផ្តល់ជូនភ្លាមដោយមិនបាច់រង់ចាំលទ្ធផលតេស្តឈាមរកមេរោគអេដស៍ឡើយ ។
- ប្រសិនបើលទ្ធផលតេស្តឈាមនៃបុគ្គលិកថែទាំ មានសញ្ញាវិជ្ជមាន
  - ត្រូវបញ្ឈប់ការព្យាបាលPEP ភ្លាម *
  - ត្រូវបញ្ជូនគាត់ទៅទទួលការផ្តល់ប្រឹក្សាយោបល់ និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

* ក្នុងស្ថានភាពនេះ ការព្យាបាល **PEP** មិនផ្តល់ផលប្រយោជន៏ដល់បុគ្គលិកថែទាំទេ ហើយអាចធ្វើឱ្យមានការកកើតឡើងនៃភាពស៊ាំនឹងថ្នាំថែមទៀតផង ។

36

## ៤.កំណត់ពីការព្យាបាល PEP

ក្នុងល័ក្ខខ័ណ្ឌច្បាស់លាស់នៃការងារដែលប្រឈមនឹងការឆ្លងមេរោគអេដស៏

| | **ប្រភពជន: អវិជ្ជមាន** | **ប្រភពជន: វិជ្ជមាន** |
|---|---|---|
| **បុគ្គលិកសុខាភិបាល: អវិជ្ជមាន** | **មិនបាច់ព្យាបាលPEPទេ** | ព្យាបាល PEP* |
| **បុគ្គលិកសុខាភិបាល: វិជ្ជមាន** | **មិនបាច់ព្យាបាលPEPទេ** បញ្ជូនបុគ្គលិកសុខាភិបាល ទៅសេវា OI/ART | **មិនបាច់ព្យាបាលPEPទេ** បញ្ជូនបុគ្គលិកសុខាភិបាល ទៅសេវា OI/ART |

***ផ្តល់ឱសថប្រឆាំងមេរោគអេដស៏ ៤ថ្ងៃ សំរាប់រយ:ពេលចាប់ផ្តើមដំបូង**

37

## សកម្មភាពទី : ករណីសិក្សា : ការងារប្រឈមនឹងការឆ្លងមេរោគអេដស៍នៅអគារសម្រាល

» គោលបំណងនៃលំហាត់នេះគឺដើម្បីសង្កេបនឹងគិតអំពីការគ្រប់គ្រងករណីក្រោយប្រឈមនឹងគ្រោះថ្នាក់

» សិក្ខាកាមត្រូវបែងចែកជា៤ក្រុម និងចែកឱ្យក្រុមនីមួយៗនូវករណីសិក្សា និងសំណួរ

» គ្រូទុកពេលឱ្យអ្នកគិតរយៈពេល២០នាទី ដើម្បីឆ្លើយនឹងសំណួរ

» អ្នកស្ម័គ្រចិត្តម្នាក់ៗនៃក្រុមនីមួយៗ  ត្រូវបានស្នើឱ្យឆ្លើយសំណួរដំបូង។

» គ្រូនឹងស្នើឱ្យក្រុមផ្សេងទៀតឡើងឆ្លើយម្តង១ក្រុមៗ រហូតដល់គ្រប់ក្រុម ដើម្បីរាយបញ្ជីអំពីដំណាក់កាលដែលត្រូវអនុវត្តតាម

| |
|---|
| **ករណីសិក្សា**<br>សុផាណា ធ្វើការនៅផ្នែកសម្ភពរហូតដល់យប់ជ្រៅ។ នាងបានដកម្ជុលសេរ៉ូមចេញពីដៃរបស់អ្នកជំងឺ។ ជាថៃដន្យនាងបានមុតម្រាមដៃនឹងម្ជុលនៅពេលដែលដកវាចេញ។ |
| សំណួរ: |
| ១.ក្រោយពីធ្វើការងារប្រឈមនឹងការឆ្លងមេរោគអេដស៍  តើមុនដំបូងបង្អស់សុផាណាគួរធ្វើអ្វីខ្លះ? |
| ២.តើនាងគួរធ្វើអ្វីបន្ទាប់មកទៀត? សូមរៀបរាប់អំពីវិធីដែលនាងត្រូវធ្វើជាបន្តបន្ទាប់។ |

## សកម្មភាពទី៧: មេរៀន: របបឱសថព្យាបាលPEP

» ស្លាយទី៤៣-៤៦ រៀបរាប់លំអិតអំពីការតាមដានបន្ត និងការធ្វើរបាយការណ៍ អំពីដំណើរការក្រោយពីទទួលគ្រោះថ្នាក់

» ចំណាំ: ការប្រកាន់ខ្ជាប់នូវការព្យាបាលPEPសម្រាប់រយៈពេល២៨ថ្ងៃមានសារៈសំខាន់ណាស់ ក៏ប៉ុន្តែវាមិនមែនជាការងាយស្រួលទេ។ ត្រូវយកចិត្តទុកដាក់គាំទ្រដល់បុគ្គលិកសុខាភិបាលនៅក្នុងរយៈពេលនេះ។

### របបឱសថព្យាបាល PEP

-ចំពោះរបួសដោយការមុតម្ជុល និង សាច់ភ្នាស-ស្បែកដែលប្រាកដថាប្រឈមមុខនឹងការឆ្លង ត្រូវផ្តល់:

▪AZT* (300 mg) + 3TC (150 mg) ប្រើរៀងរាល់១២ ម៉ោង ក្នុងរយៈពេល៤សប្តាហ៍

-ចំពោះមុខរបួសជ្រៅដោយសារមុតម្ជុលដែលមានប្រហោងក្នុង :

▪AZT* (300mg) + 3TC (150mg) + Kaletra (133/33mg): ឱ្យម្តងចំនួនបីគ្រាប់ ប្រើរៀងរាល់១២ ម៉ោង ក្នុងរយៈពេល៤សប្តាហ៍

*ប្រសិនបើ Zidovudine ធ្វើទុក្ខខ្លាំងពិបាកទ្រាំ វាអាចជំនួសដោយ Stavudine លាយជាមួយនឹងថ្នាំគ្រាប់ 3TC

* ការណែនាំពីការគ្រប់គ្រងការងារដែលងាយនឹងប្រឈមមេរោគអេដស៍ , NCHADS ខែមករា ២០០៥ 43

### ៥. ការតាមដានបន្តនូវការព្យាបាល PEP

កម្មវិធីតាមដាន :

- ថ្ងៃទី៣-៤ :ពិនិត្យឡើងវិញ
  - ជាលំអិតពីការមុតរបួស
  - ពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ជនដែលបង្កគ្រោះថ្នាក់ និងបុគ្គលិកថែទាំ
  - ពីផលវិបាកនៃការព្យាបាល PEP និងការប្រកាន់ខ្ជាប់នូវការប្រើប្រាស់ឱសថ
- ថ្ងៃទី១៤-១៦ : ពិភាក្សាពីការពិបាកក្នុងការប្រើរបបឱសថ និងធានានូវការប្រកាន់ខ្ជាប់ល្អក្នុងការប្រើប្រាស់ឱសថ។ រយៈពេល៣-៦ខែ ក្រោយការមុតរបួស : ធ្វើតេស្តឈាមរកមេរោគអេដស៍ម្តងទៀត។
- ត្រូវផ្តល់ប្រឹក្សាដល់បុគ្គលិកថែទាំ ពីការរួមភេទដែលមានសុវត្ថិភាព និងមិនត្រូវឱ្យគាត់ផ្តល់ឈាមទៅអ្នកដទៃទេ លុះត្រាតែលទ្ធផលតេស្តឈាមបង្ហាញសញ្ញា អវិជ្ជមាន នៅខែទី ៦
- ការប្រកាន់ខ្ជាប់នូវរបបឱសថព្យាបាល PEP រយៈពេល៤សប្តាហ៍ គឺមានបញ្ហាណាស់ចំពោះបុគ្គលិកថែទាំ
  - ការប្រើឱសថមិនជាប់លាប់ អាចធ្វើឱ្យការបង្ការបរាជ័យ
  - ត្រូវប្រាប់ឱ្យគាត់ប្រើឱសថឱ្យបានជាប់លាប់ រាល់ពេលមកតាមដានសុខភាពម្តងៗ 44

### ៦.ការធ្វើរបាយការណ៍

- នៅមន្ទីរពេទ្យ ត្រូវសរសេររបាយការណ៍ស្តីពីការគ្រប់គ្រងព្យាបាលបង្ការ PEP ដល់រាល់ បុគ្គលិកទាំងអស់ដែលប្រឈមនឹងការឆ្លងមេរោគអេដស៍
- របាយការណ៍នេះត្រូវរួមបញ្ចូលរបាយការណ៍ដែលប្រឈមនឹងការឆ្លងទាំងអស់ រួមទាំងអ្នកដែលមិនមានរោគសញ្ញាច្បាស់លាស់ថាអាចឆ្លង និងអ្នកដែលមិនអនុញ្ញាតឱ្យធ្វើការព្យាបាលបង្ការ PEP
- ឯកសារគួរតែចម្លងទុកមួយច្បាប់ទុកក្នុងមន្ទីរពេទ្យ

45

## គំនូសបំព្រួញៈ ដំណាក់កាលដែលត្រូវធ្វើបន្ទាប់ពីមានគ្រោះថ្នាក់ក្នុងការងារ




46

### ម៉ូឌុលទី៤.៣.៤ : ចំណុចគន្លឹះ

- ការបង្ការជាសកល គឺជាសកម្មភាពត្រួតពិនិត្យជំងឺឆ្លងដែលត្រូវអនុវត្តលើគ្រប់អ្នកជំងឺទាំងអស់គ្រប់ពេលវេលា
- PEPគឺជាការផ្តល់ឱសថប្រឆាំងមេរោគអេដស៍ សម្រាប់បង្ការការឆ្លងមេរោគអេដស៍ បន្ទាប់ពីធ្វើការងារដែលប្រឈមនឹងការឆ្លង
- ការងារដែលងាយប្រឈមនឹងការឆ្លង គឺជាការបន្ទាន់នៃផ្នែកវេជ្ជសាស្ត្រ និងត្រូវរាយការណ៍ភ្លាមៗ ព្រោះថាការបង្ការPEP មានប្រសិទ្ធិភាពខ្ពស់ ប្រសិនបើចាប់ផ្តើមឱ្យក្នុងរយៈពេល៤ម៉ោងដំបូង ក្រោយពីមុតរបួស
- រាល់បុគ្គលិកថែទាំសុខភាពទាំងអស់ ត្រូវតែទទួលបាននូវព័ត៌មាននិងបានបណ្តុះបណ្តាលស្តីអំពីការគ្រប់គ្រងការងារដែលប្រឈមនឹងការឆ្លង
- បុគ្គលិកត្រូវដឹងថា តើអ្នកណាដែលគាត់ត្រូវរាយការណ៍ជូន បន្ទាប់ពីមានគ្រោះថ្នាក់ប្រឈមនឹងការឆ្លង និងត្រូវទទួលបាននូវការព្យាបាលបង្ការ PEP ទាំងក្នុងពេលកំពុងធ្វើការងារនិងក្រៅម៉ោងធ្វើការងារ ។

# ៤.៤
# ការថែទាំនិងគាំទ្របន្ត

**វត្ថុបំណង**

នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមទាំងអស់នឹងអាច :

១. ពន្យល់អំពីទស្សនៈនៃគម្រោងថែទាំនិងព្យាបាលបន្តសម្រាប់អ្នកផ្ទុកមេរោគអេដស៍-ជំងឺអេដស៍

២. អធិប្បាយអំពីការរួមបញ្ចូលសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនទៅក្នុងគម្រោងថែទាំនិងព្យាបាលបន្ត

៣. រាយបញ្ជីសេវាថែទាំនិងព្យាបាលបន្ត នៅក្នុងគ្រឹះស្ថានសុខាភិបាល និងនៅតាមសហគមន៍

៤. សង្ខេបអំពីភារកិច្ចដែលត្រូវធ្វើសម្រាប់ជួយដល់ស្ត្រីផ្ទុកមេរោគអេដស៍ នៅសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

៥. ពន្យល់អំពីសារៈសំខាន់នៃការផ្សារភ្ជាប់ទំនាក់ទំនង និង វិធីបញ្ជូនអ្នកជំងឺ

៦. អធិប្បាយអំពីប្រព័ន្ធសេវាសម្រាប់អ្នកជំងឺ ចាប់តាំងពីពេលចូលមកសេវាថែទាំផ្ទៃពោះ



*រយៈពេល* ***២ម៉ោង***

## សកម្មភាពទី១: សង្ខេបអំពីសេវាព្យាបាល ថែទាំ និងគាំទ្រ

### យុទ្ធសាស្ត្រទី ៤: សេវាព្យាបាល ថែទាំ និងគាំទ្រ

- កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន PMTCT កំណត់រកស្ត្រីផ្ទុកមេរោគអេដស៍ដែលត្រូវការការថែទាំផ្នែកវេជ្ជសាស្ត្រ និងការគាំទ្រពីសង្គម បន្ថែមពីលើសេវាគាំពារមាតានិងទារក
- ការទទួលបាននូវសេវាថែទាំនិងព្យាបាលដល់អ្នកផ្ទុកមេរោគអេដស៍ដែលមានគុណភាពខ្ពស់អាចបង្កើនចំនួនអ្នកមកទទួលសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម
- ការយល់ដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ ធ្វើឱ្យមានការមកទទួលយកអន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនកាន់តែច្រើនឡើងៗ
- បណ្តាញទាក់ទងសេវាព្យាបាល ថែទាំ និងគាំទ្រត្រូវបានពង្រឹង ដើម្បីលើកទឹកចិត្តដល់ស្ត្រីផ្ទុកមេរោគអេដស៍និងគ្រួសាររបស់គាត់បានទទួលនូវការគាំទ្រយូរអង្វែង

6

### ការថែទាំនិងគាំទ្រដល់កុមារដែលប្រឈមនឹងមេរោគអេដស៍

កុមារប្រឈម ជាពិសេសកុមារដែលងាយរងគ្រោះ ទោះបីជាពួកគេមិនបានឆ្លងមេរោគអេដស៍ក៏ដោយ:

- ពួកគេនឹងបាត់បង់នូវកត្តាការពារដែលបានមកពីការបៅដោះម្តាយ បើសិនជាម្តាយជ្រើសរើសវិធីចិញ្ចឹមកូនដោយអាហារជំនួសទឹកដោះម្តាយវិញ
- ម្តាយអាចធ្លាក់ខ្លួនឈឺ ឬស្លាប់
- គ្រួសារអាចក្រីក្រខ្លាំងដែលបណ្តាលមកពីជម្ងឺនិងការស្លាប់

កុមារទាំងនេះត្រូវការ ការតាមដាននិងថែទាំ ជាពិសេសនៅរយៈពេល២ឆ្នាំ ដំបូងនៃជីវិត

7

## សកម្មភាពទី២ : បំផុសគំនិត: តើហេតុអ្វីបានជាគម្រោងថែទាំនិងព្យាបាលបន្តសម្រាប់អ្នកផ្ទុកមេរោគអេដស៍-ជំងឺអេដស៍ ត្រូវបានផ្តួចផ្តើមឱ្យអនុវត្តនៅកម្ពុជា?

» ចូរគិតអំពី :

- តើមេរោគអេដស៍កើតមាននៅកម្ពុជានៅឆ្នាំណា?
- តើប្រជាជនដែលមានផ្ទុកមេរោគអេដស៍នៅកម្ពុជាមានប្រហែលប៉ុន្មាននាក់ដែរ?

» ចូរគិតថា តើហេតុអ្វីត្រូវចាំបាច់មានសេវាថែទាំនិងគាំទ្របន្តនៅកម្ពុជា

### តើហេតុអ្វីបានជាយើងត្រូវការសេវាថែទាំនិងព្យាបាលបន្តសំរាប់អ្នកផ្ទុកមេរោគអេដស៍?

- ប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលនៃការរីករាលដាលនៃជម្ងឺអេដស៍ ។ ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ទាំងនោះ មានអ្នកខ្លះបានធ្លាក់ខ្លួនឈឺ និងត្រូវការការថែទាំនិងព្យាបាលបន្តដែលនៅក្នុងនោះក៏មានកុមារផងដែរ ។
- ការថែទាំនិងព្យាបាលដល់អ្នកផ្ទុកមេរោគអេដស៍-ជម្ងឺអេដស៍ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ គឺជាតំរូវការបន្ទាន់ដើម្បីឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ន ។

9

## សកម្មភាពទី៣ : ពិភាក្សាក្រុមតូចៈ សមាសភាគនៃគម្រោងថែទាំបន្តគ្រប់ជ្រុងជ្រោយ សម្រាប់អ្នកផ្ទុកមេរោគអេដស៍-ជំងឺអេដស៍

» គ្រូនឹងចែកសិក្ខាកាមជា ៣-៤ក្រុម

» សិក្ខាកាមត្រូវគិតអំពីៈ

១-ផលប៉ះពាល់នៃមេរោគអេដស៍ទៅលើបុគ្គល គ្រួសារ និងទៅលើសហគមន៍

២-តើត្រូវមានសេវាឬវិធានការណ៍អ្វីសម្រាប់ឆ្លើយតបទៅនឹងបញ្ហាទាំងនោះ?

» គ្រូសរសេរប្រធានបទ២នៅលើក្តារខៀនៈ

១. ផលប៉ះពាល់នៃមេរោគអេដស៍

២. ការឆ្លើយតបទៅនឹងមេរោគអេដស៍

» សមាជិកម្នាក់នៃក្រុមនីមួយៗនឹងឡើងមកសរសេរចម្លើយនៃគំនិតរបស់ពួកគេពីក្រោមចំណងជើងនៃប្រធានបទនៅលើក្តារខៀន

» គ្រូសម្របសម្រួលនឹងដឹកនាំការពិភាក្សា

### ផលវិបាកនៃមេរោគអេដស៍_ជម្ងឺអេដស៍

សុខភាពផ្នែករាងកាយៈ
ជម្ងឺឱកាសនិយម ការស្លាប់មុនអាយុ

សេដ្ឋកិច្ចៈ
ពុំមានលទ្ធភាពបំពេញការងារ,
ការចំណាយលើការថែទាំសុខភាព
នាំទៅរកភាពក្រីក្រ



សុខភាពផ្លូវចិត្តៈ
វិបត្តិផ្លូវចិត្ត

ផលវិបាកផ្នែកសង្គមនិងច្បាប់ៈ ការមាក់ងាយ ការរើសអើង និង ការរំលោភសិទ្ធិមនុស្ស ។ល។

11

### តើការថែទាំអ្នកផ្ទុកមេរោគអេដស៍មានអនុវត្តនៅកន្លែងណាខ្លះ?

សមាសភាគសំខាន់នៃគំរោងថែទាំនិងព្យាបាលបន្តផ្សារភ្ជាប់ទំនាក់ទំនងរវាងក្រុមថែទាំតាមផ្ទះនិងតាមសហគមន៍ ជាមួយគ្រឹះស្ថានសុខាភិបាលៈ

- ការថែទាំជម្ងឺអេដស៍នៅគ្រឹះស្ថានសុខាភិបាល-រួមមាន សេវាឯកជន
- ការថែទាំអ្នកជម្ងឺអេដស៍តាមផ្ទះ **(HBC)**
- ការថែទាំអ្នកជម្ងឺអេដស៍តាមសហគមន៍ (CBC) រួមមានៈ
  - ក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៍ (PLHA-SG)
  - អង្គការគាំទ្រផ្សេងៗនៅតាមសហគមន៍
  - សមាជិកសហគមន៍ផ្ទាល់

12

### សមាសភាគនៃគំរោងថែទាំនិងព្យាបាលបន្ត




13

## ការថែទាំអ្នកជំងឺអេដស៍ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ (១)

**<u>ការផ្តល់សេវាថែទាំព្យាបាលគ្រប់ជ្រុងជ្រោយៈ</u>**

- ✓ មិនមែនផ្តោតទៅលើការថែទាំតាមវេជ្ជសាស្ត្រទេ គឺរួមផ្សំនឹងការគាំទ្រផ្លូវចិត្ត សង្គម និងផ្លូវច្បាប់ផងដែរ
- ✓ ទាមទារឱ្យមានការធ្វើផែនការជាក់លាក់ ការសម្របសម្រួល ការបញ្ជូនការតាមដានពិនិត្យតាមគ្រប់ប្រព័ន្ធនៃគំរោងថែទាំនិងព្យាបាលបន្ត
- ✓ ការចល័តធនធាននៅតាមសហគមន៍ និងអង្គការនានាដែលធ្វើការក្រៅវិស័យសុខាភិបាល ដើម្បីធានានិរន្តរភាព។

14

## ការថែទាំអ្នកជំងឺអេដស៍ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ (២)

<u>ការថែទាំនៅតាមគ្លីនិករួមមាន</u> :

- ✓ ការធ្វើរោគវិនិច្ឆ័យនៃជម្ងឺអេដស៍ និងការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម
- ✓ ការគ្រប់គ្រងព្យាបាលជម្ងឺឱកាសនិយម ដូចជា ជម្ងឺរបេង
- ✓ ការព្យាបាលបង្ការជម្ងឺឱកាសនិយម
- ✓ ការថែទាំព្យាបាលសំរន់ និងព្យាបាលតាមរោគសញ្ញា
- ✓ ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ART
- ✓ ការបង្ការជាសកល និងការព្យាបាលបង្ការ PEP
- ✓ ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន PMTCT

15

## ការថែទាំអ្នកជំងឺអេដស៍ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ (៣)

<u>ការគាំទ្ររួមមាន</u> :

- ✓ ការប្រឹក្សាយោបល់
- ✓ ការគាំទ្រផ្លូវចិត្តនិងថវិកា
- ✓ ការគាំទ្រដល់អ្នកថែទាំកុមារ និងកុមារដែលរងគ្រោះដោយមេរោគអេដស៍-ជម្ងឺអេដស៍
- ✓ ការកាត់បន្ថយការមាក់ងាយនិងការរើសអើង

16

## ការថែទាំអ្នកជំងឺអេដស៍ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ (៤)

<u>ការលើកកំពស់សុខភាព និងការអប់រំរួមមាន</u> :

- ✓ ផ្តល់ព័ត៌មាននិងការអប់រំចំពោះអ្នកផ្ទុកមេរោគអេដស៍-អ្នកជម្ងឺអេដស៍ និងគ្រួសាររបស់ពួកគេអំពីមេរោគអេដស៍-ជម្ងឺអេដស៍
- ✓ ការផ្តល់អាហារូបត្ថម្ភ
- ✓ ការបង្ការនូវការចម្លងមេរោគអេដស៍បន្តទៀត
- ✓ ការធ្វើផែនការគ្រួសារ

17

## សកម្មភាពទី៤: មេរៀន : យុទ្ធសាស្ត្រនិងយន្តកម្មសំខាន់ៗក្នុងការអនុវត្តន៍ការថែទាំនិងព្យាបាលបន្ត

### យុទ្ធសាស្ត្រគន្លឹះដើម្បីបង្កើតសេវាថែទាំនិងព្យាបាលបន្ត សំរាប់អ្នកផ្ទុកមេរោគអេដស៍

- ភាពជាដៃគូរវាងសេវាវេជ្ជសាស្ត្រ ក្រុមអ្នកផ្ទុកមេរោគអេដស៍ ប្រព័ន្ធសុខភាពសាធារណៈ និង អង្គការក្រៅរដ្ឋាភិបាលនៅថ្នាក់ស្រុកប្រតិបត្តិ
- យន្តការបញ្ជូនរឹងមាំរវាងក្រុមថែទាំតាមផ្ទះ តាមសហគមន៍ និងគ្រឹះស្ថានថែទាំ
- សកម្មភាពចូលរួមមានប្រសិទ្ធិភាពរបស់អ្នកផ្ទុកមេរោគអេដស៍ នូវរាល់ទិដ្ឋភាពទាំងអស់នៃការថែទាំនិងព្យាបាលបន្ត
- ពង្រឹងគុណភាពនៃសេវាថែទាំដល់អ្នកផ្ទុកមេរោគអេដស៍នៅតាមគ្រឹះស្ថានសុខាភិបាល
- បង្កើតជាកញ្ចប់សកម្មភាពថែទាំសុខភាពនៅតាមថ្នាក់នីមួយៗនៃប្រព័ន្ធសុខាភិបាល

19

## សកម្មភាពទី៥: មេរៀន: សង្ខេបពីសកម្មភាពថែទាំបន្តដែលកំពុងអនុវត្តនៅកម្ពុជា

### ស្ថានភាពនៃគំរោងថែទាំបន្ត និងសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន: ខែមីនា ២០០៦

- មានសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមចំនួន១១២កន្លែង នៅគ្រប់ខេត្តទាំងអស់
- មានសេវា OI-ARTចំនួន៣៩ កន្លែង នៅក្នុង១៧ខេត្តក្រុង ក្នុងនោះមានសេវាព្យាបាលជម្ងឺអេដស៍កុមារចំនួន១២ កន្លែង
- មានក្រុមថែទាំអ្នកជម្ងឺអេដស៍តាមផ្ទះចំនួន ២៦១ក្រុម នៅក្នុង១៧ខេត្តក្រុងនិងភ្នំពេញ
- មានក្រុមមិត្តអប់រំមិត្ត ចំនួន៥៦២ក្រុម នៅក្នុង ១៤ខេត្ត
- មានសេវា PMTCT ចំនួន២៧កន្លែង នៅក្នុងស្រុកប្រតិបត្តិចំនួន១៥ ខេត្តចំនួន១០

ឯកសារយោង: NCHADS Comprehensive report on HIV/AIDS Activities in Cambodia, Quarter 1, 2002.

21

### ចំនួនអ្នកជម្ងឺអេដស៍សកម្ម កំពុងប្រើឱសថប្រឆាំងមេរោគអេដស៍: ត្រីមាសទី១_២០០៦




ឯកសារយោង: NCHADS Comprehensive report on HIV/AIDS activities in Cambodia, Quarter 1 2006

22







## សកម្មភាពទី៦: លំហាត់: ការចាត់ចែងភារកិច្ចនៃសេវា PMTCT

» គោលបំណងនៃលំហាត់នេះគឺពិនិត្យអំពីការផ្តល់សេវា **PMTCT** នៅតាមប្រភេទនៃគ្រឹះស្ថានសុខាភិបាល

» គ្រូចែកសិក្ខាកាមជា៤ក្រុម និងចែកប្រធានបទទៅឱ្យក្រុមនីមួយៗ:

ក្រុមទី១: សេវាថែទាំផ្ទៃពោះនៅមណ្ឌលសុខភាព ក្នុងរង្វង់មន្ទីរពេទ្យបង្អែក

ក្រុមទី២: សេវាថែទាំផ្ទៃពោះនៅមណ្ឌលសុខភាព ក្រៅរង្វង់មន្ទីរពេទ្យបង្អែក

ក្រុមទី៣: សេវាថែទាំផ្ទៃពោះ នៅមណ្ឌលសុខភាព អតីតមន្ទីរពេទ្យស្រុក

ក្រុមទី៤: អគារសម្ភពនិងអាគារក្រោយសម្រាលនៃមន្ទីរពេទ្យបង្អែកដែលមានសេវា **PMTCT**

● ក្រុមនីមួយៗត្រូវរៀបរាប់អំពីសេវា **PMTCT** ដែលផ្តល់ជូនអតិថិជន ទៅតាមប្រភេទនៃគ្រឹះស្ថានសុខាភិបាល

● ក្រុមនីមួយៗត្រូវសរសេរចម្លើយលើក្ដារខៀនពីក្រោមចំណងជើងឱ្យបានសមស្រប

## មណ្ឌលសុខភាពដែលស្ថិតនៅក្នុងបរិវេណមន្ទីរពេទ្យបង្អែក

សង្ខេបៈ ការផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដល់ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ និងដៃគូរបស់ពួកគេ

- ការអប់រំសុខភាព
- ការផ្តល់ប្រឹក្សា-ធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់
- ការបញ្ជូនទៅរកសេវាព្យាបាលជម្ងឺឱកាសនិយម និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍
- ការថែទាំផ្ទៃពោះជាប្រចាំមុនពេលសំរាល




26

## មណ្ឌលសុខភាពដែលស្ថិតនៅក្រៅបរិវេណមន្ទីរពេទ្យបង្អែក

សង្ខេបៈ ការផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដល់ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ និងដៃគូរបស់ពួកគេ

- អប់រំសុខភាព
- ការផ្តល់ប្រឹក្សា-ធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់
- បញ្ជូនទៅកាន់សេវា **OI/ART** ដែលនៅជិតបំផុត ដោយមានក្រុមថែទាំតាមផ្ទះ ក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៍ ឬឆ្មបបុរាណ បើសិនជាមាន ។
- ពិនិត្យថែទាំផ្ទៃពោះជាប្រចាំ ប្រសិនបើស្ត្រីមានផ្ទៃពោះសំរេចចិត្តមកទទួលសេវាថែទាំផ្ទៃពោះនៅមណ្ឌលសុខភាព
- បញ្ជូនទៅកាន់មន្ទីរពេទ្យដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដែលនៅជិតបំផុត នៅពេលសំរាលកូន ។







27

## អតីតមន្ទីរពេទ្យស្រុក

សង្ខេបៈ ការផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដល់ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ និងដៃគូរបស់ពួកគេ

- អប់រំសុខភាព
- ការផ្តល់ប្រឹក្សា-ធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់
- បញ្ជូនទៅកាន់សេវា OI-ART ដែលនៅជិតបំផុត
- ផ្តល់ឱសថប្រឆាំងមេរោគអេដស៍ ដើម្បីបង្ការដោយបុគ្គលិកដែលបានបណ្តុះបណ្តាលពីកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន បើសិនស្ត្រីមានផ្ទៃពោះពុំទាន់គ្រប់ ល័ក្ខខ័ណ្ឌទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅឡើយ ។
- ពិនិត្យផ្ទៃពោះជាប្រចាំ
- បញ្ជូនទៅកាន់មន្ទីរពេទ្យដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដែល នៅជិតបំផុតដើម្បីសំរាល ។






## ផ្នែកសម្ភពនៃមន្ទីរពេទ្យបង្អែក

សង្ខេប : ការផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (PMTCT) ចំពោះស្ត្រីមានផ្ទៃពោះដែលមានផ្ទុកមេរោគអេដស៍នៅ**ពេលឈឺពោះសំរាល**

- ផ្តល់ការគាំទ្រ និងថែរក្សា តាមរយៈបុគ្គលិកដែលបានបណ្តុះបណ្តាលពីកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- ផ្តល់ឱសថប្រឆាំងមេរោគអេដស៍ដើម្បីបង្ការ
- អនុវត្តការសំរាលកូនប្រកបដោយសុវត្ថិភាពជាងគេនៅពេលឈឺពោះ និងនៅពេលសំរាល

29

## ផ្នែកសម្ភពនៃមន្ទីរពេទ្យបង្អែក (១)

**សង្ខេប : ផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន** (PMTCT) **ដល់ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍និងកូនរបស់គាត់នៅក្រោយពេលសំរាល ។**

- ផ្តល់ការគាំទ្រ និងការថែទាំតាមរយៈបុគ្គលិកដែលបានបណ្តុះបណ្តាលពីកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- ផ្តល់ឱសថប្រឆាំងមេរោគអេដស៍ ដើម្បីបង្ការដល់ម្តាយនិងទារក
- ផ្តល់ការប្រឹក្សាយោបល់ស្តីពីការចិញ្ចឹមកូនដែលប្រកបដោយសុវត្ថិភាពជាងគេ
- រៀបចំតាមដានបន្តនៅគ្លីនិកជម្ងឺអេដស៍កុមារនៅរយៈពេល៦សប្តាហ៍
- ទំនាក់ទំនងជាមួយក្រុមអ្នកថែទាំជម្ងឺអេដស៍តាមផ្ទះ ឬក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៍ ដើម្បីឱ្យស្ត្រីប្រើឱសថបានត្រឹមត្រូវនិងទៀងទាត់ ។

30

## សេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (OI-ART)នៅមន្ទីរពេទ្យបង្អែក

សង្ខេប :ផ្តល់សេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដល់ស្ត្រីដែលមានផ្ទៃពោះផ្ទុកមេរោគអេដស៍ និងដៃគូរបស់គាត់ ។

- ផ្តល់អាទិភាពដល់ស្ត្រីក្នុងការទទួលសេវាថែទាំនិងព្យាបាលបន្ត
- វាយតម្លៃពីល័ក្ខខ័ណ្ឌក្នុងការទទួលការព្យាបាល ឬ ការបង្ការដោយឱសថប្រឆាំងមេរោគអេដស៍
- ផ្តល់ឱសថប្រឆាំងមេរោគអេដស៍ដើម្បីព្យាបាល ឬ បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន




- ស្រាវជ្រាវរកជម្ងឺរបេង និង មេរោគអេដស៍
- បញ្ជូនទៅកាន់មន្ទីរពេទ្យដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដែលសមស្រប ដើម្បីសំរាលកូន
- បញ្ជូនទៅកាន់ក្រុមថែរក្សាអ្នកជម្ងឺអេដស៍តាមផ្ទះ ឬក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៍ ដើម្បីគាំទ្រឱ្យអ្នកជម្ងឺមកទទួលសេវាថែទាំនិងព្យាបាលបន្ត




31

## សេវាជម្ងឺអេដស៍កុមារនៅមន្ទីរពេទ្យបង្អែក

**សង្ខេប : ផ្តល់សេវាថែទាំដល់ទារកដែលប្រឈមការឆ្លងមេរោគអេដស៍ (ទារកដែលសំរាលពីម្តាយផ្ទុកមេរោគអេដស៍)**

- កំណត់រកអត្តសញ្ញាណទារកប្រឈមនឹងមេរោគអេដស៍
- ផ្តល់សេវាតាមដានបន្ត រួមមាន :
  - ការបង្ការជម្ងឺឱកាសនិយម
  - ការធ្វើតេស្តឈាមរកមេរោគអេដស៍
  - ការផ្តល់ការថែទាំវេជ្ជសាស្ត្រ
  - ការប្រឹក្សាស្តីពីអាហារូបត្ថម្ភ
- ទំនាក់ទំនងជាមួយក្រុមថែទាំអ្នកជម្ងឺអេដស៍តាមផ្ទះ និងក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៍ ។

32

## សកម្មភាពទី៧: ប្រព័ន្ធសេវាសម្រាប់អ្នកជំងឺ

- » គោលបំណងនៃលំហាត់នេះ គឺដើម្បីគូសផែនទីនៃសេវាដែលស្ត្រីផ្ទុកមេរោគអេដស៍ត្រូវទៅទទួលសេវា PMTCT ផ្សេងៗនៅឯមន្ទីរពេទ្យបង្អែក
- » អ្នកត្រូវចាប់ផ្តើមនិយាយពីស្ត្រីនិងស្វាមីរបស់គាត់ចេញពីផ្ទះរហូតមកដល់មន្ទីរពេទ្យបង្អែក
- » គ្រូសុំឱ្យមានអ្នកស្ម័គ្រចិត្តម្នាក់ឡើងមកបញ្ជាក់អំពីទីកន្លែងដែលប្តីប្រពន្ធនេះត្រូវទៅទទួលសេវាថែទាំផ្ទៃពោះជាដំបូង និងបន្ទាប់មកគឺសេវា PMTCT
- » អ្នកស្ម័គ្រចិត្តម្នាក់ទៀតនឹងត្រូវឡើងមកគូសអំពីដំណាក់កាលបន្ត
- » ការគូសនេះត្រូវធ្វើពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត រហូតដល់ស្ត្រីបានសម្រាលកូននិងរៀបចេញពីមន្ទីរពេទ្យទៅផ្ទះវិញ



# សកម្មភាពទី៨៖ គណៈកម្មការសម្របសម្រួលការថែទាំនិងព្យាបាលបន្ត

សេវា PMTCTជា សមាសភាគនៃគម្រោងថែទាំនិងព្យាបាលបន្ត

ការសម្របសម្រួលនិងសហប្រតិបត្តិការ ត្រូវធ្វើឡើងនៅគ្រប់កម្រិតទាំងអស់ ដើម្បីឱ្យអតិថិជនអាចទទួលបាននូវផលប្រយោជន៍ពីសេវាថែទាំ ព្យាបាលនិងគាំទ្រសម្រាប់អ្នកផ្ទុកមេរោគអេដស៍-ជំងឺអេដស៍កាន់តែប្រសើរឡើង។

## គណៈកម្មការសំរបសំរួលការថែទាំនិងព្យាបាលបន្ត ថ្នាក់ស្រុកប្រតិបត្តិ

- ប្រធានស្រុកប្រតិបត្តិ
- ប្រធានមន្ទីរពេទ្យបង្អែក
- ប្រធានឬអនុប្រធានមន្ទីរពេទ្យបង្អែក
- អ្នកសំរបសំរួលកម្មវិធីអេដស៍/ ជម្ងឺកាមរោគនៃស្រុកប្រតិបត្តិ
- ប្រធានផ្នែកជម្ងឺឆ្លងឬផ្នែកវេជសាស្ត្រនៃមន្ទីរពេទ្យបង្អែក
- បុគ្គលិកថែទាំសុខភាពដែលសំរបសំរួលមណ្ឌលមិត្តជួយមិត្ត
- ប្រធានផ្នែកជម្ងឺរបេង
- ប្រធានផ្នែកជម្ងឺរបេង
- តំណាងអង្គការមិនមែនរដ្ឋាភិបាល
- តំណាងក្រុមថែទាំជម្ងឺអេដស៍តាមផ្ទះ
- ប្រធានផ្នែកការផ្តល់ប្រឹក្សា-ធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់
- តំណាងក្រុមអ្នកគាំទ្រអ្នកផ្ទុកមេរោគអេដស៍
- តំណាងអង្គការនៅតាមសហគមន៏
- អ្នកដឹកនាំសាសនានិងសហគមន៏
- អ្នកសំរបសំរួលកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ថ្នាក់ស្រុកប្រតិបត្តិ

36

## ចំណងទាក់ទងរវាងសេវា PMTCTនិងគណៈកម្មការសំរបសំរួលការថែទាំបន្ត (CoCCC)

- តួនាទីគណៈកម្មការសំរបសំរួលការថែទាំបន្ត
  - កំណត់ពីតំរូវការ គំលាត និង វិស័យនៃកិច្ចសហប្រតិបត្តិការ និងការសំរបសំរួលជាមួយដៃគូ ដែលពាក់ព័ន្ធក្នុងការថែទាំអ្នក ជម្ងឺអេដស៍ក្នុងស្រុកប្រតិបត្តិ
  - កំណត់យន្តការបញ្ជូនរវាងគ្រឹះស្ថានសុខាភិបាល និង ក្រុមថែទាំតាមផ្ទះនិងតាមសហគមន៏
  - ផ្តល់នូវវេទិកាពិភាក្សាឱ្យបានទៀងទាត់ស្តីពីបញ្ហាដែលពាក់ព័ន្ធទៅនឹងការថែទាំនិងព្យាបាលបន្ត
- អ្នកសំរបសំរួលកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនរបស់ស្រុកប្រតិបត្តិ គឺជាសមាជិកស្នូលនៃគណៈកម្មការសំរបសំរួលការថែទាំ និងព្យាបាលបន្ត

37

## ការជ្រើសរើសមណ្ឌលសំរាប់សេវា PMTCT

**មណ្ឌលត្រូវមាន :**

- សេវាថែទាំមុននិងក្រោយសំរាលនិងសេវាពន្យារកំណើត
- ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម ឬអាចទទួលសេវានេះបាន
- បន្ទប់ផ្តល់ប្រឹក្សាឯកជនដែលអាចរក្សាការសំងាត់ សំរាប់សេវា PMTCT
- សេវាសំរាលនិងថែទាំទារកទើបនឹងកើត
- ទំនាក់ទំនងសេវា OI-ART

**សេវាផ្សេងទៀតដែលត្រូវការបន្ថែម :**

- មណ្ឌលមិត្តជួយមិត្ត
- ការថែទាំអ្នកជម្ងឺតាមផ្ទះ
- សេវាគាំទ្រនិងថែទាំនៅតាមសហគមន៏
- សេវា OI-ART សំរាប់កុមារ ( ព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍)

38

**ម៉ូឌុលទី៤.៤: ចំណុចគន្លឹះ**

- សេវាព្យាបាល ថែទាំ និងគាំទ្រគឺជាយុទ្ធសាស្ត្រទី៤ នៃយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងការកាត់បន្ថយការចម្លងមេរោគអេដស៍នៅលើទារកនិងកុមារតូចៗ
- គម្រោងថែទាំនិងគាំទ្របន្ត អនុវត្តពីផ្ទះ សហគមន៍ រហូតដល់គ្រឹះស្ថានសុខាភិបាល
- ប្រព័ន្ធបញ្ជូននិងចំណងទាក់ទងរឹងមាំរវាងសមាសភាគផ្សេងៗនៃគម្រោងថែទាំបន្តមានសារៈសំខាន់ណាស់
- ការថែទាំគ្រប់ជ្រុងជ្រោយ មានការថែទាំផ្នែកវេជ្ជសាស្ត្រ រួមនឹងការគាំទ្រផ្លូវចិត្ត សង្គម និង ផ្លូវច្បាប់
- បុគ្គលិកសុខាភិបាលគ្រប់រូប ត្រូវរួមចំណែកក្នុងការផ្តល់សេវាព្យាបាល ថែទាំ និងគាំទ្រគ្រប់ជ្រុងជ្រោយដែលមានគុណភាពខ្ពស់ដល់អ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា

## ម៉ូឌុលទី៥
# ការថែទាំដល់អ្នកផ្តល់ប្រឹក្សា

**វត្ថុបំណង**

នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមទាំងអស់អាចនឹង:

១. ឱ្យនិយមន័យនៃពាក្យ **ស្ត្រេស (Stress) និង ប៊ឺនអាវ (Burn-Out)** និងពន្យល់អំពីភាពខុសគ្នារវាងពាក្យទាំងពីរនេះ

២. រៀនសម្គាល់សញ្ញានិងរោគសញ្ញានៃ **ស្ត្រេស** និង **ប៊ឺនអាវ**

៣. រៀបរាប់កត្តាប្រឈមទាំងឡាយណាដែលបណ្តាលឱ្យមាន **ប៊ឺនអាវ**

៤. ឱ្យឈ្មោះ **ស្ត្រេស** ដែលទាក់ទងនឹងការងារនៃសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

៥. កំណត់បាននូវយុទ្ធវិធីគ្រប់គ្រង **ស្ត្រេស** និងបង្ការកុំឱ្យមាន **ប៊ឺនអាវ** នៅក្នុងបរិបទនៃការផ្តល់ប្រឹក្សាពីមេរោគអេដស៍-ជំងឺអេដស៍ និងការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

*រយៈពេល: **១ម៉ោង៥០នាទី***

## សកម្មភាពទី១: តើអ្វីទៅដែលហៅថា ស្រ្តេស (Stress)? តើអ្វីទៅដែលហៅថា ប៊ីនអាវ (Burn-Out)?

» អ្នកនឹងចាប់ផ្តើមម៉ូឌុលនេះដោយធ្វើការជាក្រុមតូចៗ ដោយកំណត់រក ស្រ្តេសដែលអ្នកធ្លាប់ជួបប្រទះក្នុងការងារ

» សូមពិភាក្សាយោងទៅនឹងសំណួរដែលស្ថិតនៅម្ខាងទៀត បើសិនជាអ្នកត្រូវការជំនួយ

» នៅក្នុងម៉ូឌុលនេះ អ្នកនឹងត្រូវការបញ្ជីរៀបរាប់អំពីស្រ្តេសនេះ

១. តើការជំនះឧបសគ្គក្នុងការងារប្រចាំថ្ងៃរបស់អ្នកដែលសំខាន់បំផុត គឺអ្វី?
២. តើស្ថានភាពបុគ្គលិករបស់អ្នកយ៉ាងដូចម្តេចដែរ? មានបុគ្គលិកគ្រប់គ្រាន់ដែលឬទេ? តើបុគ្គលិកត្រូវបានណែនាំបង្ហាញពីការងារដែរឬទេ? តើមានការបណ្តុះបណ្តាលគ្រប់គ្រាន់ដែរឬទេ? តើជំនាញរបស់គាត់មានបំប៉នបន្ថែមដែរឬទេ?
៣. តើអ្នកមានសម្ភារៈបរិក្ខារផ្គត់ផ្គង់គ្រប់គ្រាន់តាមដែលអ្នកត្រូវការគ្រប់ពេលដែរឬទេ?
៤. តើមានយន្តកម្មគាំទ្រដល់បុគ្គលិកដែរឬទេ? តើអ្នកនឹងទៅជួបអ្នកណា ប្រសិនជាអ្នកមានបញ្ហា?
៥. មានដំណោះស្រាយពាយ៉ាងដែលអាចជួយឱ្យការងាររបស់អ្នកងាយស្រួល តើជាអ្វី?

| ស្រ្តេស Stress | ប៊ីនអាវ (Burn-Out) |
|---|---|
| **ស្រ្តេស** សំដៅលើភាពថប់កង្វល់ ឬ ភាពតឹងតែងនៃផ្លូវកាយ ចិត្ត និងអារម្មណ៍ដែលបណ្តាលមកពីចិត្តនិងកាយធ្វើការហួសប្រមាណ។<br>■ **ស្រ្តេស** មានប្រភពភាគច្រើនមកពីព្រឹត្តិការណ៍ខាងក្រៅ ឬ ស្ថានភាពដែលទាមទារឱ្យធនធានខាងក្នុងឬខាងក្រៅរបស់បុគ្គលត្រូវតែទទួលយក។<br>■ ហេតុការណ៍មួយអាចបង្កឱ្យមាន **ស្រ្តេស** ទំហំប៉ុណ្ណានោះ គឺវាអាស្រ័យទៅលើបុគ្គលខ្លួនឯងមួយផ្នែកដែរ<br>■ បើសិនជាស្ថានភាពមួយតំរូវឱ្យបុគ្គលម្នាក់ធ្វើហួសពីសមត្ថភាពរបស់ខ្លួន (ឧ: ការប្រាប់ឱ្យអ្នកដទៃដឹងពីលទ្ធផលតេស្តវិជ្ជមាន) ហើយបុគ្គលនោះមិនអាចសំរបខ្លួនបាន នោះ**ស្រ្តេស**នឹងកើតមានឡើង<br>5 | ■ **ប៊ីនអាវ** គឺជាដំណើរការបន្តបន្ទាប់របស់បុគ្គលម្នាក់ដែលមានស្រ្តេសយូរអង្វែងខាងផ្លូវកាយនិងផ្លូវចិត្ត<br>■ ប៊ីនអាវអាចបង្ការបាន ឬអាចគ្រប់គ្រងបាន<br>■ ការប្រឈមនឹងប៊ីនអាវអាចកាត់បន្ថយបាន ឬជៀសវាងបានដោយការធ្វើឱ្យស្រ្តេសថយចុះ ឬប្តូរការឆ្លើយតបទៅនឹងស្រ្តេស។<br>**ប៊ីនអាវ** នេះតែងតែកើតមានជាញឹកញាប់នៅលើបុគ្គលិកសុខាភិបាលដែលធ្វើការក្រោមសម្ពាធបរិយាកាសក្នុងរយៈពេលយូរ<br>6 |

## សកម្មភាពទី២: ភាពខុសគ្នារវាងស្រ្តេសនិងបឺនអាវ

» ស្លាយទី៨ ពន្យល់អំពីភាពខុសគ្នារវាងស្រ្តេសនិងបឺនអាវ

» នៅក្នុង "ស្រ្តេស" មានដំណើរការជាច្រើនដែលមានសកម្មភាពខ្លាំងហួស ដែលជាហេតុនាំឱ្យអស់កម្លាំងនិងរសេះរសោះក្នុងខ្លួន។ ឧ: រូបភាពនៃអ្នកធាក់ស៊ីក្លូម្នាក់កំពុងតែធាក់លឿនឡើង១ និងព្យាយាមរក្សាល្បឿនវា

» នៅក្នុងបឺនអាវ កាយនិងចិត្តមិនអាចទប់ទល់នឹងសកម្មភាពដែលខ្លាំងហួសបានយូរអង្វែងទេ។ ឧ: អ្នកធាក់ស៊ីក្លូឈប់ធាក់ ហើយស៊ីក្លូចាប់ផ្តើមថយល្បឿន និងជាយថាហេតុ ស៊ីក្លូបានឈប់វិលកង់។

### ភាពខុសគ្នារវាងស្ត្រេសនិងប៊ឺនអាវ

| ស្ត្រេស | ប៊ឺនអាវ |
|---|---|
| ការរំជួលចិត្តក្លាយទៅជាសកម្មហួសហេតុ | ការរំជួលចិត្ត ក្លាយទៅជាលែងសូវសកម្ម |
| ការខូចខាតរូបរាងកាយកើតមានជាបឋម | ការខូចខាតផ្លូវចិត្តកើតមានជាបឋម |
| ភាពអស់កំលាំងល្ហិតល្ហៃនៃស្រ្តេសធ្វើឱ្យប៉ះពាល់ដល់ថាមពលនៃរាងកាយ | ភាពអស់កំលាំងល្ហិតល្ហៃនៃបឺនអាវធ្វើឱ្យប៉ះពាល់ដល់បំណង និងការជំរុញចង់ធ្វើអ្វីមួយ |
| បង្កើតឱ្យមានជាអារម្មណ៍វាយមាយ | ធ្វើឱ្យមានការប្រព្រឹត្តខុសសីលធម៌ |
| វាជាការបាត់បង់កម្លាំងនិងថាមពល | វាជាការបាត់បង់នូវឧត្តមគតិនិងក្តីសង្ឃឹម |
| ធ្វើឱ្យមានអារម្មណ៍តក់ក្រហល់និងមានសកម្មភាពហួសកំរិត | ធ្វើឱ្យលែងមានអារម្មណ៍ជួយអ្វីទាំងអស់ និងអស់សង្ឃឹម |
| ធ្វើឱ្យមានការឆាប់ភ័យតក់ស្លុត និងទុក្ខព្រួយមិនទៀងទាត់ | ធ្វើឱ្យបាត់បង់នូវបុគ្គលិកភាព និង ឃ្លាតឆ្ងាយពីអ្នកដទៃ |

8

## សកម្មភាពទី៣: ពាក្យគន្លឹះ: សញ្ញានិងរោគសញ្ញានៃបឺនអាវ

» គ្រូនឹងស្នើឱ្យអ្នកគិតអំពីសញ្ញានិងរោគសញ្ញាដែលមានទំនាក់ទំនងទៅនឹងកំណើននៃស្រ្តេស និងការប្រឈមទៅនឹងបឺនអាវ

### សញ្ញានិងរោគសញ្ញានៃប៊ឺនអាវ

**ផ្នែកឥរិយាបថ**

- ផ្លាស់ប្តូរអារម្មណ៍ញឹកញាប់
- ការបរិភោគប្រែប្រួល
- សេពគ្រឿងស្រវឹងច្រើន
- ជក់បារីច្រើន

**ផ្នែកសញ្ញាណ**

- ការបាត់បង់នូវអំណាចក្នុងការសំរេចចិត្ត
- ឧស្សាហ៍ភ្លេចភ្លាំង
- ផ្តោតអារម្មណ៍តិចតួច
- ឆាប់ច្រឡោតនៅពេលដែលមានគេរិះគន់

**ផ្នែករាងកាយ**

- ឡើងសម្ពាធឈាម
- ញ័រទ្រូង ញ័រដៃញ័រជើង
- ស្ងួតមាត់និងបែកញើសត្រជាក់
- ចុកក្រពះឬរាករូស

**ផ្នែកតួនាទីការងារ**

- សុំឈប់ច្រើនដោយសារមានជម្ងឺ
- ឈ្លោះជាមួយអ្នករួមការងារ
- សមិទ្ធិផលការងារចុះទាប
- ថាមពលតិច
- អស់ទឹកចិត្តធ្វើការងារ

10

## សកម្មភាពទី៤: កត្តាប្រឈមនឹងស្ត្រេសនិងបឹនអាវ

- នៅក្នុងលំហាត់នេះ គ្រូសួរទៅអ្នកដោយយោងទៅលើបញ្ជីដែលអ្នកបានសរសេរនៅក្នុងសកម្មភាពទី១
- ក្រុមនីមួយៗនឹងត្រូវឡើងមកបង្ហាញអំពីស្ត្រេសខ្លះៗដែលគាត់បានរកឃើញ

### កត្តាប្រឈមនឹងស្ត្រេសនិងបឹនអាវ អនុវត្តជាក់ស្តែង

**បឹនអាវ** អាចបណ្តាលមកពីធ្វើការងារច្រើនហួសរួមមាន:

- ការងារច្រើនជាងលទ្ធភាពនៃពេលវេលាដែលអាចធ្វើបាន
- ធ្វើការច្រើនម៉ោង តែមានពេលវេលាសំរាកតិច ឬ ក៏ខ្ជិលពេក
- ការទទួលខុសត្រូវច្រើន តែបានទទួលការគាំទ្រតិច
- តួនាទីចំរុះនិងការរំពឹងទុកច្រើនលើអ្នកផ្តល់ប្រឹក្សា (ឧ: ការរំពឹងគិតថា គាត់ជាគិលានុបដ្ឋាយិកាផង ជាអ្នកផ្តល់ប្រឹក្សាផង ជាអ្នកអប់រំផង និងជាអ្នកបណ្តុះបណ្តាលទៀត ។)
- ទទួលការបណ្តុះបណ្តាលមិនគ្រប់គ្រាន់
- ខ្វះការអភិបាលនិងគាំទ្រ

12

### កត្តាប្រឈមនឹងស្ត្រេសនិងបឹនអាវ : ផ្លូវចិត្ត

បឹនអាវអាចបណ្តាលមកពីអារម្មណ៍រំជើបរំជួលហួសក៏រិតទាក់ទងនឹង:

- ការផ្តល់លទ្ធផលតេស្តឈាមវិជ្ជមានដល់អតិថិជន
- ការស្លាប់ ឬការបាត់បង់សព្វបែបយ៉ាងរបស់អតិថិជន
- ការភ័យខ្លាចឆ្លងមេរោគអេដស៍
- សេចក្តីត្រូវការសព្វបែបយ៉ាងរបស់អតិថិជន (ជាពិសេសនៅក្នុងតំបន់ដែលមានភាពក្រីក្រធ្ងន់ធ្ងរ និងនៅទីណាដែលសេវាសុខភាពមានការខ្វះខាតនិងមិនអាចរកបាន)
- ខ្វះជាសុកភាពក្នុងការធ្វើការងារជាមួយក្រុមមនុស្សពិសេស (ដូចជាអ្នករួមភេទដូចគ្នា អ្នកសេពគ្រឿងញៀន ស្ត្រីរកស៊ីផ្លូវភេទ យុវជនក្មេងៗ មនុស្សចាស់ បុរសនិងស្ត្រី )
- ការជំនះនឹងជំនឿផ្នែកសាសនា បុគ្គល និងគំនិតខាងផ្នែកវប្បធម៌

13

### តួនាទីរបស់អ្នកអភិបាលផ្នែកផ្តល់ប្រឹក្សា

អ្នកអភិបាលនៅផ្នែកផ្តល់ប្រឹក្សា:

- ត្រូវតែរកឱ្យឃើញនូវសញ្ញានៃស្ត្រេសនិងបឹនអាវ
- ជួយដល់អ្នកផ្តល់ប្រឹក្សា ក្នុងការគ្រប់គ្រងស្ត្រេស និង ការពារបឹនអាវ
- ឆ្លើយតបទៅនឹងស្ត្រេសនិងបឹនអាវឱ្យបានឆាប់រហ័ស
- ត្រូវដឹងពីរបៀបគ្រប់គ្រងស្ត្រេសរបស់ខ្លួនការពារមិនឱ្យមានបឹនអាវ និងធ្វើជាគំរូក្នុងការអនុវត្តន៍

14

## សកម្មភាពទី៥: យុទ្ធវិធីសម្រាប់បង្ការបឹនអាវ

» គ្រូនឹងសុំឱ្យអ្នកបញ្ចេញគំនិតនិងយោបល់ សម្រាប់កាត់បន្ថយ ឬការពារស្ត្រេស កុំឱ្យឈានទៅរកបឹនអាវ

» ជាដំបូងត្រូវគិតរកវិធីកាត់បន្ថយស្ត្រេស ដើម្បីការពារកុំឱ្យមានបឹនអាវ

» បន្ទាប់មកត្រូវគិតរកយុទ្ធវិធីគ្រប់គ្រងស្ត្រេសដែលជាក់លាក់ណាមួយ

» គ្រូនឹងស្នើឱ្យអ្នកឡើងបង្ហាញចម្លើយសម្រាប់ធ្វើការពិភាក្សា

### វិធីកាត់បន្ថយស្ត្រេសនិងបង្ការបឹនអាវ

បង្ការបឹនអាវតំរូវឱ្យមានការគ្រប់គ្រងស្ត្រេសដែលជាយថាហេតុបង្កឱ្យមានបឹនអាវ ។

សូមពិចារណាលើគំនិតដូចតទៅនេះ:

អ្នកអាចព្យាយាមៈ

១. ផ្លាស់ប្តូរស្ថានភាពដែលជាមូលហេតុបណ្តាលឱ្យមានស្ត្រេស

២. សំរបតាមប្រភពនៃស្ត្រេស

៣. ជៀសវាងស្ត្រេសឱ្យបាន

16

### យុទ្ធវិធីទី (១)

**ផ្លាស់ប្តូរស្ថានភាពដែលបង្កឱ្យមានស្ត្រេសៈ**

**សួរខ្លួនឯង :**

- តើខ្ញុំអាចផ្លាស់ប្តូរ ឬមានឥទ្ធិពលលើវាដែរឬទេ?
- តើខ្ញុំអាចចាត់វិធានការដោយខ្លួនឯងបានដែរឬទេ?
- តើអ្នកណាអាចជួយខ្ញុំបាន?
- តើការផ្លាស់ប្តូរនេះមានគុណសម្បត្តិនិងគុណវិបត្តិចំពោះខ្ញុំនិងអ្នកដទៃដែរឬទេ?

17

## យុទ្ធវិធីទី (២)

**សំរបទៅនឹងប្រភពនៃស្ត្រេស** (បើសិនជាវាមិនអាចផ្លាស់ប្តូរបាន)**:**

- តើខ្ញុំអាចចាត់ទុកថាវាមិនមែនជាបញ្ហាធំដុំបានដែរឬទេ?
- តើខ្ញុំអាចប្រែក្លាយវាឱ្យទៅជាបញ្ហាវិជ្ជមានវិញបានដែរឬទេ?
- សូមគិតថា " ខ្ញុំនឹងមិនមានបញ្ហាអ្វីទេ ទោះជាមានរឿងអ្វីកើតឡើងក៏ដោយ"
- សូមស្វែងរកដំណោះស្រាយ ហើយត្រូវធ្វើចិត្តឱ្យបានទូលាយ
- ធ្វើលំហាត់ប្រាណដើម្បីឱ្យធូរស្រាល (កាយនិងចិត្ត)
- ត្រូវចេះនិយាយហេតុផល កំណត់ព្រំដែន និង រៀននិយាយពាក្យថា " ទេ "
- សំរាកឱ្យបានទៀងទាត់
- ជ្រើសរើសវាងឱ្យបាននូវប្រតិកម្មអវិជ្ជមាន (ឧ: ការប្រើសារជាតិគីមី ទទួលទានច្រើនហួស ទំលាក់រឿងលើអ្នកដទៃ គេចចេញពីបញ្ហា រិះគន់អ្នកដទៃខ្លាំងៗ ធ្វើមិនដឹងមិនឮពីបញ្ហា) ។

18

## យុទ្ធវិធីទី (៣)

**ជៀសវាងស្ត្រេសឱ្យបាន:**

សួរខ្លួនឯង:

- តើវាជាការប្រសើរបំផុតសំរាប់ខ្ញុំដែរឬទេ ក្នុងការជៀសវាង ឬដកខ្លួនចេញពីស្ត្រេសទាំងនេះ?
- តើខ្ញុំបានចំណេញអ្វីពីការដកខ្លួនចេញពីស្ត្រេសនេះ?
- តើខ្ញុំមានមធ្យោបាយអ្វីផ្សេងទៀតដើម្បីយកមកប្រើដែរឬទេ?

19

## អនុវត្តយុទ្ធវិធីគ្រប់គ្រងស្ត្រេស (១)

**ការគ្រប់គ្រងនៅកន្លែងធ្វើការ**

- សំរាកឱ្យបានច្រើន
- ផ្ទេរការងារទៅអ្នកដទៃ បើសិនជាយល់ថាសមស្រប
- លើកទឹកចិត្តធ្វើការងារជាក្រុម
- ឆ្លើយតបទៅនឹងបញ្ហាមុននឹងវាក្លាយទៅជារឿងធំ

**ការបណ្តុះបណ្តាល**

- បង្កើនចំណេះដឹង ជំនាញ និងបង្កើនជំនឿចិត្ត
- បណ្តុះបណ្តាលប្រធានបទថ្មី ឬបើកវគ្គបំប៉ន

20

## អនុវត្តយុទ្ធវិធីគ្រប់គ្រងស្ត្រេស (២)

**ថែទាំខ្លួនឯង**

- មិត្តគាំទ្រមិត្ត: ជជែកលេង សើច ចំណាយពេលវេលានៅជាមួយមិត្តភ័ក្រ្ត
- ការជួយណែនាំ: រកអ្នកដែលទុកចិត្តណាម្នាក់ដែលអាចស្តាប់ គាំទ្រនិងណែនាំអ្នកបាន
- គាំពារពេលកំសាន្តនិងពេលវេលាជាមួយគ្រួសារ ធ្វើអ្វីដែលអ្នកចង់ធ្វើ ស្តាប់តន្ត្រី ច្រៀងប្រឡែងជាមួយកូនរបស់អ្នក
- ថែរក្សាខ្លួនប្រាណ: ធ្វើលំហាត់ប្រាណឱ្យបានទៀងទាត់ ហូបឱ្យបានសមសួន និង សំរាកឱ្យបានគ្រប់គ្រាន់

**បញ្ឈប់ស្ត្រេស**

- ការសំរាកលំហែ: ធ្វើលំហាត់ប្រាណ ឬ សកម្មភាពផ្សេងៗ សូត្រធម៌ តាំងសម្មាធិ
- គិតក្នុងផ្លូវវិជ្ជមាន និងជ្រើសរើសវាងឱ្យបាននូវឥទ្ធិពលអវិជ្ជមានទាំងឡាយ បើសិនជាអាច
- ធ្វើជាម្ចាស់របស់ស្ត្រេស : សរសេរកត់ត្រាពីវាទុកវាមួយកន្លែងសំរាប់ពេលក្រោយ ទុកវាសំរាប់ពិចារណានៅពេលអនាគត (ស្រមៃខ្លួនអ្នកនៅ៥ឆ្នាំខាងមុខ- តើវានៅតែជាបញ្ហាទៀតដែរឬទេ? )

21

## អាកប្បកិរិយាដែលត្រូវជៀសវាង

- **ការមានអារម្មណ៍ថាត្រូវបានគេប្រើប្រាស់/ប្រើប្រាស់អស់ថ្លៃ**
  ត្រូវដឹងពីសិទ្ធិ និងតំរូវការរបស់អ្នក និងត្រូវឱ្យអ្នកដទៃដឹងពីសិទ្ធិ និងតំរូវការរបស់អ្នកផងដែរ
- **ញៀននឹងការងារ**
  ធ្វើឱ្យមានតុល្យភាពរវាងការងារ គ្រួសារ សំរាក និងលេងសើច
- **គំនិតអវិជ្ជមាន ឬគំនិតអ្នកបរាជ័យ**
  គំនិតវិជ្ជមានស្រូបទាញនូវថាមពល ការញញឹមបន្ធូរនូវភាពតឹងតែង
- **ការដាក់ទណ្ឌកម្មខ្លួនឯង**
  ត្រូវផ្តល់យុត្តិធម៌ចំពោះខ្លួនឯង ឱ្យដូចការដែលអ្នកមានចំពោះអ្នកដទៃដែរ
- **ការមិនពេញចិត្តនឹងខ្លួនឯង**
  ត្រូវចេះពេញចិត្តនូវអ្វីដែលខ្លួនមាន
- **ការបិទបាំងកំហុស**
  ត្រូវគិតថាខ្លួនអ្នកជាអ្នកណា ត្រូវគិតថាខ្លួនអ្នកគឺជាមនុស្សម្នាក់

22

## លំហាត់ប្រាណដើម្បីសំរួលភាពតានតឹង

**ញាក់ស្មា**

- ស្រូបខ្យល់ចូលក្នុងដង្ហើម និងលើកស្មារបស់អ្នកឡើងលើរហូតដល់ត្រចៀក
- បង្វិលស្មាអ្នកទៅក្រោយ ទាញស្មាអ្នកទាំងពីរឱ្យត្រង់
- បន្ធូរដង្ហើម ដោយបញ្ចេញសំឡេងខ្យល់ចេញ
- ធ្វើដូច្នេះឱ្យបាន៣ដង

**បន្ធូរភាពតានតឹងនៅលើមុខ**

- ឈ្លីលើមុខរបស់អ្នក ធ្វើហាក់ដូចជាអ្នកកំពុងតែច្របាច់សម្ពាធតានតឹងទាំងនោះចេញ តាមចុងច្រមុះរបស់អ្នកដូច្នេះដែរ
- បន្ធូរដង្ហើមដើម្បីឱ្យខ្យល់ចេញក្រៅ
- ឥឡូវនេះស្រូបដង្ហើមចូលដោយបើកមាត់ឱ្យបានធំតាមដែលអាចធ្វើបាន និងលើកចិញ្ចើមឡើងដើម្បីឱ្យមុខរបស់អ្នកវែង។ ធ្វើដូចជាស្វាបអីចឹង។
- ឥឡូវនេះបញ្ចេញខ្យល់ចេញពីសួត (ក្រោយពីធ្វើលំហាត់នេះ អ្នកនឹងមានអារម្មណ៍ថាអ្នកស្វាប។ សូមកុំព្រួយ វាគ្រាន់តែបង្ហាញថាអ្នកបានសំរួលភាពតានតឹងរួចហើយ)
- ធ្វើដូច្នេះឡើងវិញម្តងទៀត។

23

## ពាក្យគន្លឹះ

**ម៉ូឌុលទី៥: ចំណុចគន្លឹះ**

- ធ្វើការងារជាអ្នកផ្តល់ប្រឹក្សាផ្នែកបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន គឺជាការងារមួយពោរពេញទៅដោយស្ត្រេស
- ប្រជុំសញ្ញានៃ**ប៊ឺនអោរ**ទាក់ទងទៅនឹងស្ត្រេសដែលបណ្តាលមកពីការងារតឹងតែង និងយូរអង្វែង
- សញ្ញា**ប៊ឺនអោរ** រួមមានទាំងរោគសញ្ញាផ្លូវកាយនិងផ្លូវចិត្ត
- ស្ត្រេសអាចគ្រប់គ្រងបាន ហើយគ្រោះប្រឈមនឹង**ប៊ឺនអោរ** អាចបន្ថយបាន ដោយវិធានការណ៍ផ្ទាល់ខ្លួនរបស់បុគ្គលនិងការគាំទ្ររបស់អង្គភាព។

# ម៉ូឌុលទី៦
# ការតាមដាននិងវាយតម្លៃ

**វត្ថុបំណង**

នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមទាំងអស់អាចនឹងៈ

១. ពន្យល់អំពីសារៈសំខាន់នៃការកត់ត្រា ចុះបញ្ជី និង ការធ្វើរបាយការណ៍ដែលត្រឹមត្រូវ

២. រៀបរាប់ទម្រង់របាយការណ៍សង្ខេប ដែលប្រើសម្រាប់ប្រមូលរបាយការណ៍នៃសកម្មភាពបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

៣. អធិប្បាយអំពីគោលបំណងនៃសៀវភៅបញ្ជីនិងទម្រង់របាយការណ៍សង្ខេប

៤. បំពេញបែបបទឱ្យបានត្រឹមត្រូវនិងពិតប្រាកដ

ក) - សៀវភៅបញ្ជី **PMTCT**

ខ) - ទម្រង់របាយការណ៍សង្ខេបប្រចាំខែ នៅផ្នែកពិនិត្យផ្ទៃពោះ

គ) - ទម្រង់របាយការណ៍សង្ខេបប្រចាំខែ នៅផ្នែកសម្ភព

ឃ) - ទម្រង់របាយការណ៍សង្ខេបប្រចាំខែ នៅផ្នែកតាមដានកុមារ

៥. ពន្យល់អំពីគោលបំណងនៃការតាមដាននិងវាយតម្លៃ

៦. ពន្យល់អំពីការអភិបាលសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន



*រយៈពេលៈ* ***យ៉ាងតិចបំផុត = ៣ម៉ោង***

(ពេលវេលាអាចយូរជាងនេះ ដោយត្រូវការបំពេញសៀវភៅបញ្ជី)

## សកម្មភាពទី១: បំផុសគំនិត: ហេតុអ្វីបានជាយើងត្រូវការប្រព័ន្ធកត់ត្រានិងរបាយការណ៍?

» គ្រូនឹងសួរអ្នកអំពីសារៈសំខាន់នៃការកត់ត្រានិងធ្វើរបាយការណ៍

### ហេតុអ្វីបានជាយើងត្រូវការប្រព័ន្ធកត់ត្រា និង របាយការណ៍?

ការថែទាំព្យាបាលអ្នកជម្ងឺ

អ្នកជម្ងឺម្នាក់ៗត្រូវបានមើលថែដោយក្រុមបុគ្គលិកសុខាភិបាលដែលត្រូវទំនាក់ទំនងជាមួយអ្នកជម្ងឺពីបញ្ហាវេជ្ជសាស្ត្រ ចិត្តសាស្ត្រ និងសង្គមសាស្ត្រ។

ការតាមដានបន្ត

ស្ត្រីមានផ្ទៃពោះត្រូវការតាមដានជាប្រចាំចាប់តាំងពីពេលដែលគាត់មកពិនិត្យផ្ទៃពោះលើកទី១ រហូតដល់សំរាលកូន និងក្រោយសំរាលកូន

ការត្រួតពិនិត្យគុណភាព

អាចកំណត់ដឹងពីអ្វីដែលដំណើរការល្អ និងអ្វីដែលត្រូវធ្វើឱ្យកាន់តែប្រសើរឡើង

ការផ្គត់ផ្គង់

គេត្រូវការព័ត៌មានពិតប្រាកដ ដើម្បីធ្វើផែនការ បញ្ជាទិញ និង ចែកចាយឱសថ និងបរិក្ខារឱ្យបានគ្រប់គ្រាន់

ការគ្រប់គ្រងកម្មវិធី

អ្នកគ្រប់គ្រងត្រូវការព័ត៌មានសំរាប់តាមដាននិងវាយតម្លៃ 5

## សកម្មភាពទី២: បញ្ជីកត់ត្រាសកម្មភាពបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

### បញ្ជីកត់ត្រាសកម្មភាពបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

- ទិន្នន័យដែលប្រមូលផ្តុំនៅក្នុងបញ្ជីកត់ត្រាអ្នកជម្ងឺ អាចឱ្យបុគ្គលិកសុខាភិបាលប្រមូលព័ត៌មានពីអ្នកជម្ងឺដែលមកទទួលសេវាពិនិត្យផ្ទៃពោះ និងសេវាសំរាលៈ
  - តើគាត់ជាអ្នកណា?
  - តើគាត់មកនៅពេលណា?
  - តើគាត់បានទទួលសេវាអ្វីខ្លះ?
- យើងអាចតាមដានអ្នកជម្ងឺជាប់ជាប្រចាំ
- យើងអាចប្រើទិន្នន័យនេះដើម្បីបំពេញក្នុងទំរង់របាយការណ៍សង្ខេប

7

### សង្ខេបពីបញ្ជីកត់ត្រាសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

បញ្ជីកត់ត្រាសំរាប់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនមាន៣ផ្នែកៈ

១. បញ្ជីកត់ត្រាសំរាប់ផ្នែកពិនិត្យផ្ទៃពោះ

២. បញ្ជីកត់ត្រាសំរាប់ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍

៣. បញ្ជីកត់ត្រាសំរាប់ស្ត្រីផ្ទុកមេរោគអេដស៍នៅផ្នែកសំរាល

8

## សកម្មភាពទី៣: ធ្វើការជាក្រុម: ការបំពេញឯកសារ

- នៅក្នុងសកម្មភាពនេះ អ្នកត្រូវចំណាយពេលដើម្បីបំពេញលើក្រដាសថតចម្លងនៃបញ្ជីកត់ត្រាចំនួន៣ (ឧបសម្ព័ន្ធទី៦)

## សកម្មភាពទី៤: ទម្រង់របាយការណ៍សង្ខេបប្រចាំខែ

### របាយការណ៍សង្ខេបនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

- ទំរង់របាយការណ៏សង្ខេបត្រូវបានប្រមូលពីទិន្នន័យដែលបានកត់ត្រាប្រចាំខែ
- ទំរង់របាយការណ៏សង្ខេបត្រូវបានបញ្ជូនទៅអ្នកសំរបសំរួលកម្មវិធីខេត្តជារៀងរាល់ខែ
- របាយការណ៏ដែលប្រមូលពីគ្រប់មណ្ឌល ត្រូវបានដាក់បញ្ចូលគ្នាឱ្យទៅជារបាយការណ៏តែមួយរបស់ខេត្ត
- របាយការណ៏នៃមណ្ឌលនីមួយ១ និងរបាយការណ៏ខេត្ត ត្រូវបានបញ្ជូនមកការិយាល័យបង្ការការចម្លងមេរោគអេដស៏ពីម្តាយទៅកូនជារៀងរាល់ខែ
- ការិយាល័យបង្ការការចម្លងមេរោគអេដស៏ពីម្តាយទៅកូន ប្រមូលផ្តុំទិន្នន័យដែលបញ្ជូនមកពីគ្រប់ខេត្តទាំងអស់ ដើម្បីឱ្យក្លាយជាទិន្នន័យជាតិ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ។

11

### សង្ខេបទំរង់របាយការណ៏នៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

ទំរង់របាយការណ៏សង្ខេបមាន៣:

១. ទំរង់របាយការណ៏សង្ខេបប្រចាំខែសំរាប់ផ្នែកពិនិត្យផ្ទៃពោះ

២. ទំរង់របាយការណ៏សង្ខេបប្រចាំខែសំរាប់ផ្នែកសំរាល

៣. ទំរង់របាយការណ៏សង្ខេបប្រចាំខែសំរាប់ផ្នែកពិនិត្យជម្ងឺក្រៅ

ទំរង់របាយការណ៏សង្ខេបត្រូវបានបំពេញដោយប្រមូលព័ត៌មានដែលបានកត់ត្រាទុកក្នុងបញ្ជីនៃផ្នែកពិនិត្យផ្ទៃពោះ បញ្ជីស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៏ និងបញ្ជីស្ត្រីផ្ទុកមេរោគអេដស៏នៅផ្នែកសំរាល ។

12

## សកម្មភាពទី៥: ធ្វើការជាក្រុម: ការបំពេញទម្រង់របាយការណ៏សង្ខេបរបស់សេវា PMTCT

- នៅក្នុងសកម្មភាពនេះ អ្នកត្រូវចំណាយពេលដើម្បីបំពេញលើក្រដាសថតចម្លងនៃទម្រង់របាយការណ៏សង្ខេប នៃកម្មវិធីបង្ការការចម្លងមេរោគអេដស៏ពីម្តាយទៅកូនចំនួន៣ (ឧបសម្ព័ន្ធទី ៦)

## សកម្មភាពទី៦ : ការតាមដាន និង វាយតម្លៃ










### វដ្តនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

**១. ការប៉ាន់ប្រមាណកម្មវិធី:** គឺជាតំរូវការក្នុងការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

**២. ការធ្វើផែនការ:** ការផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ក្នុងគំរោងផែទាំបន្ត តើមានគោលបំណងអ្វីខ្លះ?

**៣. ការអនុវត្តន៍:** ការបណ្តុះបណ្តាលបុគ្គលិក ការរៀបចំនីតិវិធីក្នុងការអនុវត្តន៏កម្មវិធីឱ្យមានលក្ខណ:ស្តង់ដា ការបញ្ជ្រាបកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនទៅក្នុងប្រព័ន្ធសុខាភិបាល

**៤. ការតាមដាន:**
តើសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនបានដំណើរការយ៉ាងដូចម្តេចហើយ?

**៥. ការវាយតម្លៃ:**
តើសេវាបង្ការការចម្លងមេរោគអេដស៍បានទទួលផលប៉ះពាល់យ៉ាងដូចម្តេចហើយ?
តើត្រូវធ្វើឱ្យសេវានេះរីកចំរើនយ៉ាងដូចម្តេច?

វដ្តនេះកើតមានឡើងជាបន្តបន្ទាប់: ការវាយតម្លៃនាំឱ្យមានការរៀបចំផែនការ និងការអនុវត្តន៏ជាបន្ត

18

## ការតាមដាន

ការតាមដានត្រួតពិនិត្យ គឺអាស្រ័យលើការប្រមូលទិន្នន័យជាប្រចាំ និងការធ្វើរបាយការណ៍ ដូចជា:

- សៀវភៅបញ្ជីកត់ត្រា
- របាយការណ៍ប្រចាំខែ
- របាយការណ៍ថ្នាក់ខេត្ត
- របាយការណ៍ថ្នាក់ជាតិ

ព័ត៌មានទាំងនេះ ត្រូវបានប្រើសំរាប់:

- ប៉ាន់ប្រមាណការអនុវត្តន៍សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- រាវរកនិងកែលំអនូវបញ្ហា
- ប្រើប្រាស់ធនធានដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធិភាព ។

19

## ការវាយតម្លៃ

ការវាយតម្លៃនេះ អាចវាស់វែងនូវការផ្លាស់ប្តូរនានាទាក់ទងទៅនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលបណ្តាលមកពីសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ។

គេវាស់ស្ទង់សុច្ចនករដោយស្រង់ព័ត៌មានដែលបានផ្តល់ឱ្យពីមូលដ្ឋាន ដើម្បី:

- ឆ្លុះបញ្ចាំងពីគោលដៅ គោលបំណង និងសកម្មភាពអន្តរាគមន៍នានាក្នុងការកាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅទូទាំងប្រទេស
- ធ្វើការប៉ាន់ប្រមាណពីប្រសិទ្ធិភាពនៃកម្មវិធី ដែលឆ្លើយតបទៅនឹងការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- ឆ្លើយតបទៅនឹងសុច្ចនករសកលលោក ដែលមានគោលដៅបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ។

20

## តួនាទីរបស់បុគ្គលិកសុខាភិបាលក្នុងការប្រមូលទិន្នន័យ

ការតាមដានត្រួតពិនិត្យ និង វាយតម្លៃមានសារៈប្រយោជន៍តែក្នុងករណីដែលទិន្នន័យមានជាប់ពាក់ព័ន្ធ ត្រឹមត្រូវ និង ពេញលេញបុគ្គលិកសុខាភិបាលត្រូវតែប្រាកដថា ខ្លួន:

- យល់ច្បាស់ពីទិន្នន័យដែលត្រូវប្រមូល
- កត់ត្រាទិន្នន័យជារៀងរាល់ពេល
- កត់ត្រាទិន្នន័យទាំងអស់
- កត់ត្រាទិន្នន័យតាមរបៀបតែមួយជារៀងរាល់ពេល

ការផ្តល់ព័ត៌មានត្រឡប់ស្តីពីប្រព័ន្ធរបាយការណ៍ដែលកំពុងតែដំណើរការ និងការធ្វើឱ្យប្រព័ន្ធរបាយការណ៍នោះកាន់តែប្រសើរឡើងមានសារៈសំខាន់ណាស់ ។

21

## សុច្ចនករ (Indicator) (១)

សុច្ចនករជាតិសំរាប់កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន:

- ត្រូវបានរៀបចំឡើងដើម្បីតាមដានពីសមិទ្ធិផលនានា ក្នុងកិច្ចអន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
